## *ប្រវត្តិផ្ទាល់មាត់នៃជីវិតរបស់អ្នកស្រី នៅ សារីម ក្នុងរបបខ្មែរក្រហម*

***កំណត់និពន្ធ៖*** *អ្នកស្រីនៅ សារីម អតីតគ្រូបង្រៀនដែលបានមកសិក្សាបន្ថែមនៅប្រទេសបារាំងបានសម្រេចវិលត្រឡប់ទៅប្រទេសកម្ពុជាវិញក្នុងសម័យដែលខ្មែរក្រហមគ្រប់គ្រង។ អ្នកស្រីបានសម្រេចវិលទៅប្រទេសវិញនៅឆ្នាំ១៩៧៦ដើម្បីទៅស្វែងរកកូនស្រីពីរនាក់និងស្វាមីប៉ុន្តែដំណើរវិលត្រឡប់វិញរបស់គាត់បាននៅទីត្រឹមតែកន្លែងឃុំឃាំងរបស់ខ្មែរក្រហមនៅបឹងត្របែកដែលគេរៀបចំឡើងដើម្បីដាក់បញ្ញាវ័ន្តដែលវិលប្រឡប់ពីបរទេស។*

*បន្ទាប់ពីអស់សង្ឃឹមក្នុងការស្វែងរកសមាជិកក្រុមគ្រួសារ អ្នកស្រីបានសម្រេចវិលចាកចេញពីកម្ពុជាវិញហើយត្រូវបានអង្គការមនុស្សធម៌មួយធានាមកនៅសហរដ្ឋអាមេរិក ជាទីដែលអ្នកស្រីបានចូលរួមការងារសហគមន៍ជាច្រើនដើម្បីជួយដល់ជនភៀសខ្លួនខ្មែរដែលបានមកនៅទឹកដីសហរដ្ឋអាមេរិក។ អ្នកស្រី ក៏ ធ្លាប់បម្រើការជាបុគ្គលិកផ្នែកការផ្សាយនៃវីអូអេផ្នែកខេមរភាសាមុននឹងចូលនិវត្តន៍ក្នុងឆ្នាំ២០១១។ ខាងក្រោមនេះជាប្រវត្តិនិទានផ្ទាល់មាត់ពីដំណើរផ្សងព្រេងរបស់អ្នកស្រីនៅ សារីមដែលបានពិភាក្សាជាមួយនឹងលោកប៉ូច រាសី។*

**សេចក្តីផ្តើម៖** លោកអ្នកនាងជាទីមេត្រី ប្រសិនបើអស់លោកអ្នកនាងកំពុងរស់នៅឯបរទេសនៅពេលដែលពួកខ្មែរក្រហមកំពុងកាន់អំណាចរវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះ តើលោកអ្នកនាងហ៊ានវិលត្រឡប់ទៅកាន់ប្រទេសកម្ពុជាវិញដែរទេ? អ្នកគ្រូម្នាក់ដែល កំពុងរស់នៅក្នុងប្រទេសបារាំងនៅពេលនោះហ៊ានវិលត្រឡប់ទៅវិញទោះជាអ្នកគ្រូ ដឹងថាពួកខ្មែរក្រហមសាហាវយង់ឃ្នងយ៉ាងណាក៏ដោយ អ្នកស្រីរូបនេះគឺគ្មានអ្នកណាក្រៅពីអ្នកស្រី នៅ សារីមដែលសព្វថ្ងៃជាបុគ្គលិកនៃវី-អូ-អេសំឡេងសហរដ្ឋអាមេរិកនោះទេ តើហេតុអ្វីបានជាអ្នកស្រីវិលត្រឡប់ទៅកាន់ប្រទេសកម្ពុជាវិញ ក្នុង សម័យដ៏ជូរចត់ខ្លោចផ្សានោះ តើហេតុអ្វីបានជាអ្នកស្រីនៅរស់រានមានជីវិតនៅពេលដែលអ្នកឯទៀតជាច្រើនបានបាត់បង់ជីវិតនោះ? អ្នកស្រីនៅ សារីម នឹង ឆ្លើយនូវសំណួរទាំងនេះ ព្រមទាំងជម្រាបអស់លោកអ្នកនាងកញ្ញាឱ្យបានជ្រាបនូវដំណើរដើមទងនៃឆាកជីវិតនិងបទពិសោធន៍របស់អ្នកស្រីចាប់ផ្តើមពីពេលដែលអ្នកស្រីរស់នៅក្នុងប្រទេសបារាំងដែលជាប្រទេសមានឧស្សាហកម្មជឿនលឿនមួយ រហូតដល់ពេលអ្នកស្រីហាលភ្លៀង ហាលខ្យល់ក្នុងវាលស្រែចម្ការនៅក្នុងប្រទេសកម្ពុជានិងដល់ពេល

អ្នកស្រីធ្វើដំណើរមកតាំងទីលំនៅជាថ្មីឡើងវិញនៅលើទឹកដី អាមេរិក ក្រោយរបបវាលពិឃាតខ្មែរក្រហម។ វី-អូ-អេ សំឡេងសហរដ្ឋអាមេរិកនឹងផ្សាយជូនកម្រងភាគនិទានដ៏កំសត់និងដ៏គួរឱ្យទាក់ទាញអារម្មណ៍របស់ អ្នកស្រី នៅ សារីម ពីរលើកក្នុងមួយសប្តាហ៍ គឺនៅក្នុងកម្មវិធីផ្សាយរបស់យើងនៅយប់ថ្ងៃអាទិត្យនិងយប់ថ្ងៃសុក្រ ចាប់តាំងពីថ្ងៃ អាទិត្យទី២ ខែមីនា នេះតទៅ។ សូមលោកអ្នកនាង រង់ចាំស្តាប់កម្រងកម្មវិធីនេះកុំបីខានឡើយ។ សូម អរគុណ។

រាសី ៖ខ្ញុំសូមជម្រាបសួរអ្នកស្រី នៅ សារីម បាទ!។

សារីម ៖ចាំ! ជម្រាបសួរលោក ប៉ូច រាសី។

រាសី ៖បាទ! អរគុណសួរស្តីអស់លោកអ្នកស្តាប់បាទ! ដូចអស់លោកអ្នកស្រីនាងកញ្ញាជ្រាបស្រាប់ហើយថា អ្នកស្រីជាបុគ្គលិក វី-អូ-អេ សំឡេងរបស់សហរដ្ឋអាមេរិក ខេមរភាសាហ្នឹងតាំងពីឆ្នាំ២០០០មក បាទ! មែនទេបាទ?

សារីម ៖ចាំ!

រាសី ៖ ក៏ប៉ុន្តែអ្វីដែលប្រហែលជាអស់លោកអ្នកនាងកញ្ញាមិនទាន់ដឹងនោះគឺថា ក្រោយពីពួកខ្មែរក្រហមបានឡើងកាន់អំណាចមកនៅឆ្នាំ១៩៧៥អ្នកស្រី នៅ សារីម បានធ្វើដំណើរវិលត្រឡប់ពីប្រទេសបារាំងទៅប្រទេសកម្ពុជាវិញ។ តើអ្នកស្រីវិលត្រឡប់ទៅវិញឆ្នាំណាដែរ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនោះ ហើយតើហេតុអ្វីបានជាអ្នកស្រីសម្រេចចិត្តថាត្រឡប់ទៅវិញនោះបាទ!?

សារីម ៖ ចាំ! ជម្រាបសួរម្តងទៀតអស់លោកអ្នកស្តាប់និងជម្រាបសួរលោក ប៉ូច រាសី ខ្ញុំធ្វើជាគ្រូបង្រៀនអស់ពេល១០ឆ្នាំនៅក្នុងប្រទេសកម្ពុជា ហើយខ្ញុំបានអាហារូបករណ៍ពីរដ្ឋាភិបាលបារាំងមកធ្វើការសិក្សាមួយឆ្នាំនៅក្នុងប្រទេសបារាំងនៅឆ្នាំ១៩៧៤ ពេលនោះគឺខែកញ្ញាដែលខ្ញុំមកដល់ប្រទេសបារាំងឆ្នាំ១៩៧៤ ខ្ញុំមានកូនពីរនៅស្រុកខ្មែរ ហើយនឹងប្តីខ្ញុំក៏នៅស្រុកខ្មែរ។ មកត្រឹមបីខែ ខ្មែរក្រហមក៏យកស្រុកទៅបានចាំ! ហើយខ្ញុំដែលមកប្រទេសបារាំងនោះគឺថាបានអាហារូបករណ៍ហើយផ្ញើប្រាក់ទៅវិញ ដើម្បីជួយឧបត្ថម្ភក្នុងគ្រួសាររបស់យើង ព្រោះពេលនោះប្រាក់ចុះថ្លៃគឺថាយើងទៅជាក្រពិបាកវេទនាដូច្នេះខ្ញុំដល់ពេលខ្មែរក្រហមយកស្រុកបានទៅខ្ញុំ

ឃើញខ្លួនខ្ញុំ នៅក្នុងប្រទេសបារាំងគឺថាខ្ញុំពិបាកវេទនាមែនទែន ពីព្រោះកូនយើង ដែលយើងចិញ្ចឹម មិនឱ្យស្រមោចវាលើនោះ ស្រាប់តែឥឡូវពួកខ្មែរក្រហមមក ដេញចេញពីផ្ទះទីណាត់ ទីណែងដូចខែចែត្រក្តៅហែងអីចឹងគឺថាខ្ញុំរស់នៅមិនកើត ទេ ដោយមិនបានត្រឡប់ ទៅវិញទៅជួយកូននោះចាំ! ហើយទុកអាក្តៅក្រហាយ ពីរបៀបដែលខ្មែរក្រហម ដេញមនុស្សចេញពីក្នុងទីក្រុងភ្នំពេញហ្នឹងក៏ដោយ គឺថា ខ្ញុំក៏នៅតែសុខចិត្តត្រឡប់ទៅ ស្រុកខ្មែរវិញដែរចាំ! ហើយគឺថាខ្ញុំដឹងអ្វីៗដែលខ្មែរ ក្រហមធ្វើហ្នឹង គឺថាការដេញ មនុស្សចេញពីភ្នំពេញ ហើយយើងយល់ថាយើង អស់គ្រាប់ផ្លោងហើយ ហើយដូច ថាចប់សង្គ្រាមហើយស្រាប់តែមកដេញមនុស្ស ចេញអីចឹង គឺថាដូចថាយើងអត់យល់ៗពីរបបខ្មែរក្រហមដែលបានស្រុកហើយ មកធ្វើបាបមនុស្សនៅក្រោយពេល ច្បាំងអីចឹងចាំ! ហើយខ្មែរក្រហមហ្នឹងថា ខ្លួន ឯងឱ្យមនុស្សចេញហ្នឹងគឺថា ដោយសារអាមេរិកាំងហ្នឹងមានគម្រោងការទម្លាក់ គ្រាប់បែក។ កាលហ្នឹងខ្ញុំឮសួរអីចឹង នៅស្រុកបារាំង ហើយខ្ញុំគិតថា អាមេរិកាំង ឯណាទៅទម្លាក់គ្រាប់បែកបើអាមេរិកាំងគេដកទ័ពថយចេញពីសង្គ្រាមវៀតណាម អស់ហើយចាំ! ហើយខ្ញុំយល់ថាហ្នឹង ជាការភូតភកុហករបស់ខ្មែរក្រហម ហើយខ្ញុំ ពេលស្រុកអីចឹងទៅ ខ្ញុំព្រួយចិត្តពេកហ្នឹងដល់ពេលនឹកកូននោះ ខ្ញុំខំទៅធ្វើការ ស្ម័គ្រចិត្តនៅសាលាកូនក្មេងចាំ! សាលាមត្តេយ្យ ដែលគេមើលកូនក្មេងនោះ ដើម្បីឱ្យបានជួបកូនក្មេងចាំ! ហើយខ្ញុំពេលខ្លះហ្នឹង នឹកកូនខំមើលរូបថតកូន ស្រាប់ដូចឃើញរូបថតហ្នឹងកូនវាលោតចេញពីរូបថត មកចាំ! រួចខ្ញុំពេលហ្នឹងខ្ញុំ ភ័យណាស់ ខ្ញុំញីភ្នែកថាចុះម៉េចអីចឹង ហើយខ្ញុំៗចេះតែស្រមើស្រមៃថាចង់ឱ្យ ដូចខ្ញុំចង់ទប់ផែនដីហ្នឹងអីចឹង កុំឱ្យវាវិលហើយបង្វិលឱ្យវាទៅនៅពេលដែលខ្ញុំនៅ ពីក្មេងដូចថានៅរៀនសាលានៅឡើយ នៅសាលាស៊ីសុវត្ថិអី ដែលថា ពេលហ្នឹង យើងអត់មានកូនមានប្តីអី យើងដូចជាសប្បាយ ដូចថាមិនៗមាន អត់ មានកង្វល់ នោះចាំ! ហើយឥឡូវវាខ្វល់ពេកហ្នឹង ខ្ញុំចង់បកទៅរកសម័យហ្នឹង ពេលខ្លះខ្ញុំបន់ ថាឱ្យតែមានឡានអីមកបុកខ្ញុំឱ្យចំសសៃអីមួយឱ្យខ្ញុំភ្លេចអស់ កុំឱ្យខ្ញុំស្គាល់ ខ្លួន ឯងចាំ! ពេលឃើញផ្លែបារាំងស៊ីបាយតាមទូរទស្សន៍ ខ្ញុំក៏ស្រក់ទឹកភ្នែកដែរចាំ!

ហើយខ្ញុំមិនអាចទៅជួបជុំអ្នកណាដែលគេមានកូនចៅគេនៅជុំគ្នាទេចាំ! ហើយខ្ញុំស្តាប់ ភ្លេងខ្មែរក៏អត់បានទៀត ពេលទទួលទានបាយគឺថាបាយហ្នឹងវាលេបមិនចូល ហើយទឹកភ្នែកធ្លាក់ចូលចានបាយចាំ! ហើយខ្ញុំចេះតែឮសូរសំឡេងកូនខ្ញុំហ្នឹងស្រែកហៅ នៅក្នុងក្បាលខ្ញុំហ្នឹង ហើយខ្ញុំដើរគ្រវីក្បាលគឺថា វាឮសូរសំឡេងហ្នឹងរំពងពេកថាខ្ញុំភ័យណាស់ខ្លាចខ្ញុំទៅជាឆ្កួតចាំ! ខ្ញុំក៏សម្រេចចិត្តថាខ្ញុំនៅប្រទេសបារាំងគឺឥតប្រយោជន៍ខ្ញុំនឹងត្រឡប់ទៅប្រទេសកម្ពុជាវិញ ហើយខ្ញុំក៏សុំគេខាងខ្មែរក្រហម ហ្នឹងគឺថាដាក់ពាក្យសុំដើម្បីឱ្យខ្ញុំបានចូលទៅក្នុងប្រទេសកម្ពុជាវិញ តែខ្ញុំដាក់ពាក្យសុំ ហ្នឹងគឺខ្ញុំមិនបានសុំចូលជាដែលគេហៅថាហ្វ៊ុងនោះទេ ហើយខ្ញុំ...

រាសី ៖ បាទ! ចូលជាលក្ខណៈរបៀបម៉េចវិញអីចឹង?

សារីម ៖ ចាំ! ចូលជាលក្ខណៈថាអ្នកសុំចូលទៅស្រុកខ្មែរជាលក្ខណៈមហាជន។

រាសី ៖ បាទ! មិនមែនថាៗជាបុគ្គលិក ឬជាសមាជិកនៃគណបក្សកុម្មុយនីស្តអីចឹងអត់ទេ?

សារីម ៖ ចាសៗ! អត់មានចូលហ្វ៊ុងទេ ហ្វ៊ុងហ្នឹងគេហៅថារណសិរ្សរំដោះជាតិខ្មែរហ្នឹង ចាំ! Front Uni National Khmer ជាភាសាបារាំងចាំ! ខ្ញុំអត់មានចូលក្នុងហ្នឹងទេ ខ្ញុំទៅជាមនុស្សធម្មតាគឺចង់ទៅជួបកូនចៅរបស់យើងតែប៉ុណ្ណោះចាំ!។

រាសី ៖ បាទ! តើអ្នកស្រីនៅពេលហ្នឹងដឹងថាគេជម្លៀសប្រជាជនចេញពីទីក្រុងដែរ តើអ្នកស្រីមានការព្រួយបារម្ភអំពីសុវត្ថិភាពដែរ?

សារីម ៖ ចាំ! ពេលហ្នឹងគឺថាខ្ញុំនៅក្នុងប្រទេសបារាំងគឺខ្ញុំតាមដានស្ថានការណ៍នៅក្នុងស្រុកខ្មែរហ្នឹងខ្ញុំស្តាប់រ៉ាត់យោ(វិទ្យុ)អ្វីរាល់ពេលហើយខ្ញុំដឹងរឿងដូចជារឿងកប៉ាល់ម៉ៃយ៉ាហ្គេ របស់អាមេរិកាំងដែលច្រឡំថាច្រឡំចូលទៅក្នុងដែនសមុទ្រខ្មែរនៅម្តុំកំពង់សោម ហ្នឹងចាំ! រួចទៅពួកខ្មែរក្រហមបាញ់ ហើយទៅខ្ញុំដឹងទៀតពីរឿងថា លោក ហ៊ូ យន់ ហ្នឹងចាំ! ឮសូរគេនិយាយចចាមអារ៉ាមហ្នឹងថា លោក ហ៊ូ យន់ ហ្នឹងត្រូវគេសម្លាប់ ភ្លាមហ្នឹងចាំៗ! ព្រោះថាគាត់ហ្នឹងប្រឆាំងនឹងការជម្លៀស

ប្រជាជនចេញពីភ្នំពេញចា៎! ចា៎! ប៉ុន្តែខ្ញុំមិនស្មានថា ខ្មែរក្រហមសម្លាប់មនុស្សដូច ដែលយើងបានដឹង។

រាសី ៖ ក្រោយមកទៀត?

សារីម ៖ ក្រោយមកទៀតចា៎! ខ្ញុំគិតថាខ្ញុំត្រឡប់ទៅស្រុកខ្មែរវិញគឺខ្ញុំនឹងប្រគល់ខ្លួនខ្ញុំឱ្យខ្មែរក្រហមហ្នឹងគេអប់រំខ្ញុំទៅ ហើយខ្ញុំគិតថាគេអប់រំប្រហែលជា៦ខែអី ប្រហែលជាគេបណ្តោយឱ្យខ្ញុំហ្នឹងទៅរកគ្រួសារខ្ញុំ កូនខ្ញុំវិញហើយ ហើយពេលខ្ញុំទៅហ្នឹង គឺខ្ញុំត្រៀមលក្ខណៈគឺខ្ញុំទិញសំពត់ខោអាវខ្មៅទៅតាមដែលថា ដឹងថាគេឱ្យស្លៀកពាក់ខ្មៅ នោះចា៎! ហើយទៅខ្ញុំទិញតាំងពីថ្នដែកកេះ តាំងពីថ្នាំ ហើយកាំបិតកែតូចតាច ហើយនឹងថ្នាំសម្រាប់កូនក្មេង គឺខ្ញុំមានលុយទាំងប៉ុន្មានខ្ញុំទិញស្ទើរតែទាំងអស់។

រាសី ៖ គឺថាត្រៀមខ្លួន...។

សារីម ៖ ចាស១! ហើយយកទៅហ្នឹងខ្ញុំភ័យខ្លាចកូនខ្ញុំហ្នឹងស្លាប់អស់មុនពេលខ្ញុំទៅដល់ ខ្ញុំថាខ្ញុំទៅខ្ញុំនឹងបានជួយកូនខ្ញុំ ព្រោះខ្ញុំមានការសោកស្តាយដូចថាទុកឱ្យកូននៅជាមួយប្តី ហើយនឹងម្តាយខ្ញុំពេលស្រុកវេទនាអីចឹង គឺខ្ញុំត្រូវតែទទួលរងដូចថាខ្លួនឯងបង្កើតកូន មកត្រូវតែទទួលខុសត្រូវកូនរបស់ខ្លួន ចា៎!។

រាសី ៖ បាទ! សូមអរគុណអ្នកស្រី នៅ សារីម។

សារីម ៖ ចា៎! អរគុណលោក ប៉ូច រាសី ចា៎! អរគុណ។ ចា៎! ខ្ញុំសុំបន្តថា ក្រោយ ខ្មែរក្រហមយកស្រុក ខ្ញុំទៅពេទ្យក្រពះសឹងតែរាល់ខែ ហើយពេទ្យខំអង្វរខ្ញុំឱ្យខ្ញុំឈប់ គិតថាខ្ញុំមិនឈប់គិតទេ ក្រពះខ្ញុំហ្នឹងអត់ជាទេចា៎! ហើយស្រីអាមេរិកាំងម្នាក់ទៀតនោះវារៀនជាមួយខ្ញុំ គឺគាត់ឃើញខ្ញុំព្រួយចិត្តខ្លាំងពេកហ្នឹងគាត់នាំខ្ញុំថា មកយើងទៅធ្វើបាតុកម្ម ជួយខ្ញុំថាដើម្បីថ្កោលទោសពួកខ្មែរក្រហម ហើយនឹងយើងសុំឱ្យ អង្គការកាកបាទក្រហមហ្នឹងជួយរកកូនខ្ញុំចា៎! ខ្ញុំប្រាប់នាងនោះថា ធ្វើទៅអត់បាន ផលអ្វីទេចា៎! ហើយលោកអាចារ្យ Church ម្នាក់ហ្នឹងដែលគាត់ទាក់ទងជាមួយកូនសិស្សនៅបឺហ្សង់សុងហ្នឹង ប៉ៃហ្សីល គាត់បានជួយឃាត់ខ្ញុំ ព្រោះខ្ញុំចង់ទៅស្រុកសៀមដើម្បីទៅស៊ើបការណ៍មើលថាយើងធ្វើយ៉ាងម៉េចដើម្បីរកកូនយើងឱ្យឃើញ

ហើយគាត់ឃាត់ខ្ញុំថាទៅតាមស្រុកសៀមហ្នឹងមានគ្រោះថ្នាក់ ហើយខ្ញុំចេះតែខំច្រក មកពីខ្ញុំភ័យខ្លាចរឿងដូចយល់សប្តិដែលខ្ញុំឃើញហ្នឹងចាំ! ខ្ញុំយល់សប្តិឃើញកាលពីឆ្នាំ ១៩៧៣ពេលខ្ញុំមានកូនតែមួយនោះ ឃើញថាយៀកកុងវាយបែកភ្នំពេញហើយ ចូលមកដេញប្រជាជនចេញពីភ្នំពេញអស់ ហើយខ្ញុំពេលនោះខ្ញុំនៅបង្រៀនសាលា Lycee d’applicationហ្នឹងជិតវិមានឯករាជ្យហ្នឹង ខ្ញុំជួលផ្ទះនៅក្រោយសាលាហ្នឹង ហើយខ្ញុំរត់មកផ្ទះឃើញទ្វារចំហ ហើយអត់ឃើញកូនខ្ញុំ អត់ឃើញប្តីខ្ញុំ ហើយនឹង ឈ្នួលអីទាំងអស់ ខ្ញុំរត់ទៅរកផ្ទះម្តាយក្មេកខ្ញុំនៅជិតពេទ្យចិន មិនឃើញមនុស្ស ខ្ញុំរត់ទៅផ្សារថ្មី រត់ចុះឡើងទៅ ខ្លួនខ្ញុំធ្លាក់ទៅដល់សមុទ្រស្រាប់តែខ្ញុំឃើញកប៉ាល់ មួយធំ ខ្ញុំក៏រត់ជ្រុលជើងទៅធ្លាក់ចូលក្នុងកប៉ាល់ហ្នឹងទៅខ្ញុំឃើញសាច់ញាតិ ខ្ញុំម្នាក់ហ្នឹងគាត់នៅក្នុងហ្នឹង ហើយប្តីគាត់ធ្វើរដ្ឋមន្ត្រីនៅពេលលន់ នល់ ឃើញគាត់ ស្លៀកពាក់សុទ្ធតែអាវស័ក្តិ ហើយកូនគាត់នៅជុំខ្លួន ហើយកប៉ាល់ហ្នឹងក៏ចេញទៅ ហើយខ្ញុំយំរហូតដល់ភ្ញាក់ខ្លួន ហើយខ្ញុំមកដល់ស្រុកបារាំងក៏ខ្ញុំជួបបងសាច់ញាតិខ្ញុំ ហ្នឹងប្តីគាត់មកធ្វើការនៅហ្ស៊ីណែវ គាត់មកលេងខ្ញុំពេលនោះខ្ញុំរឹតតែស្លុតថែម ទៀតចាំ! ហេតុដូច្នេះហើយបានខ្ញុំទប់មិនចង់ឱ្យរឿងហ្នឹងវាកើតឡើង មានខ្ញុំតែម្នាក់ឯងនៅប្រទេសបារាំងគឺខ្ញុំខំត្រឡប់ទៅស្រុកខ្មែរវិញ ដើម្បីកុំឱ្យដូចយល់សប្តិចាំ! ខ្ញុំមិនបានប្រាប់ប្តីខ្ញុំឱ្យដឹងពីយល់សប្តិហ្នឹងទេ ហើយដល់មកស្រុកបារាំងពេលជួបសាច់ញាតិដែលមកលេងខ្ញុំហ្នឹង ហើយដែលខ្ញុំឃើញគាត់នៅក្នុងកប៉ាល់ដូចគ្នាហ្នឹង ខ្ញុំក៏សរសេរសំបុត្រទៅប្តីខ្ញុំឱ្យគាត់រៀបចំដំណើរយកកូនមកស្រុកបារាំង ហើយខ្ញុំក៏សរសេរទៅប្អូនស្រីគាត់ ហើយប្តីគេធ្វើជាអ្នករកស៊ីដឹកទំនិញ គេហៅកុងវ័រទន្លេសាប នោះពេលហ្នឹង គេអាចមានលុយឱ្យគាត់ខ្ចីដើម្បីរៀបចំដំណើរយកកូនមកស្រុកបារាំង ប្រាក់ដែលឱ្យប្តីខ្ញុំខ្ចីទាំងប៉ុន្មានហ្នឹង ខ្ញុំនឹងសងទាំងអស់ ព្រោះឥឡូវហ្នឹងខ្ញុំគ្រាន់តែអត់មានពេលសម្រាប់ធ្វើការរកប្រាក់តែប៉ុណ្ណោះ ដល់ខែមីនាហើយបានប្អូនថ្លៃខ្ញុំ ហ្នឹងសរសេរសំបុត្រមកថាគេឱ្យលុយខ្ចី តែប្តីខ្ញុំគាត់អត់អើពើអំពីរឿងហ្នឹង។

រាសី ៖  បាទ! កាលហ្នឹងកូនរបស់អ្នកស្រីទាំងពីរនាក់ហ្នឹងអាយុប៉ុន្មានដែរ?

សារីមៈ ចាំ! ពេលហ្នឹងកូនខ្ញុំបងទីមួយហ្នឹងអាយុ៥ឆ្នាំចាំ! ហើយកូនទី២នៅកូនខ្ចីនៅឡើយទេ ពេលខ្ញុំមកហ្នឹងកូនហ្នឹងអាយុ២ខែចាំ! ពេលខ្មែរក្រហមចូលហ្នឹង កូនហ្នឹងអាយុប្រហែលជា១០ខែ។

រាសីៈ បាទៗ! អីចឹងក្រោយពីសម្រាលកូនទី២ហើយ អ្នកស្រីអញ្ជើញទៅស្រុកបារាំង?

សារីមៈ ចាសៗ!។

រាសីៈ បាទ! ហើយខ្ញុំសុំត្រឡប់មកពេលដែលអ្នកស្រីមានប្រសាសន៍ថាទៅដាក់ពាក្យនៅជាមួយខ្មែរក្រហមដើម្បីសុំមកវិញហ្នឹង តើមកដាក់ពាក្យនៅទីណា? នៅទីក្រុងប៉ារីស ឬ នៅទីណា?

សារីមៈ ចាំ! នៅទីក្រុងប៉ារីសហ្នឹងគេមានកន្លែងមួយគេហៅថា Mission របស់គេហ្នឹងចាំ! ហើយដាក់ពាក្យហ្នឹងយើងត្រូវសរសេរពាក្យហ្នឹងទៅតាមពាក្យសម្ដីរបស់គេខ្ញុំអត់ចេះសរសេរ ខ្ញុំពឹងគេឱ្យសរសេរឱ្យ។

រាសីៈ ជាខ្មែរ?

សារីមៈ ចាំ!

រាសីៈ ប៉ុន្តែយ៉ាងម៉េចបានមិនចេះសរសេរ?

សារីមៈ ខ្ញុំមើលសរសេរមិនកើត។

រាសីៈ ពាក្យបដិវត្តន៍ច្រើនពេក?

សារីមៈ ចាំ! ពាក្យខ្លាំងពេកទៅ ហើយនេះខ្ញុំសរសេរអត់កើតខ្ញុំពឹងគេឱ្យសរសេរឱ្យ ខ្ញុំគ្រាន់តែស៊ីញ៉េ។

រាសីៈ បាទៗ! ហើយៗពេលហ្នឹងប៉ុន្មាននាក់គេដាក់ពាក្យហ្នឹងហើយដែលដាក់ពាក្យជាមួយអ្នកស្រីហ្នឹង?

សារីមៈ ចាំ! ពេលហ្នឹងស្រីៗដែលមកជាមួយខ្ញុំហ្នឹងមានគ្នាទាំងអស់៨នាក់ ហើយទៅបីនាក់ត្រឡប់ទៅវិញ ខ្ញុំ សួន ហើយនឹង វណ្ណា។ យើងទាំងបីនាក់ដាក់ពាក្យទៅជាមួយ

គ្នាហើយនឹងមានលោកគ្រូម្នាក់ទៀតហ្នឹងឈ្មោះលោក អាន ចាំ! គាត់ទៅវិញដែរ ចាំ! ហើយក្នុងអ្នកមកជាមួយខ្ញុំហ្នឹង មានអ្នកពីរនាក់ហ្នឹងប្ដីគាត់បានចេញមក ឈ្មោះ អ្នកស្វាត់ស្យា ប្ដីគាត់ទៅប្រជុំនៅក្រៅប្រទេសមុនស្រុកធ្លាក់ហ្នឹង គាត់យក កូនគាត់ ប្រុសទាំងពីរហ្នឹងទៅជាមួយ ហើយនឹងយកបងថ្លៃស្រីហ្នឹងទៅជាមួយ ផង រួចក៏បាន ជួបប្រពន្ធនៅបីហ្សង់សុងហ្នឹង ហើយអ្នកម្នាក់ទៀតហ្នឹងឈ្មោះអ្នក តាន់តាន់ ហ្នឹង Madam អ៊ុំង ប៉ូហូ ហ្នឹងគាត់យកកូនគាត់មកជាមួយរួចហើយ ប៉ុន្តែ ប្ដីគាត់ក៏បានចេញមក ព្រោះគាត់ធ្វើអង្គការ Care ប្ដីហ្នឹង ហើយអាមេរិកាំងក៏ យកគាត់ចេញមក នៅថ្ងៃទី១១ ខែមេសា ដែលគេដឹកមនុស្សចេញតាម ឧទ្ធម្ភាគចក្រនោះចាំ!។

រាសី ៖ បាទ! តាំងពីដាក់ពាក្យដល់រហូតគេឱ្យឡើងកប៉ាល់ហោះហ្នឹង រយៈពេលប៉ុន្មានថ្ងៃទៅ?

សារីម ៖ ចាំ! ពេលហ្នឹងខ្ញុំដាក់ពាក្យដូចជា៤-៥ខែមុនទៅ។

រាសី ៖ ពួកខ្មែរក្រហមគេទទួលអ្នកដាក់ពាក្យទាំងអស់ដែរ ឬក៏គេមានផាត់អ្នកណាចោល?

សារីម ៖ ចាំ! អាហ្នឹងខ្ញុំអត់ដឹងទេចាំ! ខ្ញុំអត់ដឹង ខ្ញុំដឹងតែខ្លួនឯង ហើយជាមួយពួកហ្នឹងខ្ញុំ មិន សួរហ៊ានសួរដេញដោលទេចាំ! ព្រោះអ្នកខ្លះហ្នឹងឆ្វេងពេក រហូតដល់ថា ប្រឈមមុខតជាមួយខ្ញុំពីរឿងថា អ្នកដែលបានមកស្រុកបារាំងសុទ្ធតែអ្នកជិះជាន់ គេ ទាំងអស់ ហើយខ្ញុំថាចំពោះខ្ញុំ គ្រួសារខ្ញុំមិនដែលជិះជាន់នរណាទេ ព្រោះ ឪពុកម្ដាយខ្ញុំជាអ្នកចម្ការ។ យើងខំធ្វើការហើយយើងខំរៀនសូត្រ។ យើងបានអី មក ហ្នឹងគឺសុទ្ធតែបានដោយសារកម្លាំងរបស់យើង។ អ្នកហ្នឹងប្ដីគាត់ហ្នឹងឈ្មោះ ស្វាយ ហុកឃី ចាំ! គាត់ហ្នឹងប្រាប់ខ្ញុំថា នែ! បើមិនជិះជាន់គេដោយផ្ទាល់ ក៏ ជិះជាន់ជា ប្រយោលដែរ។ ខ្ញុំថាខ្ញុំអត់បានយកជើងអ្នកណាទៅជិះជាន់គេទេចាំ!។

រាសី ៖ បាទ! បើអីចឹងអ្នកស្រីដឹងខ្លះដែរអំពីថាទៅហ្នឹងគឺគ្រោះថ្នាក់ប្រឈមនៅពីមុខហ្នឹងគឺដឹង ដែរ ក៏ប៉ុន្តែ?

សារីម ៖ ចាំ! ខ្ញុំដឹងថាអាចមានគ្រោះថ្នាក់ ប៉ុន្តែខ្ញុំគិតថាខ្ញុំជាស្រី ហើយធ្វើគ្រូបង្រៀន ហើយប្ដី ខ្ញុំមិនមែនជាអ្នកធ្វើទាហាន គាត់ធ្វើការនៅធនាគារជាBank Teller។ អីចឹងម្ល៉ោះ

ហើយខ្ញុំគិតថា យើងមិនមានគ្រោះថ្នាក់អីទេ ខ្ញុំគិតថាអីចឹងចាំ! ប្អូន ប្រុសខ្ញុំដែលធ្វើទាហានម៉ារីន ជាអាំងហ្សេញ៉ូរ(វិស្វករ)អេឡិកត្រូនិកមករៀននៅប្រទេសអាមេរិក មកក្រោយខ្ញុំមួយខែ ខ្ញុំបានឃាត់មិនឱ្យប្អូនប្រុសខ្ញុំហ្នឹងត្រឡប់ទៅប្រទេស កម្ពុជាវិញទេ ព្រោះប្អូនប្រុសខ្ញុំហ្នឹងធ្វើទាហាន។ ខ្ញុំខ្លាចមានគ្រោះថ្នាក់។ ប្អូនប្រុសខ្ញុំគេថានឹកប្រពន្ធ។ គេចង់ទៅវិញ។ ខ្ញុំបានប្រាប់គេថា ប្រពន្ធឯងគេមានសំណាង ថាដែល ឯងជាទាហានហ្នឹងមិននៅជាមួយគេពេលស្រុកផ្លាស់ប្តូររបៀបនេះចាំ! ខ្ញុំបានប្រាប់ វណ្ណា ថាកុំឱ្យទៅស្រុកខ្មែរវិញ ព្រោះមានតែប្តី។ ប្តីគាត់ហ្នឹងមើលទៅឃើញប្រសប់ ណាស់ ព្រោះគាត់អាចរស់ក្នុងរបបខ្មែរក្រហមបាន ហើយឱ្យនៅស្រុកបារាំងទៅចាំ ស្រុកយ៉ាងណាទៅបើប្តីនៅរស់ចាំទទួលគាត់មកស្រុកបារាំងហើយ វណ្ណា គាត់ថា ហ៊ឺស! ទាល់តែបងនៅបានខ្ញុំនៅដែរ។

រាសី ៖ បាទ! ហើយចុះសំបុត្រកប៉ាល់ហោះ? ហើយកប៉ាល់ហោះសោហ៊ុយអីទាំងអស់ហ្នឹង តើ យើងចេញខ្លួនឯង ឬក៏ពួកខ្មែរក្រហមចេញឱ្យ?

សារីម ៖ ចាំ! យើងចេញខ្លួនឯង ព្រោះយើងបានបួកមកហ្នឹង គេឱ្យសំបុត្រកប៉ាល់ហោះយើងមកហើយទៅស្រុកវិញចាំ! ដូច្នេះយើងយកសំបុត្រកប៉ាល់(ហោះ) ដែលសម្រាប់ទៅទៅឱ្យគេ ហើយគេទិញដំណើរទៅហ្នឹងជាក្រុម ហើយយើងចេញពីស្រុកបារាំងទៅ យើងទៅ ចុះនៅស្រុកចិននៅសម្រាកហ្នឹងមួយយប់ រួចទៅស្អែកឡើងបានយើងទៅស្រុក ខ្មែរចាំ!។ ចាំ! ហើយអ្នកខ្លះទៅដល់ស្រុកចិនហ្នឹង គេមិនទាន់ទៅស្រុកខ្មែរភ្លាមទេ គេនៅលេងស្រុកចិនមួយអាទិត្យអីទៅ ហើយស្រុកចិនហ្នឹងគេយក៦០ប្រាំងក្នុងមួយថ្ងៃ។

រាសី ៖ បាទ! ពីស្រុកចិនទៅស្រុកខ្មែរ តើអ្នកស្រីជិះកប៉ាល់ហោះដែលគេជួលឱ្យដាច់មុខ ព្រោះពេលហ្នឹងអត់មានកប៉ាល់ហោះឯកជនអីហោះចេញចូលទេមិនអីចឹងបាទ?

សារីម ៖ ចាំ! ពេលហ្នឹងមានតែប្រទេសចិនមួយទេដែលចូលស្រុកខ្មែរបាននៅពេលនោះ ដូច្នេះមនុស្សណាដែលចង់ទៅស្រុកខ្មែរ កូនសិស្ស និស្សិតអីដែលមកពីទៅពីប្រទេសអាមេរិកទៅអីៗហ្នឹង ត្រូវទៅស្រុកបារាំងសិនចាំ! ទៅដល់ស្រុកបារាំងសិនហើយ

បានពួកខាងហ្នឹងគេរៀបចំដំណើរអ្នកដែលថាចង់ទៅស្រុកខ្មែរវិញហ្នឹង គេយក យើង ទៅទិញជាក្រុមសម្រាប់កប៉ាល់ហោះចិន យើងជិះកប៉ាល់ (ហោះ) ចិនពី ប៉ារីសទៅស្រុកចិន ក៏កប៉ាល់ហោះចិន បានចិនគេជូនដំណើរយើងទៅស្រុកខ្មែរ ទៀតចាំ!

រាសី ៖ បាទ! សូមអរគុណអ្នកស្រី នៅ សារីម បាទ!។

សារីម ៖ អរគុណលោក ប៉ូច រាសី ចាំ! មុននឹងខ្ញុំត្រឡប់ទៅប្រទេសខ្មែរវិញឆ្នាំ១៩៧៦ហ្នឹង ខាង ប៊ុយរ៉ូ (Bureau) ពួកហ្នឹងដែលជារណសិរ្សរបស់សម្ដេច សីហនុ រួមគ្នា ជាមួយខ្មែរ ក្រហមដើម្បីវាយពួកលន់ នល់ ហ្នឹង បានបង្គាប់ឱ្យយើងទៅមើលកុន មួយ ហើយនឹង ទៅគោរពផ្នូរសពរបស់បុរសម្នាក់ដែលគេស្លាប់ពេលដែលពួក ហ្នឹងឈ្លោះគ្នាជាមួយនឹងពួកកាន់ជើងខាងពួកលន់ នល់។ ពួកហ្នឹងឈ្លោះគ្នានៅ ផ្ទះខ្មែរដែលគេហៅថា Masion du Cambodge នៅក្នុងប្រទេសបារាំងហ្នឹង ហើយ ផ្ទះខ្មែរដែលផ្ទះសម្រាប់កូនសិស្ស មកសំណាក់នៅរៀនហ្នឹង ពេលខ្ញុំទៅដល់ហ្នឹង ខ្ញុំឃើញគួរឱ្យអាណោចអធម គឺថា វាបែកកញ្ចក់ បង្អួចអីធ្លាក់មក រួចទៅមាន សុទ្ធតែការគួរក្រវើមក្រវ៉ាម។ ពួកខ្ញុំមកពី បីហ្សង់សុងហ្នឹងគិតថាគ្នាមិនទៅគោរព ផ្នូរសពរបស់វីរបុរសហ្នឹងហ្នឹងទេ យើងគ្រាន់តែ ទៅមើលកុន ព្រោះយើងចង់ដឹង ថាកុនហ្នឹងគេនិយាយពីអី? ដល់យើងទៅមើលកុន ហ្នឹងមុននឹងគេបញ្ចាំង គេមាន លេងរបាំឱ្យយើងមើល ហើយរបាំហ្នឹងស្រាប់តែមាន ច្រៀងផង រាំផង ស្រាប់តែ ចេញសុទ្ធតែស្រីយួនស្លៀកអាវយ៉េហ្នឹងកាន់មែកឫស្សី ចេញមក ហើយរាំច្រៀង ទ្រូងទូងឆាំងអីចឹងទៅ ចប់ទៅបានគេបញ្ចាំងកុនឱ្យយើង មើល។ ហើយកុនហ្នឹង ចំណងជើងរបស់វាជាភាសាបារាំងថា "La Feu et Les Fleurs" បើបកជាខ្មែរវិញ ថា «បុប្ផាហើយនឹងកាំភ្លើង» គឺថាគេនិយាយរៀបរាប់ បញ្ចាំងឱ្យឃើញពីសភាព ដែលពួកយៀកកុងតស៊ូច្បាំងនៅតាមផ្លូវក្នុងទីក្រុង ហើយគេ ជីករន្ធពួននៅក្នុង ទីក្រុង ហើយគេមាននមនុស្សជិះកង់ ស្រីៗជិះកង់ច្រើនណាស់ចាំ! តាមខ្ញុំចាំ ទេសភាពនៅពេលហ្នឹង ហើយពួកខ្ញុំពេលហ្នឹងគឺថា ស្រឡាំងកាំង ព្រោះថា យើង

ទៅស្រុកខ្មែរ ស្រាប់តែគេឱ្យទៅមើលកុននិយាយពីរឿងយួនដែលគេតស៊ូចាំ! ហើយមានរបាំយួនកាន់មែកឫស្សីទៀត។ មុននឹងខ្ញុំទៅស្រុកខ្មែរ ខ្ញុំបានមើលកាសែតមួយឈ្មោះ ឡឺម៉ុង នៅថ្ងៃទី៥ ខែ Janvier ខែមករា ហ្នឹងចាំ! ហើយគេចេញផ្សាយថាៗមានខាងបរទេសហ្នឹងគេឱ្យថ្នាំខ្មែរច្រើនណាស់ ចាំ! ថ្នាំពេទ្យថ្នាំអីហ្នឹងរាប់តោន ប៉ុន្តែខ្មែរក្រហមមិនយក ដោយខ្មែរក្រហមថាខ្លាំងចូលមកតាមគ្រប់រូបភាព ហើយខ្មែរក្រហមមានជំហរឯករាជ្យម្ចាស់ការ ដូច្នេះគេមិនយកថ្នាំជំនួយទាំងនោះទេចាំ! ដល់ពេលខ្ញុំឡើងកប៉ាល់ហោះចេញពីស្រុកបារាំងទៅហ្នឹងស្ត្រីម្នាក់ ហ្នឹងឈ្មោះ ប៉ុក ម៉ូណា គាត់ធ្លាប់រៀន សាលាសាកលវិទ្យាល័យ អក្សរសាស្ត្រ ហើយគាត់ធ្វើគ្រូបង្រៀនភាសាខ្មែរបារាំងដែរ គាត់ជាសមាជិកហ្នុំងហ្នឹងពេលយើងត្រឡប់ទៅវិញហ្នឹង ថ្ងៃហ្នឹងគាត់បានយកកញ្ចប់បារាំងមួយហ្នឹងពីគ្រូបារាំង ម្នាក់ហ្នឹងដែលគេយកមកឱ្យនៅវាលកប៉ាល់ហោះហ្នឹង។ គ្រូបារាំងហ្នឹងធ្លាប់បង្រៀនពួកខ្ញុំដែរចាំ!។ ចាំ! ខ្ញុំសុំបន្តចាំ! ពេលនៅស្រុកបារាំងហ្នឹងមុននឹងទៅស្រុកខ្មែរហ្នឹង ខ្ញុំខំប្រឹងណាស់។ ខ្ញុំខំប្រឹងឱ្យយល់ពីរបបក្រហមចាំ! ហើយបង្ខំខ្លួនឯង ឱ្យទៅរកសៀវភៅមើលសៀវភៅកុម្មុយនីស្ត ជាពិសេសគឺថាសៀវភៅកុម្មុយនីស្ត ចិនចាំ! រួចទៅខ្ញុំមើលៗមើលទៅខ្ញុំមើលអត់ទៅមុខរួច ខ្ញុំធុញ ចាំ! មើលមិនបាន ចប់ទេ ធុញ ព្រោះខ្ញុំមើលទៅឃើញដូចថាស្អីសុទ្ធតែកើតឡើងដោយសារប្រធាន ម៉ៅទាំងអស់ រួចតាំងមនុស្សម្នាក់ៗហ្នឹងដូចអត់មានការសម្រេចអីខ្លួនឯង ខួរក្បាល អីខ្លួនឯងគិតអីចឹង ប្រធានម៉ៅគិតឱ្យទាំងអស់ចាំ! ហើយនៅស្រុកបារាំងពេលហ្នឹង គឺថាតាមកញ្ចក់លក់សៀវភៅ ហាងលក់សៀវភៅឃើញដាក់បង្ហាញសៀវភៅ ដែលមានចំណងជើងថា ជាភាសាបារាំងគេថា"*Quand la Chine s'éveillera, le monde tremblera*" បានន័យថាដល់ពេលប្រទេសចិនហ្នឹងភ្ញាក់ពីដេកបើកភ្នែកភ្ញាក់ពីដេក មានន័យថា ពិភពលោកនឹងរញ្ជួយកក្រើកហើយចាំ!។

រាសី ៖ បាទ! ទៅដល់ថ្ងៃមុនឡើងយន្តហោះ តើអ្នកស្រីមានអារម្មណ៍ដូចម្តេចដែរ?

សារីម ៖ ចាំ! មុនត្រឡប់ទៅវិញហ្នឹង ខ្ញុំមកសំចតជួលបន្ទប់កន្លែងកូនសិស្សនៅក្នុងប៉ារីស គេហៅ Masion des provinces ឬផ្ទះសំណាក់សម្រាប់អ្នកមកពីខេត្ត ចាំ! ពេលហ្នឹងខ្ញុំជួបពេលខ្ញុំទៅងូតទឹក ប្រុសខ្មែរម្នាក់គាត់ដើរនៅកន្លែងតាមផ្លូវ ដែលខ្ញុំទៅងូតទឹកហ្នឹង ហើយគាត់ឃើញយើងហ្នឹង គាត់ថា អូ! អ្នកអញ្ជើញទៅ ស្រុកខ្មែរ ដូចថាគាត់របៀបដូចថាអរយើងបានត្រឡប់ទៅស្រុកខ្មែរវិញអីចឹង។ រួចទៅខ្ញុំថា ហ៊ឹស! ហ្នឹងហើយខ្ញុំទៅហ្នឹងគឺថា ខ្ញុំអត់ចូលចិត្តរបបខ្មែរក្រហមដែល ជម្លៀសមនុស្សចេញពីភ្នំពេញអីហ្នឹងទេចាំ! ប៉ុន្តែខ្ញុំមានកូនពីរខ្ញុំនៅហ្នឹង មិនដឹងឱ្យខ្ញុំ ធ្វើម៉េច ខ្ញុំត្រូវតែទៅ។ រួចទៅ ហើយទៅខ្ញុំដើរទៅងូតទឹក។ ដល់ពេលខ្ញុំទៅដល់ស្រុកខ្មែរ ហ្នឹង ខ្ញុំទៅនៅកន្លែងគេហៅថា ជំរំដែលគេដាក់ពួកយើងទៅពីបរទេសទៅនៅតាលៃ ហ្នឹង ប៉ុន្មានខែក្រោយមកស្រាប់ឃើញម្នាក់ហ្នឹងគេនៅកន្លែងដែលយើងកំពុងច្រូត ស្រូវចាំ! រួចទៅពេលហ្នឹងក្តៅមែនទែន ហើយគេថា ហ៊ូ! អ្នកនៅហ្នឹងនៅឡើយទេ ហី? ខ្ញុំថា ខ្ញុំនៅហ្នឹងនៅឡើយទេ ខ្ញុំអត់ទាន់ទៅណាទេ ខ្ញុំសូមជម្រាបថា កិច្ចសន្យា ដែលយើងត្រឡប់ទៅស្រុកខ្មែរវិញហ្នឹង គេប្រាប់យើងថាបើទៅដល់ស្រុកចិន ហើយ អ្នកឯងចង់ប្តូរគំនិត អ្នកឯងអាចប្តូរគំនិតបាន ហើយយើងអាចត្រឡប់មកស្រុក បារាំងវិញបានអីចឹងចាំ! ហើយទៅ ប៉ុន្តែដូចខ្ញុំអីចឹង ខ្ញុំផ្តាតថាខ្ញុំអាណិតកូនខ្ញុំខ្លាំង ខ្ញុំនៅមិនកើត ទទួលទានបាយក៏មិនកើត ពេលបាយទឹកភ្នែកស្រក់ចូលចានរាល់ថ្ងៃចេះតែនឹក ឃើញស្រមៃទៅដល់ទុក្ខវេទនារបស់កូនយើងដែលនៅក្នុងស្រុកខ្មែរហ្នឹង គឺថាម្លេ៉ះ ហើយយើងហ្នឹងវាទៅជាឈឺចាំ!។

រាសី ៖ បាទ! នេះជាផ្លូវ?

សារីម ៖ ចាំ! ផ្លូវចិត្តចាំ!។

រាសី ៖ ហើយមានអ្នកណាគេតើមិនចង់ទៅត្រឡប់ពីចិនវិញទេ?

សារីម ៖ ចាំ! ខ្ញុំឮសូរគេនិយាយថាមានលោកម្នាក់នោះគាត់ទៅដល់ស្រុកចិន ហើយទៅដល់នោះគាត់ឮសូរថានៅស្រុកខ្មែរគេដូរឈ្មោះមនុស្ស ដល់រួចស្រាប់តែគាត់ថា ហ៊ឺ!

បើដូរឈ្មោះអីចឹងគាត់ទៅរកកូនគាត់ម៉េចឃើញ ហើយថាគាត់ក៏មិនទៅស្រុកខ្មែរ ចាំ! អាហ្នឹងខ្ញុំឮសូរគេនិយាយអីចឹងចាំ!។

រាសី ៖ បាទ! ការធ្វើដំណើរតាមយន្តហោះពីស្រុកចិនទៅស្រុកខ្មែរ ទៅភ្នំពេញ អ្នកស្រីនៅចាំទេ រយៈពេលប៉ុន្មានម៉ោង?

សារីម ៖ ចាំ! ប្រហែលជាបីម៉ោងតាមខ្ញុំគិតចាំ! ហើយពេលនោះយើងចេញពីស្រុកបារាំង ទៅគឺថាថ្ងៃ៦ ខែ១ ឆ្នាំ១៩៧៦ ចាំ! ហើយដល់ខ្ញុំទៅដល់ស្រុកចិនសម្រានមួយ យប់ទៅ ហើយទៅដល់ស្រុកខ្មែរគឺថ្ងៃ៧ មករា ឆ្នាំ១៩៧៦ចាំ!។

រាសី ៖ ៧ មករា បាទ!

សារីម ៖ ហើយពេលបែកមុនចេញទៅស្រុកខ្មែរហ្នឹង ខ្ញុំរួមតុជាមួយលោកយាយ គឹម ជាម្ដាយរបស់លោក អ៊ិន សុកាន លោក អ៊ិន សុកាន ជាគ្រូពេទ្យ ហើយក្នុងតុបាយហ្នឹងមានកូនចៅគាត់ហ្នឹងលោក អ៊ិន សុផាន់ ហ្នឹងកូនគាត់ធ្វើជាវិស្វករ ហើយប្រពន្ធ ហើយនឹងកូនស្រីរបស់លោកយាយ គឹម ក៏រួមតុបាយជាមួយខ្ញុំដែរ ហើយម្ហូបរបស់ យើងមានច្រើនមុខ តែពិសេសមាននំប៉ាវ។ ខ្ញុំឃើញនំប៉ាវហ្នឹងខ្ញុំលូកយកនំប៉ាវ ព្រោះថាខានទទួលទាននំប៉ាវយូរហើយ ស្រាប់តែយកមកខាំទៅនំប៉ាវហ្នឹងអត់មានស្នូល ទេចាំ! សូមអរគុណចាំ!

រាសី ៖ បាទ! សូមអរគុណអ្នកស្រី នៅ សារីម បាទ។

សារីម ៖ ចាំ! អរគុណលោក ប៉ូច រាសី ចាំ! អរគុណ។ ចាំ! ក្នុងកប៉ាល់ហោះជិះពី ស្រុកបារាំងទៅស្រុកចិនហ្នឹង ខ្ញុំអង្គុយជាប់លោកម្នាក់នោះឈ្មោះលោក យូ តុល គាត់ធ្វើជាទាហានខាងថ្មើរជើង ហើយគាត់មកដល់ស្រុកអាមេរិកហើយ គាត់ត្រឡប់ ទៅវិញ ហើយខាងស្ដាំដៃខ្ញុំឆ្លងផ្លូវដើរក្នុងកប៉ាល់ហោះហ្នឹងមានស្ត្រីម្នាក់ហ្នឹងគាត់មានកូនមួយទៅជាមួយ ខ្ញុំគួរសមជាមួយគាត់។ ខ្ញុំក៏សួរថា កូនអ្នកឈ្មោះអីចាំ!? ហើយគាត់ថា កូនខ្ញុំនេះបើឈ្មោះកូនកម្មករកសិករ ឈ្មោះវា អាវ៉ា បើកូន ចក្រពត្តិ ឈ្មោះវាអា កុសល ហើយខ្ញុំស្រឡាំងកាំងចាំ! រួចក្នុងកប៉ាល់ (ហោះ) ដែលទៅពីស្រុកចិនទៅស្រុកខ្មែរហ្នឹង មានម្នាក់នោះគាត់ស្ពាយកូនផង កូនអាយុប្រហែល

មួយ ខូប គាត់ស្លាយ ហើយកូនពីរនាក់ទៀតគាត់ដឹកដៃតូចៗប្រហែល៤ឆ្នាំ ៥ឆ្នាំ ខ្ញុំសួរ គាត់ថា! អ្នកកូនតូចៗអីចឹងយកទៅស្រុកខ្មែរដែរពេលពិបាកអីចឹង? គាត់ថាបើទុកនៅស្រុកបារាំងកូនរបស់ខ្ញុំទៅចក្រពត្តិអស់ហើយ។ ដល់ទៅដល់ស្រុកខ្មែរ ខ្ញុំដឹងថាអ្នកហ្នឹងប្ដីគាត់ទៅតាមក្រោយគាត់។ គាត់ហ្នឹងទៅមុន ហើយអ្នកមួយទៀត ប្ដីគាត់ក៏ទៅតាមក្រោយដែរ។ អ្នកដែលមានកូនឈ្មោះ កុសល កូនចក្រពត្តិហ្នឹង ខ្ញុំឮសួរឆ្លើយអីចឹងធ្វើឱ្យខ្ញុំពិចារណាអំពីជំហារអ្នកដែលត្រឡប់ទៅស្រុកខ្មែរវិញអ្នកខ្លះ នោះចាំ! អរគុណ។

រាសី ៖ បាទ! ហើយអ្នកស្រីពេលចុះពីកប៉ាល់ហោះភ្លាម អ្នកស្រីបានឃើញអ្វីខ្លះ?

សារីម ៖ ចាំ! កប៉ាល់ (ហោះ) គេប្រាប់ថា ឥឡូវយើងចុះដល់ដីខ្មែរហើយហ្នឹង។ អ៊ូយ!រំភើបណាស់ ខ្លួនខ្ញុំវាញ័រកន្ត្រាក់ម៉េចមិនដឹងទេចាំ! រួចខ្ញុំក៏រៀបចំផ្លាស់សំពត់ថា ចុះទៅស្រុកខ្មែរដែល មានខ្មែរក្រហមអីចឹង យើងស្លៀកខោទៅដូចជាមិនល្អមើលទៅ ហើយយើងមើល ទៅតាមបង្អួចទៅខាងក្រោម យើងឃើញផ្ទះតូចៗ ខ្មមៗច្រើនណាស់ ហើយខ្ញុំឆ្ងល់ ណាស់ម៉េចបានមានផ្ទះតូចៗដូចខ្មមអីក៏ច្រើនម្ល៉េះ។ ហើយដល់កប៉ាល់ហោះចុះ ដល់ពោធិ៍ចិនតុងៗដូចចុះវាឃើញ...

រាសី ៖ ស្ងាត់អស់ហើយ?

សារីម ៖ ស្រុកវាចប់សង្គ្រាម ហើយឡានអីខ្មោចឡាននៅរកេតរកូត ហើយឃើញពួកខ្មែរក្រហមហ្នឹងគាត់ស្លៀកពាក់ខ្មៅគាត់លាងកញ្ចក់អគារនៅកន្លែងពោធិ៍ចិនតុងហ្នឹង ហើយអត់មានមនុស្សអីទេចាំ! ពេលយើងចុះទៅ។

រាសី ៖ ហើយមានគេមកទទួលទេ?

សារីម ៖ ចាំ! ដល់យើងចុះទៅមានឡានក្រុងបើកមកសឹងដល់ជណ្ដើរកប៉ាល់ហោះយើងម៉ង។ ចាំ! រួចគេឱ្យយើងចូលផ្លុកៗក្នុងឡានហ្នឹងទៅ ហើយគេឱ្យយើងយកតែកាបូបយួរយើងទេចាំ! ហើយអីវ៉ាន់យើងកុំគិត ចាំគេយកទៅតាមក្រោយឱ្យ។

រាសី ៖ បាទ! គេប្រាប់អីចឹងឬបាទ?

សារីមៃ ៖ ចាំ!

រាសី ៖ ហើយអីចឹងពីពោធិ៍ចិនតុងទៅគេយកទៅដាក់នៅកន្លែងណា?

សារីមៃ ៖ ចាំ! ដល់យើងចេញពីពោធិ៍ចិនតុងយើងមិនដឹងទេថា យើងផ្សងព្រេងទៅតាមការដឹកនាំរបស់គេហ្នឹងចាំ! ដល់ទៅដល់ស្រាប់តែយើងទៅដល់សាលាតិចណូរូស សាលាបច្ចេកទេសរុស្ស៊ីដែលជួយខ្មែរនោះចាំ! ដល់ទៅដល់ខ្ញុំឃើញមនុស្សច្រើនមក ឈរដែលពេលយើងចុះពីលើឡាន ហើយស្លៀកពាក់ខ្មៅ រួចខ្ញុំចេះតែមើលថាអ្នកណាអីចេះក៏មក? រួចក៏ខ្ញុំឃើញមនុស្សខ្លះដែលខ្ញុំធ្លាប់ឃើញនៅស្រុកបារាំងនោះ ដែលគេទៅមុនខ្ញុំ។

រាសី ៖ គេទៅមុន?

សារីមៃ ៖ ចាំ! ដល់ខ្ញុំឃើញ ឃើញអ្នកដែលថាខ្ញុំធ្លាប់ស្គាល់ ខ្ញុំខំព្រិចភ្នែករកនឹកឃើញថាអ្នកណាចេះមុខហ្នឹងធ្លាប់ស្គាល់ ដល់មួយសន្ទុះទៅ បានខ្ញុំឃើញថាអូ៎! កូនស្រីតូចហ្នឹង នៅស្រុកបារាំងគឺនៅទីក្រុងនីស ហើយគាត់ ឪពុកគាត់ឈ្មោះលោក ស្វាយហុកឃី ហើយគាត់ពេលហ្នឹងនាងតូចហ្នឹងធ្លាប់ជាក្មេងដែលដូចថារហ័សៗហួសស្រាប់តែ ឃើញឥឡូវហ្នឹងដូចថាស្ងួយ ហើយមុខហ្នឹងឱ្យស្រពោនក្រៀមដូចថាស្រមីស ស្រមុះណាចាំ! ដល់នេះទៅបានយើងចុះទៅដល់ក្រោមផ្ទះ សាលាតិចណូហ្នឹង ខ្ញុំឃើញស្រីម្នាក់ទៀតហ្នឹងឈ្មោះអ្នក ដារ៉ា ហើយខ្ញុំចាំកាលខ្ញុំទៅដាក់ពាក្យសុំនៅ ប៉ិយរ៉ូ ហ្នុំងនៅប៉ារីសហ្នឹង ខ្ញុំសួរគាត់ថាម៉េចទៅមានបានដំណឹងអ្វីពីរស្មីទេព្រោះរស្មី ហ្នឹងជាបងស្រីរបស់អ្នក ដារ៉ា ហ្នឹង។ រស្មី ហ្នឹងធ្លាប់រៀនជាមួយខ្ញុំនៅសាលាអក្សរសាស្ត្រនៅភ្នំពេញហ្នឹងរួចទៅអ្នក ដារ៉ា ហ្នឹងគាត់ថាហឹស! អ្នកនៅស្រុកខ្មែរទាំងអស់សុខសប្បាយទាំងអស់។ ហើយដល់ខ្ញុំឃើញគាត់ នៅសាលាតិចណូហ្នឹង ខ្ញុំឃើញគាត់វាភ័ន្តប្រែខ្លាំងមែនទែន មុខគាត់ហ្នឹងក្រៀម ហើយគាត់ត្រឡប់ទៅវិញហ្នឹង គាត់ទៅមុនប្តីគាត់ គាត់មានកូនមួយយកទៅជាមួយ ហើយអ្នក ដារ៉ា ហ្នឹងជាកូនរបស់ហាងលក់សៀវភៅហុងយូចាំ!។ ខ្ញុំជម្រាបថា បងស្រីគាត់ដែលឈ្មោះ រស្មី ហ្នឹង ឈ្មោះ លី មុនីរស្មី កូនហាងលក់

សៀវភៅ ហុងយូហ្នឹង គាត់ធ្លាប់ធ្វើជាគ្រូជួយបង្រៀនបុត្រារបស់សម្តេចឪជាមួយ អ្នកម្នាង មុនិច បង្រៀននៅចម្ការមនចាំ! សូមអរគុណចាំ!។

រាសី ៖ ហើយពេលហ្នឹងមានអារម្មណ៍ម៉េចដែរអ្នកស្រី នៅ សារីម?

សារីម ៖ ចាំ! ខ្ញុំពេលហ្នឹងខ្ញុំយើងថាយើងច្របូកច្របល់ក្នុងខ្លួន យើងមិនដឹងគិតយ៉ាងម៉េច ទេ គ្រាន់តែថា។

រាសី ៖ មានការតក់ស្លុត?

សារីម ៖ ចាំ! ខ្ញុំមិនស្លុតអីប៉ុន្មានទេប៉ុន្តែខ្ញុំស្ងៀម ខ្ញុំចេះតែមើលវាម៉េចទៅទៀតចាំ!។

រាសី ៖ ហើយពេលហ្នឹងយើងអាចនិយាយស្តីអីបានទេពួកខ្មែរក្រហមហ្នឹង?

សារីម ៖ ចាំ! ខ្ញុំអត់និយាយទេ ពីព្រោះខ្ញុំយល់ថាកាលនៅស្រុកបារាំងហ្នឹងមានលោកយាយចាស់ៗខ្លះដែលមានកូនគាត់ចូលហ្វ៊ុងហ្នឹងណា ហើយគាត់ចេះតែនិយាយថា ហ៊ឺស! ដល់ចូលហ្វ៊ុងហ្នឹងស៊ុបទៅលែងនិយាយអីម៉ង។ ចាំ! លែងហ៊ាននិយាយអី ម៉ង រួចដល់ខ្ញុំឃើញអីចឹងថាឥឡូវនេះខ្ញុំមកដល់ស្រុកខ្មែរហើយវាចូលក្នុងហ្វូងរបស់ អ្នកអស់ហ្នឹងហើយ ម្ល៉ោះហើយខ្ញុំចេះតែនៅស្ងៀមហើយខ្ញុំចេះតែចាំសង្កេតគេធ្វើយ៉ាងម៉េចទៀតចាំ!

រាសី ៖ រួចថ្ងៃទី១ គេឱ្យធ្វើអីខ្លះចេញទៅដល់?

សារីម ៖ ចាំ! អូ! ខ្ញុំទៅដល់យើងរង់ចាំយកអីវ៉ាន់យើង ហើយទៅស្រាប់តែខ្ញុំជួបមិត្តភក្តិខ្ញុំ ម្នាក់ដែលធ្លាប់រៀនជាមួយគ្នា ដេកបួកនៅសាលាកាឡេស(វិទ្យាល័យ)នរោត្តមហ្នឹង គាត់មកស្រុកបារាំង ហើយគាត់ឈឺកង់ស៊ែ(មហារីក)ស្បូនចាំ! គាត់មកនៅពេលដែលស្រុកខ្មែរមិនទាន់ខ្មែរក្រហមយកហ្នឹង ដល់ខ្ញុំ ជួបខ្ញុំនៅស្រុកបារាំង ហើយគាត់ថាគាត់ទៅស្រុកខ្មែរ ប៉ុន្តែខ្ញុំក៏មិនបានជួបគាត់ ដល់ទៅ ដល់ស្រាប់តែខ្ញុំឃើញគាត់នៅហ្នឹង។ គាត់ឈ្មោះ ណាប់ ហុងថៃ។ គាត់ធ្វើគ្រូបង្រៀន។ គាត់ជាប្រពន្ធរបស់លោក រស់ ពិន។ លោក រស់ ពិន ហ្នឹងភាសាខ្មែរនៅក្នុងប្រទេសចិន ក្នុងសម័យឆ្នាំ១៩៦០។ ដល់ខ្ញុំទៅដល់ គាត់ចេះតែសួរខ្ញុំថា

មានយកនំប៉ាវមកទេ? ខ្ញុំមានយកនំប៉ាវមកទេ? ខ្ញុំថា ហ៊ឹស! ខ្ញុំថាគាត់នេះឡប់ទេ ហី ឱ្យខ្ញុំយកនំប៉ាវម៉េចចេះ រួចទៅថា នំប៉ាវដែលយើងញ៉ាំនៅ ហាងចិនដែលយើងទៅស្រុកចិនហ្នឹងគេឱ្យនំប៉ាវហ្នឹង ខ្លួនមានខ្ចប់មកទេ? ខ្ញុំថាទេ នំប៉ាវអត់សាច់ផង ខ្ញុំអត់យកមក។ បានខ្ញុំដឹងៗថា អូ! បើអីចឹងអ្នកហ្នឹងគាត់ឃ្លានហើយ គាត់ចង់បាននំប៉ាវចាំ!។

រាសី ៖ ប៉ុន្តែអីចឹងដល់ពេលបន្ទាប់ពីហ្នឹងមក មួយថ្ងៃហ្នឹងជួបបានគេ អ្នកណាមកជួបយើងពេលត្រឡប់ភ្លាម?

សារីម ៖ ចា៎! ថាមានមេខ្មែរក្រហមមែនទែននោះណាចា៎! មិនមែនពួកចូលហ្នឹងដែលទៅពីស្រុកបារាំងទេ មានមេគេម្នាក់ហ្នឹងមេគេមកហ្នឹងខ្ញុំចាំឈ្មោះគាត់ហ្នឹងឈ្មោះ មិត្ត យន ៗ ហ្នឹងគាត់មក ហើយគាត់ហៅយើង ញោមៗចា៎! គាត់ហៅយើង ញោមៗ ខ្ញុំប្លែកណាស់ ព្រោះថា ញោម គេច្រើនហៅ...

រាសី ៖ លោកសង្ឃ...

សារីម ៖ លោកសង្ឃហៅម្ដាយរបស់ខ្លួនឯង ហើយដល់ យន ហ្នឹងគាត់មកហៅពួកយើង ញោមៗ ខ្ញុំចេះតែខំប្រឹងតែស្ងៀមទៅ។ ខ្ញុំអត់ហ៊ាននិយាយអី ហើយទៅគាត់ប្រាប់យើងថា អីវ៉ាន់យើងហ្នឹងទាល់តែស្អែកបានមកដល់អីចឹង ហើយឥឡូវឱ្យយើងត្រៀមខ្លួនទៅ ហើយគេប្រាប់យើងថា គេចែកបន្ទប់ឱ្យយើងនៅ ព្រោះនៅកន្លែងសាលាហ្នឹងជាកន្លែងដែលគេដាក់សម្រាប់គ្រូរុស្ស៊ីគេនៅនោះចា៎! ដល់ចឹងយើងនៅ កន្លែងហ្នឹងឯងចា៎!

រាសី ៖ បាទ! សូមអរគុណអ្នកស្រី នៅ សារីម។

សារីម ៖ ចា៎! អរគុណលោក ប៉ូច រាសី។ ចា៎! អរគុណ។

រាសី ៖ ហើយគេរៀបចំបាយទឹកអីឱ្យយើងញ៉ាំទៀត?

សារីម ៖ ចា៎! យើងទៅមុនដំបូងហ្នឹង គេឱ្យយើងនៅជាភ្ញៀវរបស់អង្គការ គេឱ្យយើងពិសាបាយបីពេលពីរ-បីថ្ងៃដំបូង។

រាសី ៖ មានចែកឱ្យឬញ៉ាំមួយឆ្អែត?

សារីម ៖ អត់ទេ គេយកមក ហើយទៅដួសរបបឱ្យយើងចែកអីចឹង ចា៎! ប៉ុន្តែមិនច្រើនទេ ចា៎! ហើយយើងទៅក៏យើងអត់ទាន់ឃ្លានប៉ុន្មានដែរ។ យើងឃើញបាយអស់ហ្នឹង យើងក៏ មិនទទួលទានអីច្រើនទេចា៎!

រាសី ៖ បាទ! អីចឹងអ្នកស្រីស្នាក់នៅសាលាតិចណូរុស្ស៊ីហ្នឹងអស់រយៈពេលប៉ុន្មានដែរ?

សារីម ៖ ចា៎! ខ្ញុំនៅហ្នឹងតាំងពីខ្ញុំទៅដល់ខែ១ហ្នឹងរហូតដល់ខែ៥ ហួសខែបុណ្យចូលឆ្នាំខ្មែរ ធ្វើបុណ្យថ្ងៃ១៧ មេសាអីរួចហើយហ្នឹង បានគេបញ្ជូនយើងឱ្យចេញនៅភូមិមួយហ្នឹង គេហៅថាភូមិតាលៃចា៎! ហើយអ្នកដែលទៅមុនខ្ញុំហ្នឹងគេនិយាយថាមុននឹងបញ្ចេញ ពួកយើងហ្នឹងទៅឱ្យធ្វើអីនៅខាងក្រៅសាលាតិចណូហ្នឹង គេទាល់តែឱ្យយើងហ្នឹងរៀន សូត្រសិនធ្វើជីវទស្សន៍បដិវត្តន៍រួចហើយបាន គេបញ្ជូនយើងទៅកន្លែងផ្សេងៗទៀត ពេលហ្នឹង ខៀវ សំផន គាត់មកបង្រៀន ចា៎! ហើយអ្នកដែលទៅពីមុនខ្ញុំហ្នឹងគេ រៀនមុនទៅ ហើយពួកក្រុមខ្ញុំដែលទៅតាមក្រោយហ្នឹងក៏រៀនតាមក្រុមរៀងខ្លួនទៅ។ គេបង្រៀននៅកន្លែងសាលធំរបស់សាលាតិចណូរូសហ្នឹងដែលគេដាក់ គេហៅអង់ហ្វេទុយអាត គេហ្នឹងចា៎! រួចមុននឹងទៅបានរៀនសូត្រនៅជាភ្ញៀវរបស់អង្គការ នៅឡើយហ្នឹង ៣-៤ថ្ងៃក្រោយ ថ្ងៃទៅដល់ហ្នឹង ថ្ងៃមួយហ្នឹងខ្ញុំបានចុះទៅ ខាងក្រោម ហើយខ្ញុំបានជួបលោកម្នាក់ហ្នឹងគេហៅគាត់ឈ្មោះមិត្ត ទ្រី ម៉េងហួត ចា៎! ហើយគាត់ហ្នឹងហ្នឹងធ្លាប់ធ្វើការនៅប៉ុយរ៉ូហ្វ៊ុងនៅទីក្រុងប៉ារីសហ្នឹង ពេលហ្នឹង គាត់ចេះតែនិយាយពីឯករាជ្យម្ចាស់ការៗចា៎! មាគ៌ារបស់អង្គការហ្នឹងមានមាគ៌ា ឯករាជ្យម្ចាស់ការហ្នឹងចា៎! រួចដើរទៅខ្ញុំឮសួរគាត់និយាយចឹង ហើយខ្ញុំធុញណាស់ ឮសួរឯករាជ្យម្ចាស់ការហ្នឹងរាល់ថ្ងៃតាំងពីទៅដល់ ខ្ញុំក៏ថា ហ៊ឺស! ចេះតែឯករាជ្យ ម្ចាស់ការអី ខ្ញុំមុនមកហ្នឹងពីថ្ងៃ៥ ខែ Janvier ហ្នឹងខ្ញុំមើលកាសែតនៅស្រុក បារាំងឈ្មោះកាសែតឡឺមុងហ្នឹង ហើយគេនិយាយថា បរទេសហ្នឹងគេឱ្យថ្នាំពេទ្យហ្នឹងមកស្រុកខ្មែរច្រើនណាស់ច្រើនតោន ហើយអង្គការហ្នឹងអង្គការមិនយក ព្រោះ ប្រកាន់យកមាគ៌ាឯករាជ្យ

ម្ចាស់ការ ហើយថា បើសិនយកមកហ្នឹងខ្មាំងហ្នឹងចូលមក តាមគ្រប់រូបភាព ដូច្នេះ មិនយកអីវ៉ាន់គេឱ្យទេ ស្រាប់តែអ្នក ម៉ូណា គាត់ទៅយក ពេលដែលយើងឡើង កប៉ាល់ហោះពីស្រុកបារាំងទៅស្រុកចិនហ្នឹង ស្ទីម៉ាកញ្ចប់ពី លោកគ្រូឈ្មោះដូច រូស្ស៊ីម្នាក់ហ្នឹង លោកគ្រូម្នាក់ហ្នឹងគាត់ធ្លាប់បង្រៀនពួកខ្ញុំដែរនៅ សាលាសាកល វិទ្យាល័យអក្សរសាស្ត្រហ្នឹង ហើយគាត់របៀបដូចអ្នកខាងមាននិន្នាការ ទៅរបៀប ក្រហមចាំ! ហើយខ្ញុំថាឱ្យ ទ្រី ម៉េងហួត ហ្នឹងថា ចេះតែឯករាជ្យម្ចាស់ការអីៗ គេឱ្យ ថ្នាំច្រើនរាប់តោនហើយយើងមិនយក យើងធ្វើអីចឹងគេហៅ កោងក្រ យើងកំពុង តែលំបាកយើងត្រូវតែយកជំនួយបរទេស។ យើងធ្វើអីចឹង កូនខ្ញុំអីមុខតែងាប់អស់ ហើយ ខ្ញុំនិយាយហ្នឹងប្រហែលម៉ោង៩ព្រឹក ស្រាប់តែម៉ោង ជាង១ពេលបាយអីរួច ហើយ យើងកំពុងសម្រាកនៅក្នុងបន្ទប់ ស្រាប់តែមានគេមក គោះទ្វារហៅយើង ឱ្យចេញទៅប្រជុំ។ ដល់ទៅប្រជុំគេប្រាប់កន្លែងយើងថាទៅប្រជុំ កន្លែងណាៗ ហើយយើងទៅដល់ឃើញគេហៅសុទ្ធតែស្រីៗទៅប្រជុំចាំ! ពេលខ្ញុំ ឃើញមាន កងឈ្លបម្នាក់ហ្នឹងកុមារហ្នឹងគាត់ស្ពាយកាំភ្លើងសឹងអូសដី ហើយគាត់ រេកាំភ្លើង ហ្នឹងមករកយើង ហើយទៅគេប្រាប់យើងថា មើលអ្នកឯងនាំចេញមើល អ្នកមក ស្រុកខ្មែរហ្នឹង អ្នកឯងមកស្រុកហ្នឹង ហេតុអីបានជាអ្នកឯងត្រឡប់មកស្រុក វិញ? រួចទៅគេសំដៅដូចថាយើងជាពួកសេអ៊ីអា (CIA) អីចឹង កាហ្សេបេ (KGB)អីចឹង ចាំ! ម្នាក់ៗបាននាំចេញដូចគេនិយាយអីចឹង នាំចេញបានន័យថាយើងនិយាយ ស្អីដែលយើងបញ្ចេញប្រាប់គេទៅថា ហេតុអីបានយើងមកស្រុកខ្មែរត្រឡប់ មកវិញ ម្នាក់ៗហ្នឹងនិយាយថាមកស្រុកខ្មែរអីមកជួយកសាងស្រុក មកអីចឹងទៅ។ ដល់ពេល ដល់វេនខ្ញុំត្រូវនិយាយ ខ្ញុំប្រាប់ថា នែខ្ញុំមកស្រុកខ្មែរហ្នឹងបានខ្ញុំមកហ្នឹង ទីមួយខ្ញុំជា ខ្មែរ ទីពីរខ្ញុំមានកូនតូចៗពីរនាក់ ហើយខ្ញុំមានវិប្បដិសារីពេលស្រុក ពិបាកអីចឹង ខ្ញុំទុក ឱ្យកូនខ្ញុំ ឱ្យម្ដាយខ្ញុំមើលកូន។ ខ្ញុំនៅស្រុកបារាំងមិនកើតទេ ខ្ញុំ ត្រូវតែមករងទុក្ខ ទោសកម្មដែលខ្ញុំបានបង្កើតកូនមកហ្នឹង។ ខ្ញុំត្រូវតែមកដើម្បី ជួយកូនខ្ញុំ ហើយខ្ញុំភ័យខ្លាចកូនខ្ញុំស្លាប់មុនខ្ញុំមកដល់។ ដល់ខ្ញុំនិយាយអីចឹងទៅ ខ្ញុំនិយាយផង យំផងពេល ហ្នឹង ហើយខ្ញុំប្រាប់ថាឥឡូវខ្ញុំមិនដឹងធ្វើម៉េចទេ ខ្ញុំ

មកដល់ស្រុកខ្មែរហើយ ហើយខ្ញុំ ប្រគល់ខ្លួនហ្នឹងឱ្យអង្គការ ស្អីអង្គការហ្នឹងយកខ្ញុំទៅដុតក៏ដោយ យកខ្ញុំទៅស្ងោក៏ដោយ អាំងក៏ដោយថាំ!។ ហើយតាំងពីថ្ងៃហ្នឹងមក បន្ទប់ដែលខ្ញុំនៅហ្នឹងមានគេមកផ្អឹបត្រចៀកស្តាប់នៅតាមទ្វារខ្ញុំដែលយើងសង្ស័យមើលទៅថាំ! ហើយក្នុងបន្ទប់ ដែលខ្ញុំនៅហ្នឹងមានគ្នា១៤នាក់ថាំ! មានខ្ញុំ សួន ហើយនឹង វណ្ណា ហើយនាងហ្នឹង ឈ្មោះនាង ថាច់ ចាន់មូលី។ គាត់ជាកូនសិស្សខ្ញុំដែលខ្ញុំបង្រៀននៅសាលា Lycee d'applicationហើយគាត់ត្រឡប់ទៅស្រុកវិញជាមួយមារបស់គាត់ហ្នឹងឈ្មោះ លោក តាន់ អ៊ីម។ គាត់មកលេងឪពុកក្មេកគាត់ឈ្មោះលោក គុន វេច ហ្នឹង ពេលហ្នឹងគេធ្វើទូតនៅស្រុកជប៉ុនអីថាំ! ហើយក៏យកកូនពីរមកផង ហើយគាត់នៅស្រុកបារាំងនៅអត់កើត គាត់ក៏ត្រឡប់ទៅស្រុកខ្មែរវិញចោលកូននៅស្រុកបារាំង គាត់ទៅរកប្តីគាត់។ ហើយពេលប្រជុំហ្នឹងខ្ញុំអត់យល់ទេ គេនិយាយកាហ្សេបេអីហ្នឹង។ ពេលដែលយើងប្រជុំដែលថាមានកងឈ្លបគេស្ពាយកាំភ្លើងមកយាមយើងហ្នឹង ចេញ មកក្រៅខ្ញុំក៏សួរគេថាកាហ្សេបេហ្នឹងស្អី? បានគេពន្យល់ខ្ញុំពីរឿងកាហ្សេបេហ្នឹង ដូចសេអ៊ុំអាអីចឹង តែរបស់រូស្ស៊ី ចាំ! ហើយខ្ញុំវាដូចថាស្លុតដែរ ដូចជាគេ និយាយរឿងសុទ្ធតែស៊ើបការណ៍អីចឹងចាំ! ហើយមិត្ត ទ្រី ម៉េងហួត ហ្នឹងពេល ដែលយួនចូល គាត់បកទៅនៅស្រុកបារាំងវិញហ្នឹង គឺគាត់ហ្នឹងត្រូវគេសម្លាប់ៗក្នុងឆ្នាំប្រហែល១៩៨០ជាងហ្នឹង សូមអរគុណ។ ដែលពេលរៀនសូត្រហើយហ្នឹង អ្នកដែលគេនៅ ទៅពីមុនយើងហ្នឹង ដែលគេបានរៀនសូត្រហើយហ្នឹង អ្នកណាដែល គេមានជំហរខ្ពស់ហ្នឹង ខ្ញុំឃើញថាគេបញ្ជូនអ្នកអស់ហ្នឹងចេញទៅធ្វើការនៅខាង ក្រៅកន្លែងសាលាតិចណូហ្នឹង។ ដូចនាងម្នាក់ហ្នឹងឈ្មោះនាង ប៉ុក យ៉ានីន ហ្នឹងចេញ ទៅធ្វើការនៅខាងក្រៅជាមួយពួកកម្មកររោងចក្រអីចឹង ដើម្បីកាប់ដី ឬក៏សែងដីអី ទៅ ហើយថ្ងៃក្រោយមក ខ្ញុំឃើញប្តីគាត់ហ្នឹងទៅដល់ ប្តីគាត់ហ្នឹងឈ្មោះ ក្រវ៉ាន់ ថៃក ក្រវ៉ាន់ ចាំ! ហើយក្នុងបន្ទប់ខ្ញុំនៅហ្នឹងពេលមួយហ្នឹងក្រោយមកហ្នឹងស្រាប់តែថ្ងៃមួយហ្នឹង សួន គាត់យំងោងៗហ្នឹង ហើយគាត់ថា អូយ! ស្រុកយើងអីចឹង ហើយដល់តែពេលអីចឹង ពួកខ្ញុំទាំងបីនាក់ហ្នឹងថា ហ៊ឺស! ម៉េចក៏ សួន ឯងអត់ដឹង

អីចឹង ក្រែងយើងដឹងស្រុកខ្មែរ ស្រុកយើងវាទៅអីចឹងទាំងអស់គ្នា យើងដឹងអីចឹង? សូន ថាខ្ញុំដឹង ប៉ុន្តែខ្ញុំមិនដឹងថាអីចឹង ហើយដល់រួចទៅពួកយើងចេះខំលើក ទឹកចិត្ត សូន ហ្នឹងឱ្យខំពង្រឹងសតិអារម្មណ៍ហ្នឹងកុំឱ្យទន់ជ្រាយអីចឹង ខ្លាចមាន គ្រោះ ថ្នាក់ដល់ខ្លួនចាំ! សូមអរគុណ ចាំ! អរគុណលោក ប៉ូច រាសី ចាំ!។

រាសី ៖ បាទ!សូមអរគុណអ្នកស្រី នៅ សារីម បាទ!។

សារីម ៖ គេមុននឹងបញ្ជូនយើងចេញទៅកន្លែងណាមួយហ្នឹង គេត្រូវបើកវគ្គសិក្សាឱ្យ យើង រៀនសូត្រចាំ! ពេលដែលយើងដើរចូលទៅរៀននៅសាលាតិចណូរុស្ស៊ីហ្នឹង គេឱ្យ យើងដើរដូចព្រះសង្ឃនិមន្តបិណ្ឌបាតអីចឹងចាំ! ពេលហ្នឹង ខៀវ សំផន គាត់ មក បង្រៀន ខ្ញុំភ្ញាក់គាត់មកដល់ ចេញមកគាត់ស្លៀកពាក់ខោអាវខ្មៅ ហើយ ខោហ្នឹង មិនមែនខោដែលយើងថាខោបារាំងទេ ខោខ្សែ ខ្សែយឺតដូចខោភីសម៉ា យើងស្លៀក សម្រានអីចឹងហើយខោខ្មៅ អាវខ្មៅបង់កក្រមាដូចយើងឃើញ កម្មាភិបាលខ្មែរ ក្រហមគេបង់កអីចឹងចាំ! ប៉ុន្តែយើងអត់ដែលធ្លាប់ឃើញ យើង អត់ដែលធ្លាប់ឃើញ ខ្ញុំៗស្រឡាំងកាំង ខ្ញុំខ្ទប់មាត់ រួចទៅខ្ញុំចេះតែមើលគាត់ហ្នឹង ហើយពាក់ស្បែកជើង កង់ឡាន ហឺស! ខ្ញុំអត់យល់ចាំ! ហើយពេលដែលរៀនហ្នឹង គាត់ច្រាស់ច្រាលមើលអីចឹង។ គាត់អង្គុយស្តាប់អីចឹងទៅ ហើយទៅគាត់ដើរចេញ ទៅៗក្រៅ រួចទៅគាត់ឧស្សាហ៍ចេញចូលណាស់ចាំ! ខ្ញុំពេលហ្នឹងខ្ញុំដូចជាស្ញើប ណាស់ចាំ!។

រាសី ៖ ពីព្រោះអ្នកស្រីធ្លាប់ឃើញលោក ខៀវ សំផន ពីមុនស្លៀកពាក់ខោអាវធម្មតា អីចឹង អី?

សារីម ៖ ចាំ! ខ្ញុំមិនដែលដូចថាឃើញគាត់ជារូបហ្នឹងច្បាស់លាស់អីទេ ប៉ុន្តែឃើញអ្នកធ្វើ ការ នៅស្រុកខ្មែរយើងស្លៀកខោបារាំង ខោឡេវអីចឹងទៅណាចាំ! ហើយពាក់អាវ សាមិ ពាក់អីទៅ ប៉ុន្តែយើងមិនដែលឃើញសម្លៀកពាក់ហ្នឹងចាំ!។

រាសី ៖ ប៉ុន្តែនៅពេលហ្នឹងអ្នកស្រីស្គាល់លោក ខៀវ សំផន ច្បាស់លាស់ដែរ?

សារីម ៖ ខ្ញុំមិនដែលបានស្គាល់លោក ខៀវ សំផន ផ្ទាល់អីទេ ប៉ុន្តែពេលពីដើមហ្នឹងយើងដឹង ថាគាត់ធ្វើតំណាងរាស្ត្រនៅខាងស្អាងកោះធំ ហើយគាត់ហ្នឹងល្បីថាជាតំណាងរាស្ត្រ មិនទាន់មានប្រពន្ធ ស្អាតស្អំ រស់នៅជាមួយម្តាយអីចឹង ហើយយើងនៅភ្នំពេញនរណាក៏ ដឹងដែរថាគាត់ហ្នឹងត្រូវពួកគេវាយគាត់ប្រស្រាតខោនៅមុំជិតយុគន្ធរនោះ ពេល សម័យសង្គមរាស្ត្រនិយមនោះ ហើយដល់ពេលគាត់បាត់ខ្លួនទៅមានពាក្យចចាម អារ៉ាមថា លោក ខៀវ សំផន ត្រូវពួកប៉ូលិស ឬពួកស៊ើបការណ៍ហ្នឹងចាប់គាត់ហ្នឹងដាក់ ទៅក្នុងធុងអាស៊ីតអី។ នៅសម័យហ្នឹង មានអ្នកខ្លះគេនិយាយកំប្លែងថា ពួកចិន ហ្នឹងហៅអ្នកធំនៅស្រុកខ្មែរហ្នឹង ពួកចិនចង់មកសូកហ្នឹងហៅ«អាលោកៗ» យក លុយអីមកឱ្យហ្នឹង ហើយថាអាលោកៗ ខៀវ សំផន ហ្នឹងថា ល្បីថាគាត់ហ្នឹងមិន ដែលយកសំណូកអីពីពួកចិនទេចាំ! អាហ្នឹងពីដើមហ្នឹងខ្ញុំឮសូរអីចឹង។

រាសី ៖ ទើបជាលើកទីមួយជួបមុខគាត់ផ្ទាល់?

សារីម ៖ ចាំ! ដែលយើងឃើញមុខចាំ! ហើយគាត់ឈរនៅលើឆាកគេហ្នឹង ហើយខាងក្រោមដែលពួកខ្ញុំអង្គុយសឹងពេញសាលហ្នឹង។ ពីដើមយើងថាអ្នកមុខមាត់ហ្នឹងមាន លោក ភួង តុន មានលោកតា ឈូក ម៉េងម៉ៅ អ្នកទំនាក់ទំនងខាងវប្បធម៌ជាAttaché culturel របស់រដ្ឋាភិបាលលន់ នល់។ លោកម្នាក់នោះឈ្មោះលោកទេស សារ៉ាវុធ នៅខាងគ្រូបង្រៀនដែរចាំ! ហើយទៅខ្ញុំចេះគិតថា «ហ៊ឺ! លោកខៀវ សំផន មកបង្រៀនហ្នឹង ប្រហែលគាត់មកគួរសមជាមួយលោក ភួង តុន ហើយមើលទៅ ព្រោះលោក ភួង តុន ធ្វើ Director សាលានៅស្រុកខ្មែរដែរ ហើយគាត់ជាអ្នកមន្ត្រីនៅក្មេងដែរ ស្រករៗលោក ខៀវ សំផន»។ ប៉ុន្តែគេអត់មានអី គួរសមជាមួយយើងទេចាំ!។

រាសី ៖ បាទ! ហើយលោក ខៀវ សំផន មកបង្រៀនហ្នឹង បង្រៀនអំពីអ្វី?

សារីម ៖ ចាំ! គេបង្រៀនហ្នឹងគេបង្រៀនឱ្យយើងហ្នឹងយល់ពីបដិវត្តន៍ចាំហើយប្រាប់ថាបដិវត្តន៍ហ្នឹងវាធ្វើឡើងពីបាតដៃទទេ ខំប្រឹងវាយតស៊ូជាមួយអាមេរិកាំង។ លោក

ខៀវ សំផន ហ្នឹង គាត់បញ្ជាក់ថា ជ័យជម្នះធំរបស់ទ័ពកម្មករកសិករហ្នឹងគឺបាន កងទ័ពបដិវត្តន៍ហ្នឹងបានវាយប្រចាច់កខ្លាំង ដោយផ្ដាច់ខ្សែរយៈហ្នឹងមិនឱ្យមានអី ចេញ ចូលបានមកដល់ភ្នំពេញហ្នឹងគឺប្រចាច់កខ្លាំងនៅភ្នំពេញចាំ! ពេលហ្នឹង ហើយគាត់ថា ស្ថានការណ៍នៅភ្នំពេញហ្នឹងគឺផុយស្រួយដូចចំបើងត្រូវថ្ងៃនៅ ខែចែត្រអីចឹង ឱ្យតែមានអី ប៉ះគឺឆេះហើយ។ គេបង្រៀនថាឱ្យយើងទទួលស្គាល់ ថា វណ្ណៈកម្មករកសិករថ្នាក់ក្រោម ហ្នឹងមានគុណលើបដិវត្តន៍ហ្នឹងណាស់ ហើយ និយាយអំពីវីរភាពរបស់កសិករក្រថ្នាក់ ក្រោមអ្នកដែលអត់មានដីធ្លីនោះ ព្រោះ គេបញ្ជូនកូនគេមួយហើយមួយទៀតមក បម្រើអង្គការបដិវត្តន៍ ហើយកសិករក្រ ថ្នាក់ក្រោមមានជំហរស្មោះស្ម័គ្រចំពោះ បដិវត្តន៍នេះណាស់ ហើយគេនិយាយ ពីរឿងថា ការខំតស៊ូរបស់គេហ្នឹងដើម្បីវាយខ្មាំងអាមេរិកាំងរហូតដល់ពេលយប់ខ្លះ អត់ហ៊ានដុតភ្លើងទេ គេមិនឱ្យមានផ្សែងហុយ ឡើងលើទេចាំ! គឺថាឃើញថា ការតស៊ូហ្នឹងស្វិតស្វាញ ហើយលំបាកវេទនាខ្លាំង ណាស់ដែលយើងស្ដាប់ទៅ នោះចាំ! លោក ខៀវ សំផន គាត់បញ្ជាក់ឱ្យយើងស្គាល់ អំពីសីលធម៌ខ្ពស់របស់ កងទ័ពបដិវត្តន៍ថា មិនដែលហ៊ានប៉ះពាល់អ្វីដែលជារបស់ ប្រជាជនទេ សូម្បីតែ ម្ទេសមួយផ្លែ អំបិលមួយគ្រាប់ អំបោះមួយសសៃក៏សុំ ប្រជាជនដែរចាំ! ហើយទៅ លោក ខៀវ សំផន ថាយើងរាល់ថ្ងៃនេះយើងចាក់ ស្នុកនៅគល់ត្នោត។ យើង មិនមែនចាក់ស្នុកនៅចុងត្នោតទេចាំ! ហើយបដិវត្តន៍នេះ គឺយកបាន៥០ឆ្នាំមុន គម្រោងការចាំ! រួចទៅគាត់ថា លុយយើងមានហើយ យើង បោះពុម្ពហើយចង់ ចាយអង្កាលក៏បានដែរចាំ!។

រាសី ៖ បាទ! បានសេចក្ដីថាគាត់ប្រៀបធៀបពីរឿងចុងត្នោត ហើយនឹងដើមត្នោតគឺថា ឥឡូវគឺអនុវត្តន៍ជាក់ស្ដែងបាន ទទួលបានជាក់ស្ដែងមិនមែនយល់សប្តិដូចមុន ទេ?

សារីម ៖ ចាំ! មិនមែនពីដើមយើងនិយាយថា ថៅចាក់ស្មុកនៅចុងត្នោតនោះ គាត់ៗ យល់សប្តិថា គាត់មាន ទៅហើយគាត់មានឈ្នូលអី គាត់ផាក់ឈ្នូលគាត់ទៅ ក៏ធ្លាក់ពីលើចុងត្នោតមកចាំ!។

រាសី ៖ បានន័យថាបដិវត្តន៍ខ្មែរក្រហមបានសម្រេចហើយ ធ្វើបានសម្រេចហើយ?

សារីម ៖ ចាំ! ដូចថាគេពិតប្រាកដមានគ្រឹះមាំ គឺថានៅដី នៅគល់ត្នោតអត់ធ្លាក់ទៅណាទេចាំ!។

រាសី ៖ បាទ! មានឫសចាក់ឫសចាក់វាស់បាទ!។

សារីម ៖ ហើយបណ្តាកសិករហ្នឹងខាងខ្មែរក្រហមគេចែកមានកសិករមាន កសិករកណ្តាល កសិករកណ្តាលថ្នាក់ក្រោម ហើយកសិករក្រ និងកសិករក្រថ្នាក់ក្រោម។ ចំពោះ អ្នកដែលរៀនសូត្រក៏អង្គការបដិវត្តន៍ហ្នឹងបែងចែកជាវណ្ណៈដែរចាំ! មានគេហៅ វណ្ណៈបញ្ញាជន វណ្ណៈសិស្សៗដែលរៀនបានច្រើនហ្នឹងគេឱ្យឈ្មោះដូចបញ្ញាជនអីចឹង ហើយចំពោះសិស្សដែលបានរៀនសូត្រតិចតួចហ្នឹង គេមានឈ្មោះគេថា អនុធន សិស្សនោះចាំ! ហើយគេបានពន្យល់យើងអំពីជំហររបស់ពួកបញ្ញាជន ហើយនឹង ពួកដែលរៀនសូត្រ បានរៀនសូត្រហ្នឹងមិនសូវជាមានជាជំហររឹងមាំប៉ុន្មានទេ ច្រើនទន់ជ្រាយ ហើយខ្លាចការនឿយហត់ចាំ! ហើយលោក ខៀវ សំផន បាន និយាយអំពីការដោះស្រាយរឿងប្រជាពលរដ្ឋយួននៅក្នុងប្រទេសកម្ពុជា នៅពេល ជម្លៀសប្រជាជនចេញពីទីផ្សារ ពីទីក្រុងទៅនៅជនបទនោះថា ប្រជាជនយួនគាត់ និយាយថា គាត់មិនចេះធ្វើស្រែទេ គាត់ចេះតែលក់បាញ់ហាយ ហើយលោក ខៀវ សំផន ថា នេះប្រជាជននៅក្នុងប្រទេសកម្ពុជាទាំងអស់ត្រូវតែធ្វើស្រែ បើអ្នកណា មិនចេះធ្វើស្រែគេរៀបចំ ជាពិសេសប្រជាជនយួនគេត្រូវរៀបចំបញ្ជូនទៅប្រទេស វៀតណាមវិញចាំ! ហើយ ដូច្នេះគឺថាគេបានធ្វើការរៀបចំបញ្ជូនប្រជាពលរដ្ឋយួន ទៅស្រុកយួនវិញ ហើយគេមានរៀបចំដាក់ស្បៀងអាហារ ហើយទៅគេបញ្ជូនតាម ទូកអីចឹងទៅ ហើយគាត់ថា នេះបញ្ហាហ្នឹងគឺគេដោះស្រាយរួចបានយ៉ាងងាយស្រួល ចាំ! ហើយគាត់សង្កត់លើថា

អង្គការបដិវត្តន៍ហ្នឹងខំប្រឹងធ្វើយ៉ាងម៉េចឱ្យប្រជាជន ហ្នឹងមានរបប១៥ថាំងក្នុងមួយឆ្នាំ ហើយអារឿងធ្វើផលស្រូវហ្នឹងគេឱ្យយើងខំប្រឹងធ្វើឱ្យបានបីតោនមួយហិកតាចា៎! ហើយមានគម្រោងការធ្វើស្រូវហ្នឹងឱ្យបានច្រើន រដូវ ហើយគេមានពាក្យស្លោករបស់គេហ្នឹងគឺ «យើងមានស្រូវ គឺយើងមានអ្វីៗ» ហើយគាត់សង្កត់ថាមនុស្សនៅក្នុងសង្គមបដិវត្តន៍ហ្នឹងចេះដូចៗគ្នា ហើយខ្ញុំហួសចិត្ត ណាស់កន្លែងគាត់ថាមនុស្សចេះដូចៗគ្នា។

ពាសី ៖ តើលោក ខៀវ សំផន មកបង្រៀនអ្នកស្រី និងអ្នកដទៃទៀតដែលត្រឡប់មកពីប្រទេសបារាំងហ្នឹង តើមានរយៈពេលប៉ុន្មានថ្ងៃដែរ?

សារីម ៖ ចា៎! ការបង្រៀនហ្នឹងគឺមានបីថ្ងៃ ហើយលោក ខៀវ សំផន ហ្នឹងគាត់បង្រៀនតែមួយថ្ងៃទេចា៎! គាត់ចប់ទៅហ្នឹង គាត់ជូនពរយើងថា សូមឱ្យអ្នកទាំងអស់ដែលត្រឡប់ចូលមកស្រុកវិញសូមឱ្យរកសុភមង្គលឱ្យឃើញនៅក្នុងរបបថ្មីហ្នឹង។

ពាសី ៖ បាទ! ហើយបន្ទាប់ពីលោក ខៀវ សំផន មកបង្រៀនហើយអីចឹង តើយើងមានឱកាសសួរគាត់ផ្សេងអីនៅក្រៅទេ?

សារីម ៖ ចា៎! អត់មានអ្នកណាហ៊ានសួរអីទេចា៎! គ្រាន់តែបង្រៀនចប់ភ្លាម ចេញហើយ ទៅមើលទៅឃើញដូចថាលក្ខណៈវាអត់មានការកក់ក្តៅរាក់ទាក់ចា៎! អត់ទេ សុទ្ធតែស្តាប់ ទាំងអស់អត់មានអ្នកណាសួរអីទាំងអស់ គឺស្តាប់។

ពាសី ៖ ហើយបន្ទាប់មកទៀត មានអ្នកណាទៀតដែលមកបង្រៀន?

សារីម ៖ ចា៎! មានម្នាក់ទៀតឈ្មោះឮគេហៅថា មិត្ត ភុំ ខ្ញុំអត់ស្គាល់ជាអ្នកណាទេ ប៉ុន្តែគាត់នៅក្មេងដែរ មិត្ត ភុំ ហើយគាត់មកបង្រៀនបន្តមកទៀតពីរថ្ងៃ ហើយគាត់បង្រៀនយើងអំពីរបៀបថាយើងម៉េចបានគេធ្វើសហករណ៍ កើតឆ្នាំ១៩៧៣ នៅក្នុងប្រទេសកម្ពុជាអីចឹង រួចទៅ ប៉ុន្តែមុននឹងបានឈានទៅដល់បង្កើតសហករណ៍ហ្នឹង នៅតំបន់រំដោះហ្នឹងគេបានបង្កើតក្រុមបង្វះដៃ ចា៎! ក្រុមបង្វះដៃ បានន័យថាជួយយកដៃគ្នាដើម្បីជួយច្រូតកាត់ស្រូវ ឬបេះសណ្តែកអីចឹង ហើយនឹងគេបានប្រមូលដីធ្លីពីអ្នកដែលមានដីច្រើន ហើយធ្វើដីខ្លួនឯងមិនអស់ហ្នឹងយកមកដាក់រួម

សម្រាប់សហគមន៍ប្រើប្រាស់ចាំ! ហើយដល់ឆ្នាំ៧៣ តាមខ្ញុំចាំ គឺគេបង្កើត សហករណ៍ឡើង ហើយគេយករបស់មកដាក់រួម ហើយធ្វើស្រូវធ្វើស្រែអីហ្នឹង រួមគ្នា ដល់ខ្មែរក្រហម យកជ័យជម្នះបានហ្នឹង ខាងមិត្ត ភុំ ដែលគាត់មកបង្រៀន ថា ឥឡូវនេះយើងគ្រប់គ្រងប្រទេសកម្ពុជាហើយ ផលដែលយើងត្រូវវាយសម្រុក យកឱ្យបានសម្រាប់មក កសាងប្រទេសជាតិយើងហ្នឹង គឺយើងត្រូវធ្វើស្រូវឱ្យបាន បីតោនក្នុងមួយហិកតា ចាំ! ហើយគេយកតាមគំរូរបស់កូរ៉េខាងជើងដែលល្បឿន សេះហោះ គេហៅថា ឈើលីម៉ា នោះចាំ! ខ្មែរក្រហមក៏ខំធ្វើតាមគំរូរបៀបហ្នឹង យកមកធ្វើស្រូវហ្នឹងឱ្យ បានបីតោនក្នុងមួយហិកតាចាំ!។

រាសី ៖ បាទ! អីចឹងអ្នកស្រីប៉ុន្មាននាក់ដែលស្នាក់នៅសាលាតិចណូជាមួយគ្នា?

សារីម ៖ ចាំ! ច្រើនៗរយនាក់ចាំ!

រាសី ៖ ច្រើនរយនាក់ហ្នឹង តើសុទ្ធតែមកពីបារាំង ឬប្រទេសផ្សេងៗទៀត?

សារីម ៖ ចាំ! ច្រើនរយនាក់ហ្នឹង ខ្លះមកទៅពីស្រុកបារាំង ប៉ុន្តែសុទ្ធទៅពីស្រុកបារាំងទាំង អស់ ពីព្រោះដើម្បីចូលស្រុកចិន ត្រូវទៅស្រុកបារាំងសិន។ មានតែ Mission(ស្ថាន បេសកកម្ម) គេនៅ ស្រុកបារាំងហ្នឹងទេរបស់ខ្មែរក្រហម ដើម្បីធ្វើប្តូរ ប៉ាស់ស្ព័រ (លិខិតឆ្លងដែន)យើងទៅ ប៉ាស់ស្ព័រ ហ្វ៊ុងនោះចាំ! អ្នកត្រឡប់ទៅវិញហ្នឹង ភាគច្រើនៗតែជាសមាជិកពួកហ្វ៊ុងចាំ! ហ្វ៊ុងហ្នឹង គឺរណសិរ្សរបស់សម្តេច សីហនុ ចូលឆ្លៀតរបស់ខ្មែរក្រហមដើម្បីវាយពួកលន់ នល់ នោះចាំ!។ ក្រៅពីហ្នឹងមាន អ្នកដែលទៅក្រៅពីបីហ្សង់សុងដូចខ្ញុំហ្នឹង គឺសុទ្ធតែ យើងចង់ទៅជួបកូនចៅរបស់ យើង ប៉ុន្តែមានអ្នកខ្លះហ្នឹងមកស្រុកបារាំង ហើយ ប្រពន្ធត្រឡប់ទៅតាំងពីស្រុក មិនទាន់ធ្លាក់ហ្នឹងទៅកើតកូន។ អ្នកអីចឹងក៏ត្រឡប់ទៅវិញ ដែរចាំ! អ្នកខ្លះ ហើយ មានអ្នកខ្លះហ្នឹងគាត់មានសង្សារទាហានចាំ! ហើយមករៀន នៅស្រុកសៀមក៏ ត្រឡប់ទៅវិញដែរចាំ!។

រាសី ៖ បាទ! ចំពោះអ្នកស្រីៗវិលត្រឡប់ទៅស្រុកខ្មែរវិញ គឺគោលបំណងទៅជួបកូន ហើយនឹងប្តី ប៉ុន្តែអ្នកដទៃទៀតដែលទៅជាមួយនោះ តើគេទៅគោលបំណងជួបជុំគ្រួសារដែរឬក៏គេចង់ទៅជួយកសាងប្រទេស?

សារីម ៖ ចាំ! តាមខ្ញុំមើលសមាជិកពួកហ៊្មុងរណសិរ្សរបស់សម្តេច សីហនុ ចូលជាមួយខ្មែរក្រហមហ្នឹង គឺគេទៅហ្នឹងគេហ៊ានយកកូនគេតូចៗទៅជាមួយ ហើយគេទៅមុនប្តីគេទៀត គឺថាអាហ្នឹងគេសំដៅទៅរកមុខនាទីនៅក្នុងរបបខ្មែរក្រហមហ្នឹងចាំ! អ្នកដែលទៅជាមួយខ្ញុំបីនាក់ស្រីៗហ្នឹងគឺសុទ្ធតែមានបំណងដូចគ្នា ចង់ទៅជួបប្តី ហើយនឹងកូន ចាំ! ហើយលោកម្នាក់ហ្នឹងប្រុសហ្នឹងក៏គាត់អីចឹង គាត់អត់នៅស្រុកបារាំង កើត។ គាត់ហ្នឹងឈឺទៅសម្រានពេទ្យទៀតណោះ។ ប៉ុន្តែដល់គាត់ហ្នឹង ដល់គាត់ទៅដល់ ខ្មែរក្រហមយកគាត់ទៅនៅកន្លែងផ្សេង ទៅនៅដីក្រហមទៅ រួចទៅគាត់លែងមក រហូតទៅបាត់គាត់រហូតទៅចាំ!។

រាសី ៖ បាត់មុខរហូតបាទ?

សារីម ៖ ចាំ! ក្នុងបណ្តាអ្នកទៅវិញហ្នឹងថាមានអ្នកខ្លះហ្នឹងជាលោកយាយ លោកតាចាស់ៗដែលគាត់មកគេចពីចម្បាំងហ្នឹងមកនៅស្រុកបារាំង ហើយដែលមានកូនចូល ជាសមាជិកហ៊្មុងហ្នឹងក៏គាត់ត្រឡប់ទៅវិញដែរ ដូចជាលោកយាយ គឹម ម្តាយលោក អ៊ិន សុកាន ហើយពីរនាក់ប្តីប្រពន្ធហ្នឹងជាឪពុកម្តាយរបស់លោក ទ្រី វ៉ាន់ហ្នឹង។ លោក ទ្រី វ៉ាន់ ក៏គាត់ចូលជាសមាជិកហ៊្មុងហ្នឹងចាំ! ហើយទៅមានអ្នកម្នាក់ទៀតហ្នឹងជាគាត់មកពីស្រុកបារាំងពីរនាក់ប្តីប្រពន្ធ ប្តីគាត់ហ្នឹងធ្វើពេទ្យហ្នឹង ប៉ុន្តែគាត់ត្រឡប់ទៅវិញតែម្នាក់ឯង ទៅរកកូនគាត់ និងឈ្មោះអ្នក ថាច ចាំ! គាត់ធ្វើគ្រូបង្រៀន។ ចាំ! អ្នក ថាច ហ្នឹងប្តីគាត់ឈ្មោះលោក Doctor ហូ សិនរុង ប៉ុន្តែ គាត់ហ្នឹងក៏មិនរស់ទេចាំ! ហើយនឹងម្តាយក្មេកលោក អៀង សារី គឺម្តាយអ្នកគ្រូ ធីរិទ្ធ ព្រមទាំងបងស្រីអ្នកគ្រូ ធីរិទ្ធ ហ្នឹងឈ្មោះអ្នកគ្រូ ខៀវ ធារ៉ាត ចាំ! ក៏គាត់ ត្រឡប់ពីប្រទេសអាឡឺម៉ង់ទៅស្រុកខ្មែរវិញដែរ ហើយក្នុងអ្នកត្រឡប់ទៅវិញ ហ្នឹងក៏មានមាននាយទាហានច្រើននាក់ដែរចាំ! ទាហានទាំងអស់ហ្នឹងច្រើនទៅពី ស្រុក

អាមេរិកចាំ! ហើយក្នុងបណ្ដាអ្នកទៅវិញហ្នឹងមានម្នាក់ទៀតហ្នឹងគាត់ធ្លាប់រៀន ជាមួយខ្ញុំកាលពីនៅកាលេសនរោត្តមហ្នឹងតាំងពីថ្នាក់ទី៦ដល់ថ្នាក់ទី៣ឈ្មោះអ្នក ហៃម ម៉ាលី ចាំ! អ្នក ហៃម ម៉ាលី ហ្នឹងប្ដីគាត់ឈ្មោះ ប៊ុន បេងលី។ គាត់មកស្រុក បារាំងក៏ចូលហ្នុងអីចឹងទៅ ហើយគាត់ភ្ញាក់ផ្អើលណាស់ដល់ទៅដល់ស្រុកខ្មែរ ស្រាប់តែពួសូរគេហៅឈ្មោះ ប៉ុល ពត អីចឹង ស្រាប់តែគាត់មកនិយាយជាមួយខ្ញុំ ថា យីម៉េចក៏មានឈ្មោះ ប៉ុល ពត អីចឹង? គាត់មិនដែលឮទេ។ ខ្ញុំថាកុំនិយាយ ជាមួយខ្ញុំឈ្មោះពួកអ្នកធ្វើបដិវត្តន៍នៅខាងអង្គការខ្មែរក្រហមអីចឹង ខ្ញុំអត់ដឹងអ្នក ណាទាំងអស់។ ខ្ញុំមកស្រុកនេះ ខ្ញុំគ្រាន់តែមកដើម្បីជួបកូនខ្ញុំតែបណ្ណឹងទេពីរឿង អ្នកនយោបាយ គេធ្វើអីនៅពីលើហ្នឹង ចង់អ្នកណាគេឡើងគេចុះអី រឿងហ្នឹងរឿង របស់ គេ មិនមែនរឿងរបស់ខ្ញុំទេចាំ! ចាំ! ហើយពិសេសទៅទៀតហ្នឹងក្នុងអ្នកទៅ ហ្នឹង មានអ្នកម្នាក់ហ្នឹងគាត់ជាប្រពន្ធសមាជិកទូតរបស់ហ្នុងហ្នឹងនៅប្រទេស រុស្ស៊ី។ គាត់ ត្រឡប់ទៅវិញជាមួយកូនបីនាក់ កូនប្រុសមួយឈ្មោះ មុនី កូនស្រី មួយឈ្មោះ រ័ត្ន ហើយកូនមួយទៀតហ្នឹងឈ្មោះ វិរត្តន៍ ហ្នឹង។ នាង វិរត្តន៍ ហ្នឹងតូច ជាងគេពេលគាត់ និយាយគាត់ហៅឈ្មោះគាត់ វិរត្តការ របៀបដូចពួករុស្ស៊ីអីចឹង ចាំ! ហើយមិនសូវ ចេះនិយាយខ្មែរទេ។ ដល់អ្នកហ្នឹងគាត់ទៅដល់ហ្នឹង គាត់មាន សាច់ញាតិគាត់ទៅដល់ មុនគាត់ហ្នឹងទៅពីស្រុកបារាំងទៅ ហើយថាគាត់ឈ្លោះ ជាមួយសាច់ញាតិគាត់ហ្នឹង។ ដូចក្មួយគាត់អីចឹង។ ហើយដល់ថ្ងៃក្រោយមក ពួ សូរគេយកគាត់ចេញពីកន្លែង សាលាតិចណូហ្នឹងទៅ នៅតែកូនបីនាក់ហ្នឹង ហើយពួសូរគេនិយាយថា គាត់ហ្នឹងបាន ហៅ ឃើញពួកខ្មែរក្រហមដែល ដឹកអីវ៉ាន់តាមឡានជញ្ជូនចុះជញ្ជូនឡើងនៅតាម ផ្លូវមុខសាលាតិចណូហ្នឹង គាត់ ថាពួកហ្នឹងពួកចោរហោរយតើ។ ពួសូរគេនិយាយថា គាត់ថាអីចឹង។ ហើយ ក្រោយមក បានពួកខ្ញុំមកនៅបឹងត្របែកហ្នឹង ស្រាប់តែ ឃើញប្រុសម្នាក់ហ្នឹង ឡើងសស្គុសត្រឡប់ចូលទៅវិញ ពួគេនិយាយថា អូ! អ្នក លោកហ្នឹងឪរបស់ មុនី រ័ត្ន ហើយនឹង វិរត្តន៍ ហ្នឹងឯង ហើយលោកហ្នឹងទៅដល់ គាត់សួរកូនគាត់ថា ឯណាម៉ែពួកឯង? ហើយពួកកូនហ្នឹងអត់ដឹង អង្គការយកចេញ ទៅណាបាត់

ហើយក្រោយមកឪពុកហ្នឹងក៏មិនបាននៅបឹងត្របែកហ្នឹងតទៅទៀត សល់តែកូនបីនាក់ហ្នឹងនៅជាមួយពួកយើងខ្ញុំហ្នឹងរហូតដល់ពេលយួនចូលហ្នឹងចាំ! ហើយរត់មកជាមួយពួកខ្ញុំ។ ពិសេសទៅទៀតពួកដែលស៊ីឈ្នួលធ្វើការបម្រើ ពួកអស់លោកទូត ឬក៏បម្រើអ្នកណាផ្សេងដែលគេយកឈ្នួលគេមកស្រុកបារាំងហ្នឹង ហើយតាមខ្ញុំមើលទៅ ពួកទាំងអស់ហ្នឹង អ្នកឈ្នួល អត់សូវមានអ្នកណានៅរស់ទេ ចាំ! នៅសល់តែយាយ យ៉ែម មួយទេទីបំផុតដែលនៅរត់ពីយួន ពេលយួនចូលចាំ! សូមអរគុណលោក ប៉ូច រាសី ដែលបានលើកសំណួរទាំងអស់នេះចាំ!។

រាសី ៖ បាទ! សូមអរគុណអ្នកស្រី នៅ សារីម បាទ!។ បាទ! អ្នកស្រីៗមាន ប្រសាសន៍ថានៅពេលដែលអ្នកស្រីស្នាក់នៅសាលាបច្ចេកទេសមិត្តភាពខ្មែរ សូវៀតហ្នឹងគេតម្រូវឱ្យធ្វើជីវទស្សន៍បដិវត្តន៍ សូមអ្នកស្រីបកស្រាយមើល តើអ្វីទៅដែលហៅថាជីវទស្សន៍បដិវត្តន៍ នោះបាទ?

សារីម ៖ ចាំ! ជីវទស្សន៍បដិវត្តន៍ហ្នឹងគឺក្រោយពីយើងបានទៅរៀនជាមួយលោក ខៀវ សំផន ហើយនឹងលោកម្នាក់ទៀតដែលគេហៅថា មិត្ត ភុំ អស់ពេលបីថ្ងៃមកហ្នឹងក្រុមដែលទៅរៀនជាមួយខ្ញុំហ្នឹង ខាងស្រីៗគេប្រមូលផ្តុំគ្នាម្តុំទៅ ហើយឱ្យទាំងអស់ គ្នាសរសេរប្រវត្តិរូបរៀងៗខ្លួនយ៉ាងលម្អិត ហើយយកទៅអានឱ្យក្រុមប្រជុំ ក្រុម របស់ខ្លួនហ្នឹងស្តាប់ចាំ! ហើយយើងអានចប់ហើយទៅ ទាំងអស់គ្នាដែលបានទៅ រៀនសូត្រជាមួយយើង ហើយនៅក្នុងក្រុមជាមួយយើងធ្វើជីវទស្សន៍បដិវត្តន៍ហ្នឹង គេលើកសំណួរសួរមកយើងចាំ! ហើយដើម្បីឱ្យគេស្គាល់យើងឱ្យច្បាស់ថាយើងជា អ្នកណា ហើយមានជំហរយ៉ាងម៉េចនៅក្នុងសង្គមថ្មីហ្នឹងចាំ!

រាសី ៖ បាទ! តើគេឱ្យសួរហ្នឹង គេមានឱ្យពេលវេលាអ្នកស្រី និងអ្នកឯទៀតទាំងអស់គ្នាហ្នឹង ប៉ុន្មានម៉ោង ឬប៉ុន្មានថ្ងៃដែរបាទ! សរសេរហ្នឹងបាទ!?

សារីម ៖ ចាំ! យើងសរសេរហើយបានដល់គេណាត់ថ្ងៃថា ថ្ងៃណាទៅធ្វើហ្នឹង គឺយើងធ្វើជុំគ្នា ហើយគេសួរសំណួរយើងអាន ហើយគេសួរសំណួរយើងហ្នឹងគឺមួយថ្ងៃពេញ។

ពាសី ៖ បាទ! ហើយគេៗទុកពេលឱ្យយើងសរសេរប៉ុន្មានថ្ងៃដែរ?

សារីម ៖ មិនយូរទេចាំ! ប្រហែលជាពីរថ្ងៃអីហ្នឹងចាំ!

ពាសី ៖ បាទ! ហើយគេឱ្យយើងសរសេរដៃ ឬក៏ដាក់ទីឡូយ៉ាងម៉េច?

សារីម ៖ ចាំ! អត់មានដាក់ទីឡូអីទេ យើងសរសេរដៃហ្នឹងទៅ ហើយយកទៅអានឱ្យគេស្តាប់ ចាំ!

ពាសី ៖ បាទ! ហើយចុះកាលពេលដែលអ្នកស្រីស្ថិតនៅប្រទេសបារាំង ហើយរៀបចូលមក ស្រុកខ្មែរវិញហ្នឹង តើគេមានឱ្យសរសេរខ្លះហើយឬនៅបាទ!?

សារីម ៖ ចាំ! អាហ្នឹងគេឱ្យយើងសរសេររួចហើយចាំ! យើងជាអ្នកណា អីអ្នកណា។

ពាសី ៖ ប៉ុន្តែមិនពិស្តារ។

សារីម ៖ ចាំ! មិនល្អិតចាំ! ដូចថាលម្អិតហ្នឹងតាំងពីយើងនៅពីក្មេងក្តីហ្នឹងមានអ្នកទាក់ទងអីខ្លះ ធ្វើអីខ្លះ រៀនសូត្រនៅឯណាខ្លះ អីគ្រប់សព្វទាំងអស់ចាំ! ម៉េចហៅថាលម្អិតចាំ!

ពាសី ៖ បាទ! ហើយដល់ពេលគេប្រជុំគ្នាអីចឹងយើងអានចឹងទៅ ហើយអ្នកដែលទៅជាមួយ គ្នាហ្នឹង អ្នកដែលទៅពីប្រទេសបារាំងដូចគ្នាហ្នឹងគេសួរយើងដែរ គេអាចសួរយើង ដែរបាទ!។

សារីម ៖ ចាំ! ទាំងអស់គ្នាហ្នឹងអ្នកធ្វើជាមួយគ្នាហ្នឹង បានន័យថា ក្នុងហ្នឹងគ្នាជាង១០នាក់ហ្នឹង ម្នាក់ៗអានប្រវត្តិរូបរៀងខ្លួន ហើយទៅគេក៏សួរយើងទាំងអស់គ្នា។ គេសួរវេនខ្ញុំ អាន។ ខ្ញុំអានចប់ គេសួរខ្ញុំ។

ពាសី ៖ បាទ! ហើយអ្នកស្រីមានអារម្មណ៍ភិតភ័យក្នុងខ្លួនទេ នៅពេលដែលអាន?

សារីម ៖ ចាំ! ខ្ញុំសម្រេចថាទៅស្រុកខ្មែរហ្នឹងដូចថាយើងកាន់កូនខ្មោចអីចឹង គឺថាអត់មានខ្លាចងាប់ខ្លាចអីទេចាំ! ពីព្រោះថាដូចថាស្អីក៏ដោយ យើងនិយាយត្រង់ទាំងអស់ពីអ្វី ដែលយើងមាន យើងធ្វើ គឺយើងអានប្រវត្តិរូបយើងហើយ គេសួរយើងមក។

រាសី ៖ បាទ! ហើយខាងខ្មែរក្រហមហ្នឹងគេសួរអ្នកស្រីផ្ទាល់ហ្នឹង សួរសំណួរអីខ្លះដែរ?

សារីម ៖ ចាំ! ក្នុងហ្នឹងគឺថាអ្នកទៅរៀន អ្នកដែលទៅជិះកប៉ាល់ហោះជើងជាមួយយើងហ្នឹង គេសួរខ្ញុំតាមខ្ញុំមើលគេដូចសម្រុកសំណួរមកលើខ្ញុំច្រើន ខ្ញុំចាំសំណួរទី១ អ្នក អេត ដែលម៉ែ អារ៉ា ហ្នឹងគាត់ធ្វើគិលានុប្បដ្ឋាយិការ ហើយពេលហ្នឹងគាត់សួរខ្ញុំថា អ្នកឯងទៅដល់ស្រុកបារាំងហើយ ម៉េចបានអត់ចូលហ្វ៊ុង? ខ្ញុំថា ហឺស! ឱ្យខ្ញុំចូលហ្វ៊ុងម៉េចកើត បើខ្ញុំអត់ចូលចិត្តរបបឡើងកាន់អំណាចតពូជ។ ចាំ! ហើយខ្ញុំឆ្លើយថា ខ្ញុំមកស្រុកបារាំង ខ្ញុំមិនមែនមានលុយជិះកប៉ាល់ហោះមកធ្វើនយោបាយ នៅស្រុកបារាំងទេ ខ្ញុំមកស្រុកបារាំងហ្នឹងគឺខ្ញុំបានបួកបារាំងឱ្យខ្ញុំ ហើយខ្ញុំមកខ្ញុំបាន លុយបួកហ្នឹង ហើយខ្ញុំផ្ញើលុយទៅស្រុកខ្មែរទៀត ពីព្រោះយើងនៅស្រុកខ្មែរយើង ក្រវេទនាដោយសារចម្បាំងហ្នឹង យើងខ្វះខាតប្រាក់កាក់ចាយ។ ខ្ញុំបើចេះធ្វើនយោបាយហ្នឹងខ្ញុំមិនបាច់មកដល់ស្រុកបារាំងទេ ខ្ញុំជិះរ៉ឺម៉ក ម៉ូតូទៅចូលក្នុងតំបន់រំដោះ ហើយ។

រាសី ៖ ហ្វ៊ុងៗហ្នឹងជាអក្សរកាត់បានន័យថាយ៉ាងម៉េចបាទ!?

សារីម ៖ ចាំ! រណសិរ្សរួបរួមជាតិរំដោះជាតិខ្មែរនោះចាំ! របស់សម្តេច សីហនុ បង្កើតចាំ!។

រាសី ៖ បាទ! កាលហ្នឹងក្នុងហ្វ៊ុងហ្នឹងមានប៉ុន្មានគណបក្សអ្នកស្រីចាំទេ?

សារីម ៖ តាមមើលហ្វ៊ុងហ្នឹងគឺមានខ្មែរក្រហម និងសម្តេច សីហនុ វាយជាមួយពួកលន់ នល់ ចាំ!។

រាសី ៖ បាទៗ! ហើយនឹងៗអ្នកនៅក្រោយការសួរសំណួរទាំងអស់ហើយហ្នឹង គេធ្វើម៉េចទៀតបាទ?

សារីម ៖ ចាំ! ហើយខ្ញុំចង់បញ្ចប់សំណួរខ្ញុំមិញ ហើយទៅគេសួរខ្ញុំថា រឿងអីបានអ្នកឯងមិនទៅតំបន់រំដោះទៅបើជិះរ៉ឺម៉កតែ១២រៀលហ្នឹង? រឿងអីខ្ញុំទៅតំបន់រំដោះ ពីព្រោះអ្នករត់មកពីតំបន់រំដោះហ្នឹង គេថាសុទ្ធតែយួនយៀកកុង។ អ្នក អេត ហ្នឹងប្រាប់ខ្ញុំថា នែ! កុំឱ្យហៅយួនយៀកកុង ឱ្យហៅមិត្តវៀតណាម។ ខ្ញុំថា បើគេយួន

យៀកកុង គេនៅតែយួនយៀកកុងអីចឹងចាំ! ហើយអ្នកម្នាក់ទៀតហ្នឹងឈ្មោះ អ្នក ឆាយ ហាន់តេក ចាំ! អ្នក ឆាយ ហាន់តេក ហ្នឹងជាប្អូនរបស់ ដុកទ័រ ហ្វាម៉ាស៊ី ឆាយ ហាន់តេក ហ្នឹង ហើយគាត់ហ្នឹងទៅស្រុកខ្មែរវិញហ្នឹងជាមួយប្តី ហើយនឹង កូន គាត់ទាំងអស់ ប្តីគាត់ហ្នឹងធ្វើ ដុកទ័រ ពេទ្យចាំ! គាត់សួរខ្ញុំថា អ្នកឯងស្បែក លឿង ច្រមុះទាលអីចឹងធ្វើគ្រូបារាំងហ្នឹងបានប្រយោជន៍អី? ខ្ញុំថា ខ្ញុំធ្វើគ្រូបារាំង មកពីខ្ញុំ ចូលចិត្តធ្វើគ្រូបារាំង ហើយខ្ញុំយល់ថាជារបរ ម្លោះហើយក៏ធ្វើគ្រូបារាំង ស្រួលជាង ធ្វើគ្រូខ្មែរ ព្រោះវាបង្រៀនទៅមានការទើស ដូចថាយើងធ្វើការទិតៀន រិះគន់សង្គម អីចឹងទៅ វាមានការទើសទៅលើអ្នកដទៃហ្នឹង ម្លោះហើយយើងធ្វើតែ គ្រូបារាំងទៅ បង្រៀនតែអ៊ីអ៊ុយៗទៅ វាស្រួលចាំ! វាមិនមានរឿង ហើយក៏ជាការ មួយជួយ ស្រុកដែរ ពីព្រោះថាគេត្រូវការគ្រូបារាំង ហើយខ្ញុំខ្មែរបង្រៀនបារាំងហ្នឹង គឺជួយ ក្នុងថវិកាមិនបាច់ចេញលុយច្រើនជួលគ្រូបារាំងមកច្រើនពេកចាំ! ហើយ ឈ្មោះ អ្នក យ៉ែន យុសៀវ នោះគាត់ជាដុកទ័រអង់ហ្វាម៉ាស៊ី។ គាត់ដុកទ័រ ខាងផ្សំ ថ្នាំពេទ្យ ចាំ! គាត់សួរខ្ញុំថា អ្នកឯងខ្មាស់គេទេនៅស្រុកបារាំងយើងខ្មាស់គេណាស់ ដែល កាសែតគេថតខ្មោចយួនធ្លាក់ទឹកអណ្តែត ហើយពួកលន់ នល់ ពួកទាហាន បាញ់ យួននៅក្នុងកប៉ាល់នៅជ្រោយចង្វានោះ អ្នកឯងគិតយ៉ាងម៉េចដែរ? ខ្ញុំថា ហ៊ឺស! ខ្ញុំមិនមែនជាអ្នកនៅក្នុងជួរអ្នកដឹកនាំសម្រេចកិច្ចការអី ដូច្នេះខ្ញុំមិនអាចធ្វើ អ្វីបាន ទេ ប៉ុន្តែជាមនុស្ស ខ្ញុំគិតថា បើយើងសម្លាប់គេគ្រាន់តែសម្លាប់ អាហ្នឹងជា អំពើអសីលធម៌ប៉ុន្តែនៅក្នុងពេលហ្នឹង ខ្ញុំឮស្ងរគេនិយាយថា គេចាប់យួនចាប់ កប៉ាល់ហ្នឹង មានក្មេងយួនម្នាក់ហ្នឹងគាត់ឈឺបត់ជើង ហើយគាត់ទៅសុំគេទៅរក កន្លែងបត់ជើង ដើបឡើងពេលយប់ ប៉ុន្តែមានអ្នកខ្លះពេលហ្នឹងធ្វើឱ្យមាន ចលាចលឡើង ហើយដល់ អីចឹងទៅអ្នកទាហានៗគាត់ភ័យក៏មានការបាញ់អីចឹង ទៅ ហើយក៏ខ្មោចធ្លាក់ទឹកអីចឹង ទៅ។ ហើយអ្នកម្នាក់ទៀតហ្នឹងឈ្មោះអ្នក ដារ៉ាមុនី ដួង ដារ៉ាមុនី គាត់ហ្នឹង គាត់សួរខ្ញុំថា រឿងអីបាននាមត្រកូលខ្ញុំហ្នឹង ខុសពីបងប្អូនឯងទៀតៗ។ តើឪពុកខ្ញុំមាន ប្រពន្ធចុងប៉ុន្មាន? រួចទៅខ្ញុំថា ខ្ញុំ ឪពុកខ្ញុំអត់មានប្រពន្ធចុងអីទេ ឈ្មោះខ្ញុំគាត់ដាក់ យកឈ្មោះគាត់ជានាមត្រកូល

ហើយចំពោះបងប្អូនខ្ញុំឯទៀតហ្នឹង គាត់យកឈ្មោះ ជីតាខ្ញុំជានាមត្រកូល ចាំ! អីចឹងបានឈ្មោះខុសគ្នា។ ហើយទៅគេសួរខ្ញុំទៀតថា ចុះបើអ្នកឯងមកស្រុកខ្មែរហ្នឹងសម្រាប់តែចង់មកជួបកូន ហើយចុះបើកូនអ្នកឯង ស្លាប់អស់ទៅ តើអ្នកឯងគិតយ៉ាងម៉េចដែរ? ខ្ញុំថា យី! បើកូនខ្ញុំស្លាប់អស់ គឺថា ខ្ញុំត្រូវស្រឡាញ់អីដែលខ្ពស់នៅក្នុងជីវិត ហើយអ្នក ដារ៉ា ដួងដារ៉ាមុនីហ្នឹង គាត់ថា ហ៊ឹស! ខ្ញុំមានប្រវត្តិរូបល្អដូច្នេះសុំឱ្យមិត្តឯងហ្នឹងខំកសាងខ្លួនឡើង ដើម្បីរកសុភមង្គលឱ្យឃើញនៅក្នុងសង្គមថ្មីហ្នឹងចាំ! ហើយដល់ពេលយើងចេញមកពីអង្គប្រជុំ ហ្នឹងមានអ្នកម្នាក់នោះគាត់និយាយថា រឿងយៀកកុងនោះ គាត់និយាយ ថាម្ដាយគាត់នៅតាកែវ ហើយថា ពួកយៀកកុងហ្នឹងពេលខ្លះហ្នឹងគេមកក្រោមផ្ទះ គាត់ហ្នឹង គេមកបោសអាចម៍គេសម្អាតក្រោមផ្ទះឱ្យគាត់។ រួចទៅខ្ញុំក៏សួរគាត់ថា ម៉ែអ្នកឯងមានឆ្ងល់ទេ ហេតុអ្វីបានយៀកកុងគេស៊ីបាយគេ គេមកធ្វើការ បម្រើយើងទទេៗអីចឹង? មានគិតទេថាតើគេចង់បានអីទេចាំ? សុំអរគុណលោក ប៉ូច រាសី ចាំ!។

រាសី ៖ បាទ! សុំអរគុណអ្នកស្រី នៅ សារីម បាទ!។

រាសី ៖ នៅក្រោយថ្ងៃដែលធ្វើជីវទស្សន៍បដិវត្តន៍រួចមកមានហេតុការណ៍អ្វីកើតឡើងបន្តមកទៀតបាទ!?

សារីម ៖ ចាំ! ដល់យើងធ្វើហើយអីចឹង គេចាត់យើងជាក្រុម ជាពួកតាមរបៀបកុម្មុយនីស្ដចាំ! គេចាត់យើងជាមានពួក ហើយទៅ៣-៤ពួកបង្កើតជាក្រុមមួយ ហើយ ពួកខ្ញុំក៏នៅក្នុងពួកមួយហ្នឹងដែលមានខ្ញុំទាំងបីនាក់ដែលទៅពីស្រុកបារាំងទៅដូចគ្នាហ្នឹង។ មានខ្ញុំ ហើយស្រីពីរនាក់ទៀតហ្នឹង ហើយនឹងមេពួករបស់ខ្ញុំគឺនាងម្នាក់ៗហ្នឹង ឈ្មោះអ្នកស្រី ម៉ូណា។ គាត់អ្នក ប៉ុក ម៉ូណា អ្នកហ្នឹងគាត់ធ្វើគ្រូបង្រៀនដូចខ្ញុំដែរ ហើយគាត់មកស្រុកបារាំង ហើយគាត់ចូលហ្វ៊ុង ហើយប្ដីគាត់ហ្នឹងជាអ្នកមានឋានៈធំដុំនៅក្នុងហ្វ៊ុងហ្នឹងចាំ! ហើយថ្ងៃមួយហ្នឹងយើងបានតែមួយថ្ងៃទៅ គេរំលាយពួកខ្ញុំហ្នឹងចោលទៅ។ គេលើកជំហរសន្សំសំចៃមក។ សួន ហ្នឹង

ម្នាក់ៗទៅពីបីហ្សង់សុង ដូចគ្នា គាត់ថាថ្ងៃហ្នឹងគាត់មិនទាន់បានបំផ្លាញអីទេចាំ! ហើយសន្សំសំចៃអីក៏មិនចេះដែរ។ ឃើញថាចង្អុលមកខ្ញុំហ្នឹង ថាឃើញខ្ញុំប៉ុនសន្សំសំចៃឃើញអីក៏រើសទុកដែរ ប៉ុន្តែគេថ្ងៃនេះមិនទាន់បានបំផ្លាញអីទេ រួចគ្រាន់តែប៉ុណ្ណឹង ស្អែកឡើងពួកខ្ញុំហ្នឹងរលាយ។ គេលែងឱ្យនៅជាមួយគ្នា។

រាសី ៖ តើគោលបំណងនៃការបែងចែកជាក្រុមហ្នឹង តើអ្នកស្រីដឹងថាដើម្បីអ្វីដែរបាទ?

សារីម ៖ ចាំ! តាមមើលគេថា គេឱ្យយើងហាត់ពិនិត្យខ្លួនយើងតាមរបៀបកុម្មុយនីស្តនោះ គេធ្វើទិតៀន ស្វ័យទិតៀន ពេលធ្វើការហើយហ្នឹង ល្ងាចត្រូវប្រជុំទាំងអស់គ្នាហ្នឹង គេឱ្យយើងលើកនាំចេញមកស្អីដែលយើងឃើញខុសឆ្គង ស្អីដែលយើងមិនបានបំពេញទៅតាមជំហរបដិវត្តន៍របស់គេ។ យើងនឹកកូនចៅយើងយ៉ាងម៉េច យើងស្មុគស្មាញយ៉ាងម៉េចអី។

រាសី ៖ ហើយការប្រជុំទិតៀន ស្វ័យទិតៀនគ្នាហ្នឹង គេធ្វើឡើងញឹកញាប់ដែរទេ?

សារីម ៖ ចាំ! រាល់តែល្ងាច។

រាសី ៖ ហ្វ! ពេលល្ងាចរាល់បញ្ចប់ការងារហើយហ្នឹង?

សារីម ៖ ចាំ!។

រាសី ៖ ហើយការងារដែលគេឱ្យទៅធ្វើហ្នឹងធ្ងន់ធ្ងរទេពេលហ្នឹង?

សារីម ៖ ចាំ! ការងារយើងគឺថាយើងចែកជាពួកអីចឹងទៅ ពេលខ្លះគេចាត់ឱ្យពួកយើងហ្នឹងដាំបាយ យើងជាអ្នកដាំបាយអីចឹងទៅ ហើយដាំបាយហ្នឹងដាំបាយខ្ទះត្នោត ម្ល៉ោះហើយយើងហ្នឹងមិនដែលធ្លាប់ដាំបាយខ្ទះត្នោតឯណា ប៉ុន្តែចេះតែប្រឹង ចេះតែទៅរួចដែរចាំ! ហើយមិនហ៊ានដាំអីឱ្យខូចបាយគេទេ ខ្លាចខ្លោច ខ្លាចមានរឿងទៀត។ វីវរគេថាខ្មាំង គេថាអី។

រាសី ៖ ពេលហ្នឹងឆ្នាំ៧៦ហើ?

សារីម ៖ ចាំ! ឆ្នាំ៧៦ ពេលដល់ខែ១។

រាសី ៖ ពេលហ្នឹងមិនទាន់មានបាយរួមទេ ប៉ុន្តែម៉េចបានដាំបាយ...?

សារីម ៖ ចាំ! យើងនៅហ្នឹងគឺថាយើងសមូហភាពមុនពួកអ្នកជនបទហើយណាពីព្រោះយើងទៅជា យើងមានឆ្នាំងបាយយើងអីណា។ យើងទៅពីស្រុកបារាំងទៅគេដាក់ យើងក្នុងជំរំពួកអ្នកដែលទៅពីស្រុកបារាំងដូចគ្នា ហើយជាសមូហភាពចាំ!។

រាសី ៖ អីចឹងអ្នកស្រីដាំហ្នឹង និយាយពីរឿងដាំបាយហ្នឹង ដាំបាយឱ្យទាំងអស់គ្នាប៉ុន្មាននាក់?

សារីម ៖ ដាំបាយក្នុងគ្នាហ្នឹង។

រាសី ៖ ចំនួនច្រើនណាស់ បាទ?

សារីម ៖ ចាស។!

រាសី ៖ ហើយពេលហ្នឹងគេឱ្យញ៉ាំឆ្អែតគ្រប់គ្រាន់ទេ?

សារីម ៖ ពេលហ្នឹងគឺថា ខ្ញុំតែងតែខ្ញុំនិយាយថាមុនដំបូងយើងមានបាយ ហើយគេឱ្យយើងលាយជាមួយអង្ករចេកៗហ្នឹងគេយកចេកទៅស្ងោរ ហើយគេយកមកហាន់ ហើយគេហាល រួចទៅគេប្រើសម្រាប់ពេលគេធ្វើសង្គ្រាមនោះចាំ! ហើយនៅសល់គេយកមកឱ្យពួកយើងហ្នឹងប្រើចាំ!

រាសី ៖ ហើយពេលហ្នឹងអ្នកស្រីចុះធ្វើស្រែឬនៅពេលហ្នឹង គេឱ្យចុះទៅឥឡូវ?

សារីម ៖ ចាំ! ពេលហ្នឹងគេបង្ហាត់យើងឱ្យរៀនធ្វើថ្នាលសម្រាប់ដាំបន្លែចាំ! ហើយទៅកាប់ដី ហើយគេឱ្យយើងរៀនរែកទឹកទៀតចាំ! យើងពីព្រោះពីដើមយើងចេះតែទូលទឹក ណា អ្នកខ្លះចេះរែក ប៉ុន្តែដូចខ្ញុំអីមិនចេះរែកទឹកទេចាំ! ដល់រែកទៅ អាដងរែក ហ្នឹងវាចេះតែមកនៅលើកញ្ចឹងក វាមិននៅលើស្មា ចាំ!។

រាសី ៖ ហើយមានការលំបាក ហើយគេពេលយើងៗរៀន គេបង្រៀនយើងហ្នឹង?

សារីម ៖ ចាំ! គេឱ្យយើងធ្វើដីលេខមួយទៀត ចាំ!។

រាសី ៖ ហើយពេលគេបង្រៀនឱ្យធ្វើកិច្ចការទាំងអស់ហ្នឹង តើគេមានស្រែកគំហកឱ្យយើង ឬ ក៏គេនិយាយស្រួលជាមួយយើង?

សារីម ៖ ចា៎! មិនជា គេមិននេះអីទេ ពីព្រោះអ្នកទៅពីហ្នឹងដូចតែគ្នា អ្នកទៅពីស្រុកបារាំងទៅហ្នឹង អ្នកខ្លះមិនទាំងចេះធ្វើអីផង។ អ្នកមកពីស្រុកបារាំងនោះ កូនគេអ្នកមានអី អ្នកខ្លះអត់ចេះអីទាំងអស់ហ្នឹង។

រាសី ៖ ប៉ុន្តែអ្នកដែលបង្រៀនហ្នឹងគឺខ្មែរក្រហមបង្រៀនដូចថា រៀងធ្វើស្រែ ធ្វើសំណាបអីចឹងណា?

សារីម ៖ ចា៎! ស្ទូងអី គេធ្វើថ្នាលមួយអីចឹងទៅ កន្លែងហ្នឹងមានទឹក គេវែកកំប្លោក វែកអីចេញទៅ គេឱ្យយើងរៀនស្ទូង។ គេមិនជាធ្វើបាប ស្រែកអីឱ្យយើងទេ។ គេស្ទូងឱ្យយើងមើលទៅ គេប្រាប់របៀបយើងកាន់យ៉ាងម៉េចៗ បោះជំហានយ៉ាងម៉េច។ ខ្ញុំថាវាមិនពិបាកទេ អារឿងរៀនយើងមើលឃើញ។

រាសី ៖ ហើយពេលគេងៗនៅកន្លែងដដែល?

សារីម ៖ ចា៎! ពេលសម្រាននៅកន្លែងដដែល នៅបន្ទប់យើងហ្នឹងចា៎!។

រាសី ៖ ហើយនៅក្នុងពេលហ្នឹងតើមានអ្នកណាហ៊ានសួរថាតើពេលណាបានយើងអាចទៅជួប គ្រួសារយើងបានទេ?

សារីម ៖ ពេលហ្នឹង ខ្ញុំមិនបានសួរទេ ប៉ុន្តែមានអ្នកខ្លះគេចេះដើរស៊ើបទៅណេះទៅណោះអីទៅ ហើយគេមកនិយាយប្រាប់ខ្ញុំថា ហ៊ឺ! នែពួកខាងមិត្តខ្មែរក្រហមដែលផ្លាស់ពីជនបទ មកហ្នឹងគាត់ថា ហ៊ឺ! អ្នកខ្លះបដិវត្តន៍ចិនហ្នឹង អ្នកខ្លះគេមិនទាន់រកបងប្អូនគេឃើញផង ហើយអ្នកហ្នឹងគាត់មកនិយាយប្រាប់ខ្ញុំអីចឹងថា ឮសួរគេនិយាយអីចឹង។ ខ្ញុំថាអ្នកណា រកបងប្អូនមិនឃើញ មានតែបងប្អូនវាងាប់ហើយ ឥឡូវហ្នឹងមកដល់ឆ្នាំ៧៥-៧៦ ហើយរកមិនឃើញមានតែស្លាប់។

រាសី ៖ ហើយបាននៅពេលហ្នឹង តើអ្នកស្រីមានការអន្ទះអន្ទែងក្នុងខ្លួនទេដែលរង់ចាំហ្នឹងពីព្រោះ អ្នកស្រីគោលបំណងដែលត្រឡប់ទៅវិញហ្នឹងគឺធំបំផុតទៅជួបគ្រួសារ

ហើយដល់ពេលប៉ុន្មានខែមកហើយអត់បានជួបអីចឹង ក្នុងខ្លួនច្បាស់ជាមានការពិបាក?

សារីម ៖ ខ្ញុំពិបាកហើយខ្ញុំយើងថាពិបាកស្មុគស្មាញហើយ ប៉ុន្តែខ្ញុំមិនទៅសួរមិនទៅអីទេ ពីព្រោះខ្ញុំមិនចូលចិត្តឱ្យពួកហ្នឹងកសាងខ្ញុំ។ ពេលហ្នឹងលោកយាយម្ដាយក្មេក លោក អៀង សារី ហ្នឹង គាត់ដូចតែខ្ញុំដែរចូលចិត្តឈរមើលមកផ្លូវថ្នល់នៅមុខសាលាតិចណូ ហ្នឹង។ ខ្ញុំឈរមើលដើម្បីដូចថាវាស្មុគស្មាញពេកគ្មានកន្លែងណាមើល ឈរមើលផ្លូវ ហ្នឹងពេលខ្លះ ហើយលោកយាយហ្នឹងគាត់ឈរមើលតាម។ អ្នកគ្រូ ធារ៉ាត់ ប្រាប់ខ្ញុំថា គាត់ឈរមើលក្រែងលោឃើញឡានណាប្លែកមកហ្នឹង គាត់រង់ចាំកូនគាត់ហ្នឹង អ្នកគ្រូ ប៉ុណ្ណារី ប្រពន្ធ សាឡុត ស ប្រពន្ធ ប៉ុល ពត ហ្នឹង ឬក៏អ្នកគ្រូ ធីរិទ្ធ ប្រពន្ធ អៀង សារី ហ្នឹង ក្រែងលោពួកហ្នឹងមកជួបគាត់ចាំ! ដូចថាយើងព្រួយចិត្តនោះណា ចាំ!។ ហើយគាត់សួរខ្ញុំថា «នាងៗឯងម៉េចក៏អត់មានកូនចៅអីគេអីចឹង?» ខ្ញុំថាខ្ញុំមកហ្នឹងតែម្នាក់ឯងទេ ហើយកូនខ្ញុំនៅក្នុងស្រុកទាំងអស់ ហើយប្ដីអី រួចទៅ គាត់ថា «ហ៊ី! មើលវាធ្វើបាបគេអីចឹង»។ គាត់និយាយអីចឹង។ ហើយយាយហ្នឹងគាត់ទៅស្រុកខ្មែរហ្នឹង គាត់មានកូនស្រីគាត់ម្នាក់ទៀតឈ្មោះ អ្នកគ្រូ ធារ៉ាត់ ហ្នឹងចាំ! ហើយអ្នកគ្រូ ធារ៉ាត់ ហ្នឹង។ គាត់ហើយនឹងខ្ញុំស្គាល់គ្នា ព្រោះយើងបង្រៀន នៅសាលាជាមួយគ្នា គាត់បង្រៀនកូនសិស្សគ្រូ ខ្ញុំបង្រៀនកូនសិស្សតូចៗ ចាំ!។

រាសី ៖ ម្ដាយក្មេក អៀង សារី?

សារីម ៖ ចាំ! ម្ដាយក្មេកលោក អៀង សារី ម្ដាយអ្នកគ្រូ ធីរិទ្ធ ចាំ!។

រាសី ៖ អីចឹងម្ដាយក្មេកលោក អៀង សារី អាយុប្រហែលចំណាស់ណាដែរអ្នកស្រីចាំទេ?

សារីម ៖ ចាំ! គាត់ចាស់ហើយខ្ញុំមើលទៅដូចជាង៧០អីហើយ គាត់ចាស់ហើយ។

រាសី ៖ ប៉ុន្តែគាត់អត់មានមុខនាទីអីនៅក្នុងជួរបន្ទាត់ជាអ្នកដឹកនាំអី អត់ទេហី?

សារីម ៖ ចាំ! គាត់ទៅជាមនុស្សដូចថាត្រឡប់ទៅស្រុកខ្មែរដូចលោកយាយឯទៀតៗដែរ ប៉ុន្តែគ្រាន់ពិសេសគាត់មានកូនគាត់ធ្វើធំនៅហ្នឹង ហើយអ្នកគ្រូ ធារ៉ាត់ ដែលកូនគាត់ប្រាប់ខ្ញុំថា នាងម្ដាយខ្ញុំមកដល់ពោធិចិនតុងហ្នឹងគាត់ចាំកូនគាត់ឯទៀតៗ ដូចអ្នកគ្រូ ប៉ុណ្ណារី និង អ្នកគ្រូ ធីរិទ្ធ ហ្នឹងទៅទទួលនៅពោធិចិនតុងអី ស្រាប់ដល់មិនឃើញ គាត់ឃើញពួកក្មេងៗដែលធ្លាប់នៅផ្ទះជាមួយហ្នឹង ដែលគេចូលក្នុងក្រុមខ្មែរក្រហមដែរហ្នឹងទៅទទួលគាត់ គាត់សួរថា ឯណាមីងអ្លែង? រួចទៅពួកនោះ ថា រវល់ ដល់អីចឹងទៅ ហើយថាពួកពេទ្យចិនដែលជូនយាយហ្នឹងទៅស្រុកខ្មែរវិញ ហ្នឹង គាត់មកមើលជំងឺនៅស្រុកអាល្លឺម៉ង់អីហ្នឹងណា។ គាត់ត្រឡប់ទៅវិញ ហើយពួក ពេទ្យចិនដែលជូនយាយហ្នឹងទៅដល់ស្រុកខ្មែរក៏ចាំ ចាំថាក្រែងលោពួកខាងកូនគាត់ ដែលធ្វើមេខាងខ្មែរក្រហមហ្នឹងគេមកជួបពួកពេទ្យចិនហ្នឹង ដល់អត់ឃើញ ក៏ចាំយូរ ពេក គេក៏ត្រឡប់ទៅវិញទៅ។

រាសី ៖ បើអីចឹងសូម្បីតែបងប្អូនសាច់ញាតិខ្លួនឯងក៏គេធ្វើអីចឹងដែរ មិនរវីរវល់ប៉ុន្មានដែរទេ?

សារីម ៖ ចាំ! គេមិនទៅទទួលអីទេ ប៉ុន្តែគ្រាន់ថា យាយហ្នឹងគាត់ដល់មកនៅហ្នឹងទៅ ខ្ញុំឃើញមានគេចេះយកម្ហូបមកឱ្យគាត់ចាំ! ឃើញគេទួលកញ្ជើមកគេយកសាច់ជ្រូកដូចថាមួយដុំធំអីចឹងចាំ! យកមកឱ្យគាត់ ប៉ុន្តែដល់នេះគាត់ថា គាត់ពិសាមិនកើតទេ ម្នាក់ឯង ព្រោះអីឃើញគេអត់មានអីហូបអីចឹង ក៏គាត់ដាក់មកឱ្យពួកខាងសមូហភាព ហ្នឹងគេចាត់ចែងទៅ ហើយធ្វើម្ហូបអីទៅ ហើយធ្វើឱ្យគាត់ខ្លះទៅចាំ!។

រាសី ៖ ហើយចុះការស្នាក់នៅរបស់គាត់ គាត់នៅដាច់ដោយឡែកពីគេ នៅជាមួយ?

សារីម ៖ ចាំ! ពួកខ្ញុំបីនាក់ហ្នឹងនៅបន្ទប់ជាប់គាត់ហ្នឹង ហើយដល់ពេលគាត់បានម្ហូបអីពិសេសដូចផ្លែឈើអីចឹង ពេលខ្លះគាត់ឱ្យយើង១-២អីទទួលទានដែរ។

រាសី ៖ ហើយគាត់ដែលនិយាយប្រាប់អ្នកស្រីដែរពីរឿងប្រវត្តិគាត់យ៉ាងម៉េច ពីលោកអៀង សារីយ៉ាងម៉េច?

សារីម ៖ ចាំ! យើងមិនបាននិយាយអីចឹងទេ ប៉ុន្តែមើលទៅគាត់ជាមនុស្សអ្នកធម៌អារ្យ ស្លូតត្រង់ណាស់។ ហើយថ្ងៃមួយ អ្នកគ្រូ ធារ៉ាត់ នៅក្នុងរោងបាយ គាត់ប្រាប់ ខ្ញុំថា ម្ដាយគាត់ហ្នឹងរកស៊ីពីដើមហ្នឹងមានរកស៊ីកាន់មាសពេជ្រលក់តាមផ្ទះ អីចឹង ហើយគាត់លក់ចំណេញបានច្រើនណាស់ ដល់ចំណេញច្រើនទៅ គាត់ថ្ងៃ ក្រោយគាត់មិនហ៊ានយកចំណេញពីគេច្រើនពេកទេ គាត់លក់បញ្ចុះថ្លៃ គឺគាត់ ខ្លាចបាបអីចឹង។ ហើយអ្នកគ្រូ ធារ៉ាត់ ថ្ងៃហ្នឹងគាត់និយាយប្រាប់ខ្ញុំថា «ហ៊ុំនាង ពួក គេធ្វើបដិវត្តន៍នៅព្រះរាយឯណោះ។ គេនាំគ្នាធ្វើបដិវត្តន៍នៅព្រះរាយ ទៅជានាង ឯងនិងខ្ញុំហ្នឹងមកកសាងខ្លួន ឱ្យគេកសាងនៅក្នុងស្រុកទៅវិញ»។ ហើយ ពេលហ្នឹងមាន លោក ឈូក ម៉េងម៉ៅ ហ្នឹង គាត់អង្គុយនៅកន្លែងរោងបាយហ្នឹង ជាមួយពួកខ្ញុំហ្នឹង ហើយគាត់សួរ សួន ថា «សួន ឯងមកពីស្រុកណា?» ហើយ សួន ក៏ថា ប្ដីគាត់ នៅកំពត អីចឹង ហើយគាត់ថា អូ! អីចឹងនៅស្រុកជាមួយគ្នា ហើយ ចាំដល់ពេលគេ បញ្ជូនឱ្យយើងទៅរកបងប្អូនហ្នឹង យើងដើរទៅជាមួយ គ្នា ហើយថ្ងៃហ្នឹង លោកតា ឈូក ម៉េងម៉ៅ គាត់ថា ហ៊ឺស! នែពួកខាងកសិកម្មគេ នាំគ្នាមកច្រើនណាស់ ប៉ុន្តែ ពួកគ្រូបង្រៀនយើងហ្នឹងមិនសូវមានអ្នកណាមក ប៉ុន្មានទេ។ ខ្ញុំប្រាប់គាត់ថា យើងអត់មានបបួលគ្នាមកទេ។ អ្នកណាមកគឺមក ដោយស្ម័គ្រចិត្ត ដោយខ្លួនឯង។ ហើយថ្ងៃដែលលោកតា ឈូក ម៉េងម៉ៅ មក អង្គុយនៅកន្លែងដាំបាយដាំបបរហ្នឹង ថ្ងៃហ្នឹងពួកខ្ញុំយកអីវ៉ាន់ទៅលាងនៅក្នុង ស្រះទឹកជិតហ្នឹង ហើយយើងលើកមកហ្នឹង វាធ្ងន់ ហើយយើងធ្វើការហាត់ ខ្ញុំក៏ រអ៊ូថា ហ៊ឺស! យើងរាល់ថ្ងៃធ្វើការហាត់ណាស់ ហើយអត់មានអីហូបទេ ហូបសុទ្ធតែ បបរទឹករាវៗ ហើយលោកតា ឈូក ម៉េងម៉ៅ ហ្នឹង គាត់ថា អ៊ូ! ហ្នឹងហើយស្រុក យើង គឺថាស្រុកយើងកុំឱ្យយើងរអ៊ូរទាំ ហើយ មួយភ្លែតហ្នឹងស្រាប់តែគាត់ហ្នឹង មិនដឹងម៉េចទេ។ គាត់ភ្លាត់ខ្លួនគាត់ហ្នឹងដួលបះជើង ទៅធ្លាក់ពីលើជើងម៉ាដែល គាត់អង្គុយហ្នឹង ហើយទាំងអស់គ្នានាំគ្នាសើច រួចទៅគាត់ក៏ សើចដែរថ្ងៃហ្នឹង។ ហើយលោកយាយហ្នឹង ថៅគាត់គឺកូនលោក អៀង សារី ឧស្សាហ៍មកជួបគាត់ ណាស់ គឺថៅស្រី ហើយខ្ញុំមិនស្គាល់ទេ ប៉ុន្តែមាននាងម្នាក់ដែល ខ្ញុំនិយាយ

ថាឈ្មោះនាង ម៉ូលី គាត់ជាកូនសិស្សខ្ញុំហ្នឹង គាត់ទៅពីស្រុកបារាំង ទៅដែរហ្នឹង។ គាត់ស្គាល់ គាត់ធ្លាប់រៀនជាមួយនាងអស់ហ្នឹងដែលជាកូនលោក អៀង សារី ហ្នឹង។ គាត់ថា ណោះកូនលោក អៀង សារី ហ្នឹងមកសួរជីដូនគេហើយ ចាំ!។

ពាសី ៖ បាទ! ប៉ុនលោក អៀង សារី មិនដែលបានមកទេ?

សារីម ៖ ចាំ! អត់ដែលៗឃើញមកកន្លែងហ្នឹងទេ រួចទៅគាត់នៅហ្នឹងបានប៉ុន្មានទេ ហើយឃើញគេនាំគាត់ចេញបាត់ទៅ។ រួចដល់ទៅថ្ងៃក្រោយពួកខ្ញុំមកនៅកន្លែងបឹងត្របែក ហ្នឹង មានលោកយាយម្នាក់ហ្នឹងឈ្មោះលោកយាយ គីម ម្ដាយគ្រូពេទ្យ អ៊ិន សុកាន ហ្នឹង គាត់មកសួរលោក អៀង សារី ពេលមកជួបពួកយើងនៅបឹងត្របែកហ្នឹង។ គាត់សួរថា «ហ៊ឺ! ក្មួយលោកយាយ និងនាង ធារ៉ាត់ សុខសប្បាយទេ?» រួចទៅលោក អៀង សារី គាត់ឆ្លើយចង់ប្រាប់ថា អ្នកគ្រូ ធារ៉ាត់ ហ្នឹងខ្លាំងគេធ្វើឱ្យរស់មិនកើត។ រួចទៅពួកយើងក៏ស្ដាប់ឮសូរអីចឹង ហើយចេះតែឮសូរចចាមអារ៉ាម ប៉ុន្តែមិនដឹងរឿងពិតមិនពិតទេថា គេសម្លាប់គាត់ ឬ គាត់សម្លាប់ខ្លួនយើងមិនដឹង។

ពាសី ៖ ហ្នឹងក្រោយមកទៀត?

សារីម ៖ ចាំ! នៅពេលយើងនៅបឹងត្របែកហើយចាំ! ហើយអ្នកគ្រូ ធីរិទ្ធ ហ្នឹងជា គ្រូអង់គ្លេសខ្ញុំកាលនៅកាលេសនរោត្តម ហើយអ្នកគ្រូ ប៉ុណ្ណារី គឺគាត់ជាគ្រូខ្ញុំកាលបង្រៀនខ្មែរនៅ Class Premier នៅ Lycee ស៊ីសុវត្ថិនេះចាំ!

ពាសី ៖ បាទ! អ្នកគ្រូ នៅ សារីម ជាគ្រូបង្រៀនម្នាក់ មិនមែនជាសមាជិកហ្វ៊ុងទៅពីស្រុកបារាំងវិញទេនោះ ហើយកាលដែលអ្នកស្រីសម្រេចចិត្តត្រឡប់ទៅស្រុកខ្មែរវិញនោះ នៅពេលដែលពួកខ្មែរក្រហមកំពុងកាន់អំណាចហ្នឹងមិនមែនមានន័យថាអ្នកស្រីគាំទ្រ ពួកគេទេបាទ! មែនទេ?

សារីម ៖ ចាំ! ខ្ញុំមិនមែនគាំពួកហ្វ៊ុងហ្នឹងទេ ប៉ុន្តែដល់យើងចង់ទៅស្រុកខ្មែរ គេត្រូវឱ្យយើងសរសេរសំបុត្រសុំគេ ហើយដូចយើងគាំទ្រគេអីចឹងចាំ! យើងត្រូវសរសេរសំបុត្រដែលថាខ្ញុំសរសេរមិនកើតហ្នឹងចាំ!។

រាសី ៖ បាទៗ! ហេតុដូច្នេះទើបពួកខ្មែរក្រហមគេទុកចិត្តអ្នកស្រីដែរ តែអ្នកស្រីមានអារម្មណ៍ថាគេតាមមើលរាល់សកម្មភាពរបស់យើងដែរ?

សារីម ៖ ចាំ! ពេលទៅដល់ដែលថាខ្ញុំនៅកន្លែងសាលាតិចណ្ហហ្នឹង ពួកខ្មែរក្រហម ពួកខាងហ្ស៊ុងហ្នឹងដែលគេអនុញ្ញាតឱ្យយើងទៅហ្នឹងគេដឹងហើយថា យើងជាអ្នកណាៗ ចាំ! ហើយដែលគេអនុញ្ញាតឱ្យយើងទៅហ្នឹងដោយសារថាលោក អៀង សារី ហ្នឹង ពេលដែលគាត់ទៅស្រុកបារាំងពេលដែលគេបានអំណាចហើយនោះ ខ្ញុំឮសួរ គេនិយាយថាលោក អៀង សារី ទៅស្រុកបារាំងប្រាប់គេអ្នកនៅស្រុកបារាំង សមាជិកហ្ស៊ុងហ្នឹងថា អ្នកណាចង់ទៅស្រុកវិញ ត្រូវឱ្យគេទៅៗ។ ហ្នឹងជាលក្ខណៈ មហាជនដែលខ្ញុំនិយាយពីលើកមុនហ្នឹងណា ខ្ញុំទៅជាលក្ខណៈមហាជន អ្នកដែលចង់ ទៅស្រុកវិញ ដូច្នេះគេដឹងហើយថាយើងជាអ្នកណា។

រាសី ៖ បាទ! បើអីចឹងគេមិនទុកចិត្តយើងប៉ុន្មានទេមិនអីចឹង?

សារីម ៖ ចាំ! តាមខ្ញុំមើលគឺគេមិនមែនឱ្យយើងទៅធ្វើស្នូលអីកន្លែងគេទេ ប៉ុន្តែអ្នកទៅភាគច្រើនហ្នឹងច្រើនជាសមាជិកហ្ស៊ុងដែលគេចូលហ្ស៊ុងហ្នឹងតាំងពីសម័យពួកលន់ នល់មក។ ហើយបើតាមខ្ញុំមើលឃើញថា គេប្រើយើងគេប្រើអ្នកនោះដូចតែគ្នាហ្នឹង។ គេប្រើ យើងឱ្យធ្វើការហ្នឹង គេប្រើដូចតែគ្នា ហើយគេឱ្យយើងដាំបាយ គេឱ្យយើងកាប់ដី ធ្វើថ្នាលដាំដំណាំ បង្រៀនស្ទូងស្រូវ។ គេប្រើដូចតែគ្នាហ្នឹង។

រាសី ៖ បាទៗ!

សារីម ៖ ប៉ុន្តែគ្រាន់យើងមិនមែនធ្វើប្រធាន ធ្វើអីយើងអត់មានចូលអីចឹងៗទេ។

រាសី ៖ បាទៗ!

សារីម ៖ សួន ហ្នឹងគេឱ្យគាត់យកពាងទឹកនោមពីបន្ទប់យើងរាល់ថ្ងៃ យកចុះមកក្រោម យកចាក់លាយជាមួយលាមក។ យើងមានបង្គន់បត់ជើងធំនៅក្រោមហ្នឹងជាមួយលាមកហ្នឹង ហើយជាមួយផេះ ជាមួយកំប្លោក ដើម្បីធ្វើជីលេខមួយហ្នឹង រួចទៅ យើងរៀនធ្វើថ្នាលសម្រាប់ដាំដំណាំ គឺថាពេលនោះយើងកាប់ដីហើយដីមួយដុំធំៗ យើងទៅ

អង្គុយជុំដីហ្នឹងគឺថាឱ្យតួចបំបែកវា ហើយធ្វើរង ធ្វើថ្នាលឡើងហ្នឹង។ ពេល ជំដីហ្នឹងគឺខ្ញុំដូចជាមួមៅ ឃើញថាៗខ្មែរក្រហមដឹកពួកចិនទាំងឡានៗ អ្នក ឯកទេសចិនហ្នឹងឃើញតាមផ្លូវពោធិចិនតុង។ យើងឃើញយកមកធ្វើការ រួចចំណែក ពួកដែលទៅពីស្រុកបារាំងទៅវាអ្នកចេះអី ច្រើនសឹងអី គេអត់មានយកទៅប្រើ។ គេដាក់យើងនៅក្នុងជំរំហ្នឹង។ ពេលខ្ញុំជំដីហ្នឹង ខ្ញុំប្រទេចផ្កាសារ។ ខ្ញុំថាអារបបនេះ ដូចជារបបឱ្យតម្លៃទៅពួកបរទេសជាងខ្មែរគ្នាឯងដែលមានតម្រិះ។ ហើយ និយាយពីពួកខ្ញុំហ្នឹងក្រោយពីគេបំបែកពីពួកដែលមានប្រធាន ពួកអ្នកម៉ូណាជាប្រធាន ពួកហ្នឹង គេយកពួកខ្ញុំហ្នឹងទៅដាក់នៅក្នុងពួករបស់កូនគាត់ហ្នឹង។ កូនកសិករឈ្មោះ អារ៉ា ហ្នឹង។ អ្នកហ្នឹងឈ្មោះ អ្នកអេតហ្នឹង។ គាត់ជាប្រធានពួកថ្មីរបស់ខ្ញុំ ហើយ ក្នុងហ្នឹងមាន សួន មានខ្ញុំ និង វណ្ណា និងមានម្នាក់ទៀតហ្នឹងឈ្មោះ អំ ហ្នឹង។ ខ្ញុំហៅគាត់បង អំៗ។ គាត់ជាឈ្នួលរបស់លោកផាន់ ប៊ុយហាក់។ ផាន់ ប៊ុយហាក់ហ្នឹងគាត់ ធ្លាប់ធ្វើជានាយកខាងសាលាច្បាប់។ បងអំ ហ្នឹងគាត់ប្រាប់ខ្ញុំថា ពួកសមាជិកហ្វ៊ុងនៅប៉ារីសហ្នឹងបានទៅជួយរំដោះគាត់ហ្នឹងឱ្យចេញឈប់នៅធ្វើឈ្នួលលោក ផាន់ ប៊ុយហាក់ ហ្នឹង មកយកគាត់មកនៅជាមួយ ពួកគេ។ បង អំ ហ្នឹងខិលណាស់ គាត់ប៉ិនលួចពេលដែលក្នុងពួកជាមួយខ្ញុំហ្នឹងគឺថ្ងៃ មួយហ្នឹង គាត់ទៅប្រាប់ប្រធានក្រុមអ្នកម៉ូណាហ្នឹងថា គាត់ចង់សម្អាតក្រណាត់ជូត ចានព្រោះគាត់ចង់ស្ងោរវាសម្លាប់មេរោគ រួចអ្នកម៉ូណាក៏ឱ្យធ្វើ។ ស្រាប់ដល់គាត់ មិនមែនស្ងោរក្រណាត់ឯណា។ គាត់ស្ងោជំឡូង ស្ងោរជំឡូងក្រោមក្រណាត់ហ្នឹង។ គាត់ ទៅលួចជំឡូងពីយប់ ហើយគាត់យកមកស្ងោរ ហើយគាត់យកមកឱ្យខ្ញុំ។ រួចខ្ញុំប្រាប់ ថាបង អំ ឯងកុំយកជំឡូងយកអីមកឱ្យខ្ញុំ ខ្ញុំអត់ចង់បានទេ ហើយគាត់ប្រាប់ថា នែ! សង្ឃិតឯងបើថាមិនយកអាចឹងៗទៅហូបទេ ប្រយ័ត្នងាប់លែងបានជួបកូន រកកូនមិនឃើញផង ងាប់មុន។ ខ្ញុំប្រាប់ថា ខ្ញុំមិនចូលចិត្តឱ្យគាត់ទៅលួចអីចឹងទេ ប្រយ័ត្នគេយកគាត់ទៅសម្លាប់ចោល ហើយគាត់ថា បើគេចាប់គាត់សម្លាប់ចោល មានតែសង្ឃិតឯងហ្នឹងទៅរាយការណ៍ ហើយគាត់មិនលួចប៉ុណ្ណឹងទេ។ គាត់ទៅលួចម្សៅ ទឹកដោះគោអ្នកដែលថាមានកូនតូច ហើយខ្ញុំចេះចង់ប្រឹងខំពន្យល់គាត់ថាកុំឱ្យគាត់ហ្នឹង គិតថាវណ្ណៈគាត់ហ្នឹងជាឈ្នួលអី។ គាត់ដូចថាមានភ្លើតភ្លើនថាខ្លួនឯងជាឈ្នួលអី គេចេះតែអត់ឱនអីណា។

ហើយបង អំ ហ្នឹង ឱ្យតែមិត្ត អេត ហ្នឹងប្រធានពួក ហ្នឹងកសាងអី គាត់ចេះតែក្តិចខ្ញុំ ហើយ ហើយមិត្ត អេត ហ្នឹងគាត់ចូលចិត្តនិយាយថា គាត់ហ្នឹងទៅកន្លែងណាគាត់ពាំ វណ្ណៈកសិកររបស់គាត់ហ្នឹងទៅជាមួយ។ ហើយបង អំ ហ្នឹងពេលហ្នឹងគាត់ចេះតែយក ជើងរបស់គាត់មកធាក់ខ្ញុំ ខ្ញុំហើយដល់ចេញពីអង្គប្រជុំ ទៅ គាត់ថា «ហ៊ឺស! វណ្ណៈកម្មករ កសិករអី សុទ្ធតែពួកចក្រពត្តិ»។ ហើយបង អំ ហ្នឹង ក្រោយមកគេយកគាត់ទៅចេញទៅ ដីក្រហម ហើយលែងមក លែងឃើញគាត់មក វិញ។ ហើយនិយាយពីមិត្តម្នាក់ដែល ឈ្មោះ គង់ បុណសិរី ហ្នឹងដែលថាជាពួក ម៉ាកប្តីខ្ញុំហ្នឹង ថ្ងៃមួយហ្នឹងស្រាប់តែឃើញ គាត់បីនាង ម៉ូលី ហ្នឹងដើរកាត់ពីខាងមាត់ បឹងសាលាតិចណូហ្នឹងមកក្រោមផ្ទះមួយហ្នឹង ព្រោះនាងហ្នឹងលង់ទឹក ហើយខ្ញុំពេល ហ្នឹង ខ្ញុំស្ទើបណាស់ឃើញតែបីមនុស្សស្វែង នៅ ក្នុងមានខ្មែរក្រហមអីចឹង ខ្ញុំខ្លាចមែនទែនពេលហ្នឹង។ ហើយតាំងពីថ្ងៃហ្នឹងមក លោក គង់ បុណសិរី គាត់ចេះ តែប្រាប់នាង ម៉ូលី ហ្នឹងថា «យើងចង់ធ្វើតាមចិត្តយើងប្រាថ្នា

ហ្នឹង គឺថា ធ្វើទៅ ពីព្រោះយើងមករស់នៅហ្នឹងដូចជាយើងវាអត់មានសេរីភាព អត់មាន អីទាំងអស់ ម្លោះហើយយើងធ្វើអីទៅតាមចិត្តយើងទៅ កុំឱ្យយើងស្តាយ»។ ហើយទៅខ្ញុំ ប្រាប់ នាង ម៉ូលី ថា «ប្រយ័ត្នកុំធ្វើអីផ្តេសផ្តាស ប្រយ័ត្នពួកហ្នឹងយកយើងទៅសម្លាប់ ចោលអត់អំពើ»។ ហើយលោក គង់ បុណសិរី ហ្នឹងគាត់បានចេញទៅធ្វើការនៅ ខាង

ក្រៅ ហ្នឹង។ ពេលខ្លះគាត់បានអំពៅ កាត់អំពៅជាចំណិតៗតូចៗហ្នឹងលាក់យក មកហ្នឹង។ ពេលខ្លះគាត់យកមកឱ្យពួកយើង ហើយមិត្ត គង់ បុណសិរី ហ្នឹង ថ្ងៃមួយ គាត់មកប្រាប់ ពួកខ្ញុំថា នែ! គាត់ដើរទៅធ្វើការហ្នឹងឃើញពួកអ្នកមិត្តនារីខាងខ្មែរ ក្រហមធ្វើការនៅ ក្បែររទេះភ្លើងហ្នឹងគេថា នុះ! នៅកន្លែងសាលារៀននោះ មាន ពួកអ្នកមកពីស្រុកបារាំង ហ្នឹង។ ពួកវាមកនៅតែហ្នឹង ហើយពួកហ្នឹងស្មានថាខ្លួនឯង ហ្នឹងមកបានធ្វើការអីនៅ កន្លែង Bureauនៅអីហើយ។ ពួកហ្នឹងថា ដេកចាំទៅ។ ចំណែកអ្នកម៉ូណាជាប្រធាន ក្រុម ពេលដែលយើងធ្វើការដាំបាយហ្នឹង គាត់មិនដឹង យ៉ាងម៉េចថាមុខមាត់គាត់អីហ្នឹង មុខមាត់គាត់ប្រឡាក់សុទ្ធតែធ្យូង។ ឱ្យតែគាត់ចូលចង្ក្រាន គាត់ចេញមកវិញប្រឡាក់ សុទ្ធតែធ្យូង សំពត់គាត់ឃើញអូសជាមួយតែខ្ទះដាំបាយ ហ្នឹង។ រួចខ្ញុំខំប្រាប់គាត់ថា ម៉ូណាឯងកុំព្រួយពីរឿងដាំបាយដាំអី គឺចាំខ្ញុំជួយ មិនបាច់ថាភ័យខ្លាចខូចបាយខូចអី

ទេ។ យើងប្រឹងធ្វើដាំអីឱ្យបានល្អឱ្យបានអីចឹង ព្រោះ ឃើញគាត់ហ្នឹងភ័យភិត ហើយមិនដឹងគាត់ធ្វើឱ្យប្រឡាក់ធ្យូង ឬក៏គាត់មិនប្រសប់ ធ្យូងវាចេះតែប្រឡាក់គាត់យ៉ាងនេះ។ ហើយពេលដាំបាយថ្ងៃមួយហ្នឹងខ្ញុំយកត្រីទៅលាងនៅកន្លែងស្រះនៅជិតកន្លែងដាំបាយហ្នឹង រួចខ្ញុំបានឃើញខ្យង ខ្ញុំឃ្លានណាស់។ ពេលហ្នឹង មិនមែនថាខ្ញុំមិនឃ្លានទេ ប៉ុន្តែខ្ញុំខំទ្រាំណាស់។ ខ្ញុំមិននិយាយ ដូចថាមិនបញ្ចេញឱ្យដឹងណា។ ខ្ញុំចាប់បានខ្យង២-៣យកមកបោះចូលនៅក្នុងចង្ក្រានទៅដុតទៅឡើងខ្លោច។ ទំរាំកៀរចេញបានមកវិញល្ងចយកមកទទួលទានហ្នឹងឡើង ប្រឡាក់ធ្យូងពេញមាត់ ហើយពេលខ្លះទៅលាងត្រីចាប់បានកំពឹសពិសាទាំងឆៅ។

រាសី ៖ ហើយនៅក្នុងឆ្នាំណាដែលព្រះមហាក្សត្រ នរោត្តម សីហនុ បានសុំលាចេញពីមុខ តំណែងនៅក្នុងរដ្ឋាភិបាលខ្មែរក្រហម ពេលហ្នឹងអ្នកស្រីនៅស្រុកខ្មែរហើយឬនៅ បាទ?

សារីម ៖ ចាំ! ពេលហ្នឹងខ្ញុំចាំគឺនៅខែមេសាឆ្នាំ៧៦ ហើយខ្ញុំចាំ ពេលមួយហ្នឹងខ្ញុំ កំពុងនៅកន្លែងដាំបាយគេឱ្យដាំបាយខ្វះត្នោត។ រោងបាយគេហ្នឹង រួចទៅស្រាប់តែមានម្នាក់ហ្នឹងគេមកសួរយើងដូចស្ទង់មតិអីចឹង ឃើញគេទៅចង្ក្រានកន្លែង ដាំបាយរួចគេសួរពួកអ្នកដាំបាយហ្នឹង។ គេថា ឥឡូវបើសិនជាសម្តេច សីហនុ ចូល និវត្តន៍ អ្នកទាំងអស់គ្នាហ្នឹងគិតយ៉ាងម៉េចដែរ? ពេលហ្នឹងខ្ញុំនៅដាំបាយខ្ញុំងើបមើលមុខអ្នកសួរហ្នឹងក៏ថា យី! រឿងហ្នឹងម៉េចមកសួរយើងខ្ញុំឆ្ងល់ក្នុងចិត្តណាស់ ម៉េចបានមកសួរយើង។ ខ្ញុំឆ្លើយថា ហ្នឹងជារឿងរបស់អង្គការ ពួកខ្ញុំអត់ដឹងរឿងអី ទេ ខ្ញុំគ្រាន់តែមកស្រុកដើម្បីជួបកូនចៅ។

រាសី ៖ បាទ! តើអ្នកស្រីយល់យ៉ាងណាដែរថា នៅពេលហ្នឹងហេតុអីបានគេមកសួរយើងអីចឹង?

សារីម ៖ តាមខ្ញុំមើលប្រហែលជាគេចង់ស្ទង់មតិ ឬក៏ចង់មើលប្រតិកម្មរបស់យើងម្នាក់ៗចាំ!។

រាសី ៖ ប៉ុន្តែអ្នកស្រីអត់មានអីទទួលព័ត៌មាន អត់មានអីស្តាប់ទេ អត់ដឹងទេ?

សារីម ៖ ចាំ! ពេលគេសួរយើងអីចឹងទៅ ប៉ុន្មានថ្ងៃក្រោយមកហ្នឹង គេមានបើកអង្គប្រជុំនៅហ្នឹង គេខ្មែរក្រហមប្រើពាក្យមីទីងនិងគេប្រើពាក្យមីទីងនិង ដូចស្មាត់ ណាស់ ចាំ!មីទីងនិង ដល់មីទីងនិងទៅមីទីងនិងនៅក្រោមកន្លែងយើង នៅហ្នឹង ព្រោះផ្ទះហ្នឹងខ្ពស់ៗ រួចទៅស្រាប់តែគេមានចាក់សំឡេងសុន្ទរកថារបស់ លោក ខៀវ សំផន ឱ្យយើងស្តាប់ពីរឿងថា សម្តេច សីហនុ ចូលនិវត្តន៍ហើយ។ គេនិយាយពីគុណបំណាច់របស់សម្តេច ដែលជួយនៅក្នុងការរំដោះជាតិគេនោះណា ជួយនៅក្នុងបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យហ្នឹង ហើយទៅបានគេថា ខ្ញុំចាំៗតែពាក្យ ខ្លះដូចថាវាៗឱ្យខ្ញុំចាប់អារម្មណ៍ហ្នឹងណា។ ឃើញលោក ខៀវ សំផន ហ្នឹងគាត់និយាយ ថា សម្តេច សីហនុ ជាអង្គក្សត្រស្នេហាជាតិ។ រួចទៅខ្ញុំចាំមួយ ទៀតខ្លាំងហ្នឹងគឺថា ឥឡូវហ្នឹងគេប្រគល់គុណបំណាច់ហ្នឹងទៅឱ្យសម្តេចហ្នឹងជាប្រាក់ខែ ជាប្រាក់ចាយហ្នឹងក្នុងមួយឆ្នាំហ្នឹង៨០០០ដុល្លារសម្រាប់សម្តេចចាយវាយអីចឹង ដោយសារ គុណបំណាច់របស់ព្រះអង្គដែលជួយក្នុងបដិវត្តន៍។ ឥឡូវព្រះអង្គចូលនិវត្តន៍ហើយ ថាព្រះអង្គមានប្រាក់បំណាច់៨.០០០ដុល្លារក្នុងមួយឆ្នាំ។

រាសី ៖ ហើយចុះសមាជិកហ្នុំងដែលនៅក្បែរអ្នកស្រីទាំងប៉ុន្មានហ្នឹង តើគេមានប្រតិកម្មយ៉ាងដូចម្តេចដែរ?

សារីម ៖ ខ្ញុំឃើញថាពេលហ្នឹងយើងទៅស្តាប់អង្គមីទ្វិងហ្នឹង ហើយទៅស្រាប់តែគេនិយាយអី ស្តាប់សុន្ទរកថារួចទៅមានគេឡើងចាប់អារម្មណ៍។ ខ្ញុំភ្ញាក់ដូចថាវាមិនដឹងខ្លួនពេល គេស្រែកថា ប្តេជ្ញាៗៗ រួចទៅគេលើកដៃ ខ្ញុំអត់ដែលធ្លាប់ឃើញអីចឹង។ ខ្ញុំ ឡេងឡង់ខ្ញុំមិនដឹងលើកដៃទៅខាងណាខាងណីអី។

រាសី ៖ ប្តេជ្ញាពីរឿងអីបាទ?

សារីម ៖ គេប្តេជ្ញាដូចថា ខំកសាងស្រុកក្រោយពីដូចថាឥឡូវវាមានសម្តេចចូលនិវត្តន៍អីចឹង ហើយទៅគេប្តេជ្ញាទៅមុខទៀតអីចឹង ហើយមានខ្ញុំមើលទៅមានអ្នកខ្លះគេពូកែណាស់ គាត់ពូកែខាងរបៀបធ្វើការឃោសនា។ ពេលហ្នឹងគាត់ស្រែកងើប

ឡើង ប្ដេជ្ញាអីចឹង ប៉ុន្តែដល់យើងដូចអត់ដែលធ្លាប់ឡើងដូចៗឯាកទៅដូចមិនទៅមិនរួច។

ពាសី ៖ ប៉ុន្តែនៅក្នុងអារម្មណ៍អ្នកស្រីៗយល់យ៉ាងណាដែរចំពោះព័ត៌មានដែលថា សម្ដេចសីហនុ ចូលនិវត្តន៍អីចឹង? អ្នកស្រីមានការព្រួយបារម្ភពីអនាគត និងកាន់តែយ៉ាប់ជាង ឬក៏យ៉ាងម៉េចដែរ?

សារីម ៖ ខ្ញុំអត់មានវល់ពីរឿងអ្នកណាកាន់អំណាចអីទេពេលហ្នឹង ខ្ញុំខំធ្វើយ៉ាងម៉េចឱ្យខ្លួនខ្ញុំបាន រស់នៅទៅដល់ស្រុកខ្មែរហ្នឹងណា ធ្វើយ៉ាងម៉េចឱ្យខ្លួនខ្ញុំបានរស់ជីវិតដើម្បីខ្ញុំជួបកូនខ្ញុំ ហើយខ្ញុំយើងអត់មានធ្វើអីកើតទេ ចាំ! ចង់អ្នកណាឡើងកាន់អំណាច ចង់អ្នកណាគេ ចុះអីរឿងរបស់អ្នកអស់នោះ។ ពួកយើងខ្ញុំនេះគ្រាន់តែទៅក្នុងន័យថាចូលស្រុក ជាពិសេសគឺជួបកូនតូចៗធ្វើម៉េចឱ្យតែថាគេព្រលែងទៅ ហ្នឹងអាលបានទៅជួបកូនចៅយើងហ្នឹង។ យើងរស់តែប៉ុណ្ណឹងទេ។

ពាសី ៖ បាទ! និយាយដល់រឿងកូនចៅហ្នឹង តើនៅក្នុងរយៈពេលដែលអ្នកស្រីស្ថិតនៅសាលាតិចណូហ្នឹងតើគេមានរំឭកយើង ឬក៏ឱ្យព័ត៌មានយើងដឹងដែរថាថ្ងៃណាថ្ងៃណីទេ?

សារីម ៖ អត់មានទេ ហើយខ្ញុំក៏មិនចង់សួរ ពីព្រោះខ្ញុំស្ទាបស្ទង់ស្ថានការណ៍ទៅឃើញថាគេអត់ខ្វល់ពីរឿងអ្នកឯងជួបកូន ឬមិនជួបកូនអីទេ។ ខ្ញុំមើលទៅឃើញអីចឹងហើយ ប៉ុន្តែអ្នកដែលនៅជុំវិញខ្ញុំហ្នឹងគេចេះតែប្រាប់ថា មិត្តឯងកុំព្រួយបារម្ភអី កូនមិត្តឯងៗមើលតែកុមារនៅក្នុងមន្ទីរយើងហ្នឹងទៅ កុមារបានហូបបីពេល ព្រលឹមឡើងមានស្រស់ស្រូបថ្ងៃត្រង់ ហើយទៅល្ងាចមានអីគឺថា អង្គការគិតកុមារមុនគេ។ រួចទៅខ្ញុំស្ដាប់ហើយ ព្រោះយើងឃើញកុមារហូបច្រើនជាងយើងអីចឹងមែន យើងធ្វើបាយអីឱ្យកុមារអីចឹងមែន ប៉ុន្តែយើងឃើញកុមារនៅជុំវិញយើងហ្នឹងគាត់ ឃ្លាន ហើយប៉ុន្តែខ្ញុំចេះតែគិតថា ប្រហែលយើងនេះមិនសូវមានអ្វីហូបទេមិនដឹង ព្រោះយើងនៅទីក្រុង ខ្ញុំគិតអីចឹងណា ហើយប្រហែលជាកូនចៅខ្ញុំបើថាទៅបើកូន ចៅខ្ញុំមិនស្លាប់ពេលគេជម្លៀសទេ បើថាទៅស្រុកខ្ញុំនៅកៀនស្វាយហ្នឹង ខ្ញុំ

យល់ថា ប្រហែលកូនចៅខ្ញុំអាចរស់បាន ពីព្រោះយើងមានចម្ការមានអី នៅស្រុកចម្ការវាមិន ក្រដូចនៅភ្នំពេញទេ។ ហើយខ្ញុំចេះតែភ័យខ្លាចថា ខ្លាចម្ដាយខ្ញុំទៅពោធិ៍សាត់ ព្រោះម្ដាយខ្ញុំជាអ្នកពោធិ៍សាត់។ ខ្ញុំយល់ថាបើទៅពោធិ៍សាត់ហ្នឹងគឺដូចជាពិបាកសង្ឃឹម ព្រោះនៅពោធិ៍សាត់ដូចថាយើងមិនសូវសម្បូរផ្លែឈើអីៗ កាលណាទឹកជន់មកម្ដងៗ ដើមឈើច្រើនតែរលំ។ អាហ្នឹងខ្ញុំគិតអីចឹង ចា៎! ហើយទៅខ្ញុំចេះតែខំប្រឹងៗ ទប់ខ្លួនឯងដើម្បីខ្លួនឯងបានរស់។

ពាសី ៖ ហើយអីចឹងអ្នកដែលទៅពីស្រុកបារាំងទៅជាមួយហ្នឹង អ្នកស្រីបានជម្រាបលើកមុនថាមានអ្នកខ្លះមានកូនមានទៅជាមួយដែរ តើគេអនុញ្ញាតឱ្យនៅជាមួយជួបជុំគ្រួសារ អីចឹងដែរនៅពេលហ្នឹង?

សារីម ៖ ចា៎! អ្នកដែលទៅជាមួយយើងពេលហ្នឹងៗដែលយើងនៅសាលាតិចណូហ្នឹង គេអត់មានបំបែកកូនចៅទេ។

ពាសី ៖ នៅជាមួយគ្នា ឃើញគ្នារាល់ថ្ងៃអីចឹង?

សារីម ៖ ចា៎! ខ្ញុំសុំជម្រាបថាកុមារដែលគេចាត់ឱ្យខ្ញុំមើលពេលមួយហ្នឹងគឺមានកូនអ្នក ម៉ុច ឬ នរោត្តម អែវ៉ារដ្ដី ដែលទៅពីស្រុកចិនក្រុងប៉េកាំង ចា៎! កូនប្រុសទាំងពីរនាក់ហ្នឹងគឺឈ្មោះ ឈីតៗ ហើយនឹង ទីនទូន។ ឈ្មោះគេហៅក្រៅហ្នឹង ចា៎! ហើយម្ដាយ កុមារហ្នឹងប្ដីគាត់ឈ្មោះ ង៉ោ ពិន ដែលគេធ្វើការនៅស្រុកចិនតំណាងខាងហ្ស៊ុងនោះ។ ម៉ុច ហ្នឹង គាត់យកកូនប្រុសពីរនាក់ហ្នឹងចូលស្រុកវិញមុនប្ដីគាត់ហើយ ឈីតៗ និង ទីនទូន ហ្នឹងគាត់ស្និទ្ធណាស់នៅដីហ្នឹង។គាត់លេងដីលេងអីអង្គុយដី។ គាត់ អង្គុយយ៉ាងស្និទ្ធ ហើយមានកុមារម្នាក់ហ្នឹង គាត់មិនសប្បាយចិត្តហ្នឹងយើង គាត់ស្ទុះ ទៅបោកក្បាលគាត់នៅសសរ។ រួចយើងខំស្ទុះទៅចាប់ ខ្លាចគាត់បែកក្បាល។ ខ្ញុំសួរថាដែលស្គាល់ទេកុមារហ្នឹង គាត់មកហ្នឹងម៉េចបានគាត់មានអាកប្បកិរិយាអីចឹង? ចង់តែធ្វើបាបខ្លួនឯង? រួចទៅបានម្នាក់នោះគេនិយាយថា «អាវេហា ហ្នឹងវាធ្វើតែ អីចឹង។ នៅស្រុកបារាំងម៉ែវាចេះតែ ចង់ដើរលេង

ម្តាយចង់ទៅណាអីចឹង អត់មានអ្នកណាមើល គាត់ចងកូននៅប្រឡាយខ្សែអីចឹង»។

ពាសី ៖ អាយុប៉ុន្មានៗ?

សារីម ៖ អាយុតូចណាស់បីឆ្នាំជាង បួនឆ្នាំអីចឹង ហើយកុមារហ្នឹងទៅវិញ គាត់ទៅតែជាមួយ ឪពុកទេ ចាំ! រួចទៅអ្នកម្តាយហ្នឹងអត់ទៅទេ។ ខ្ញុំសួរថា ម៉េចអត់ឃើញម្តាយមក? គេថាម្តាយហ្នឹងប្តីថាទៅស្រុកខ្មែរ គាត់ចេះតែទៅ ស្រាប់តែពេលឡើងកប៉ាល់ហោះ គាត់អត់ទៅ ដល់អីចឹងទៅ ទៅតែជាមួយកូន ឪពុករបស់កុមារ វោហា ហ្នឹងហើយទៅដល់ស្រុកខ្មែរវិញហ្នឹងចុះធ្វើការកាប់ស្មៅកាប់អីហ្នឹង។ ឃើញគាត់ស្លៀកពាក់ស្អាតបាតជានិច្ច រួចដល់កុមារខ្លះទៀតដែលគាត់ឃ្លានគាត់រត់លួចតែថ្នាំដុសធ្មេញទៅ ពិសា រួចខ្ញុំចង់ជម្រាបថា កុមារពីរនាក់ទៀតខ្ញុំឃើញដែលគេចេះប្រាប់ខ្ញុំថា កុមារសម្បូរអីហូបនៅជនបទ ប៉ុន្តែកុមារដែលទៅពីស្រុកបារាំងទៅ ខ្ញុំឃើញកុមារពីរ នាក់ទៀត។ ខ្ញុំស្គាល់ឪពុកកុមារហ្នឹង។ លោកហ្នឹងឈ្មោះលោក ឈឹម ហែប។ គាត់ធ្វើតំណាងរាស្ត្រសម័យសម្តេច ហើយគាត់មកស្រុកបារាំងគាត់ចូល ហ៊្មង ហើយលោក ឈឹម ហែប គាត់ចូលទៅស្រុកវិញហ្នឹង គាត់នាំប្រពន្ធ គាត់និងកូនពីរនាក់ទៅ។ កូនស្រីឈ្មោះ នោ កូនប្រុសឈ្មោះ កូ ធំអាយុ១០-១១ ឆ្នាំ។យើងទៅដល់ភ្លាមយើងឃើញ។ ខ្ញុំមិនដែលឃើញនៅស្រុកបារាំងទេ ប៉ុន្តែទៅដល់ស្រុកខ្មែរភ្លាម ខ្ញុំឃើញពីរនាក់ហ្នឹង នាង នោ និង កូ ហ្នឹង ឃើញ ស្អាតៗ ស្រាប់តែប៉ុន្មានខែក្រោយមកឡើងរួញដូចទៅមនុស្សតូច។ វាអត់អី ហូប។

ពាសី ៖ បាទ! ដូចដំបូងឃើញសាច់ឈាមល្អ។

សារីម ៖ ចាំ! ឃើញសាច់ឈាមថ្លាដូចមនុស្សជិតពេញក្រមុំអីចឹង។

ពាសី ៖ នៅក្នុងរបបខ្មែរក្រហម ខ្មែរក្រហមលើកតម្កើងកុមារដែរ ប៉ុន្តែចំពោះកុមារទៅពីបរទេសទៅអីចឹង គេមានធ្វើសកម្មភាពអីមានឱ្យរៀនសូត្រ ឬក៏ឃើញខុសពីមនុស្ស ធំទេ?

សារីម ៖ ចាំ! កុមារពេលដែលខ្ញុំនៅសាលាតិចណូហ្នឹង រឿងរៀនសូត្រខ្ញុំមិនបានចាំច្បាស់ទេ ប៉ុន្តែនៅតាលៃ ខ្ញុំឃើញថាមានបង្រៀនកុមារនៅក្រោមផ្ទះរាល់ពេលបាយថ្ងៃត្រង់រួច។ ហើយចំពោះកុមារខ្លះហ្នឹង គាត់អត់ចេះខ្មែរទេ ទៅពីស្រុក បារាំង អ្នកខ្លះធ្លាប់តែនិយាយបារាំងនោះ ប៉ុន្តែដល់ទៅដល់ទៅ គាត់ចេះតែខំប្រឹង។ ខ្ញុំឃើញថាកុមារហ្នឹងគាត់ខំប្រឹងហើយ ហើយគាត់ចេះពាក្យវប្បធម៌បដិវត្តន៍ហ្នឹងច្រើនផង។ ពេលខ្លះយើងឃើញគាត់ស្លៀកខោ។ អ្នកខ្លះពេលទាញខោគាត់ គាត់ថា «យី!ប្រយ័ត្នខុសសីលធម៌!»

រាសី ៖ បាទ! ក្មេងៗរៀនភាសាឆាប់ចេះណាស់?

សារីម ៖ ចាំ! ហើយកុមារីម្នាក់ទៀតហ្នឹង ម៉ែវាហៅ អាយោៗ។ គាត់ហ្នឹងម្ដាយ ស្ពាយឡើងកប៉ាល់ហោះពីស្រុកចិនទៅ។ កុមារីហ្នឹងមានបងពីរនាក់ទៀត។ បងប្រុសឈ្មោះ យី ហើយនឹងបងស្រី យើងហៅ អាយ៉ា ហើយអាយោ ហ្នឹង គាត់ អត់ចូលចិត្តខ្ញុំទេ ព្រោះខ្ញុំធ្លាប់ស្រែកឱ្យគាត់ម្ដងពេលគាត់លេងឃ្លី។ ហើយដល់ ពេលគាត់ឃើញមុខខ្ញុំ គាត់គេចមុខចេញហើយ ហើយខ្ញុំចេះតែខំលួងគាត់ឱ្យគាត់ទុកចិត្តខ្ញុំវិញ។ ហើយគាត់ចូលចិត្ត វណ្ណា ជាងខ្ញុំ ហើយកុមារទាំងបីនាក់ហ្នឹង អាយោ អាយី អាយ៉ា ហ្នឹង មានម្ដាយឈ្មោះ អ្នក លី មុនីវណ្ណា ហើយឪពុកគាត់ហ្នឹង ឈ្មោះ គារវីនណូ ជាស្ថាបត្យករ។ អ្នក លី មុនីវណ្ណា ហ្នឹងយកបីនាក់ ហ្នឹងទៅស្រុកវិញមុនប្ដីគាត់។ ហើយកុមារខ្លះសុំម្ដាយគាត់ថាឱ្យគាត់ទៅ ស្រុកបារាំងតែមួយភ្លែត គាត់សុំទៅយកតែស្ករគ្រាប់ហើយគាត់មកវិញហើយ។ ហើយបង អំ ដែលធ្លាប់ជាឈ្នួលរបស់លោក ផាន់ ប៊ុយហាក់ ហ្នឹង គាត់មិនចូលចិត្តមើលកុមារទេ ហើយគាត់ចេះតែថា គាត់សុខចិត្តទៅកាប់ដី ដាំដំឡូងវិញ។ គាត់ថា ពួកកុមារអស់នេះមិនមែនជាកូនវណ្ណៈអធនទេ គឺជាកូនពួកចក្រពត្តិ ហើយខ្ញុំសុំធ្វើការ កែតម្រូវក្នុងការផ្សាយភាគនេះ អំពីលោក ផាន់ ប៊ុយហាក់ កាលពីភាគទី១១ នោះ គាត់មិនធ្លាប់ជានាយកសាលាច្បាប់ទេ។ គាត់ធ្លាប់ជានាយកមហាវិទ្យាល័យ វិទ្យាសាស្ត្រ ចាំ!

ពាសី ៖ ខ្ញុំចង់សួរអ្នកស្រីថា អ្នកស្រីបាននិយាយថាការរៀបចំហូបចុកជាមួយគ្នា គេចែកបាយទឹកអីចឹង ហូបរួមហើយពេលហ្នឹងសម្រាប់អ្នកដែលត្រឡប់ទៅវិញ ពេលហ្នឹង?

សារីម ៖ ចាំសៗ! ពេលហ្នឹងយើងដាំបាយខ្ទះត្នោតដូចខ្ញុំជម្រាបអីចឹងលាយអង្ករចេក ដល់ក្រោយមកយើងលែងមានបាយហើយ យើងបបរ ចាំ! បបរហ្នឹងលាយត្រកួនលាយអីចឹងទៅ ហើយដាក់មកភាវៗ។

ពាសី ៖ បើតាមខ្ញុំចាំ កាលហ្នឹងនៅតាមតំបន់ជនបទដែលប្រជាពលរដ្ឋគេជម្លៀសទៅហ្នឹង គេបាយរួមហ្នឹងដល់ឆ្នាំ៧៧ទេបានចាប់ផ្តើម ប៉ុន្តែសម្រាប់ក្រុមអ្នកស្រីដែលត្រឡប់មកពីបារាំងវិញ គេៗចាប់ផ្តើមមុនហ្នឹងទៅទៀត?

សារីម ៖ ចាំ! យើងទៅ យើងអត់មានអង្ករដាំបាយៗ យើងមានថ្នាំពេទ្យយកទៅច្រើនអីចឹងមែន ប៉ុន្តែពេលទៅដល់នោះរឿងទទួលទានហ្នឹង គេឱ្យយើងទទួលទានជាក្រុម ហ្នឹងយើងដាំទៅ ហើយយើងចែកគ្នា ហើយគេយកអង្ករហ្នឹងមកឱ្យយើង។

ពាសី ៖ ហើយនិយាយអីចឹង អ្នកស្រីមានប្រសាសន៍អំពីថ្នាំពេទ្យអីយកទៅហ្នឹង គេឱ្យយើង ប្រើដែរ ឬក៏គេតម្រូវឱ្យចែកគ្នាយ៉ាងម៉េច?

សារីម ៖ ចាំ! យើងទៅដល់ហ្នឹង ដល់ខ្ញុំជម្រាបថា ដល់យើងរៀនជីវទស្សន៍បដិវត្តន៍អី រួចហើយហ្នឹង គេយល់ថាយើងហ្នឹងដឹងហើយ ដឹងរឿងថានៅក្នុងរបបគេហ្នឹង គេធ្វើយ៉ាងម៉េច គេខំតែកសាងយើងហ្នឹងឱ្យខំជម្រុះកម្មសិទ្ធិ ហើយយើងទៅដំបូងហ្នឹងយើងមិនទាន់ស្គាល់ពាក្យទេ ឱ្យជម្រុះកម្មសិទ្ធិ។ យើងដឹងហើយកម្មសិទ្ធិ ប៉ុន្តែគេឱ្យ ជម្រុះកម្មសិទ្ធិ ជម្រុះតាំងពីកម្មសិទ្ធិដែលមើលឃើញហ្នឹងដូចជា ថ្នាំពេទ្យ ខោអាវដែលយើងយកទៅហ្នឹង គេថាកម្មសិទ្ធិស្រាលកាលណាកសាងខ្លួនឆាប់បានកាលហ្នឹង ហើយដល់រួចទៅយើងក៏ជម្រុះហើយ យើងតែគេកសាងយើងម្តងៗឡើង គេអង្គប្រជុំម្តងឡើងគេនិយាយរឿងជម្រុះហ្នឹង យើងហ្នឹងដឹងខ្លួនហើយថាយើងត្រូវតែជម្រុះឱ្យវាត្រូវទៅតាមដែលថាគោលដែលគេដៅមកហ្នឹង

ណា។ បើយើងមិនជម្រុះ សោះហ្នឹងគេថាយើងហ្នឹងកម្មសិទ្ធិក្រាស់ ហើយបើនរណាឆាប់ខឹងគេកសាង។ គេកសាងខ្ញុំខ្លាំងណាស់ថាខ្ញុំហ្នឹងបុគ្គលក្រាស់ ហើយពាក្យ«បុគ្គល» ខ្ញុំថា យី! «បុគ្គល»គេច្រើននិយាយឱ្យពួកខ្មោចងាប់តើ។ គេថាបុគ្គលនៅលើផ្ទះដូចថាខ្មោច មិនទាន់យកចេញ ប៉ុននេះម៉េចថាបុគ្គលអីចឹង? គេថាខ្ញុំហ្នឹង«បុគ្គលក្រាស់»មានន័យថា គេពន្យល់ខ្ញុំហ្នឹងគេនិយាយអីមកអត់ចេះដូចថានៅក្រោមគេទេ ដឹងតែថាគេនិយាយអ្វី មកទើស ឆ្លើយហ្មង ហើយពេលគេកសាងយើងគេមិនឱ្យឆ្លើយទេ។ ប៉ុន្តែខ្ញុំពេលខ្លះអត់ចេះទ្រាំ។ ពេលខ្លះខ្ញុំឆ្លើយហើយ អីចឹងគេថាខ្ញុំបុគ្គលក្រាស់ណាស់។

រាសី ៖ ហើយដែលគេថាធ្វើមីទ្ទិងហ្នឹង ដើម្បីនិយាយរឿងជម្រុះហ្នឹង តើបានន័យថានៅទីបំផុតយើងយកអីវ៉ាន់ហ្នឹងទៅប្រគល់ឱ្យគេ ថ្នាំពេទ្យរបស់របរយើងយកទៅហ្នឹង?

សារីម ៖ ចាំ! យើងឱ្យខាងប្រធានក្រុមពួកយើងហ្នឹងទៅ។

រាសី ៖ អីចឹងគេអត់មានថាមកយកពីយើងទេ ដល់គេធ្វើឱ្យយើងយកទៅឱ្យដោយស្ម័គ្រចិត្ត?

សារីម ៖ ចាំ! គេអត់មានកកាយហិបយើងអីទេចាំ! គេឱ្យយើងជម្រុះបានន័យថាយើងស្ម័គ្រចិត្តយកទៅឱ្យទៅប្រធានទៅក្នុងមន្ទីរហ្នឹង។

រាសី ៖ ហើយមានអ្នកណាដែលមិនយកឱ្យគេដែរ?

សារីម ៖ ហូ! តាមខ្ញុំមើលទៅហ្នឹង វ៉ាលីសធំៗ ដល់ក្រោយមកនៅត្រឹមស្បោងនៅសល់សន្ទូច មួយ ចាំ! ហើយយើងក៏ស្តាយវាមិនរួចដែរ ព្រោះវាអីវ៉ាន់ច្រើននោះចាំ!

រាសី ៖ បាទ! ហើយដល់ពេលយកទៅហ្នឹង គេយកទៅធ្វើម៉េចដែរចែកគ្នាឬ?

សារីម ៖ ខ្ញុំអត់ដឹងគេយកទៅណាទេ ប៉ុន្តែគេថាឱ្យយើងជម្រុះ យើងជម្រុះទៅ។ យើងអត់ទៅ តាមដានអត់ដឹងថាគេធ្វើយ៉ាងម៉េចទេ ចាំ!

រាសី ៖ ហើយចុះអីចឹងបើថ្នាំពេទ្យអីរបស់របរអីយកទៅឱ្យគេអីចឹង ហើយចុះដល់ពេលមាន ឈឺម្តងម្កាលអីចឹងអ្នកស្រីបានថ្នាំអីទទួលទាន?

សារីមៃ ៖ យើងមិនមែនជម្រុះឱ្យគេទាល់អស់ទេចាំ! យើងមើលបើរបស់ណាដែលថាខ្លួនយើង ត្រូវការ ហើយដូចខ្ញុំអីចឹង ខ្ញុំជម្រុះឱ្យថ្នាំកូនក្មេងដែលខ្ញុំទិញទៅ ថ្នាំវីតាមីន ថ្នាំគ្រុនចាញ់អី របស់អី កាំបិតអី ខ្ញុំទិញទៅសន្ទូចអីទៅ ខ្ញុំជម្រុះ ប៉ុន្តែខ្ញុំទុកខ្លះ ខ្ញុំទុកថ្ម ដែកកេះអីចឹង ថ្មដែកកេះឡើងរាប់ពាន់គ្រាប់ខ្ញុំទុកប្រហែលថា២០០គ្រាប់អីចឹងទៅ។

រាសី ៖ បាទ! ហើយចុះសម្លៀកបំពាក់វិញតើយើង...?

សារីមៃ ៖ ចាំ! សម្លៀកបំពាក់ហ្នឹងខ្ញុំជម្រុះឱ្យទាល់តែអស់ ខ្ញុំទុកពិសេសទុកតែអាវទ្រនាប់ទេ។

រាសី ៖ ហើយអីចឹងគេតម្រូវឱ្យស្លៀកខ្មៅដូចគេដែរ ឬក៏យ៉ាងម៉េច?

សារីមៃ ៖ ចាំ! គេឱ្យយើងស្លៀកខ្មៅ ខោអាវយើងយកទៅហ្នឹងស្លៀកយូរទៅវាកខ្វក់អស់ហើយ។ វាទៅដូចកំប្លូកមើលមិនយល់ទេ ចាំ!

រាសី ៖ ដូច្នេះមិនមែន មិនចាំបាច់យកទៅជ្រលក់ខ្មៅអីទេ?

សារីមៃ ៖ ចាំ! វាគ្មានអ្វីជ្រលក់ផង។

រាសី ៖ បាទ! អ្នកស្រីនៅសាលាតិចណូហ្នឹងរយៈពេលប៉ុន្មានខែដែរ?

សារីមៃ ៖ ចាំ! ខ្ញុំនៅតាំងពីខែមួយដែលយើងទៅដល់រហូតដល់យើងធ្វើបុណ្យ១៧ មេសាម្តងនៅហ្នឹង គេធ្វើបុណ្យហ្នឹងគេធ្វើពេលបុណ្យចូលឆ្នាំ ហើយថ្ងៃ១៧មេសា ហ្នឹង...

រាសី ៖ ឈប់ដូចគ្នា?

សារីមៃ ៖ ចាំ! គេឱ្យឈប់៣-៤ថ្ងៃអីចឹងទៅហើយគេមានរបបបបរស្ករឱ្យយើងម្តង ហើយម្ហូបហ្នឹងក៏មានបាយគ្រាន់បើជាងមុន។ គេមានលេងរបាំកុមារឡើង សម្តែងសម្តែងពីវីរភាពរបស់ ណុប បូផាន់។ ខ្ញុំមិនដែលឮស្ទូរឈ្មោះ ណុប បូផាន់។

រាសី ៖ អ្នកណាគេ?

សារីមៈ ចាំ! ខ្ញុំអត់ស្គាល់ គេចេះតែច្រៀង ឱ! ណុប បូផាន់ អើយៗ។ ខ្ញុំចេះតែស្តាប់ ទៅ ហើយគេនិយាយពាក្យថាពួកទាហានហ្នឹងបានសម្លាប់ពួកតស៊ូហ្នឹង ខ្លះយកចំពុះទង់។ កូនបដិវត្តន៍អីហូរហៃអីចឹងទៅ ចាំ! ពេលហ្នឹងមានម្នាក់ឈ្មោះអ្នក វណ្ណា ហ្នឹងគាត់ទើបទៅដល់ ទៅតាមប្តីគាត់ឈ្មោះលោក គង់ បុណសិរី។ ហើយ លោក គង់ បុណសិរី ហ្នឹងគាត់ជាពួកម៉ាកប្តីខ្ញុំ ហើយអ្នក វណ្ណា ហ្នឹងគាត់នាំកូន ប្រុសគាត់ម្នាក់ទៅជាមួយហ្នឹងឈ្មោះ ណេ ហ្នឹង។ ពេលមើលសិល្បៈហ្នឹងថ្ងៃ១៧ មេសា ហ្នឹងគាត់ចេះថា យី! ខ្ញុំធ្លាប់មើល Opera រួចខ្ញុំមកមើលអីចឹង។ ហើយទៅ គាត់អង្គុយជិតខ្ញុំគាត់និយាយអីចឹង។ ខ្ញុំចេះតែកេះគាត់ថា គេសម្តែងឱ្យមើលចេះតែមើលទៅ ហើយអ្នកសម្តែងពេលហ្នឹងមានកុមារម្នាក់ហ្នឹងគាត់ជាកូនរបស់លោកម្នាក់ឈ្មោះលោក ហោ ហ្នឹងគាត់ធ្វើដូចខាងកសិកម្ម ហើយប្រពន្ធគាត់ឈ្មោះ សុផុន អ្នក សុផុន ហ្នឹងជាប្អូនរបស់លោក អ៊ិន សុកាន។ គេទៅ គេនាំកូន ថៅគេទៅ ហើយកុមារហ្នឹងគាត់ឡើងសូត្រកំណាព្យពីបេះដូងក្រហមៗ។ ខ្ញុំថ្នាក់ ខ្ញុំថ្នមថៃទាំរាល់ថ្ងៃ បម្រើបដិវត្តន៍អីហូរហៃអីចឹងទៅ។ អ្នក វណ្ណា ហ្នឹងគាត់ជាប្អូនថ្លៃអ្នកមានម្នាក់នៅស្រុកខ្មែរពីដើមម្នាក់គាត់ពូកែរកស៊ីឈ្មោះលោក ទេព ភុនណា នុះចាំ! ទេព ភុនណា ហ្នឹងគាត់បានបើកហាងបាយលក់នៅក្នុងស្រុកបារាំងដែរ។ ខ្ញុំសួរលោក វណ្ណា ប្រពន្ធលោក គង់ បុណសិរី ហ្នឹងថា ម៉េចបានមកស្រុកវិញ បើមានប្តីហើយកូននៅជុំគ្នា ហើយគាត់ថាប្តីគាត់ហ្នឹងលោក គង់ បុណសិរី ចេះតែយំព្រោះរឭកស្រុក រឭកបងប្អូន ហើយម៉្យាងទៀតហ្នឹងខ្លួនគាត់ហ្នឹងក៏មិន សប្បាយនឹងរស់នៅស្រុកបារាំងដែរ ពីព្រោះថា គាត់ខ្មាសគេដោយសារក្នុង គ្រួសារគាត់មានបងប្អូនស្រីគាត់ហ្នឹងយកប្តីជាមួយគ្នា ហើយពេលបុណ្យអត់មាន ធ្វើការទេតែមានមីទ្និងច្រើន ហើយមេខ្មែរក្រហមដែលគេមកចូលរួមក្នុងមីទ្និងហ្នឹង គេថាបដិវត្តន៍របស់ខ្មែរក្រហមគេហ្នឹងទូលំទូលាយណាស់។ ស្តេចក៏រស់នៅបានដែរជាមួយបដិវត្តន៍ហ្នឹង ហើយគេថាសម្តេចឪឥឡូវហ្នឹងលោកកំពុងតែសោយរាជ្យនៅក្នុងវាំង។ លោករស់នៅក្នុងវាំង ហើយលោកមានផ្កៃលោកបណ្តើរដើរលេងក្នុងវាំងទៀតផង ហើយខ្មែរក្រហមគេថាគេចិត្តល្អ គេបានឱ្យអង្ករទៅឱ្យពួកលាវ

ដែលសុំអង្ករគេ។ ពេលចូលឆ្នាំគេថាបើប្រទេសជិតខាងគេសុំហើយបើយើងមិនឱ្យ ដូចជា មិនសមរម្យ។

ពាសី ៖ ហើយៗដល់ខែណាបានគេឱ្យចេញពីសាលាតិចណូ?

សារីម ៖ ខ្ញុំចាំគឺចូលឆ្នាំខ្មែរហើយហ្នឹងបុណ្យ១៧មេសា ហើយហ្នឹងគេត្រៀមយើងឱ្យចេញហើយ ចេញពីសាលាតិចណូ។ ខ្ញុំដូចចាំខ្ញុំចេញទៅហ្នឹងប្រហែលខែ៥។

ពាសី ៖ ពេលហ្នឹងៗគេសម្រេចថាម៉េចបានឱ្យចេញ គេថាយើងបានសិក្សាគ្រប់គ្រាន់ហើយ។

សារីម ៖ ចា៎! គេពីព្រោះតាមខ្ញុំមើលគឺទុកនៅហ្នឹងច្រើនពេកពីព្រោះដូចថាមនុស្សចេះតែទៅបន្តៗ។ រួចខ្ញុំហ្នឹងដូច្នេះអ្នកណាទៅមុនហ្នឹង គេបញ្ចេញយើងទៅក្រៅមុនគេ។

ពាសី ៖ ហើយអ្នកដែលមកក្រោយៗអ្នកស្រីហ្នឹង ច្រើនអ្នកស្រុកបារាំងដែរ ឬមកពីខាងណា?

សារីម ៖ យើងអត់ស្គាល់ទេ ប៉ុន្តែមកក្រោយខ្ញុំហ្នឹងកាលហ្នឹងខ្ញុំចាំ មានលោកចាងហ្វាង សាលា Lycee d'applicationដែលខ្ញុំបង្រៀន។ គាត់ធ្លាប់ធ្វើចាងហ្វាងខ្ញុំ។ ស្រាប់តែខ្ញុំឃើញទៅវិញហ្នឹង ខ្ញុំអត់ដឹងថាគាត់មកស្រុកបារាំង ឬស្រុកណាទេ ប៉ុន្តែ ដល់ឃើញគាត់ទៅ ខ្ញុំក៏ទៅសួរគាត់ លោកហ្នឹងឈ្មោះលោក ប៊ីបឿន។ គាត់ថា របៀបគាត់របៀបតាមខ្ញុំមើលបែបធ្វើការខាងលន់ នល់ ហើយគេឱ្យចេញទៅ តំណាងនៅបរទេសអីចឹងណា។ ខ្ញុំពេលហ្នឹងខ្ញុំមិនសួរដេញដោលអីទេ ស្រាប់ឃើញ គាត់ត្រឡប់ទៅវិញហ្នឹង ហើយមានប្រពន្ធគាត់ទៅ។ ខ្ញុំចេះសួរលោកម៉េចបាន មកវិញ? គាត់ថាប្រពន្ធគាត់អត់ចេះនៅស្រុកគេ។

ពាសី ៖ បាទ! ហើយអីចឹងអ្នកដែលមកថ្មីក្រោយអ្នកស្រីហ្នឹង យើងអាចទៅនិយាយទាក់ទងជាមួយគេបានទេ?

សារីម ៖ ចា៎! យើងឃើញៗគេមកអីចឹង យើងឃើញគេអ៊ូរអែៗ។ លោកហ្នឹងគាត់កំពុងរើអីវ៉ាន់ ទៅឃើញពួកខ្មែរក្រហមគេមកមើលអីវ៉ាន់គាត់។ គាត់ថាអានេះកម្រាល

ពួកខ្ញុំទេ ហើយខ្ញុំពេលហ្នឹងខ្ញុំចេះតែខំខាំមាត់ញញឹមថា ហ៊ឺស! មិនស្រួលឥឡូវហើយ។

រាសី ៖ ដូចថាអ្នកស្រីធ្លាប់ឆ្លងកាត់ហើយ គាត់ទើបមកដល់មិនទាន់ដឹង?

សារីម ៖ ចាំ!

រាសី ៖ ប៉ុន្តែអ្នកមានៗឃើញដូចថានឹកថាដូចកាលអ្នកស្រីទើបអញ្ជើញមកដល់ស្រុកខ្មែរវិញ ហ្នឹង គេមកសួរភ្លាមថាមានយកនំប៉ាវមានយកអីមកទេ អ្នកស្រីមាននឹកឃ្លានម្ហូប អីចឹងដែរ សួរគេចឹងដែរ?

សារីម ៖ ខ្ញុំជម្រាបត្រង់ដូចមានកុសលម៉្យាង ខ្ញុំឃ្លានហើយ ប៉ុន្តែដូចថាខ្ញុំមិនសម្តែងណាព្រោះខ្ញុំដូចអ្នកថៃណា អ្នកថៃ សួររកនំប៉ាវពេលខ្ញុំទៅដល់។ គាត់ក្រោយមកគេប្រាប់ខ្ញុំថា គាត់ទៅសួរប្រុសម្នាក់ទៀតដែលទើបទៅដល់។ គាត់សួរគេថាមានយក សូស៊ីសុងមកទេ? សូស៊ីសុងជាសាច់ក្រកធំៗ ហើយអ្នកនៅជុំវិញគាត់ហ្នឹងគេនាំគ្នាសើច។

រាសី ៖ ហើយនៅពេលចាកចេញទៅហ្នឹង តើអ្នកស្រីក្នុង ខ្លួនមានអារម្មណ៍អាឡោះអាល័យអ្វីដែរចំពោះការរស់នៅសាលាតិចណូរយៈពេល ប៉ុន្មានខែហ្នឹង?

សារីម ៖ ចាំ! ខ្ញុំមានការសប្បាយចិត្តហ្នឹងមនុស្សដែលដូចថាចេះជួយខ្ញុំ ចាំ! ហើយខ្ញុំសុំបញ្ជាក់ពីទិដ្ឋភាពចុងក្រោយនៅសាលាតិចណូហ្នឹង ពិសេសពេលមុនចេញហ្នឹងស្រាប់តែខ្ញុំធ្លាក់ខ្លួនឈឺ ខ្ញុំឈឺ-ក ខ្លាំងមែនទែន ហើយខ្ញុំគ្រុន ហើយមានលោកម្នាក់ហ្នឹង ត្រឡប់ទៅវិញគាត់ធ្វើពេទ្យ គាត់មកមើលខ្ញុំ ហើយគាត់ប្រាប់ខ្ញុំថាខ្ញុំរលាក-កខ្លាំង ហើយអីចឹងមានលោកម្នាក់ឈ្មោះលោក ឡាច វីរផុន ហ្នឹងគាត់ជាពួកម៉ាករបស់បងប្រុសខ្ញុំ។ គាត់ជាគ្រូបង្រៀន គាត់យកថ្នាំប៉េនីស៊ីលីនហ្នឹងមកឱ្យខ្ញុំប្រើទទួលទានទៅឱ្យ សះរលាកបំពង់ក ហើយលោកគ្រូពេទ្យហ្នឹងគាត់ថាបើមានថ្នាំខ្ពុលមាត់អីហ្នឹង ខំខ្ពុល មាត់ឱ្យមែនទែន ដើម្បីសម្លាប់មេរោគកុំឱ្យវាចូលទៅធ្វើឱ្យរលាក-ក។ ទិដ្ឋភាពមួយ ទៀតនោះ អ្នកដែលនៅចូលចិត្តពិសាបារីនោះ។ គាត់អស់បារីហើយ គាត់ញាណ ខ្លាំងពេកគឺ មានលោកម្នាក់ហ្នឹងឈ្មោះ

លោក ហុង ស៊ីផា។ គាត់រែកតែស្មៅដើម្បីរកកន្ទុយបារីដែលគេបោះចោលនោះ។ ពួកខ្ញុំស្រីៗហ្នឹងឃើញគាត់ធ្វើអីចឹង ខ្ញុំចេះតែថាគាត់ហ្នឹងតាមចាប់កង្កែបហើយ ហើយលោក ស៊ីផា ហ្នឹងថា ហ្នឹងហើយ ម្តាយខ្ញុំប្រាប់ថាឱ្យរៀនពេទ្យទៅ បាន លុយមកត្រជាក់ត្រជុំ។ ហើយលោក ស៊ីផាថា ត្រឡប់មកស្រុកវិញដើម្បីជួយធ្វើ ពេទ្យមើលអ្នកស្រុក តែឥឡូវហ្នឹង គាត់សូម្បីកន្ទុយបារីហ្នឹងក៏គាត់រែកស្មៅរើស ដែរ។ អាហ្នឹងហើយដូចថាជាសំណើចចម្អក ព្រហ្មលិខិតមួយអីចឹង ហើយ ពិសេសទៅទៀតទិដ្ឋភាពមួយទៀតដែលអ្នក ម៉ុច ឬ នរោត្តម រ៉ាវត្តី ដែលគាត់ ត្រឡប់ទៅវិញហ្នឹង ម៉ែ ឈីតៗ ហើយនឹង ទីនទូន ហ្នឹង គាត់ស្មុគស្មាញព្រោះគាត់ នៅស្រុកចិនគាត់ធ្លាប់ឃើញទស្សនាវដ្តីកម្ពុជាហ្នឹង មានរូបថត ផ្លែឈើ ដុះ ននៀលដី ផ្លែខ្នុរសឹងផុសចេញពីដី ហើយផ្លែល្ពៅ ផ្លែ ត្រឡាចយ៉ាងធំៗ ហើយត្រី ក៏សម្បូរ ហើយដល់គាត់មកឃើញថាយើងអត់មាន អីហូបនៅសាលាតិចណូរូស្ស៊ី ហ្នឹង គាត់ស្មុគស្មាញ គាត់យំ។ គាត់ចោមពង់តែសំពត់ខ្មៅគាត់ហើយពេលហ្នុង ខែចែត្រវាក្តៅ ហើយគាត់ថា គាត់មិនចង់រស់ទេ គាត់ចង់សម្លាប់ខ្លួន ហើយ អ្នកម៉ូណាដែលជាប្រធានក្រុមរបស់ពួកខ្ញុំហ្នឹង គាត់ដូច អៀនខ្លួនជួសអ្នក ម៉ុច។ គាត់ខំតែរត់តាមនិយាយធ្វើសតិអារម្មណ៍អ្នក ម៉ុច ហ្នឹង។ ពាក្យចចាមអារ៉ាមថា គាត់ហ្នឹងមកស្រុកហ្នឹងគាត់ទម្ងន់ផង ហើយពួកខ្ញុំឮសួរ ថាគាត់ទម្ងន់អីចឹងដូចថា មានចិត្តអាណិតគាត់ណាស់ ព្រោះមនុស្សយើងមានផ្ទៃពោះ ចង់ដូចមាយាអីចឹង ចង់ហូបអី ចង់បានទទួលទានឱ្យបានភ្លាមៗ ហើយខ្មែរក្រហម ដែលគេមកធ្វើ ការសតិអារម្មណ៍មុនយើងចេញទៅហ្នឹង គេថា«ហ៊ឺ! ទៅជឿអីរូបថត។ គេចង់ ពង្រីករបស់ហ្នឹងតែប៉ុណ្ណាក៏បានដែរ»។ពេលមុនបុណ្យចូលឆ្នាំខ្មែរហ្នឹង ខ្មែរក្រហម គេមិនសប្បាយទេ អ្នកណាមានថ្នាំអត់កូនហ្នឹង។ គេឱ្យជម្រុះឱ្យគេទាល់ អស់ ហ្នឹង។ មានអ្នកម្នាក់ហ្នឹងឈ្មោះម៉ែអា ទី ឃើញគាត់ហ្នឹងប្លែកណាស់។ ខ្ញុំសួរគាត់ ថា «អ្នកឯងម៉េចអីចឹងដូចស្លាំងៗ?» ហើយគាត់ប្រាប់ខ្ញុំថា គាត់ទម្ងន់ រួចខ្ញុំ រឹត ទ្រូង។ «ហើយម៉េចបានឱ្យទម្ងន់អីចឹង?» ហើយគាត់ថាមកពីយប់អាបបរ ស្ករហ្នឹង ឯង គាត់មិនស្មានថាអីចឹង។ ក្រោយមកឮសួរគេថាគាត់ហ្នឹងដើរខ្វេះស្បោងគេ

លួចអីៗពិសា ហើយម៉ែអាទីហ្នឹងគាត់ប្រាប់ខ្ញុំថាកាលគាត់នៅស្រុកបារាំងហ្នឹង ឱ្យតែអ្នកណាយកកូនក្មេងផ្ញើគាត់ឱ្យមើល ឱ្យតែយំច្រើនពេកហ្នឹងគាត់ឱ្យថ្នាំហ្សេណោហ្កង់ ផឹកឱ្យដេកលក់ហើយ។ រួចខ្ញុំសួរគាត់ថា «ចុះអ្នកឯងដល់មានកូនទៅមានយកថ្នាំហ្សេណោហ្កង់មកទេ?»។ សូមជម្រាបថា ពួកខ្មែរក្រហមដែលគេមកធ្វើការងារសតិអារម្មណ៍យើងហ្នឹង គឺគេមកណែនាំយើងឱ្យយល់ និងឱ្យចេះកម្ចាត់សត្រូវឱ្យដល់ផ្ទៃ ក្នុងៗហ្នឹងគឺចិត្តលោភលន់របស់យើងដែលថាមនុស្សយើងតែងមានតណ្ហានោះចាំ! ហើយគេខំឱ្យយើងចេះកម្ចាត់សួនតួ បានន័យថាកុំយកផ្អែតតែម្នាក់ឯងឱ្យគិតគូរដល់ អ្នកដទៃ ហើយគេខំប្រាប់យើងថា «នែ៎! កង់ប្រវត្តិសាស្ត្រហ្នឹងវិលទៅមុខហើយ ដូច្នេះយើងត្រូវតែធ្វើយ៉ាងម៉េចវិលទៅតាមកង់ប្រវត្តិសាស្ត្រហ្នឹងឱ្យទាន់ធ្លាក់មកហ្នឹង។ កង់ប្រវត្តិសាស្ត្រហ្នឹងវាកិនយើង ចំដៃគឺកិនដៃ ចំជើងគឺកិនជើង»។ កាលណាមុនពេលយើងចេញទៅណាម្តងៗហ្នឹង គឺគេខំពន្យល់យើងឱ្យជម្រុះអីវ៉ាន់គ្រប់យ៉ាង ហើយដូច្នេះ គេសម្រុកឱ្យយើងជម្រុះគ្រឿងអលង្ការ ហើយនឹងរបស់អ្វីដែលមាន តម្លៃនោះ ប៉ុន្តែខ្ញុំអត់បានជម្រុះគ្រឿងអលង្ការអីទេ។ ខ្ញុំមានបន្តិចបន្តួចយកជាប់ទៅ ខ្លួន ដល់ពេលប្រជុំពួក ប្រធានពួករបស់ខ្ញុំហ្នឹងគឺ អ្នកអេត ដែលថា ម៉ែ អារ៉ា ហ្នឹង គាត់លើកឡើងពីគ្រឿងអលង្ការចាំ! រួចខ្ញុំក៏កសាង អ្នក អេត ហ្នឹង ព្រោះគាត់ថា គ្រឿងអលង្ការហ្នឹងអត់មានតម្លៃអីទេ។ រួចខ្ញុំកសាងគាត់ថា គ្រឿងអលង្ការនៅតែមានតម្លៃអីចឹង អត់តម្លៃតែពេលក្នុងសង្គមដែលមិនប្រើទេ ហើយនៅសង្គមគេឯទៀតៗដែលគេប្រើគ្រឿងអលង្ការ បើយើងមិនប្រើអង្គការអាចយកគ្រឿង អលង្ការហ្នឹងដែលយើងជម្រុះឱ្យហ្នឹងទៅលក់ឱ្យបរទេសទៅ ប្រហែលជាបាន ប្រាក់មកសម្រាប់ទិញត្រាក់ទ័រអីធ្វូរកម្លាំងយើងខ្លះ។ ហើយមានលោកម្នាក់ ទៀតហ្នឹងឈ្មោះលោកសុខា។ គាត់ធ្វើទាហាន។ គាត់ថាបើកឡានស្ទើរពេញស្រុក អាមេរិកអស់ហើយតែគាត់នៅស្រុកអាមេរិកមិនកើត។ គាត់ត្រឡប់ទៅស្រុកវិញ គាត់អួតអាងថាគាត់ចេះធ្វើការស្រែចម្ការហ្នឹងគ្រប់បែប ហើយរាល់យប់ហ្នឹងឮសួរ គាត់និយាយរិះគន់ពួកដូចថាឱកាសនិយម ពួកអ្នកអែបអបនៅក្នុងគ្រប់របប នយោបាយទាំងអស់

ហើយដល់ពេលទៅតាលៃហ្នឹង យើងអត់ឃើញគាត់ហ្នឹងទៅតាលៃជាមួយពួក យើងទេ។ ហើយពេលមុនចេញទៅសាលាតិចណូហ្នឹង ខ្ញុំឮ សួរគេថា អ្នកដែល ចេញពីទីក្រុងភ្នំពេញទៅភូមិខ្ញុំនៅកៀនស្វាយហ្នឹង គេជម្លៀស ម្តងទៀតចេញ តាមកប៉ាល់ចាំ! សូមជម្រាបថា នារីខ្មែរក្រហមដែលគេដើរចុះដើរ ឡើងមកមើល ពេលយើងទៅដល់អីហ្នឹង ឃើញយើងជម្រាបសួរគ្នាអី គេកេះគ្នា មើល។ គេសួរ គ្នាគេថា ពួកហ្នឹងធ្វើអី? ពួកនារីខ្មែរក្រហមហ្នឹងគេអត់ចេះជម្រាប សួរទេ។ គេចេះ តែចាប់ដៃគ្នាដូចយើងពួកបារាំងអីចឹង។ បើជួបគ្នាគេចាប់ដៃគ្នា ពេលយើងចេញពី សាលាតិចណូហ្នឹងយើងលាដើមក្ងោកមួយដើម ដែលនៅជាប់ បង្អួចបន្ទប់យើង ហ្នឹងមានផ្កាក្រហមឆ្អិនឆ្អៅចាំ!។

រាសី ៖ ក្រោយពីបានស្ថិតនៅសាលាតិចណូអស់មួយរយៈមកហ្នឹង តើគេឱ្យអ្នកស្រីចេញ ទៅទីណាវិញបាទ?

សារីម ៖ ចាំ! ក្រោយពីសាលាតិចណូហ្នឹងនៅខែ៥ គេឱ្យពួកខ្ញុំចេញទៅភូមិមួយហ្នឹង ឈ្មោះ ភូមិតាលៃ ចាំ! ភូមិតាលៃហ្នឹងនៅជិតភ្នំពេញដែរនៅជិតរោងចក្រកែវ និង នៅជិត កន្លែងតឡូវហ្នឹងគេហៅជើងឯកហ្នឹង ចាំ!។

រាសី ៖ បាទ! តើអ្នកស្រីមាននៅចាំថ្ងៃចេញដំណើរពីសាលាតិចណូទេ?

សារីម ៖ ចាំ! ពេលហ្នឹងគេយកឡានមកដឹកពួកយើងចេញទៅ ហើយខ្ញុំចាំថាដូចគេបើក ទៅម្តុំខាងស្ទឹងជ័យ រួចទៅខ្ញុំលែងចាំហើយ ខ្ញុំមិនសូវស្គាល់ភូមិហ្នឹង។ អីចឹងយើង ទៅដល់ភូមិហ្នឹង។

រាសី ៖ ប៉ុន្តែគេមានជូនដំណឹងយើងមុនទេ យើងអាចរៀបចំអីវ៉ាន់ភ្លាមៗ?

សារីម ៖ ចាំ! គេប្រាប់យើងថារៀបចំចេញ ចាំ! ដូចខ្ញុំជម្រាបលើកមុនអីចឹង មុននឹង ចេញ ពីសាលាតិចណូរូស្ស៊ីហ្នឹង គេធ្វើការងារសតិអារម្មណ៍ថាឱ្យយើងជម្រុះអីវ៉ាន់។

រាសី ៖ បាទ! អីចឹងបានន័យថា យើងដឹងខ្លួនថា យើងទៅហ្នឹងអត់ត្រឡប់មកតិចណូវិញ ហើយ បន្តដំណើរទៅមុខទៀតហើយ?

សារីម ៖ ចាំ! យើងមិនដឹងថាយើងត្រឡប់មក មិនត្រឡប់ទេ ប៉ុន្តែយើងថាទៅ។ ពេល គេឱ្យយើងចេញទៅកន្លែងនោះចាំ!

ពាសី ៖ បាទ! ហើយនៅពេលថ្ងៃចេញដំណើរពីសាលាតិចណូ តើអ្នកស្រីក្នុងខ្លួនមានអារម្មណ៍ អាឡោះអាល័យអីដែរនៅចំពោះការរស់នៅសាលាតិចណូរយៈពេលប៉ុន្មានខែហ្នឹង?

សារីម ៖ ចាំ! ខ្ញុំនៅអាល័យផ្កាក្រោកក្រហមនៅមាត់បង្អួចខ្ញុំហ្នឹងទោះជាសម្រស់វាពេលខ្លះល្អក់ដោយសារមានកុមារឈ្លបហ្នឹងឡើងឈរស្ពាយកាំភ្លើងយាមលើបង្អៀបមែកវា ក៏ដោយចាំ! ខ្ញុំនៅតែស្រឡាញ់ដើមផ្កាក្រោកហ្នឹង ហើយចាំ! ខ្ញុំមែនទែនដូចជាមនុស្សមួយផ្សេងព្រេងអត់ចង់នៅកន្លែងដដែលទេ ចង់តែឱ្យគេចេញទៅកន្លែងណា ផ្សេងៗព្រោះយើងចង់ទៅស៊ើបរកកូនយើងទៀតនោះណា។ ម្ល៉ោះហើយបើថាបាន ចេញពីកន្លែងហ្នឹង ដូចថាយើងហ្នឹងវាមានជើងមេឃថ្មីអីចឹងចាំ!។

ពាសី ៖ បាទ! អាហ្នឹងដូចថាមានបោះជំហានទៅមុខ?

សារីម ៖ ចាំ!

ពាសី ៖ បាទ! អ្នកស្រីធ្វើដំណើរទៅតាំងទីលំនៅនៅភូមិតាលៃហ្នឹង កន្លែងនោះជាភូមិថ្មី ឬ ភូមិចាស់បាទ!?

សារីម ៖ ចាំ! កន្លែងហ្នឹងជាភូមិចាស់ចាំ! ខ្ញុំរាប់ទៅវាមានផ្ទះប្រហែល១២ផ្ទះ ហើយមានអណ្ដូងទឹក ហើយផ្ទះហ្នឹងគឺជាផ្ទះរបៀបអ្នកចម្ការ ផ្ទះខ្លះផ្ទះជញ្ជាំងស្លឹក ហើយប្រក់ ក្បឿង ផ្ទះខ្លះប្រើជញ្ជាំងក្ដារប្រក់ក្បឿង ខ្លះរនាបឫស្សី ខ្លះរនាបក្ដា។ យើងទៅដល់ នោះឃើញមានរោងបាយមួយយ៉ាងធំហើយ ដែលពួកខ្មែរក្រហមគេធ្វើទុកចាំ!។

ពាសី ៖ អីចឹងបានន័យថាមានគេធ្លាប់រស់នៅទីហ្នឹងហើយបាទ?

សារីម ៖ ចាំ! តាមខ្ញុំដឹងមុនពេលពួកខ្ញុំទៅដល់ហ្នឹង មានពួកគេហៅបងប្អូនយើងនោះចាំ! គេហៅបងប្អូនយើង បានន័យថា ខ្មែរក្រហមមូលដ្ឋានគេហើយណា គេមកនៅ

ហ្នឹង ដល់យើងមកទៅ គេដកខ្លួនទៅនៅឆ្ងាយពីយើងបន្តិចទៅ គេទុកកន្លែងហ្នឹង ឱ្យពួកយើង នៅចាំ!។

រាសី ៖ បាទ! ហើយផ្ទះតែជាង១០ខ្នងអីចឹង ទាំងអស់គ្នាហ្នឹងទៅជាមួយអ្នកស្រីហ្នឹងពី សាលាតិចណ្ឌូទៅប៉ុន្មាននាក់នៅគ្រប់គ្រាន់ទេ?

សារីម ៖ ចាំ! យើងគ្នាតែ១០០នាក់ជាងអីចឹង ប៉ុន្តែផ្ទះគេឱ្យយើងនៅ ស្រីៗនៅដោយ ស្រីៗ ប្រុសៗនៅដោយប្រុសៗ ហើយទៅគេដូចពួកខ្ញុំអីចឹងគឺថាសុទ្ធតែស្រីហ្នឹង នៅផ្ទះមួយហ្នឹងជាមួយគ្នា។ គេមានយកផ្ទះមួយហ្នឹងទៅវាយបន្ទប់ធ្វើតូចៗចាំ! ដើម្បីឱ្យ ពួកដែលមានប្តីប្រពន្ធហ្នឹងដែលមិនបាននៅជាមួយគ្នាហ្នឹង គេចាត់តាំង ឱ្យទៅសម្រាន ជាមួយគ្នា។ យប់មួយណាអីចឹង ស្អាយខ្មើយស្អាយអីចឹងទៅ។

រាសី ៖ អីចឹងមិនមែននៅជាមួយគ្នាជាគ្រួសាររាល់យប់ទេ មានតែពេលខ្លះទេចឹង?

សារីម ៖ ចាំ! ពីព្រោះវាអត់មានកន្លែង ហើយគេធ្វើចឹង ខ្ញុំដូចខ្មាសគេនៅក្នុងចិត្តខ្ញុំណាស់ ថាសូម្បីតែដេកជាមួយគ្នាជាប្តីប្រពន្ធក៏គេចាត់តាំងដែរយប់ណាមួយនោះ។

រាសី ៖ បាទ! ហើយកុមារ ហើយចុះកូនក្មេងវិញ?

សារីម ៖ កូនក្មេងគេនៅជាមួយម្តាយចាំ! ហើយមានផ្ទះនោះមានកុមារនៅដែរ គេឱ្យកុមារ នៅកុមារណាធំៗ ចាំ! តែកុមារណាតូចៗ គេឱ្យនៅជាមួយម៉ែឪ។

រាសី ៖ ហើយចុះយប់ឡើងមានពួកឈ្លបពួកអីគេដើរមើលយើងទេ តាមអ្នកស្រីដឹង?

សារីម ៖ យើងទៅហ្នឹង គេឱ្យយើងយាម គេចាត់តាំងឱ្យយើងយាម។

រាសី ៖ គេឱ្យយើងយាមកន្លែងយើងខ្លួនឯង?

សារីម ៖ ចាំ! អង្គុយក្រោមផ្ទះមួយអីចឹងទៅយើងយាម។ គេឱ្យយើងកាន់ដំបងមួយអីចឹង។

រាសី ៖ បាទ! ហើយយាមហ្នឹងរបៀបមិនមែនខ្លាចចោរខ្លាចអីទេ?

សារីម ៖ ចាំ! យាមមើលក្នុងភូមិ ក្រែងលោមានអ្នកណាចេញចូលអីគេឱ្យយើងបង្ហាញ ប្រាប់គេ អីចឹងទៅ ចាំ! នៅតាលៃមានចម្ការចេកនៅជាប់ហ្នឹងរោងបាយ ហើយ

មានដើម ក្រសាំងច្រើន ព្រមទាំងមានបឹងឈូកមួយហើយនឹងស្រះមានផ្កាកំប្លោក ពណ៌ស្វាយ នៅក្រោយផ្ទះកុមារ ហើយនៅភូមិនេះខ្ញុំសង្កេតឃើញថាមិនសូវមាន ដើមឈើស៊ីផ្លែ ទេ ហើយភូមិហ្នឹងមានដើមត្នោតច្រើន មានដើមព្រីង ហើយ ដើមដូងមិនសូវមានទេ។

រាសី ៖ បាទ! គេឱ្យបេះទេ គេឱ្យបេះពិសារទេ?

សារីម ៖ ចាំ! ហ្នឹងយើងអត់ហ៊ានបេះ ស្រេចតែអង្គការយើងគេបេះឱ្យយើង តែគេមិន ដែលៗបេះដូង បេះត្នោតអីឱ្យយើងទេ ហើយកាលដែលខ្ញុំចាប់អារម្មណ៍ខ្លាំង ហើយ សប្បាយជាងគេពេលដែលខ្ញុំទៅដល់ភូមិតាលៃនៅយប់ដំបូងហ្នឹង ខ្ញុំ សប្បាយនឹង មើលអំពិលអំពែក វាបាចភ្លើងខៀវខ្ចី បៃតងរបស់វាហ្នឹងព្រាតៗ ហើយដូច អំពូលភ្លើងរាប់ម៉ឺនរាប់សែនអីចឹងបើកបិទភ្លិបភ្លែតៗ ហើយសម្រស់ អំពិលអំពែកនៅ ភូមិតាលៃហ្នឹងធ្វើឱ្យខ្ញុំនឹកទៅដល់ក្រុងប៉េកាំងពេលយប់សម័យ ដែលខ្ញុំចុះកប៉ាល់ហោះនៅហ្នឹងឃើញភ្លើងផ្លុងៗ ដូចថាចាញ់សម្រស់ភ្លើងអំពិល អំពែកនៅតាលៃ ឆ្ងាយណាស់ ក្រុងប៉េកាំងពេលហ្នឹងងងឹតចាំ! ហើយកាលមួយ ទៀតដែលធ្វើឱ្យខ្ញុំទើស ភ្នែកនៅភូមិតាលៃពេលដែលខ្ញុំទៅដល់ដំបូងហ្នឹង គឺខ្ញុំ ឃើញបាយក្តាំងៗដុះផ្សិតស្អុយ គគ្រុកយ៉ាងក្រាស់ឃ្មឹកនៅលើគ្រែដែកពីរ នៅ ក្រោមផ្ទះមួយជិតអណ្តូងទឹកហ្នឹង ហើយនឹងពាងស្ករពីរដែលមានប្រហុក ហើយ នឹងផ្អកហ្នឹងស្អុយដង្កូវចោះពេញ។ រឿង ហ្នឹងធ្វើឱ្យខ្ញុំនឹកឃើញដល់ជំហរ សន្សំសំចៃរបស់ពួកខ្មែរក្រហមដែលគេលើកឡើងនៅសាលាតិចណូរូស្ស៊ី។ ខ្ញុំ មើលឃើញថាគេនិយាយផ្សេង គេធ្វើផ្សេង ពួកខ្មែរក្រហមខ្ជះខ្ជាយ របៀបហ្នឹង។ នៅក្រោមផ្ទះនៅភូមិតាលៃនៅពេលដែលយើងអត់បាយ យើងមានតែ បបររាវៗ ខ្ញុំឃើញមួយទៀតគួរឱ្យចាប់អារម្មណ៍គឺខ្ញុំឃើញម៉ូតូមួយអត់មានកង់ទេ មាន តែតួ។

## រាសីៈ ហើយៗកាលនៅភូមិតាលៃហ្នឹង អ្នកស្រីមានបានជួបជាមួយ អ្នកធំៗពីដើមជំនាន់ លន់ នល់អញ្ចឹងដែរ?

សារីមៈ នៅភូមិតាលៃដែលពួកខ្ញុំទៅដល់ហ្នឹង ដំបូងខ្ញុំឃើញស្រីម្នាក់។ ហ៊ឺ! ខ្ញុំឆ្ងល់ថា ហ៊ឺស! អ្នកស្រីម្នាក់ហ្នឹងមុខដូចអ្នកគ្រូបង្រៀនសាលានៅគគីរ ដែលខ្ញុំរៀននោះ ខ្ញុំថា «ចុម អ្នកគ្រូនេះម៉េចក៏នៅក្មេងម្ល៉េះ?» ដល់ខ្ញុំមើលយូរៗទៅស្រាប់តែឃើញថា អ្នកហ្នឹង គាត់ ជាកូនសម្តេចឪ ចាំ! អ្នកហ្នឹងឈ្មោះគេហៅម្ចាស់ឈូកៗ ហើយឈ្មោះ គាត់ មែនទែនហ្នឹងឈ្មោះ បុទុម បុប្ផា ចាំ! បុទុម បុប្ផា ហើយនឹងម្ចាស់ប៉ាងហ្នឹងជាបងប្អូន បង្កើត។ម្តាយគាត់ហ្នឹងឈ្មោះ ស៊ីសុវត្ថិ ពង្សសនមុនី ដែលគេហៅថា ម្ចាស់ម៉ោង នោះចាំ! ហើយគាត់អង្គុយក្រោមផ្ទះមួយនៅជាប់ផ្ទះដែលខ្ញុំនៅហ្នឹង។ រួចទៅគេ ប្រាប់ខ្ញុំថា បុទម បុប្ផាហ្នឹងជាប្រពន្ធរបស់សូភុត្រ្តា ចាំ! ហើយសូភុត្រ្តាហ្នឹងធ្លាប់រៀន ជាមួយខ្ញុំនៅថ្នាក់ទី២ សាលា Luceeស៊ីសុវត្ថិ។

រាសីៈ អ្នកស្រីបាននិយាយជាមួយគាត់ដែរ?

សារីមៈ ចាំ! ដល់ស្អែកឡើងខ្ញុំឃើញសូភុត្រ្តាហ្នឹង។ ស្រាប់តែសូភត្រ្តាហ្នឹងគាត់ចាំណាស់។ គាត់ស្ទុះមកសួរខ្ញុំ។ ហើយគាត់សួរខ្ញុំរកពួកម៉ាកខ្ញុំម្នាក់ឈ្មោះហេង ហ៊ុយ។ គាត់សួរថា «បងហេង ហ៊ុយនៅណា? បងហេង ហ៊ុយហ្នឹងជា Premier amourរបស់ ខ្ញុំ»។ ហើយខ្ញុំឮសួរគាត់និយាយពីរឿងស្នេហាដំបូងរបស់គាត់អញ្ចឹង ខ្ញុំរឹតតែចង់

ប្រញាប់លាគាត់ចេញពីកន្លែងជិតភ្លីស្រែហ្នឹង។ មុនដំបូងខ្ញុំធ្វើពើ។ ខ្ញុំធ្វើមិនស្គាល់គាត់ណាំ! រួចគាត់អត់សុខចិត្តទេ។ គាត់ថា «បងខ្ញុំស្គាល់បងឯងច្បាស់ណាស់បង។ បងឯងនៅសាលានរោត្តម ហើយដើរមករៀននៅ Lucee ស៊ីសុវត្ថិ។ ហើយត្រឡប់ទៅវិញបងឯងដើរជាមួយ ហេង ហ៊ុយ រាល់ថ្ងៃ។ ហើយហេង ហ៊ុយនៅផ្សារចាស់»។ ហើយដល់អញ្ចឹងទៅខ្ញុំក៏ប្រាប់គាត់ថា «ខ្ញុំអត់ដឹងអាហ៊ុយនៅណាទេ»។ ហើយសុំជម្រាបថា ពេលដែលសូភុត្រ្តាស្រឡាញ់ អាហ៊ុយហ្នឹងគឺតាំងពីថ្នាក់ទី២រហូតដល់ថ្នាក់ទី១។ ប៉ុន្តែអាហ៊ុយចេះតែធ្វើមិនដឹងៗទៅ។ ប៉ុន្តែថ្ងៃមួយ អាហ៊ុយភ្លេចកាបូបដែលមានសំបុត្រប្រឡងបាក់អង (Bac 1)នោះ។ ពេលធ្វើជប់លៀងសាលា ហ៊ុយភ្លេចកាបូបនៅ Lucee នៅលើតុជប់លៀង ហើយអញ្ចឹង អាហ៊ុយត្រឡប់ទៅរកវិញក៏ជួបសូភុត្រ្តាហ្នឹង នៅជិតរោងកុនកាពីតុល។ ហើយ សូភុត្រ្តាហ្នឹងក៏ជួយ កណ្ដាលអធ្រាត្រហើយក៏ជួយរកកាបូបហ្នឹងឃើញនៅសាលា។ ហើយក៏ជូនអាហ៊ុយទៅផ្ទះវិញ។ ដល់ថ្ងៃក្រោយមក សូភុត្រ្តាហ្នឹងបបួលអាហ៊ុយទៅមើលកុន។ អាហ៊ុយចេះតែណាត់ទៅ។ ប៉ុន្តែដល់ថ្ងៃទៅមើលកុនហ្នឹង អាហ៊ុយទៅកំពតបាត់ទៅ ចាំ!

រាសី៖ បាទ! ហើយហេតុអីបានជាអ្នកស្រីធ្វើជាមិនស្គាល់គាត់?

សារីមះ ព្រោះខ្ញុំមិនចង់ឱ្យមានរឿង។ កាលណាយើងស្គាល់អី រាក់ទាក់អញ្ចឹងទៅ អាចពួកខ្មែរក្រហមសង្កេត។ អង្គការខ្មែរក្រហមហ្នឹងគេថា អង្គការភ្នែកម្នាស់នោះ ចាំ! ម្ល៉ោះហើយខ្ញុំភ្នែកម្នាស់មើលមិនឃើញអីក៏ដោយ ប៉ុន្តែខ្ញុំចេះតែប្រយ័ត្នខ្លួន។ ហើយធ្វើស្គាល់សូភុត្រ្តាអញ្ចឹងទៅខ្លាចមានរឿង ចាំ! ហើយគេឃើញយើងហ្នឹងស្គាល់អញ្ចឹងទៅ គេអាចស៊ើបអញ្ចេះ ស៊ើបអញ្ចុះ។ ខ្ញុំមិនចង់ឱ្យ មានរឿង ចាំ!

រាសី៖ ដេញដោល?

សារីមះ ចាំ! ម្ល៉ោះហើយខ្ញុំធ្វើមិនស្គាល់ចាំ!

រាសី៖ បាទ! ចុះចំណែកអម្បាញ់មិញ អ្នកស្រីមានប្រសាសន៍ថា បានឃើញកូនសម្ដេចឪ បុទុម បុប្ផា ហ្នឹង។ អ្នកស្រីបានសំណេះសំណាលជាមួយគាត់ដែរ?

សារីមៈ ចាំ! ជាមួយបុទុម បុប្ផាហ្នឹង ខ្ញុំអត់ស្គាល់គាត់ទេ។ ដូច្នេះខ្ញុំអត់បាននិយាយទេ។ ខ្ញុំគ្រាន់តែមើលឃើញពីផ្ទះដែលខ្ញុំនៅហ្នឹង ហើយគេរស់នៅជាភ្ញៀវរបស់អង្គការ មិនមែនចុះធ្វើការពលកម្មអីដូចយើងទេ ចាំ! រួចទៅគេទទួលទានបាយហ្នឹងបីពេលគឺថាពួកយើងទៅដល់ហ្នឹងត្រូវដាំបាយជូនគាត់ហ្នឹងពិសារ ស្រស់ស្រូបព្រឹក ថ្ងៃត្រង់ ហើយនឹងល្ងាចគឺថា ដល់ម៉ោងគេចេញមកពិសារបាយតែម្តងចាំ!

រាសីៈ បាទ! អ្នកស្រីមានប្រសាសន៍ថា បាយគឺថា បាយមែនទែន? បាយស្រួយ?

សារីមៈ ចាំ! ពួកអ្នកអស់ហ្នឹងគេពិសារបាយ គឺបាយ ចាំ! តែពួកយើងសុទ្ធតែបបរទេ ចាំ!

រាសីៈ ហើយចុះម្ហូបគេធ្វើម្ហូបអីត្រឹមត្រូវដែរ? ម្ហូបយ៉ាងម៉េចដែរ?

សារីមៈ ចាំ! ម្ហូបហ្នឹង...គេរកត្រីបានអញ្ចឹងមក គេធ្វើម្ហូបត្រឹមត្រូវអញ្ចឹង មានមួយមុខ មានពីរមុខអញ្ចឹងទៅ ចាំ! ព្រោះគេជាភ្ញៀវរបស់អង្គការចាំ!

រាសីៈ គឺថា ហូបចុកមួយសេរី គឺមួយឆ្អែត?

សារីមៈ ចាំ! មិនមែនទេ។ យើងដាក់ឱ្យគេអញ្ចឹងគឺមិនៗពោរពាសអីពេកទេ។ ប៉ុន្តែថា វាក៏វាមិនអត់ឃ្លាន។

រាសីៈ ប៉ុន្តែតើគេចូលមកញ៉ាំជាមួយអ្នកទាំងអស់គ្នាទេ? ឬគេញ៉ាំដាច់ដោយឡែក? បាទ!

សារីមៈ ចាំ! ដាច់ដោយឡែក ចាំ!

រាសីៈ ចុះក្នុងមួយថ្ងៃគេធ្វើអីខ្លះទៅ បើសិនជាគេចេញទៅធ្វើការ?

សារីមៈ អ្នកអស់ហ្នឹងគេអត់ធ្វើការទេ។ គេជាភ្ញៀវរបស់អង្គការគឺថា អត់ធ្វើអីទេ ហើយសុភក្ត្រាហ្នឹង ខ្ញុំឃើញគាត់បណ្តើរឆ្កែអញ្ចឹង។ គាត់មានឆ្កែគាត់ហើយគាត់ស្លៀកពាក់ដូចកម្មាភិបាលខ្មែរក្រហមអញ្ចឹង តែស្បែកជើងគាត់ហ្នឹងមិនមែនស្បែកជើងកង់ឡានទេ ចាំ! ស្បែកជើងឃ្លប់។

ខ្ញុំនឹងជម្រាបពីសុភក្ត្រាជាប្តីបុទុម បុប្ផា។ ពេលដែលខ្ញុំត្រឡប់ពីអង្គរជ័យមកវិញចូលមកនៅភូមិតាលៃ ថ្ងៃមួយហ្នឹងគឺថា ក្នុងខែកត្តិក ពេលទឹកឡើង ហើយខ្ញុំឃើញ

សូភុត្រ្តា ហ្នឹងគាត់រុំជើង ហើយដើរកាន់ឈើច្រត់ ហើយគាត់បណ្ដើរឆ្កែ។ ហើយខ្ញុំសង្ស័យណាស់ ព្រោះគាត់ធ្លាប់និយាយបបួលនាងថាច់ ចាន់ម៉ូលីរត់។ នាងថាច់ចាន់ម៉ូលីជាកូនសិស្សខ្ញុំ ចាំ! គាត់បបួលរត់ ព្រោះសូភុត្រ្តាហ្នឹង ធ្លាប់ដូចថា ចេះតែចង់ដេញតាមនាងថាច់ ចាន់ម៉ូលី ហ្នឹង។ ហើយគាត់សរសើរពេលណានាងហ្នឹងចូលធ្វើបាយជាមួយក្រុមខ្ញុំ។ គាត់ថា អ្នកធ្វើហ្នឹងគឺមានទឹកដៃ ហើយគាត់បបួលថា «មានចង់រត់ទេ? បើខំរត់ហ្នឹងមិនបានទេ។ ឱ្យខំធ្វើការឱ្យមែនទេ»។ ហើយថ្ងៃណាមួយគាត់នឹងយកកប៉ាល់ហោះមកចុះនៅតាលៃ ហើយចាំរត់ឡើងកប៉ាល់ហោះគាត់។ ហើយសុំជម្រាបថា សូភុត្រ្តាជាអ្នកដែលធ្លាប់ទម្លាក់គ្រាប់បែកលើចម្ការមនក្នុងរបបសាធារណរដ្ឋរបស់លោកលន់ នល់ ដែលមានទីស្នាក់ការនៅចម្ការមន ចាំ! ហើយដល់ពេលយើងនឹកឃើញថា សូភុត្រ្តាធ្លាប់ទម្លាក់គ្រាប់បែកហើយបើកកប៉ាល់ហោះទៅព្រៃអញ្ចឹងទៅចាំ!

រាសីះ បាទ! អញ្ចឹងដូច្នេះគាត់ពេលហ្នឹងគាត់នៅជាមួយពួកខ្មែរក្រហមរហូតដល់អ្នកស្រីជួបគាត់ឬ? បាទៗ

សារីមះ ចាំ! ខ្ញុំមិនដឹងយ៉ាងណាទេ ប៉ុន្តែតាមខ្ញុំស្មានប្រហែលជាគាត់ហ្នឹងទៅចូលសម្ដេចសីហនុ ហើយទៅគាត់បានរៀបការជាមួយនឹងបុទុម បុប្ផា ជាបុត្រីហ្នឹង ចាំ! ហើយ ក៏ត្រឡប់មកនៅភូមិតាលៃវិញជាភ្ញៀវរបស់អង្គការ ហើយដល់ពេលខ្ញុំឃើញគាត់ រុំជើងអញ្ចឹង ខ្ញុំសង្ស័យថា សូភុត្រ្តាធ្លាប់បបួលនាងនោះនិយាយពីរឿងរត់។ ខ្ញុំថាសូភុត្រ្តាប្រហែលជាធ្វើកិច្ចការដើម្បីកុំឱ្យគេសង្ស័យគាត់នោះ ព្រោះគាត់គ្រេចជើង។ ចាំ! ហើយស្រាប់តែថ្ងៃមួយហ្នឹង ខ្ញុំធ្វើការនៅក្រោមផ្ទះដែលនៅជិតគាត់ ហ្នឹង។ ខ្ញុំរើសក្ដួរស្រូវ ហើយស្រាប់តែផ្ទះសូភុត្រ្តាហ្នឹងស្ងាត់ឈឹង។ ខ្ញុំរង់ចាំមើល។ កន្លែងហូបបបរពេលព្រឹកក៏មិនឃើញភ្ញៀវគេហ្នឹង។ ពេលថ្ងៃត្រង់ក៏មិនឃើញ។ ស្រាប់តែនៅម៉ោងប្រហែលជា២រសៀល ស្រាប់តែឃើញយោធាខ្មែរក្រហមជិះម៉ូតូមក ឡើង២-៣ម៉ូតូ ហើយគេក្រវ៉ាត់ខ្សែគ្រាប់កាំភ្លើង។

រាសីះ ពាក់ចំហៀងខ្លួន?

សារីមៈ ចា៎! ពាក់ហ្នឹង មិនមែនពាក់ចំហៀងទេ ពាក់នៅទ្រូងគេហ្នឹង ចា៎!

រាសីៈ ពាក់នៅលើស្មាហ្នឹង?

សារីមៈ ចា៎! អត់ទេ ពាក់ខ្វែងនៅទ្រូងគេហ្នឹង ចា៎! ហើយស្ពាយកាំភ្លើងគ្រប់គ្នា ហើយមកឡើងផ្ទះ សូត្រាហ្នឹង។ ហើយដល់ល្ងាចទៅបានពួកកុមារដែលនៅក្រោយផ្ទះដែលខ្ញុំធ្វើការហ្នឹងនិយាយថា ពីយប់មិញនោះ ប្រហែលម៉ោងពីរយប់ឃើញគ្រួសារសូត្រាហ្នឹងដើរទៅជិះទូកនៅខាងក្រោយផ្ទះកុមារ ហ្នឹង។ ពេលហ្នឹងភូមិតាលែហ្នឹងលិចទឹក ចា៎! ហើយតាំងពីថ្ងៃហ្នឹងមក យើងក៏លែងបានឃើញសូត្រាតទៅទៀត ចា៎!

រាសីៈ បាទ! សូមអរគុណអ្នកស្រី នៅ សារីម បាទ!

សារីមៈ ចា៎! អរគុណលោក ប៉ូច រាសី។

រាសីៈ បាទ! ដូច្នេះអ្នកស្រីមិនបានដឹងថា តើទៅគាត់ជាយ៉ាងណា ឬស្ថិតនៅទីណាទេក្រោយ ពីបាត់ទៅហ្នឹងបាទ!

សារីមៈ ចា៎! ខ្ញុំអត់បានដឹងទេ ហើយខ្ញុំដែលដឹងថា គាត់រត់។ ខ្ញុំគិតថា សូត្រាហ្នឹងរត់មិនរួចទេ ព្រោះគាត់មានកូន ហើយនឹងមានប្រពន្ធរយីងរយោងអញ្ចឹង។ បើម្នាក់ឯងប្រហែលរត់រួច ចា៎! ហើយបើថា រត់រួច ទាល់តែមានស្ដេចកណ្ដុរសមកជីករូងដីឱ្យដូចនៅក្នុងរឿងនាង១២អញ្ចឹង ចា៎! បានរត់រួច ពីព្រោះមិនមែនជាទល់ដែនទេ ហើយពេលហ្នឹងលិចទឹកលិចអីផង ចា៎! ពេលនៅភូមិតាលែហ្នឹង ខ្ញុំក៏ធ្លាប់ស្រមើស្រមៃចង់បានស្ដេចកណ្ដុរសហ្នឹងមកជីករូងឱ្យដែរ ចា៎!

រាសីៈ ហើយអ្នកស្រីបានធ្លាប់និយាយជាមួយគាត់ច្រើនដងដែរ? ហើយតើមានការភ័យខ្លាចទេ? នៅពេលដែលឃើញទាហានខ្មែរក្រហមមកអញ្ចឹង ខ្លាចពាក់ព័ន្ធដល់អ្នកស្រីដែរ?

សារីមេះ ចា៎! ខ្ញុំអត់ភ័យទេ ចា៎! ពីព្រោះថា ពេលគាត់ជួបជាមួយខ្ញុំដំបូងអញ្ចឹង ពេលគាត់មកនិយាយរកខ្ញុំហ្នឹង ខ្ញុំនិយាយរកគាត់តែមួយភ្លែតអញ្ចឹងទៅ ហើយក្រោយមកខ្ញុំក៏អត់ដែលទាក់ទងអីគាត់ទៀតដែរ គ្រាន់ថា ឃើញគ្នាអញ្ចឹង ញញឹមដាក់អីធម្មតា ចា៎!

រាសីះ បាទ! ហើយចុះអ្នកនាងម្នាក់ដែលអ្នកស្រីថា គាត់មកនិយាយរកហ្នឹង យ៉ាងម៉េចដែរ? អនាគតរបស់គាត់ទៅយ៉ាងម៉េចដែរ?

សារីមេះ នាងថាច់ ចាន់ម៉ូលីហ្នឹង... កូនសិស្សខ្ញុំហ្នឹងរូបរាងស្អាតណាស់ ចា៎! ហើយនៅតាលែហ្នឹង សូភុត្រ្តាចេះតែតាមទាក់ទងម៉ូលី។ ហើយពួកខាងអង្គការខ្មែរក្រហមហ្នឹងគឺពូហ៊ាន ហ្នឹងចេះតែប្រាប់យើងឱ្យបិទបង្អួចកន្លែងដែលយើងនៅ ពីព្រោះបង្អួចហ្នឹងបង្អួចស្លឹក ហើយយើងទល់បង្អួចពេលយប់ កុំឱ្យវាក្តៅស្អុះ។ ហើយគេមកប្រាប់ថាឱ្យយើងបិទបង្អួច ហើយពួកខ្ញុំ ពេលខ្លះចង់ខឹង ព្រោះខ្ញុំសម្រាននៅជិតម៉ូលីហ្នឹងដែរ។ ក្តៅស្អុះសឹងអីមកឱ្យបិទបង្អួច។ ដល់ក្រោយមកបានយើងដឹងថា គេខ្លាចសូភុត្រ្តាមកលបនាងម៉ូលី ចា៎! ហើយយើងក៏យល់ ហើយយើងខំបិទបង្អួចអីទៅកុំឱ្យមានរឿង។ រួចទៅខ្ញុំក៏ខំប្រាប់ នាងម៉ូលីថា ឱ្យចេះតែគេចៗទៅ ខំគេចទៅកុំឱ្យជាមួយគាត់យូរ។

រាសីះ បាទ! ហើយអញ្ចឹងក្រោយពីព្រឹត្តិការណ៍ហ្នឹងទៅ ចប់ត្រឹមហ្នឹង ឬក៏មានខ្មែរក្រហមមកសួរដេញដោលយើងទៀតដែរ?

សារីមេះ ចា៎! អត់មានទេ។ ខ្ញុំអី អត់មានអ្នកណាមកសួរទេ ចា៎! ចា៎! ពេលដែលសូភុត្រ្តារត់ហ្នឹងនាងថាច់ ចាន់ម៉ូលីហ្នឹងត្រូវអង្គការឱ្យរៀបការរួចទៅហើយជាមួយកូនស្តេចដែលគេហៅថា ម្ចាស់ទូចៗនោះ ចា៎! ហើយម្ចាស់ទូចហ្នឹងធ្លាប់ចូលព្រៃម៉ាក់គី ហើយខ្ញុំឮសួរគេនិយាយថា ម្ចាស់ទូចហ្នឹងជាកូនទ្រង់នរោត្តមភូរីសារ៉ាជាមួយមេនំមេនាងម្នាក់នោះ។ ហើយខ្ញុំសុំជម្រាបពីនាងម៉ូលីហ្នឹង ចា៎! ពេលខ្ញុំមកពីអង្គរជ័យវិញ ខ្ញុំឃើញមុខគាត់ឡើងហើម ប៉ោង ដូចថា ឡើងប៉ោង រួចកើតមុនពេញមុខ រួចខ្ញុំសួរថា «ម៉ូលី! ម៉ូលីឯងម៉េចក៏ប្លែកម្ល៉េះ?» គាត់យំ ហើយគាត់ប្រាប់ខ្ញុំថា គាត់ផឹកថ្នាំអត់កូន។ គាត់យំ រត់មកឱបខ្ញុំ។ ហើយគាត់ប្រាប់ថា គាត់លែងហៅខ្ញុំអ្នកគ្រូហើយ។ គាត់ថា

សុំហៅបង។ គាត់ថា«បងអើយពេលបងមិននៅ ពេលបងទៅអង្គរជ័យហ្នឹង ពួកហ្នឹងធ្វើបាបខ្ញុំណាស់»។ ហើយគាត់គ្មាននរណាជួយពិគ្រោះយោបល់។ គេបង្ខំឱ្យរៀបការអញ្ចឹង គាត់ក៏សម្រេចរៀបការជាមួយម្ចាស់ទូចហ្នឹងទៅ ចាំ! ខ្ញុំខំប្រឹងចតទឹកមុខក្រៀមក្រំរបស់ម៉ូលីក្នុងអារម្មណ៍របស់ខ្ញុំ។ ហើយយើងឈប់មើលមុខគ្នា។ តាំងពីថ្ងៃនោះមក យើងបែកគ្នារហូត ព្រោះ គេឱ្យម៉ូលីទៅនៅកន្លែងផ្សេង ចាំ! ហើយពេលដែលគេឱ្យយើងបិទបង្អួចហ្នឹង ពេលហ្នឹងខ្ញុំក៏រឹតតែប្រយ័ត្នទៀត ព្រោះខ្ញុំលួចស្តាប់វិទ្យុសំឡេងសហរដ្ឋអាមេរិក ហ្នឹងស្ទើររាល់យប់។ នៅភូមិតាលៃហ្នឹង ក្នុងពេលហ្នឹង រឿងដែលខ្ញុំចាំគឺស្តាប់ការឃោសនាពេលដែលលោកជីមមី ខាទ័រជាមួយប្រពន្ធគាត់ឈ្មោះរ៉ូសាលិន ខាទ័រហ្នឹងធ្វើការឃោសនាបោះឆ្នោត នៅឆ្នាំ១៩៧៦ហ្នឹង ចាំ! ហើយខ្ញុំឮសំឡេងអ្នកអង្គ ខេនរាល់តែយប់។

រាសីៈ បាទ! ហើយក្រៅពីរឿងហ្នឹង តើអ្នកស្រីមានជួបអ្នកណាផ្សេងទៀតដែលចាប់អារម្មណ៍ដែរទេ? បាទ!

សារីមៈ ចាំ! រឿងមួយទៀតគឺខ្ញុំជម្រាបពីលើកមុនថា បុត្រីសម្តេចឪមានពីរអង្គនៅភូមិតាលៃ មាននរោត្តមបុទុម បុប្ផាហៅម្ចាស់ឈូក ហើយនឹងមានម្នាក់ទៀតឈ្មោះនរោត្តមសូរិយារង្សី ហៅម្ចាស់ប៉ាង ហើយនៅក្នុងបដិវត្តន៍ខ្មែរក្រហមហ្នឹង គាត់ឈ្មោះយ៉ាន ចាំ! គេហៅគាត់មិត្តយ៉ាន។ ហើយពេលដែល ខ្ញុំទៅដល់ភូមិតាលៃដំបូង ខ្ញុំឃើញម្ចាស់ឈូក។ ប៉ុន្មានខែក្រោយមក ខ្ញុំឃើញម្នាក់ហ្នឹងដើរ ក្បាលធំទើងម៉ើងអញ្ចឹង ស្លៀកសំពត់ខ្មៅដូចថា បះមុខ បះក្រោយ។ ហើយខ្ញុំចេះតែតាមមើល។ ខ្ញុំថា អ្នកហ្នឹង ខ្ញុំដូចជាធ្លាប់ស្គាល់! ស្រាប់ទៅមានម្នាក់នោះគេប្រាប់ថា «យី! បងឯងមិនស្គាល់ទេ ហី? ហ្នឹងម្ចាស់ប៉ាង។ ខ្ញុំសម្លឹងមើលទៅ ខ្ញុំនឹកឃើញ «អូ! ហ្នឹងម្ចាស់ប៉ាងមែនហ្នឹង!» ហើយពេលហ្នឹងគាត់មកនៅផ្ទះមួយជិតពួកខ្ញុំនៅហ្នឹង។ ហើយគាត់មានកូនខ្ចីម្នាក់ចងអង្រឹងក្រមារដេកនៅក្រោមផ្ទះហ្នឹង យំងេះៗ ហើយទៅស្រាប់តែប៉ុន្មានថ្ងៃក្រោយមក ឮសូរកូនហ្នឹងស្លាប់ ហើយទៅម្ចាស់ប៉ាងហ្នឹងគាត់ស្រែកយំ។ គាត់ថា គាត់ខំសុំអង្គការ ដូចថា សុំទឹកដោះគោឱ្យកូនបៅ ពីព្រោះគាត់អត់មានទឹក

ដោះ។ ហើយទៅ អង្គការហ្នឹងអត់បានឱ្យទឹកដោះអីទេ។ កូនហ្នឹងក៏ស្លាប់ទៅ ចាំ! ហើយខ្ញុំសុំជម្រាបថា ម្ចាស់ប៉ាង ឬមិត្តយ៉ានហ្នឹង (ទៅស្រុកខ្មែរវិញហ្នឹង) ដល់កូនមួយហ្នឹងស្លាប់ទៅ គាត់នៅសល់កូនបីនាក់ ស្រីៗពីរនាក់ តូចៗ ៤-៥ឆ្នាំ ឈ្មោះចាន់ ហើយនឹងនួន ហើយនឹងកូនប្រុសម្នាក់ហ្នឹងគាត់ហៅថា «អ្នកថ្លុងៗ» អាយុប្រហែល ១២ឆ្នាំ ១៣ឆ្នាំហ្នឹង ដែលជាកូនរបស់គាត់ជាមួយប្តីមុនបង្អស់ឈ្មោះទេព ផល្លី ជាកូនចៅហ្វាយក្រុងភ្នំពេញឈ្មោះលោក ទេព ផន។ ហើយអ្នកថ្លុងហ្នឹងមានមុខក្រៀមណាស់រាល់តែថ្ងៃ ចាំ! យ៉ាននិយាយសម្តីគំរោះគំរើយដាក់កូន ហើយខ្ញុំចេះតែជួយប្រាប់គាត់ថា កុំឱ្យសម្តីអាក្រក់ដាក់កូនប្រុស។ យើងមកហ្នឹងមានតែកូនហ្នឹង ហើយនឹងខ្លួនឯង ដូចនេះត្រូវតែចេះឱបក្រសោបកូន ចាំ!

រាសី៖ បាទ! សូមអរគុណអ្នកស្រី នៅ សារីម បាទ!

សារីម៖ ចាំ! សូមអរគុណលោក ប៉ូច រាសី។ ហើយដល់កូនហ្នឹងស្លាប់ទៅ មិត្តយ៉ានហ្នឹង គាត់ធ្វើការជាមួយពួកយើង គឺថា គាត់ហ្នឹងមិនមែនជាភៀសរបស់អង្គការទេ ចាំ!

រាសី៖ បាទ! ពីមុនគាត់ជាភៀស?

សារីម៖ ចាំ! មិនមែនទេ។

រាសី៖ តាំងពីដើមមក?

សារីម៖ ចាំ! តាំងពីគាត់ចូលនៅភូមិតាលៃហ្នឹង គាត់មិនមែនជាភៀសទេ។ គាត់ធ្វើការដូចយើងអញ្ចឹង។ គាត់ហៅថា ចុះជាប់ប្រជាជន ចាំ!

រាសី៖ បាទ! តើអ្នកស្រីមានបានដឹងថា មូលហេតុអ្វីបានជាអ្នកខ្លះ គេចាត់ទុកជាភៀស អ្នកខ្លះមិនចាត់ទុកជាភៀស បាទ?

សារីម៖ ចាំ! បើតាមខ្ញុំដឹង យ៉ានហ្នឹង ម្ចាស់ប៉ាងហ្នឹង គាត់ប្រាប់ខ្ញុំថា គាត់បានសុំឪពុកគាត់គឺសម្តេចឪ ចេញមករស់នៅជាមួយអ្នកស្រុក បានន័យថា គាត់ប្រើ ពាក្យថា ចុះជាប់ប្រជាជន ចាំ! ហើយទៅឪពុកគាត់ហ្នឹងបានឃាត់គាត់ថា «កូនឯងកុំទៅណា!» អាហ្នឹងគាត់ប្រាប់ខ្ញុំ ចាំ! គាត់ថា «កូនឯងកុំទៅណា នៅវាំងជាមួយប៉ាៗហ្នឹងហើយ»

ពីព្រោះបដិវត្តន៍គេហ្នឹង សម្ដេចលោកប្រើពាក្យបារាំង ចាំ! Radicalណាស់។ Radicalហ្នឹងបានន័យថា ដូចថា គេខ្លាំង ហើយដូចថា....

រាសី៖ តឹងតែង?

សារីម៖ តឹងតែងមែនទែន។

រាសី៖ និយមជ្រុល។

សារីម៖ ចាំ! រួចទៅម្ចាស់ប៉ាងហ្នឹងគាត់មិនស្ដាប់សម្ដេចទេ។ គាត់ថា «ហ៊ឺស! គាត់ចង់មកចុះជាប់ប្រជាជន រស់នៅដូចគេដូចឯងជាមួយប្រជាជន។ រួចទៅគាត់កំប្លែងណាស់។ គាត់ប្រាប់ខ្ញុំនៅពេលយើងកំពុងតែយោងទឹកអណ្ដូងនៅជិតចង្ក្រានបាយ។ ហើយគាត់ថា «បងឯងឃើញទេ ឥឡូវខ្ញុំចុះជាប់ប្រជាជនហើយ។ ឥឡូវរែកទឹកជាមួយបងឯង៦០អម្រែកមួយថ្ងៃ» ចាំ! ហើយថ្ងៃហ្នឹងយើងយោងទឹកអណ្ដូងហ្នឹង។ ពេលធុងហ្នឹងដាច់ខ្សែទៅ ខ្ញុំហើយនឹងគាត់ហ្នឹងអុកគូទជាមួយគ្នា។ រួចហើយងើបឡើងនាំគ្នាសើចថា «ហ្នឹងហើយចុះជាប់ប្រជាជន»។ គាត់ហ្នឹង៦០អម្រែកមួយថ្ងៃ ចាំ!

រាសី៖ បាទ! ហើយអញ្ចឹងម្ចាស់ប៉ាងហ្នឹងមានដែលត្អូញត្អែរពីរឿងចុះមកនៅជាមួយប្រជាជនអញ្ចឹងដែរ បើតាមស្ដាប់ទៅ?

សារីម៖ ចាំ! ឃើញគាត់មិនជាស្មុគស្មាញអីទេ។ ប៉ុន្តែគាត់គ្រាន់តែរអ៊ូរទាំថា គេមិនឱ្យ ទឹកដោះគោឱ្យកូនគាត់។ ហើយគាត់ថា នៅកន្លែងមុន មិនមែនអញ្ចឹងទេ។ គាត់ស្នើអីបានហ្នឹង។ ហើយម្ហូបមានច្រើន។ គាត់មានតាំងពីដំណាប់ ដំណាប់ត្របែកទៀត ចាំ! គាត់និយាយអញ្ចឹងណា! ចាំ! ហើយដល់មកនៅកន្លែងតាលៃហ្នឹងគឺថា តឹង រកអីគ្មាន។ ហើយថ្ងៃមួយ ខ្ញុំកំពុងតែរូតអន្ទង់ ចាំ! គេចាត់ឱ្យខ្ញុំរូតអន្ទង់នៅជិតផ្ទះបាយ។ ស្រាប់តែខ្ញុំឮសូរភូសៗ ឱបៗ ហើយខ្ញុំឆ្ងល់ស្អីអីចេះ? ហើយដល់ ខ្ញុំក្រឡេកមើលទៅខាងមុខហ្នឹង ឃើញគាត់ហើយនឹងប្ដីគាត់ហ្នឹងកំពុងប្រវ៉ាយគ្នា។ ហើយប្ដីគាត់ចាប់គាត់រុញអញ្ចឹងទៅ។ ហើយគាត់ចេះតែខំផតពោះ ឃើញតាប៉ិហ្នឹងចេះតែធាក់។ ប្ដីហ្នឹងចេះតែធាក់ម្ចាស់ប៉ាងហ្នឹង។ ខ្ញុំមិនធ្លាប់ឃើញ ប្ដីអីវាយប្រពន្ធអញ្ចឹងទេ ណា៎។ ខ្ញុំដូចជាញ័រក្នុងខ្លួនណាស់។ ហើយល្ងាចឡើងខ្ញុំលើករឿងហ្នឹងក្នុងអង្គ

ប្រជុំក្រុមរបស់ខ្ញុំ ណាំ ចាំ! ខ្ញុំ ប្រាប់ប្រធានក្រុមថា «ពីថ្ងៃមិញហ្នឹង ខ្ញុំឃើញមិត្តយ៉ាន វាយប្រពន្ធនៅក្រោមផ្ទះគាត់។ ហើយក្នុងសង្គមបដិវត្តន៍ហ្នឹង ម៉េចក៏ប្ដីមក វាយប្រពន្ធដូចនៅសង្គមចាស់អញ្ចឹង? ប្រធានក្រុមខ្ញុំហ្នឹងឈ្មោះអ្នកផល្លា ណាំ។ គាត់ថា អង្គការមានមធ្យោបាយគ្រប់បែបយ៉ាងសម្រាប់កសាងមនុស្ស។ ដល់គាត់ថា អញ្ចឹងមក ខ្ញុំក៏អត់និយាយអីដែរ ចាំ!

រាសី៖ បាទ! ហើយចុះពេលវាយហ្នឹងមានអ្នកណាឃើញទៀតទេ ក្រៅពីអ្នកស្រី?

សារីម៖ ចាំ! មានតែខ្ញុំទេ ព្រោះគេឱ្យខ្ញុំរូតអន្ទង់នោះ ចាំ! ហើយល្ងាចនោះ យ៉ានហ្នឹងក៏អត់មក ប្រជុំទេ។ អ្នកផល្លាជាប្រធានក្រុមខ្ញុំហ្នឹងណា ចាំ! ពេលណាយើងចូលចង្ក្រាន ធ្វើបាយ អ្នកផល្លាហ្នឹងពេលខ្លះប្រើម្ចាស់ប៉ាង (មិត្តយ៉ានហ្នឹង) ដូចយើងប្រើឈ្នួល អញ្ចឹង ចាំ! គាត់ប្រើដូចជានិយាយថា «ឥឡូវយកវែក យកកាំបិតពីរមកឱ្យគាត់»។ ហើយខ្ញុំនៅដាំបាយជាមួយអញ្ចឹង ខ្ញុំទើសចិត្តណាស់។ ពេលបើកអង្គប្រជុំពួក ខ្ញុំ កសាងអ្នកផល្លាហ្នឹង។ ខ្ញុំថា «អ្នកឯងធ្វើឫកដូចលោកស្រីក្នុងសង្គមចាស់។ ពេលធ្វើ អី មិនចេះរកអីមកដាក់ជិតខ្លួនទេ ចាំតែប្រើឈ្នួលឱ្យរត់យក ហើយក្នុង សង្គមនេះ មិត្តយ៉ានហ្នឹងមិនមែនឈ្នួលទេ ម៉េចក៏ប្រើគាត់អញ្ចឹង»។

រាសី៖ បាទ! គាត់ឆ្លើយម៉េចវិញ?

សារីម៖ ចាំ! ហើយគាត់មិនឆ្លើយអីជាមួយខ្ញុំទេ។ ប៉ុន្តែពេលដែលគាត់និយាយថា អង្គការ មានមធ្យោបាយគ្រប់បែបយ៉ាងសម្រាប់កសាងមនុស្សនោះចាំ! អាហ្នឹង ខ្ញុំយល់ ហើយថា  ហេតុអីបានគាត់ប្រើមិត្តយ៉ាន។ អញ្ចឹង បានជាគាត់មិនប្រើអ្នកដទៃ ដូចខ្ញុំ អីនៅទីហ្នឹងដែរ។

រាសី៖ អ្នកស្រីយល់យ៉ាងម៉េចបាទ?

សារីម៖ ខ្ញុំយល់ថា តាមខ្ញុំស្មានទេ ព្រោះថា «ខាងអង្គការមានមធ្យោបាយគ្រប់បែបយ៉ាង សម្រាប់កសាងមនុស្ស» បានន័យថា ប្ដីហ្នឹងវាយអ្នកនេះ ហើយក៏ប្រើរបៀបដូចថា ចង់បំបាក់យើងអញ្ចឹង ចាំ!

រាសីៈ បានន័យថា វាអញ្ចឹង របៀបចង់និយាយថា ជាវិធានការអីរបស់គេហី?

សារីមៈ ចាំ!

រាសីៈ បាទ! "ហើយអញ្ចឹង តើនៅពេលដែលធ្វើការជាមួយគ្នាអញ្ចឹង តើម្ចាស់ប៉ាងហ្នឹង ដែលនិយាយប្រាប់អ្នកស្រីពីរឿងអីក្រៅពីរឿងការងារ រឿងក្រុមគ្រួសារ អីដែរ?

សារីមៈ ចាំ! ពេលម្ចាស់ប៉ាងធ្វើការជាមួយខ្ញុំ គាត់សប្បាយ ហើយទៅគាត់និយាយរឿងប្រាប់ខ្ញុំច្រើន ហើយគាត់ថា កាលនៅស្រុកចិនមានមន្ត្រីជាន់ខ្ពស់ខ្មែរក្រហមទៅបើកវគ្គសិក្សានៅក្នុងប្រទេសចិនហ្នឹង។ ខ្ញុំមិនចាំឈ្មោះទេ ចាំ! មិនដឹងជាខៀវ សំផន ឬ អៀង សារីទេ។ គេធ្វើវគ្គសិក្សា បើកវគ្គសិក្សាឱ្យខ្មែរដែលនៅក្នុងប្រទេសចិនហ្នឹងស្តាប់។

រាសីៈ បាទ! មុនឆ្នាំ៧៥?

សារីមៈ ខ្ញុំមិនចាំទេ ចាំ គ្រាន់តែដឹងថា ត្រូវធ្វើកម្មសិក្សា។ ហើយគាត់និយាយថា មានមនុស្សម្នាក់ជាសិល្បករ ពាក់វ៉ែនតាខ្មៅ បានទៅស្តាប់ ហើយសួរថា «ខ្ញុំជាសិល្បករ តើចូលស្រុកខ្មែរវិញ ខ្ញុំធ្វើអី? រួចទៅអ្នកឆ្លើយហ្នឹងនិយាយថា «ធ្វើស្រែ» រួចទៅថា «ទៅស្រុកខ្មែរយកអីខ្លះទៅជាមួយ? យកមុង យកថ្នាំពស់ចឹក»។ រួចទៅមិត្តយ៉ានឲ្យម្នាក់ហ្នឹងឡើងអុកគូទភឹងលើកៅអី ព្រោះដូចអស់សង្ឃឹមណាស់ដែលគេឲ្យសិល្បករទៅធ្វើស្រែនោះ ចាំ! ហើយគាត់និយាយពីរឿងគាត់ទៅតាមផ្លូវលំហូជីមិញចូលទៅស្រុកលាវ។ កន្លែងពួកដែលប៉ាថេតឡាវ គឺលាវកុម្មុយនីស្តគេកាន់ក្តាប់នោះ ចាំ! ហើយគាត់ទៅ ពេលចូលឆ្នាំហ្នឹង គាត់ទៅរាំវង់ជាមួយពួកប៉ាថេតឡាវនៅសំនឿ ជាមួយសម្តេចឪ និងឪពុកគាត់ចាំ!

ថ្ងៃមួយ ពេលសម្រាកថ្ងៃត្រង់នៅក្រោមផ្ទះខ្ញុំនៅភូមិតាលៃហ្នឹង ស្រីៗខ្លះហ្នឹងគេមានក្រសាំងទុំ។ គេនាំគ្នាកេះក្រសាំងទុំរបស់គេហ្នឹងទៅ ហើយមិត្តយ៉ាន ដែលឃើញគេជុំៗ គាត់ក៏នាំកូនស្រីរបស់គាត់ពីរនាក់ហ្នឹង ចាន់ ហើយនឹងនួន មកអង្គុយលេងនៅក្រោមផ្ទះហ្នឹងដែរ លើគ្រែតែមួយហ្នឹង។ ខ្ញុំសួរគាត់ពីរឿងអ្នកមកពីស្រុកចិន។ ហើយគាត់និយាយពីរឿងអ្នកម្នាក់ហ្នឹងដែលយកនំមកពីស្រុកចិន គឺនំបារាំង នំក្នុង

ប្រអប់ៗ ហើយដែលគេធ្វើភ្លាមៗនោះ។ គាត់ចង់យកមកផ្ញើបងប្អូន។ គេសង្ឃឹមថា ចុះពីកប៉ាក់ហោះទៅមុខជាបានទៅផ្ទះហើយ។ ពេលចូលក្នុងឡាន គាត់ថា ផ្ទះហ្នឹង នៅតាមផ្លូវយើងនៅពោធិ៍ចិនតុងហ្នឹង។ អ្នកហ្នឹងគាត់ថា «អូ! នោះៗផ្ទះខ្ញុំ! ឈប់ ហ្នឹងហើយ! ស្រាប់តែឡានហ្នឹងក៏បើកហួសទៅ។ គេអត់មានឈប់មានអីទេ។ រួចទៅគាត់ហ្នឹងដូចថា ទ្រប្រអប់នំហ្នឹងមិនឱ្យបែកទេ ព្រោះថា យកទៅឱ្យបងប្អូន នោះណាំ។ យ៉ាន ឬម្ចាស់ប៉ាងហ្នឹង ពេលគាត់និយាយប្រាប់អញ្ចឹងហ្នឹង គឺគាត់ងើប ឈរ ហើយគាត់ធ្វើដំណើរទ្រេតទ្រោត ជ្រុលទៅ មុខជ្រុលទៅក្រោយ ឈោងចាប់ ប្រអប់នំហ្នឹង ហើយវារបូតចុះ របូតឡើងតាមចលនាឡានបើក។ គាត់ប្រាប់អ្នកហ្នឹង ថា គាត់ចង់ជួយកាន់ប្រអប់នំឱ្យ ចាំ! ហើយអ្នកដែលស្តាប់ហ្នឹងគឺថា អ្នកខ្លះវេទ្រេត ទ្រោតខ្លួនដូចគាត់ដែរ ចាំ!

ពេលខ្ញុំធ្វើការជាមួយមិត្តយ៉ានហ្នឹង ខ្ញុំមើលទៅគាត់សព្វៗទៅ ខ្ញុំដូចថា អាណិតគាត់ ណាស់ ព្រោះគាត់ជាកូនស្តេច ហើយធ្លាក់ខ្លួនរស់នៅចុះជាប់ប្រជាជនអញ្ចឹង គឺថា មកជួបយើងក្នុងពេលលំបាកៗសម័យខ្មែរក្រហមហ្នឹង។ ខ្ញុំសុំជម្រាបថា ខ្ញុំជាកូនអ្នក ចម្ការ ដែលធ្លាប់ទៅចម្ការ ដើរដួលនឹងដីដុំ។ ឃើញថា ការរស់នៅសម័យខ្មែរក្រហម គឺថា ពិបាកជាងកូនអ្នកស្រែ អ្នកចម្ការធម្មតាទៅទៀត។ចុះទំរាំមិត្តយ៉ាន ដែលជាកូន ស្តេចគឺថា គាត់មករស់នៅដូចយើងអញ្ចឹង ខ្ញុំយល់ថា គាត់ហ្នឹងនឹងពិបាកក្នុង ចិត្តណាស់។ ប៉ុន្តែខ្ញុំមើលទៅឃើញគាត់ហ្នឹង ខ្ញុំសរសើរគាត់ណាស់ សរសើរក្នុង ចិត្តណាស់ថា ដូចគាត់ខំទ្រាំបានអញ្ចឹង ចាំ! ថ្ងៃមួយ ខ្ញុំទៅអង្គុយនៅកន្លែងកុមារ រៀនអក្សរ នៅក្រោមផ្ទះមួយ។ ពេលល្ងាច ខ្ញុំក៏សួរគាត់ថា «មិត្តយ៉ានឯងទៅអង្គុយ ធ្វើអីនៅក្រោមផ្ទះជាមួយកុមារហ្នឹង?» ហើយគាត់ប្រាប់ខ្ញុំថា គាត់ទៅរៀន ក, ខ។ ពេលហ្នឹង ខ្ញុំភ្ញាក់ខ្លាំងណាស់។ ខ្ញុំយកដៃរឹតទ្រូង ហើយខ្ញុំស្រែកថា «ងាប់ហើយ! កូនស្តេចផែនដី ហើយអត់ចេះអក្សរ ជាតិឯង!» រួចទៅគាត់ថា ហ៊ឺស! គាត់ហ្នឹង ឆោតណាស់។ កាលនៅពីក្មេង គាត់ជឿថា មានអ្នកមានបុណ្យ ហើយជឿចាស់ៗថា ហូបចុងអំពៅទៅចេះហែលទឹក។ គាត់ហូបចុងអំពៅ ហើយគាត់ទៅលោតចូលក្នុង អាងទឹកថា នឹងចេះហែល រួចទៅគាត់លង់ ចាំ!

រាសី៖ ហើយគាត់មិនចេះអក្សរមែន ឬគាត់និយាយៗកំប្លែងលេងទេ?

សារីម៖ ចាំ! គាត់ទៅអង្គុយរៀនហ្នឹង គាត់ទៅរៀន ក, ខ។ ហើយខ្ញុំសួរគាត់ថា «នែ! ហើយបើក្រៅពីមិនចេះអក្សរខ្មែរទេ គាត់ចេះអក្សរភាសាអីទៀតទេ?» ព្រោះថា កូនអ្នកមាន ហើយនឹងអ្នកធំអញ្ចឹង គេច្រើនទៅរៀនសាលាបារាំងចាំ! គេអាចចេះអក្សរបារាំង ឬអង់គ្លេសអីច្រើនជាងអក្សរខ្មែរ ចាំ! រួចទៅគាត់ថា គាត់អត់ចេះអក្សរអីទេ ហើយខ្ញុំថា«ហើយអញ្ចឹងចេះនិយាយអីទេ?» គាត់ថា គាត់ចេះតែឈ្នូសមួយហ្នឹង។ ពាក្យ«ឈ្នូស» លោករាសីជ្រាបទេ ពាក្យ«ឈ្នូស?»

រាសី៖ និយាយភាសាអង់គ្លេស បាទ!

សារីម៖ ចាំ! គាត់ថា «ឈ្នូស»ហ្នឹងគឺថា ពេលគាត់ពិសារអីទៅឆ្ងាញ់។ គាត់ប្រើតែពាក្យ«ស្នូស» មួយហ្នឹង ចាំ! រួចទៅគាត់និយាយថា គាត់មិនអួតទេ។ ខ្លួនគាត់ហ្នឹងជាកូនសំណព្វរបស់ឪពុកគាត់។ ហើយគាត់ហ្នឹងចូលរួមគុបាយជាមួយឪពុកគាត់ច្រើនដង។ ហើយកូនឯទៀតៗមិនសូវអ្នកណាបានចូលរួមគុបាយទេ ចាំ! ហើយពេលហ្នឹង វាធ្វើឱ្យខ្ញុំនឹកឃើញដល់សម្ដេចឪ ដែលលោកធ្លាប់មានបន្ទូលថា ពេលលោកនាំកូនស្រីម្នាស់ប៉ាងទៅបរទេសកាលនៅពីក្មេងហ្នឹង គាត់មិនចេះនិយាយអីទេ។ ប៉ុន្តែ បើគាត់ឈឺបត់ជើងអី គាត់ទះគូទទៅគឺថា គេយល់ហើយ មិនចាំបាច់ចេះភាសាទេ។ ទះគូទទៅគេយល់ថាគាត់ហ្នឹងចង់បានអីហើយចាំ!

រាសី៖ បាទ! និយាយពីរឿងការសិក្សា នៅរៀនជាមួយកូនក្មេង ហ្នឹង។ តើពេលហ្នឹងមានរៀន ជាថ្នាក់អីត្រឹមត្រូវ ឬក៏យ៉ាងម៉េចដែរ កម្មវិធីសិក្សាពេលហ្នឹង? បាទ!

សារីម៖ ចាំ! គេគ្រាន់តែបង្រៀនឱ្យក្មេងហ្នឹងចេះសរសេរ ក, ខ ហើយនឹងចេះមើលអក្សរខ្មែរ ព្រោះក្មេងអស់ហ្នឹងសុទ្ធតែទៅពីស្រុកបារាំង ដូច្នេះកុមារអស់ហ្នឹងអត់ចេះអក្សរខ្មែរទេចាំ!

រាសី៖ បាទ! ជំនាន់ហ្នឹង បើតាមខ្ញុំចាំ ពេលខ្ញុំជាកុមារដែរ។ ខ្ញុំមិនបានរៀនសូត្រអីត្រឹមត្រូវទេ អត់មានកម្មវិធីអីត្រឹមត្រូវទេ។ ហើយរៀនបានតែប៉ុន្មានខែក៏ឈប់ទៅ។ ប៉ុន្តែការណ៍ដែលអ្នកស្រីមានប្រសាសន៍ហ្នឹងធ្វើឱ្យខ្ញុំចាប់អារម្មណ៍ ព្រោះអីអ្នកដែល

អញ្ជើញមកពីប្រទេសក្រៅ មកវិញហ្នឹង គេមានកម្មវិធីបង្រៀនអញ្ចឹង តើរៀនបាន រយៈពេលប៉ុន្មានខែដែរបាទ!

សារីមៈ ចាំ! រៀនតែពេលយើងនៅតាលៃប៉ុន្មានខែហ្នឹង។ ឃើញប៉ុណ្ណឹងចាំ! ហើយដូច ថា មិនជាសូវខ្ជាប់ខ្ជួនអីប៉ុន្មានទេ តាមខ្ញុំមើលទៅ។

រាសីៈ បាទ! ហើយក្មេងអាយុប្រហែលប៉ុន្មានដល់ប៉ុន្មាន?

សារីមៈ ចាំ! ក្មេងហ្នឹងចម្រុះ ខ្លះ៧ឆ្នាំទៅ ហើយដល់១០-១២ឆ្នាំហ្នឹង ចាំ!

រាសីៈ បាទ! ហើយចុះមានសៀវភៅអី គេរៀនតាមសៀវភៅអីដែរបាទ?

សារីមៈ ខ្ញុំអត់បានទៅមើលទេ ចាំ! ខ្ញុំឃើញតែគេបង្រៀនកុមារហ្នឹង។ ខ្ញុំអត់បានទៅសួរនាំ ទៅមើលថា អ្នកបង្រៀនហ្នឹងបង្រៀនអីទេ។ ខ្ញុំដឹងតែថា គេបង្រៀនអក្សរខ្មែរ ចាំ!

រាសីៈ បាទៗ! សូមអ្នកស្រីមានប្រសាសន៍បន្តទៀតពីជីវិតនៅតាលៃហ្នឹង បាទ!

សារីមៈ ចាំ! ហើយអ្នកមកពីស្រុកបារាំងហ្នឹង ជាពិសេសអ្នកដែលជាសមាជិករណសិរ្សរបស់ សម្តេចឪបានចូលជាមួយខ្មែរក្រហម ដែលជាសមាជិកហ្នុំងនោះ។ ខ្ញុំមើលទៅគេ ភាគច្រើនអត់ចូលចិត្តមិត្តយ៉ានហ្នឹងទេ។ ហើយគេចេះតែថា មិត្តយ៉ានហ្នឹងដែល ហៅម្ចាស់ប៉ាងហ្នឹង ធ្វើឱ្យខូចឈ្មោះខ្មែរយើង ពេលដែលរស់នៅប្រទេសចិន។ គាត់ ទាមទារនេះគាត់ទាមទារនោះអញ្ចឹងទៅ ហើយពួកនោះនិយាយទៀតថា ប្រជាជន ចិនហ្នឹង អ្នកខ្លះស្តីឱ្យម្ចាស់ប៉ាងហ្នឹងថា អ្នកឯងនេះមករស់នៅហ្នឹងគឺចាយប្រាក់ របស់ប្រជាជនចិន ចាំ!

ម្ចាស់ប៉ាងហ្នឹងបាននិយាយប្រាប់ពួកយើងខ្ញុំថា ពេលដែលត្រឡប់ពីស្រុកចិនវិញ ហ្នឹង អ្នកដែលទៅជាមួយគាត់ ដែលហែរសម្តេចសីហនុចូលក្នុងប្រទេសវិញហ្នឹងគឺ ថា ខ្មែរក្រហមបានអញ្ជើញអ្នកទាំងអស់នោះ ទៅជប់លៀងនៅក្នុងវាំង ចាំ! អ្នកអស់ ហ្នឹង ខំស្លៀកពាក់ខោអាវរបៀបដូចសម័យមុនអញ្ចឹង ចាំ! ស្លៀកសំពត់មានជរជើង អី រកស្បែកជើងឱ្យត្រូវកាបូបអញ្ចឹងទៅចាំ! ស្រាប់តែទៅដល់ឃើញពួកខ្មែរក្រហម ស្លៀកសុទ្ធខ្មៅទាំងអស់។ ដល់អញ្ចឹងខ្លួនឯងហ្នឹងស្លៀកពាក់ខុសគេ ហើយរបៀប

ពិសារអីមានរបៀបនោះ ចាំ! អត់ហ៊ានយកមួបញាប់ទេ។ ស្រាប់តែមួយភ្លែតទៅមួប នោះអស់រលីង ចាំ! រួចទៅ មិត្តយ៉ានហ្នឹងគាត់ថា ដល់លើកទី២ ពេលគេជប់លៀង ម្តងទៀត ពួកគាត់ដឹងហើយ។ ម្តងនេះស្លៀកពាក់ខោអាវខ្មៅ ស្រាប់ទៅដល់គាត់ថា ពួកគាត់ពិសារញាប់ជាងពួកខ្មែរក្រហមទៀត ចាំ!

រាសី៖ ព្រោះគាត់មានបទពិសោធន៍ហើយ?

សារីមេ៖ រួចទៅលែងមានលើក៣។

ថ្ងៃមួយនៅភូមិតាលៃហ្នឹង ចាំ! ពេលយើងចូលធ្វើបាយហ្នឹង គេចាត់ម្ចាស់ប៉ាងឱ្យទៅ រកបន្លែ។ គេថា មិត្តយ៉ានទៅរកបន្លែ។ គាត់យកកញ្ច្រែងមួយយ៉ាងធំពាក់ក្បាលគាត់ ហើយគាត់ដើរទៅរកបន្លែ។ ស្រាប់តែបកមកវិញ ប្រហែលម៉ោង៣ហើយអត់មាន បន្លែអីសោះ។ គាត់មកខ្សឹបប្រាប់ខ្ញុំថា គាត់ទៅលួចកាច់ពោតគេចម្ការជិតហ្នឹង ហូប អស់៦០ផ្លែ។

រាសី៖ ហូបឆៅ?

សារីមេ៖ ចាំ! រួចខ្ញុំថា «ហ៊ឺស! មិត្តឯងម៉េចបានទៅធ្វើអញ្ចឹង? ម៉េចក៏ទៅហូបពោតអស់៦០ ផ្លែ ច្រើនណាស់!» គាត់ថា ពោតដែកអង្រួសៗនោះ ចាំ! គាត់ចេះតែញិញៗហូបអស់ ទៅ។ រួចទៅគាត់ថា ដើរខ្យល់ឡើងបាក់គុម្ពស្មៅអស់។

រាសី៖ ប៉ុន្តែខ្មែរក្រហមអត់មានដាំបន្លែទេ ហេតុអីបានឱ្យគាត់ទៅរកបន្លែ បានន័យថា ទៅ បេះបន្លែព្រៃ បន្លែ...?

សារីមេ៖ ចាំ! ទៅបេះបន្លែព្រៃហ្នឹង ចាំ! ទៅកាប់ដំបងយក្សអី ចាំ! ដំបងយក្សអី យើងធ្លាប់ហូប អស់ហើយ។ យើងកាប់យកមក ហើយយើងឱ្យគាត់ទៅដកផ្ទី ធ្វើអញ្ចឹងណា! ប៉ុន្តែ គាត់ទៅសម្ងំលួចហូបពោត រួចទៅខ្ញុំថា «អួយ! ប្រយ័ត្នខ្មែរក្រហមឃើញ យកទៅ សម្លាប់ចោល!» គាត់ប្រាប់ខ្ញុំថា បើគេយកគាត់ទៅសម្លាប់ចោលមានតែបងឯងហ្នឹង រាយការណ៍!

រាសី៖ ចុះបើគាត់អត់មានបន្លែឱ្យគេស្លផង គេមិនដឹង?

សារីមៈ ចាំ! យើងយល់ហើយថា គាត់ទៅរកមិនបាន។

រាសីៈ អូ! គាត់ប្រាប់ថា រកមិនបានអញ្ចឹងហី?

សារីមៈ ចាំ! រកមិនបានទេ។ ប៉ុន្តែគាត់មកខ្សឹបប្រាប់ខ្ញុំថា គាត់ទៅលួចហូបពោតអស់៦០។

រាសីៈ បើថា រកមិនបានអញ្ចឹង យប់ហ្នឹងអត់មានបន្លែហូបហើយអញ្ចឹង?

សារីមៈ ចាំ! ខាងសេដ្ឋកិច្ចគេយកបន្លែខ្លះមកឱ្យយើងអញ្ចឹងចាំ! ប៉ុន្តែយើងត្រូវតែរកថែមទៀត។

រាសីៈ បាទ! បើអញ្ចឹងអ្នកស្រីនៅធ្វើនៅរោងបាយដាំស្លអញ្ចឹង អ្នកស្រីមិនបាច់ចុះទៅធ្វើស្រែនឹងគេទេ ពេលហ្នឹង?

សារីមៈ ចាំ! នៅភូមិតាលៃហ្នឹងគឺគេផ្លាស់គ្នាតាមក្រុម ចាំ! តាមក្រុមដាំបាយ ពេលខ្លះ ចាំ!

រាសីៈ ដាក់វេនគ្នា?

សារីមៈ ចាំ!

រាសីៈ តើគេដាក់វេនមួយអាទិត្យផ្លាស់ម្តង ឬក៏ប៉ុន្មានថ្ងៃផ្លាស់ម្តង?

សារីមៈ ចាំ! ដូចជាមួយអាទិត្យម្តង។

រាសីៈ បាទ! ហើយអញ្ចឹងដល់ពេលដាំស្ល យើងអាចហូបចុកគ្រប់គ្រាន់ទេ ឬក៏គេឃ្លាំមើលយើងដែរ?

សារីមៈ យើងដាំស្ល យើងវាល់របប ចាំ! ប៉ុន្តែថ្ងៃមួយ ពេលថ្ងៃរសៀលមានម្នាក់ហ្នឹងដែលពួកខ្ញុំហៅម៉ែ អាយោៗ។ គាត់មកហៅឱ្យខ្ញុំទៅចង្ក្រានបាយជាមួយគាត់ ហើយខ្ញុំក៏ដើរតាមទៅ ហើយទៅដល់ខ្ញុំឃើញគ្នាគេ៣-៤នាក់ អង្គុយពួនហូបអីនៅកៀនជញ្ជាំងចង្ក្រានបាយហ្នឹង។ ខ្ញុំឃើញអញ្ចឹង ខ្ញុំដើរចេញមក ព្រោះខ្ញុំប្រាថ្នាទៅស្រុកខ្មែរហ្នឹងគឺខ្ញុំចង់រក្សាជីវិតខ្ញុំហ្នឹងឱ្យរស់ដើម្បីជួបកូនខ្ញុំ។ ហើយខ្ញុំខំទប់ចិត្ត។ ខ្ញុំមិនលួចអ្វីដែលអាចធ្វើឱ្យខ្ញុំមានទោសក្នុងរបបខ្មែរក្រហមទេ ចាំ! ហើយបើខ្ញុំលួចវិញ ចាំ! ខ្ញុំលួចក្រោមភ្នែកពួកប្រធានក្រុមអស់ហ្នឹង ចាំ! ដូច ថ្ងៃមួយ គេចែកចេក។ គេឱ្យយើងនៅ

អង្គុយនៅកន្លែងហូបបាយហ្នឹង។ ខ្ញុំអង្គុយទីហ្នឹងគេដាក់ចេកឱ្យខ្ញុំ អាតូច។ ហើយដល់អ្នកជិតខ្ញុំហ្នឹងបានអាធំ។ រួចខ្ញុំដូរនៅក្រោមភ្នែកហ្នឹង។ យើងទាំងអស់គ្នាអត់មានអីហូបដូចតែគ្នា ហើយគេលួចអញ្ចឹង ខ្ញុំដើរចេញ ចាំ!

រាសីះ បាទ! បើសិនជាលួចញ៉ាំអញ្ចឹងទៅ ហើយរបស់ដែលសល់ត្រូវចែក ព្រោះគេមានរាស់ មានវាស់វាល់។ អញ្ចឹងអ្នកដទៃទៀតបានតិចជាងរបបកំណត់ មិនអញ្ចឹង?

សារីមះ ចាំ! បើយើងលួចអញ្ចឹង គេត្រូវបានតិច។ ហើយខ្ញុំដើរចេញ ប៉ុន្តែខ្ញុំក៏មិនរាយការណ៍អីដែរ ចាំ។

រាសីះ បាទ! ហើយអញ្ចឹងម្ចាស់ប៉ាងហ្នឹងមានដែលធ្លាប់មានប្រសាសន៍អីប្រាប់អ្នកស្រីអំពីរឿងខ្មែរ ហេតុការណ៍ដែលបានកើតឡើង ដែលយើងមិនអានក្នុងកាសែត ដែលយើងមិនបានដឹងពីមុនមក បាទ!

សារីមះ ចាំ! រឿងមួយដែលគាត់និយាយប្រាប់គឺថា នៅថ្ងៃ១៨មីនា ឆ្នាំ១៩៧០ហ្នឹង គាត់ថាគាត់នៅបរទេស ហើយគាត់ដើរលេង ទៅផ្សារជាមួយអ្នកដែលហែរហមគាត់ទៅជាមួយកូនអ្នកធំនេះនោះអី។ ស្រាប់តែមួយភ្លែតហ្នឹង ស្រាប់តែបាត់គេអស់រលីង។ ហើយគាត់ឆ្ងល់ណាស់ ម៉េចក៏គេដើរចោលគាត់អស់អញ្ចឹង? ដល់គាត់មកកន្លែងនៅវិញ បានគាត់ដឹងថា សម្ដេចឪត្រូវធ្លាក់ពីតំណែង ចាំ! ហើយគាត់និយាយថាក្រោយមកដល់ពេលគាត់មកនៅស្រុកបារាំង គាត់ធ្វើការ មើលកូនឱ្យបងស្រីគាត់ម្ចាស់ក្សត្រីបុប្ផា ទេវីនោះ។ ពេលខ្លះគេត្រូវការអ្នកជួយមើលកូន។ ពេលគេចង់ដើរលេងគាត់នឹងមកមើលកូនឱ្យ ដើម្បីយកលុយចាយ អញ្ចឹងចាំ!

រាសីះ បាទ! ពេលហ្នឹង ពេលព្រឹត្តិការណ៍១៨មីនាឆ្នាំ១៩៧០ហ្នឹង តើគាត់មានប្រសាសន៍ថា គាត់នៅក្បែរព្រះមហាក្សត្រដែរ? អតីតព្រះមហាក្សត្រ។

សារីមះ គាត់ទៅបរទេស ហើយខ្ញុំមិនចាំច្បាស់ទេ។ គាត់ប្រាប់ខ្ញុំថា គាត់នៅប្រទេសអង់គ្លេស។ ខ្ញុំចាំមិនច្បាស់ទេ ចាំ!

រាសីះ ហើយគាត់មានប្រសាសន៍ថា មានអារម្មណ៍យ៉ាងដូចម្ដេចដែរក្នុងចិត្តបាទ!?

សារីមៈ	គាត់ឃើញថា ពេលគេរត់ចោលគាត់អស់ចឹងទៅ។ គាត់ដឹងខ្លួនហើយថា ពេលហ្នឹងគាត់ បាត់ហើយអ្នកដែលធ្លាប់ដើរជាមួយគាត់ អត់មានអ្នកណាមកជិតគាត់ទៀតទេ។ អូ! ខ្ញុំធ្លាប់ប្រាប់មិត្តយ៉ានថា ពេលដែលខ្ញុំទៅរៀននៅវិទ្យាល័យនរោត្តមហ្នឹងគេបញ្ជូនខ្ញុំទៅរៀនរាំក្បាច់ល្ខោនលួងនៅប្រាសាទច័ន្ទឆាយា ហើយពេលខ្លះសាលាវិទ្យាល័យនរោត្តមហ្នឹងបញ្ជូនពួកយើងខ្ញុំទៅរៀនរាំនៅដំណាក់មហាក្សត្រយានីនៅជិតវិមានឯករាជ្យនោះចាំ! ហើយពេលហ្នឹងខ្ញុំនិយាយប្រាប់ម្ចាស់ប៉ាងថា «អូ! ខ្ញុំឃើញគាត់នៅពីក្មេងទៅរៀនរាំ ពេលអាយុ ៥-៦ឆ្នាំ ឃើញគាត់ហ្នឹងពាក់អៀមម៉ាដាំ ចងសក់ ចងបូសក់ ហើយពាក់ស្បែកជើងមានស្រោមជើងហើយលើកដៃរាំបុប្ផាលោកីយ៍។ ហើយខ្ញុំឃើញម្រាមដៃគាត់ហ្នឹងក្រឡិចក្រឡុចមើលទៅដូចថា គួរឱ្យស្រឡាញ់ ម្រាមដៃគាត់ហ្នឹងក្រឡិចក្រឡុច ចាំ!

រាសីៈ	បាទ! ហើយគាត់មានប្រសាសន៍ថា ម៉េចប្រាប់បង?

សារីមៈ	ចាំ! ដល់អញ្ចឹង គាត់ថា ពេលហ្នឹងគាត់មិនសូវចេះរាំប៉ុន្មានទេ។ ប៉ុន្តែគេចេះតែឱ្យគាត់ទៅមើលគេរាំ ហើយទៅរៀនលើកដៃ លើកជើងអញ្ចឹងទៅ ចាំ! ហើយថ្ងៃមួយ នៅភូមិតាលៃ ពេលកំពុងច្រូតស្រូវ (ថ្ងៃហ្នឹងខ្ញុំចាំថា ក្តៅណាស់ ហើយខ្ញុំហើយនឹងគាត់ហ្នឹងច្រូតស្រូវជិតគ្នា) ស្រាប់តែមានម្នាក់នោះ ដែលទើបទៅដល់ពីស្រុកបារាំង ស្រាប់តែសួរខ្ញុំថា «អូ! អ្នកឯងនៅទីហ្នឹងនៅឡើយទេហី?» ខ្ញុំថា «ខ្ញុំនៅហ្នឹងនៅឡើយទេ មិនទាន់ទៅណាទេ»។ ហើយមិត្តយ៉ានក៏ឆ្លើយដែរ។ គាត់ថាបងរីម ហើយគាត់មិនទាន់ទៅណាទេ។ គាត់នៅភូមិតាលៃហ្នឹង ធ្វើបដិវត្តន៍ទាល់តែភូមិតាលៃមានភ្លើងអគ្គិសនីប្រើ។ ក្រោយមកខ្ញុំដឹងថា ម្នាក់ហ្នឹងឈ្មោះអិន ចាំ! ពេលមិត្តអិនហ្នឹងដើរចេញទៅ យ៉ានហ្នឹងសួរខ្ញុំថា «ម៉េចបានតែពូហ្នឹងមកសួរបងឯងថាមិនទាន់ទៅណាទេអញ្ចឹង? ចាំ! ពេលហ្នឹងខ្ញុំអត់ហ៊ាននិយាយប្រាប់មិត្តយ៉ានថា ខ្ញុំធ្លាប់ជួបឈ្មោះអិនហ្នឹងនៅ Masion des provinces នៅប្រទេសបារាំង មុនពេលខ្ញុំត្រឡប់ទៅស្រុកខ្មែរវិញហ្នឹង។ នៅមុខលោកអិន ខ្ញុំបាននិយាយថ្កោលទោសខ្មែរក្រហមពីរឿងជម្លៀសមនុស្សចេញពីភ្នំពេញ ចាំ! ហើយខ្ញុំអត់ហ៊ានឱ្យមិត្តយ៉ានដឹង

អំពីរឿងហ្នឹងទេ។ ខ្ញុំគ្រាន់តែប្រាប់គាត់ថា «ហ៊ឺស! ប្រហែលពូហ្នឹងមិនចូលចិត្តខ្ញុំរឿងអីមួយហើយមើលទៅ បានជាគាត់និយាយអញ្ចឹង»។ តែគាត់ថា «លោកហ្នឹងនិយាយដូចមិនសមរម្យ ចង់ឱ្យគេយកបងឯងទៅសម្លាប់ចោលអីយ៉ាងម៉េច?» ហើយមិត្តយ៉ានហ្នឹងជូនកាល ពេលនិយាយជាមួយខ្ញុំហ្នឹង គាត់សម្តែងថា គាត់ហ្នឹងមិនចូលចិត្តម្ចាស់ឈូកប្អូនស្រីគាត់ហ្នឹងទេ ព្រោះម្ចាស់ឈូកហ្នឹងមករស់នៅជាភ្ញៀវរបស់អង្គការ គឺថា ជិះជាន់កម្លាំងពលកម្មរបស់ប្រជាជន។ គាត់ចង់ឱ្យម្ចាស់ឈូកហ្នឹងចុះជាប់ប្រជាជនអញ្ចឹង ចាំ! ហើយដល់ខ្ញុំត្រឡប់ពីអង្គរជ័យមកវិញ ខ្ញុំឮសួរគេថា មិត្តយ៉ាន ឬម្ចាស់ប៉ាងហ្នឹងឈ្លោះគ្នាសម្បើមណាស់ជាមួយម្ចាស់ឈូក ប្អូនស្រីគាត់ នៅភូមិតាលៃហ្នឹងចាំ! ហើយខ្ញុំឆ្ងល់ណាស់ ហេតុអីបានម្ចាស់ប៉ាងហ្នឹងឈ្លោះជាមួយប្អូនស្រីគាត់ឈ្មោះបុទម បុប្ផាហ្នឹងកើត ពីព្រោះពេលដែលខ្ញុំនៅតាលៃហ្នឹងខ្ញុំសង្កេតឃើញថា ម្ចាស់ឈូកហ្នឹង ឬបុទមបុប្ផាហ្នឹង មិនដែលសួរឃើញចេញពីផ្ទះអីទេ។ គាត់សម្ងំតែក្នុងផ្ទះហ្នឹង ចាំ! ហើយតាមមើលទៅគាត់ហ្នឹងស្លូតណាស់។ ហើយពេលដែលខ្ញុំរស់នៅតាលៃជួបគាត់ប៉ុន្មានខែហ្នឹង ខ្ញុំឃើញថា ម្ចាស់ប៉ាង ឬមិត្តយ៉ានហ្នឹងគឺមានការស្រណោះខ្លួន។ ហើយដូចថា គាត់ស្តាយអញ្ចឹង ដោយសារគាត់មិនជឿ សម្តីឪពុកគាត់ ចាំ! រួចទៅគាត់ស្រណោះខ្លួនថា ហ្នឹងហើយឪពុកគាត់សម្តេចឪលោកប្រាប់ថា បដិវត្តន៍ហ្នឹង Radical ណាស់ ហើយលោកថា គាត់នៅជាមួយលោក។ ហើយលោកនឹងសុំឲ្យខ្មែរក្រហមដាក់ថា អ្នកធ្វើការនៅក្នុងវាំងជិតលោក។ ប៉ុន្តែខ្លួនឯងហ្នឹងមិនជឿសម្តីឪពុក។ ហើយពេលដែលខ្ញុំរស់នៅជាមួយមិត្តយ៉ានប៉ុន្មានខែហ្នឹង ខ្ញុំមិនដែលឮសួរគាត់និយាយដំណាលអំពីម្តាយគាត់សោះ។ ឱ្យតែគាត់និយាយអីឡើង គឺគាត់ដំណាលលើកតែពីឪពុកគាត់ សម្តេចឪរហូត ចាំ! ហើយពេលខ្ញុំត្រឡប់ពីអង្គរជ័យមកវិញ ម្ចាស់ប៉ាងលែងនៅទីហ្នឹងហើយ ចាំ!

ឥឡូវនេះខ្ញុំសុំជម្រាបអំពីអ្នកទៅពីអាមេរិក។ ពួកអ្នកទៅពីបរទេសចូលក្នុងប្រទេសកម្ពុជាតាមផ្លូវលំហូជីមិញនោះត្រូវគេយកទៅដាក់កន្លែងដែលពួកអាមេរិកនៅនោះ ចាំ! ក្រោយមកខ្ញុំឃើញពួកនួន ឃឿន ហើយម្នាក់ទៀតឈ្មោះប្លោកស្ងផាន់ទៅទីហ្នឹង។ ហើយពួកខ្លះទៀត ដូចជាចេងស៊ីយំប៊ិនដើរកាត់ភូមិរបស់យើងខ្ញុំហ្នឹង។ គេទៅឈប់នៅ

ក្រោមផ្ទះមួយ ហើយគេទៅដកស្មៅ ដកអីនៅកន្លែងធ្វើស្រូវ ជាមួយយើង។ ហើយខ្ញុំធ្វើអត់ស្គាល់នួន ឃឿន និងប្រពន្ធគាត់ទេ។ ពេលហ្នឹង គាត់ក៏មិនស្គាល់ខ្ញុំដែរ ឬមួយក៏គាត់ធ្វើមិនស្គាល់ខ្ញុំដែរ។ ខ្ញុំមិនដឹងទេ។ ប៉ុន្តែពេលហ្នឹង យើងអត់បាននិយាយគ្នាទេ។

រាសី៖ បាទ! ប៉ុន្តែឈ្មោះដែលអ្នកស្រីរ៉ាយរ៉ាប់ទាំងប៉ុន្មានគឺអ្នកណាគេ បាទ?

សារីម៉ះ ចាំ! នួន ឃឿនហ្នឹងគាត់អ្នកសរសេរសៀវភៅ«ដំណើរឆ្ពោះទៅទិសខាងលិច»នោះចាំ! ហើយនួន ឃឿនហ្នឹងរត់ចូលព្រៃម៉ាក់គី ទៅចូលខាងខ្មែរក្រហមសម័យលោកនល់ នល់ ក្រោយពីមានរឿងជាមួយលោកថាច់ ជានោះចាំ! លោកថាច់ ជាហ្នឹងធ្លាប់ធ្វើកុង្សីគ្រូសម័យលោកលន់ នល់ ហើយក្រោយមក គាត់ទៅលេងលោកកែវសង់គីម ដែលក្នុងឆ្នាំ១៩៧៥ហ្នឹងធ្វើកុង្សីគ្រូដែរនៅBureau ខាងកុង្សីគ្រូ។ ហើយស្រាប់តែកូនសិស្សមួយក្រុមនាំគ្នាទៅនាំលោកពីរនាក់ហ្នឹងបណ្តើរចេញទៅសាលាយុគន្ធរ ហើយក្រោយមកមានគេទៅសម្លាប់លោកទាំងពីរហ្នឹង ចាំ! លោកកែវសង់គីមហ្នឹងស្លាប់នៅ កន្លែងហ្នឹង ហើយលោក ថាច់ ជាស្លាប់នៅពេទ្យ ហើយអ្នកដែលថា ចូលដៃក្នុងការសម្លាប់លោកថាច់ ជា ហើយនឹងកែវ សង់គីមនៅសាលាយុគន្ធរហ្នឹងក៏រត់ចូលព្រៃជាមួយខ្មែរក្រហមទៅ។ ហើយខ្ញុំឮគេនិយាយថា អ្នកនោះបានត្រឡប់ទៅនៅក្នុងហ្វូងអ្នកដែលអង្គុយក្រោមផ្ទះហ្នឹងគឺមានអ្នកដែលធ្លាប់ចូលរួមក្នុងការធ្វើឱ្យលោក ថាច់ ជា និង កែវ សង់គីមស្លាប់ នៅសាលាយុគន្ធរហ្នឹងដែរ។ ហើយ នួន ឃឿនហ្នឹងក៏ធ្លាប់រៀនជាមួយខ្ញុំកូនសិស្សគ្រូបង្រៀនភាសាបារាំង។ គាត់រៀនថ្នាក់ជាមួយគ្នាខ្ញុំ ជំនាន់ខ្ញុំហ្នឹង។ ហើយលោកប្លោក សុផាន់ជាអ្នកធ្វើការនៅអគ្គិសនីកម្ពុជា។ គេបានអាហារូបករណ៍មកស្រុកបារាំង រួចទៅគេចូលហ្វ៊ីងហ្នឹង។ រួចគេត្រឡប់ទៅស្រុកខ្មែរវិញគឺថា សុទ្ធតែតាមផ្លូវលំហូជីមិញ មុនខ្មែរក្រហមយកស្រុកបាន ចាំ! ហើយទៅមានលោក ចេង ស៊ីយំប៊ិននោះ។

រាសី៖ បាទ! តើលោកជាអ្នកណា បាទ?

សារីម៉ះ ចាំ! ចេង ស៊ីយំប៊ិនហ្នឹងជានាយទាហានជាន់ខ្ពស់ម្នាក់ក្នុងសម័យសង្គម ហើយក្នុងសម័យលោកលន់ នល់ក៏ជានាយទាហានដែរ។ ហើយទៅគាត់មានរឿង ពេល

សម្តេចសីហនុធ្លាក់ពីអំណាច។ លោកចេង ស៊ីយំប៊ិនហ្នឹងកាន់ក្តាប់ខាងល្បសាន។ លោកហ្នឹងបានធ្វើឱ្យដាច់ស្ពានមួយពីខាងទិសល្បសានហ្នឹង។ ស្ពាននោះមិនធំប៉ុន្មានទេ ស្ពានឆ្លងព្រែក។ ពួកខាងលោកលន់ នល់ធ្វើការចោទប្រកាន់ថា គាត់ធ្វើមិនត្រឹមត្រូវ ដូចថា បម្រើខ្មាំងយួន យៀកកុងអីហ្នឹង ចា៎! ពេលហ្នឹងលោកលន់ នល់ច្បាំងជាមួយយួនយៀកកុង។ ហើយគេក៏បានចាប់លោកស៊ីយំប៊ិនហ្នឹងទៅ។ ក្រោយមក មិនដឹងជាយ៉ាងម៉េចទេ គាត់រត់រួច ទៅចូលព្រៃម៉ាក់គីជាមួយប្រពន្ធគាត់ទៅ។ រួចហើយគាត់ក៏មកនៅភូមិតាលៃជាប់នឹងភូមិដែលពួកខ្ញុំនៅហ្នឹង ចា៎!

រាសីះ បាទ! តើអ្នកស្រីមានដឹងថា ចំនួនអ្នកដែលត្រឡប់មកតាមផ្លូវលំហូជីមិញហ្នឹងទាំងអស់គ្នាប៉ុន្មាននាក់ដែរ? ប្រហែលជាប៉ុន្មាន?

សារីមះ ចា៎! ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា មានលោកប្លោក សុផាន់ហ្នឹងមួយ។ ហើយពួកអ្នកទៅពីស្រុកបារាំងក៏គេស្គាល់គ្នាគេខ្លះទៀត ដែលត្រឡប់តាមផ្លូវលំហូជីមិញដែរ។ ខ្ញុំឃើញគេមកអង្គុយនិយាយគ្នានៅក្រោមផ្ទះកន្លែងពួកខ្ញុំនៅហ្នឹង។ ខ្ញុំឃើញគេស្គាល់គ្នានោះ ចា៎!

រាសីះ បាទ! បានន័យថា គេធ្វើដំណើរពីប្រទេសចិនតាមឡាន ឆ្លងកាត់តាមប្រទេសវៀតណាម ហើយចូលមកប្រទេសកម្ពុជាហី?

សារីមះ ចា៎! ខ្ញុំមិនដឹងថា គេធ្វើដំណើរយ៉ាងម៉េចទេ គ្រាន់តែដឹងថា គេចូលតាមផ្លូវលំហូជីមិញ ចា៎! ហើយទៅស្រុកខ្មែររាវ (មិនរឹងមាំ)អញ្ចឹង ចា៎! ហើយក្នុងពេលដែលខ្ញុំនិយាយមិញពីថា លោកប្លោក សុផាន់និងប្រពន្ធគាត់ឈ្មោះអ្នកចាន់ សារ៉ុតហ្នឹង។ អ្នកហ្នឹងធ្លាប់រៀននៅសាលាអនុវិទ្យាល័យព្រះនរោត្តម ដូចខ្ញុំដែរ តែគេរៀនមុនខ្ញុំ។ គាត់ហ្នឹងធ្លាប់តែស្គម ទេ ចា៎! ដល់ពេលហ្នឹងគាត់រឹតតែស្គមទៀត។ ហើយទៅបងម្នាក់ឈ្មោះបងប្រចាន់ ដែលធ្លាប់រៀនជាមួយគ្នា។ ពេលឃើញអ្នកសារ៉ុតដើរមកគាត់រត់ឡើងទៅកន្លែង រោងបាយហើយគាត់ទៅស្រែកហៅអ្នកសារ៉ុតថា «អេ៎! អដ្ឋិសង្ឃគិលិ»។ ខ្ញុំឃើញគាត់ហ្នឹងដើរហើយស្គម ចា៎! ហើយអ្នកសារ៉ុតអត់ឆ្លើយទេ។ គាត់ដើរទៅភូមិគាត់ទៅ។ ហើយពួកខ្ញុំនៅពេលហ្នឹងគឺថា ហ៊ានសើច អត់ខ្លាចខ្មែរ

ក្រហមអីទេ ព្រោះបងហ្នឹងគាត់កំប្លែងពេក។ ចាំ! ហើយនៅភូមិតាលៃគឺមានពួកទៅពីអាមេរិកធ្លាប់ទៅ។ ក្រៅពីហ្នឹងមានប្រពន្ធរបស់អ្នកធំខ្មែរក្រហមខ្លះ ដែលរត់ចូលទៅព្រៃជាមួយប្ដី។ រួចទៅប្ដីស្លាប់ចោលអស់ទៅ នៅសល់ប្រពន្ធ ហើយនឹងកូនក៏មករស់នៅទីហ្នឹងដែរ ចាំ! ដូច្នេះនៅភូមិហ្នឹង មានអ្នកទៅពីអាមេរិកនៅច្រើន តែពួកអាមេរិកទៅណាបាត់អស់ហើយពេលហ្នឹង ចាំ!

រាសី៖ បាទ! ជាក្រុមគ្រួសាររបស់អ្នកដែលមានគុណបំណាច់ចំពោះបដិវត្តន៍ខ្មែរក្រហមហ្នឹង ហី?

សារីម៖ ចាំៗ! គេមករស់នៅទីហ្នឹង។

រាសី៖ ហើយតើពួកគេត្រូវទៅធ្វើការ ធ្វើស្រែចម្ការដូចគេដូចឯងដែរទេ?

សារីម៖ ចាំ! ដូចនួន ឃឿន ដូចលោក ប្លោក សុផាន់អញ្ចឹង ខ្ញុំឃើញគេដើរមកដកស្មៅ ដកអីកន្លែងធ្វើស្រូវជាមួយយើងហ្នឹង។ ប៉ុន្តែយើងមើលទៅឃើញ អ្នកខ្លះក្នុងចំណោមអ្នកអស់ហ្នឹងអត់ពាក់ខោអាវខ្មៅអីទេ ចាំ! ខោអាវគេដូចធម្មតា! ហើយប្លោក សុផាន់និងខ្ញុំមើលឃើញគាត់ពាក់មួក មួកគាត់ហ្នឹង ដូចមួកដែលយើងឃើញទាហានយួនចូលស្រុកខ្មែរពាក់ចាំ! ខ្ញុំឃើញលោកហ្នឹង គាត់ពាក់មួកអញ្ចឹង។

រាសី៖ ហើយអ្នកស្រីបានសង្កេតឃើញ ថាតើពួកគេហូបចុកគ្រាន់បើជាងយើងដែរ ឬយ៉ាងម៉េច?

សារីម៖ ចាំ! គេនៅឆ្ងាយពីយើង។ យើងអត់ដឹងទេ ចាំ!

រាសី៖ អត់ដឹងរឿង?

សារីម៖ ចាំ! យើងអត់ដឹង។ យើងអត់ដែលដឹងថា គេហ្នឹងនៅកន្លែងណាច្បាស់ផង គ្រាន់តែដឹងថា គេកាន់ភូមិយើង។ គេដឹងកន្លែងយើង ព្រោះគេដើរកាត់ភូមិយើងនោះ ចាំ!

រាសី៖ បាទៗ! សូមអរគុណអ្នកស្រីនៅ សារីម បាទ!

សារីម៖ ចាំ! អរគុណលោក ប៉ូច រាសី។

រាសីៈ ហើយតើអ្នកស្រីចេញពីភូមិតាលៃហ្នឹងនៅពេលណាដែរ? នៅឆ្នាំណាដែរ?

សារីមៈ ចា៎! ខ្ញុំចាំដូចជាខែ៩ ឆ្នាំ១៩៧៦ហ្នឹង គឺគេចេះតែឱ្យមនុស្សចេញបន្តបន្ទាប់ ហើយដល់ វេនពួកខ្ញុំចេញហ្នឹង គេមានឡានមួយមកដឹកពួកខ្ញុំហ្នឹង។ ហើយពួកយើងអត់ដឹងថា គេ ដឹកយើងទៅណាទេ។ ពេលយើងចេញទៅ យើងចេញទៅដល់ច្បារអំពៅ ចា៎! ដល់ទៅដល់ច្បារអំពៅ ខ្ញុំស្គាល់ស្រុកភូមិហើយ ព្រោះស្រុកខ្ញុំនៅកៀនស្វាយ  តាមច្បារអំពៅហ្នឹង។ យើងឃើញគេហាលពោតក្រហមនៅតាមចិញ្ចើមផ្លូវ រួចទៅយើងឆ្លងកាត់វាលស្បូវ។ ខ្ញុំឃើញផ្ទះរបស់បងប្អូនខ្ញុំដែលធ្លាប់ជាដំណាក់អ្នកម្នាងម៉ារីយិត នៅវាលស្បូវហ្នឹងគឺឆ្លងជ្រោយអំពិល ព្រែកឯងអីហ្នឹង ទៅដល់វត្តមុនីភូមិខ្ញុំ។ ខ្ញុំខំសម្លឹងសឹងធ្លុះដីក្រែងឃើញអ្នកណាដែលខ្ញុំស្គាល់ដើរតាមផ្លូវនៅមុំហ្នឹង ចា៎! រួចទៅបានយើងទៅអង្គរជ័យ ចា៎! ទៅវត្តអង្គរជ័យហ្នឹង។

រាសីៈ កន្លែងថ្មីហ្នឹងហៅវត្តអង្គរជ័យ ហី?

សារីមៈ ចា៎! ទៅដល់កន្លែងថ្មីហ្នឹងគឺចូលតាមផ្លូវវត្តអង្គរជ័យហ្នឹង។ ខ្ញុំស្គាល់អង្គរជ័យហ្នឹងព្រោះពីក្មេង ខ្ញុំធ្លាប់ទៅធ្វើ Class Prominateជាភាសាបារាំង។ គេនាំគ្រូនាំកូនសិស្សទៅលេងព្រៃនោះ ចា៎! ខ្ញុំធ្លាប់ទៅទីហ្នឹង ប៉ុន្តែគេមិននាំយើងទៅវត្តទេ។ គេគ្រាន់នាំយើងចូលតាមផ្លូវវត្តហ្នឹងទៅ។ ហើយគេឱ្យយើងសំណាក់នៅពាក់កណ្តាលផ្លូវហ្នឹងក្នុងរោងម៉ាស៊ីនមួយ ចា៎! ហើយស្អែកឡើង គេនាំយើងទៅនៅកន្លែងការដ្ឋានរបស់អង្គរជ័យហ្នឹង ចា៎! ពេលដែលយើងដើរចូលទៅតាមផ្លូវអង្គរជ័យហ្នឹង ផ្លូវហ្នឹងរអិលមើលតែលាបខ្លាញ់ជ្រូកអញ្ចឹង។ ហើយពួកយើងខ្ញុំបានឃើញអ្នកជម្លៀសនោះ ចា៎! គេដើរមកពីធ្វើការវិញ  ពីព្រោះថា ពេលយើងទៅដល់ហ្នឹងគឺពេលព្រលប់ៗ ហើយមានភ្លៀងឱ្យសស្រេច ចា៎!

រាសីៈ បាទ! តើអ្នកស្រី និងអ្នកឯទៀត ទាំងអស់គ្នាហ្នឹង ដឹងខ្លួនថា គេផ្លាស់កន្លែងដែរ ឬទេ?

សារីមៈ យើងអត់ដឹងទេ គ្រាន់ថា អង្គការឱ្យចេញ ពីព្រោះនៅនោះគេមិនដែលប្រាប់យើងថាយ៉ាងម៉េចៗទេ ចា៎!

រាសី៖ បាទ! ហើយអញ្ចឹង គេឱ្យយកអីវ៉ាន់អីទៅទាំងអស់ដែរ ហី?

សារីម៖ ចាំ! យើងយកតែស្បោងយើង សាក់កាដូយើងមួយហ្នឹង។ យើងមានតែប៉ុណ្ណឹង ចាំ!

រាសី៖ បាទ! ហើយតើមានអារម្មណ៍ភិតភ័យក្នុងខ្លួនថា ខ្លាចគេយកទៅសម្លាប់ដែរទេ?

សារីម៖ ចាំ! ខ្ញុំពេលហ្នឹង ដូចថា ខ្ញុំមិនភ័យអីទេ។ យើងឃើញថា អ្នកឯងដឹកឡានមក ខ្ញុំឡើងឡាន។ ហើយខ្ញុំជិះទៅ រួចអត់មានអារម្មណ៍ថា ភ័យអីទេ ព្រោះមើលទៅឃើញខ្លួនឯងដូចជាអត់មានធ្វើអីខុសទេ ចាំ!

រាសី៖ បាទ! ចុះអ្នកឯងទៀតមានអ្នកណាភិតភ័យ មានអ្នកណាបង្ហាញនូវការភ័យខ្លាចអីទេ?

សារីម៖ ចាំ! ពួកខ្ញុំនៅក្នុងឡានហ្នឹង ដូចអត់ឃើញមានអ្នកណាភ័យអីទេ ចាំ!

រាសី៖ តើនេះជាលើកទី១ ហើយដែលតាំងពីអ្នកស្រីចេញពីសាលាតិចណូមកនៅភូមិ នៅតាលៃហ្នឹង ហើយជាលើកទី១បន្ទាប់ពីហ្នឹងមកដែលផ្លាស់ប្តូរទីលំនៅទៀតបាទ!?

សារីម៖ ចាំ! លើកទី១ ហើយយើងចេញទៅអង្គរជ័យហ្នឹងចាំ!

រាសី៖ បាទ! ហើយសូមអ្នកស្រីបន្តទៀតបាទ!

សារីម៖ ចាំ! ដល់ទៅអង្គរជ័យហ្នឹង យើងសំណាក់នៅកន្លែងរោងឡានមួយយប់ហ្នឹង។ ហើយមានម្នាក់នៅរោងឡានហ្នឹងនិយាយខ្លាំងៗ ហើយគាត់ត្មិះតេះដៀលបញ្ញាជននេះ បញ្ញាជននោះអញ្ចឹង។ គាត់និយាយអត់មានរអែងចិត្តអ្នកណាទេ។ យើងទៅដល់ ហើយ យើងត្រូវការសម្រាកនៅពេលយប់ហ្នឹង ចាំ! ស្អែកឡើងបានគេនាំយើងទៅកន្លែងការដ្ឋានរបស់គេ។ ហើយគេចែកជាក្រុម ដូចថា ខ្ញុំអត់មានប្តីនៅជាមួយគេឲ្យនៅជាមួយពួកកងនារីគេ ចាំ! ក្នុងរោងមួយអញ្ចឹងទៅ ហើយគ្រែដែក គេដាក់ឱ្យយើងសម្រាកនៅហ្នឹង បន្តៗគ្នា។ ហើយគ្រែខ្លះ ដែលគេដាក់នៅក្បៀនជញ្ជាំងហ្នឹង សុទ្ធតែជាគ្រែមានថ្នាក់ៗ ចាំ! ហើយយប់ឡើងហ្នឹង យើងធ្វើការដល់យប់ជ្រៅទោះជាចូលមកសម្រាននៅម៉ោង២ភ្លឺក៏ដោយ ឱ្យតែម៉ោង៥ភ្លឺគេវាយជួងឱ្យយើងងើបទៀតហើយ។

ហើយនិយាយពីមូសនៅអង្គរជ័យហ្នឹង ដូចបាចអង្កាមអញ្ចឹង។ កុំដាក់ជើងចេញក្រៅ

គឺថា ទះទៅងាប់គឺមូសពេញដៃនៅអង្គរជ័យ ចាំ! ព្រឹកហ្នឹងពេលគេវាយជួង យុវនារីខ្លះស្រែកថា «អូយ! អញមិនទាន់បានដេកផង វាវាយជួងឱ្យអញងើបទៀតហើយ»។ គាត់ថា «អញមិនខ្ចីងើប»។ ប៉ុន្តែខ្ញុំលួចសើច ហើយខ្ញុំមើលឃើញគាត់ខំពត់ខ្លួនគាត់ ហើយស្វាប រួចខំអូសខ្លួនគាត់ហ្នឹងងើបឡើង គឺថា កេះអាចម៍ភ្នែក ហើយដើម្បីទៅធ្វើការទៀត គឺថា អត់មានផ្លាស់ខោអាវអីទេ ចាំ! ពេលហ្នឹងគឺគេមានផែនការវាយសម្រុកនោះ ចាំ!

រាសី៖ បាទ! ហើយអញ្ចឹងដល់ពេលហ្នឹងមានផ្លាស់ប្តូរទេបាទ?

សារីមេះ ចាំ! ក្រុមអ្នកដែលមានកូនទៅជាមួយ ហើយមានប្តីប្រពន្ធអញ្ចឹង គេដាក់នៅកន្លែងផ្សេង ឆ្ងាយពីពួកខ្ញុំ។ ហើយពួកខ្ញុំមិនដឹងថា គេនៅត្រង់ណាទេ ចាំ! ប៉ុន្តែដល់ ពេលយើងទៅដល់អង្គរជ័យហ្នឹងគឺសឹងតែពីរថ្ងៃក្រោយមក ទើបបែកការណ៍គឺពួកហ្នឹងគេដឹងថា យើងហ្នឹងមកពីបរទេស។

រាសី៖ បាទ! ពួកណាបាទ?

សារីមេះ ពួកនារីធ្វើការនៅទីហ្នឹងចាំ! គេដឹងថា យើងមកពីបរទេស ព្រោះមានលោកម្នាក់ហ្នឹងឈ្មោះលោកគង់ បុណសិរី។ ពេលគាត់ដើរទៅធ្វើការ ស្រាប់តែមាននាងម្នាក់មកហៅគាត់ថា «បងខ្ញុំស្គាល់បងឯងច្បាស់ណាស់! បងឯងនៅផ្ទះកន្លែង ជិតមេភ្លើង រួចទៅបងឯងទៅស្រុកបារាំង»។ ហើយលោកហ្នឹងឆ្ងល់ណាស់ថា អ្នកណាចេះមកស្គាល់គាត់ ហើយនាងហ្នឹងនិយាយថា គាត់ហ្នឹងធ្លាប់ស៊ីឈ្នួលនៅផ្ទះអ្នកណាជាប់ផ្ទះលោកសិរី ហ្នឹង ចាំ! ដល់អញ្ចឹងទៅ ថ្ងៃក្រោយមក ពួកខាងអង្គការខ្មែរក្រហមកន្លែងពេទ្យ ហៅកុមារណោដែលជាកូនរបស់លោកគង់ បុណសេរីហ្នឹង ហើយនឹងអ្នក វណ្ណានោះ ចាំ! គេហៅឲ្យទៅជួយមើលសំបុត្រពេទ្យ ថ្នាំពេទ្យអី ហើយឱ្យបកប្រែឱ្យគេ ចាំ! រួចមានអ្នកម្នាក់ទៀតនោះឈ្មោះអឹម។ គាត់រៀននៅសាលាមហាវិទ្យាល័យអក្សរសាស្ត្រនៅភ្នំពេញ ហើយបានលីសង់។ គាត់ទៅស្រុកបារាំង ហើយគាត់ទៅការ។ ប្តីឈ្មោះម៉េង។ ម៉េងហ្នឹងគឺជាអ្នកទៅពីអាមេរិក។ ម៉េងហ្នឹងមករៀនស្រុកអាមេរិករៀនខាងផ្នែកជំនួញ ហើយគាត់បានសញ្ញាបត្រគេហៅថា Master

degree ហើយគាត់ត្រឡប់ទៅស្រុកខ្មែរវិញជាមួយប្រពន្ធគាត់ ហើយនឹងប្អូនប្រុសរបស់ប្រពន្ធគាត់។ អ្នកអឹមនោះចាំ! ពេលអ្នកអឹមហ្នឹងទៅដល់ក៏គេស្គាល់គាត់ដែរ។ គេស្គាល់ថា គាត់ជាកូនចៅកៃលក់កង់នៅកំពង់ចាម។ ដល់អញ្ចឹងបែកការណ៍អស់ចាំ! រួចទៅ ពួកហ្នឹងគេមកស៊ើបពីខ្ញុំណាំ ហើយទៅខ្ញុំក៏និយាយប្រាប់ទៅថា «ខ្ញុំអង្គការបញ្ជូនមកកន្លែងហ្នឹង ហើយទៅគេមកសុំដូរគឺគេយកស្បែកជើងមកដូរថ្មដែកកេះជាមួយខ្ញុំ ចាំ! រួចទៅខ្ញុំដូរបានស្បែកជើងកង់ឡានមួយទៅ អស់ថ្មដែកកេះពីរប្រអប់តូចៗ។

រាសី៖ បាទ! ការដូរហ្នឹងគឺការដូរដោយចំហ ឬលួចលាក់ បាទ?

សារីម៖ ចាំ! នាងហ្នឹងមកខ្សឹបថា «បងឯងចង់បានស្បែកជើងកង់ឡានពាក់ទេ? បងឯងឱ្យថ្មដែកកេះខ្ញុំមួយប្រអប់មក»។ រួចទៅខ្ញុំថា អញ្ចឹងក៏សុខចិត្ត។ រួចទៅខ្ញុំឱ្យគាត់ទៅ។ ស្រាប់តែស្អែកឡើងគាត់មកទៀត ហើយថា «ខ្ញុំបាត់ហើយ ឥឡូវឱ្យសុំមួយប្រអប់ទៀត»។ ខ្ញុំថា អាហ្នឹងអស់ហើយ។ អញ្ចឹងបងឱ្យតែមួយប្រអប់ទៀតទេ។ អាហ្នឹងខ្ញុំអស់ហើយ ខ្ញុំសល់តែមួយទៀតទេ»។  ខ្ញុំភ្ញូតគាត់ ចាំ! រួចទៅគាត់ឱ្យខ្សែស្បែកជើងខ្ញុំមួយគូរទៀតសម្រាប់ផ្លាស់ប្តូរ។ ហើយស្បែកជើងកង់ឡានហ្នឹងជួយខ្ញុំច្រើនណាស់ចាំ!

រាសី៖ បាទ! អញ្ចឹងនៅពេលហ្នឹងកាលនៅតាលៃអត់សូវជួបជាមួយអ្នកដទៃទេ ដល់មកដល់អង្គរជ័យ ដូចជាមានការផ្លាស់ប្តូរ នៅជិតគេជិតឯង បាទ?

សារីម៖ ចាំ! ជួបតែពួកនារីដដែលហ្នឹងគឺនារីស្នូលរបស់អង្គការខ្មែរក្រហមហ្នឹង។ ប៉ុន្តែក្នុងពួកនារីស្នូលហ្នឹងមានអ្នកខ្លះជានារីសែងគ្រាប់ ហើយអ្នកខ្លះទៀតជានារីកូនអ្នកស្រុកធម្មតាទេ។  ប៉ុន្តែពេលដែលអង្គការខ្មែរក្រហមឈ្នះហ្នឹងគឺថា គេបានប្រមូលពួកយុវនារី យុវជនឱ្យមកចូលជាកងចល័ត ចាំ! ដល់អញ្ចឹងទៅ គេបញ្ជូនអ្នកទាំងអស់ហ្នឹងមកធ្វើការជាមួយគ្នា ជាកងនារីអញ្ចឹង។

រាសី៖ បាទ! ហើយអញ្ចឹងអ្នកស្រីមានប្រសាសន៍ថា កងនារីអញ្ចឹងអត់មានយុវជនទេ ហី?

សារីមៈ ចាំ! យុវជនមានតិចណាស់នៅកន្លែងហ្នឹង។ ខ្ញុំនៅទីហ្នឹង ខ្ញុំមើលនៅឃើញតែនារីៗទេ ចាំ!

(ផ្នែកនេះចុះក្រោមអត់មានអត្ថបទខ្មែរប៉ុន្តែមានអង់គ្លេស)

(មានដូចបកប្រែអង់គ្លេសពីត្រឹមនេះទៅ)

# ជីវិតក្នុងបឹងត្របែក

ចាំ! សូមជម្រាបថា នៅបឹងត្របែកហ្នឹង...ចេះតែមានអ្នកចូលទៅបឹងត្របែកហ្នឹងជាហូរហែរ រហូតដល់ឆ្នាំ១៩៧៧ ហើយក៏មានអ្នកចូលទៅ។ តាមខ្ញុំចាំ មុនដំបូងមានលោកហ៊ីន អ៊ុន ដែលជាប្រធានហ្វ៊ុងនៅស្រុកបារាំង។ គាត់ហ្នឹងជានាយកខាងកសិកម្មនៅក្រុងភ្នំពេញពីសម័យសម្ដេចសីហនុ។ គាត់ចូលទៅជាមួយម្នាក់ទៀតឈ្មោះ សៀង ហាក់។ សៀង ហាក់ហ្នឹងជាអ្នកមានឯកទេសខាងដឹកជញ្ជូនប្រេង។ គាត់ជាកូនប្រសាររបស់លោកសារិន ឆាក។ ហើយរួចមកមានកង សន្និវ៉ាត់ជាមួយប្រពន្ធគាត់ឈ្មោះកេត ហើយនឹងកូនស្រីប្រុសតូចៗពីរនាក់ ចាំ! សន្និវ៉ាត់ហ្នឹងធ្លាប់រៀននៅមហា វិទ្យាល័យអក្សរសាស្ត្រជាមួយខ្ញុំនៅទីក្រុងភ្នំពេញ ហើយខ្ញុំឮថាអេងហ្នឹងមានឯកទេសខាងរក្សាម្ហូបទុកឱ្យបានយូរ ហើយអ្នកចូលទៅចុងក្រោយគេហ្នឹងគឺមានឈ្មោះ ទេព យុនណាល់ ដែលចូលទៅជាមួយប្រពន្ធគាត់។ ហើយទេព យុនណាល់ហ្នឹងគឺជាមនុស្សដែលឥឡូវហ្នឹងកំពុងតែបានអ្នកមេម៉ាយប៉ុល ពតជាប្រពន្ធនោះ ចាំ! ហើយពេលដែលគាត់ចូលទៅហ្នឹង មានអ្នកម្នាក់ហ្នឹងឈ្មោះតាតចាន់សារី ធ្វើដុកទ័រ ភ្នែក។ គាត់ចូលពីស្រុកបារាំងទៅដែរ។ គាត់ហ្នឹងនៅលីវ ហើយជាកូនរបស់លោកតាត ហេង ធ្វើ Inspecteur គ្រូបង្រៀននោះ ចាំ! ហើយនឹងមានស្រីម្នាក់ទៀត។ គេថា ជាកូនទូត ចេះដល់៥ភាសា។ គាត់ចូលទៅថ្ងៃជាមួយគ្នាហ្នឹង

ទេព យុនណាល់ ហើយនឹងប្រពន្ធហ្នឹង។ ហើយអ្នកចុងក្រោយគេបង្អស់ដែល ចូលទៅបឹងត្របែកហ្នឹងគឺទៅពីស្រុកអាមេរិក។ គាត់ហ្នឹងឈ្មោះ យូន ឆោម។ គាត់ មានកូនឈ្មោះ យូន ដារិត។ គេធ្វើការនៅបេសកកម្មរណសិរ្សរបស់ សម្ដេចសីហនុ នៅក្រុងប៉ារីសហ្នឹង ចាំ! ហើយសុំជម្រាបថា ក្រោយពីយុនណាល់ហ្នឹងចូលទៅបាន តែមួយយប់ ស្អែកឡើងគេឲ្យពួកខ្ញុំហ្នឹង។ ខ្ញុំស្គាល់គាត ចាន់សារីហ្នឹង។ ខ្ញុំស្គាល់ គាត់ ពីព្រោះខ្ញុំនឹងគាត់ស្រករៗគ្នា។ ពេលហ្នឹង គាត់សួរអំពីខ្ញុំ ខ្ញុំគ្រាន់តែប្រាប់ថា កន្លែងនេះត្រូវនិយាយតិច ហើយស្ដាប់ឱ្យបានច្រើន។ យើងក៏បែកគ្នាទៅ ព្រោះ ស្អែកឡើងខ្ញុំត្រូវចេញទៅកន្លែងផ្សេងនោះចាំ!

ចាំ! ដូចខ្ញុំជម្រាបពីលើកមុនថា កាលដែលពួកខ្ញុំរស់នៅជុំវិបឹងត្របែកហ្នឹង គឺថា មានការប្រឈមមុខគ្នាច្រើនណាស់ ប្រធានក្រុមរបស់ខ្ញុំហ្នឹងឈ្មោះយន់។ គាត់ហ្នឹង ជូរចត់ណាស់ ចាំ! ហើយគាត់តាមកសាងខ្ញុំ ហើយនឹងមិត្តសាន ដែលជាអ្នកធ្វើ ពេទ្យនោះ។ ហើយគាត់កសាងខ្ញុំថា ខ្ញុំហ្នឹងមិនស្ដាប់អង្គប្រជុំរបស់អង្គការទេ។ ពេល ប្រជុំហ្នឹងចេះតែមើលតែផ្កា ដើមផ្កាពោធិ៍ព្រឹក្សដែលផ្កាវាជ្រុះមកក្រាលដី។ ហើយ អារម្មណ៍ហ្នឹងមិនមូលស្ដាប់អង្គការ។ រួចទៅឱ្យខ្ញុំរៀបរាប់ថា «មើលថ្ងៃមុនហ្នឹង អង្គការនិយាយអីខ្លះ»។ រួចខ្ញុំរៀបរាប់ប្រាប់។ គាត់ទាល់តម្រិះរាយការណ៍អំពីខ្ញុំមិន កើត ចាំ! ហើយមិត្តសានហ្នឹងធ្វើពេទ្យហ្នឹង។ គេឱ្យមិត្តសានហ្នឹងសម្លាប់កូនអណ្ដើក តូចមួយ។ ដោយសារមិត្តសានមិនហ៊ានសម្លាប់សត្វហ្នឹង គេបង្ខំមិត្តសានឱ្យអារ-ក អណ្ដើកហ្នឹង ចាំ! បងយនហ្នឹងនិយាយ ថា «នែ! សម័យយើងនេះ យើងរស់នៅដូច ក្នុងឋានសួគ៌ អញ្ចឹង ព្រោះថា យើងមកពីធ្វើការវិញ យើងមានបាយដាក់នៅលើតុ ព្រោះថា នៅប្រទេសណាក៏ដោយមិនមានអ្នកណាត្រឡប់ពីធ្វើការមកវិញមានបាយ ស្រាប់ចាំនៅលើតុទេ មិនបាច់ធ្វើបាយនោះ ចាំ! ហើយពួកយើង ដែលនៅខាង ក្រោយ នាំគ្នាលួចសើច ពេលគាត់និយាយថា ដូចឋានសួគ៌នោះ។ ហើយយប់ៗ គាត់សម្រានផ្ទះជាមួយយើងហ្នឹង។ គាត់មមើច្រើន មិនដឹងជាចាប់អ្នកណា អី អ្នកណា ដេញអ្នកណាអីទេ ចាំ! ឮសូរតែស្រែកហៅ«ចាប់ៗ» ចាំ! និយាយពីមិត្តយន់ ប្រធានក្រុមខ្ញុំហ្នឹង ខ្ញុំដូចជាចាំថា គាត់ហ្នឹងជាឈ្មួលទូតម្នាក់ដែរ។ ហើយគាត់ថា

ប្រជាជនយួន ហើយនឹងប្រជាជនខ្មែរហ្នឹងរាប់អានគ្នាដូចបងប្អូន តែរដ្ឋាភិបាលទេ ដែលចេះតែធ្វើឱ្យប្រជាជនទាំងពីរហ្នឹងមិនត្រូវគ្នា។ ហើយថ្ងៃមួយ ខាងអង្គការ បញ្ជូនពួកខ្ញុំហ្នឹង ពិសេសស្រីៗប្រហែលជិត២០នាក់ចេញទៅធ្វើការនៅកន្លែងមួយទៀត ហើយពេលដែលយើងចេញទៅហ្នឹងគឺមានពួកកូនពួកទូត ដែលនៅជាប់នឹងកន្លែងយើង ហ្នឹងក៏ទៅដែរ ហើយខ្ញុំចាំថា ពេលនោះមានកូនស្រីរបស់លោក ហោ ណាំហុងហ្នឹងទៅដែរ។ នាងហ្នឹងអាយុប្រហែលមិនដល់១៦ឆ្នាំទេ ចាំ! ហើយនៅមានកូនទូតឯទៀតៗ ដូចជាកូនលោកចែម ស្នួន កូនលោក អៀង គុនសុគីជាដើម ចាំ!

រាសី៖ បាទ! តើការបញ្ជូនចេញទៅកន្លែងហ្នឹង គឺគេមានឱ្យដឹងមុនអីទេ ឬក៏ធ្វើភ្លាមៗតែម្ដង បាទ?

សារីមេ៖ ចាំ! យើងអត់បានដឹងមុនទេ ស្រាប់តែគេថា ឥឡូវហ្នឹងឱ្យពួកស្រីៗហ្នឹងរៀបចំអីវ៉ាន់ទៅ។ យើងចេញទៅមានឡានគេហ្នឹង ដែលឈប់នៅផ្លូវថ្នល់នៅកន្លែងរង្វង់មូល។ ពេលយើងទៅដល់ស្រាប់តែឃើញពួកខាងកូនទូតហ្នឹងអង្គុយនៅទីហ្នឹងរួចជាស្រេច ចាំ!

រាសី៖ បាទ! អញ្ចឹងតើអ្នកស្រីមានការព្រួយបារម្ភដែរដែលថា ពីពេលមុនមានគេយកមនុស្សទៅអញ្ចឹង របៀបថា សម្លាប់ចោល។ ប៉ុន្តែគេកុហកថា ទៅធ្វើការអញ្ចឹង។ អ្នកស្រីមានការតក់ស្លុតទេពេលហ្នឹង?

សារីមេ៖ ចាំ! ខ្ញុំអត់ដែលភ័យទេនៅជាមួយខ្មែរក្រហមហ្នឹង ពេលទៅណា ខ្ញុំអត់មានបារម្ភថា «អូ! ប្រហែលយកខ្ញុំទៅសម្លាប់ចោលអី គឺអត់។ ដល់ពេលទៅ ពួកខ្ញុំឃើញឡានហ្នឹងវាមិនមែនឡានហ្សុីប ដូចគេនិយាយនោះទេ ចាំ! ឡានហ្នឹងដូចឡានក្រុង ដូចឡានឈ្នួលដឹកមនុស្សពីព្រៃវែងភ្នំពេញអញ្ចឹង ចាំ!

រាសី៖ បាទ! លក្ខណៈខុសគ្នា?

សារីមេ៖ ចាំ! ។

រាសី៖ បាទ! ហើយការធ្វើដំណើរទៅកន្លែងហ្នឹងមានចម្ងាយប៉ុន្មានដែរ?

សារីម៖ ចាំ! វត្តដែលពួកយើងទៅដល់ហ្នឹងគេហៅវត្តស្លែង។ កន្លែងហ្នឹងជាការដ្ឋានមួយ។ គេយកពួកខ្ញុំហ្នឹងទៅដាក់ឱ្យដេកនៅក្នុងវិហារវត្តហ្នឹង ចាំ! កន្លែងហ្នឹងមិនឆ្ងាយពីភ្នំពេញប៉ុន្មានទេ តាមខ្ញុំមើល ដូចជានៅខាងលិចភ្នំពេញ ហើយយ៉ាងច្រើនប្រហែលថា ១០គីឡូចុះពីភ្នំពេញហ្នឹង។ អញ្ចឹងយើងទៅនៅក្នុងវិហារហ្នឹងទៅ ហើយគេក៏ឱ្យយើងធ្វើការ ពេលហ្នឹង។ យើងទៅជួយច្រូតស្រូវ ហើយនឹងជញ្ជូនស្រូវយកមកគរទុកនៅក្នុងវត្ត ចាំ! ហើយក្រោយមក ហ្នឹងគេឱ្យយើងទៅជីកនិងរែកដី ចាំ! រែកដីហ្នឹងគឺថា មនុស្សច្រើនមែនទែនមកពីគ្រប់ទិសទី ហើយពួកយើងទៅសុទ្ធតែស្រីៗ។ ប៉ុន្តែអ្នកដែលយើងទៅជួបហ្នឹងគឺថា មានយុវជន យុវនារីមកពីណាយើងមិនដឹងទេ ចាំ!

រាសី៖ បាទ! រែកដីធ្វើអី ធ្វើទំនប់ ឬក៏ជីកប្រឡាយអី?

សារីម៖ ចាំ! គេឱ្យយើងជីកដី ហើយគេថា ធ្វើទំនប់ទប់ទឹក ចាំ!

រាសី៖ បាទ! ហើយអញ្ចឹងបានន័យថា ពេលចេញទៅ ទៅវត្តស្លែងហ្នឹងគឺយើងនៅគេងយប់ហ្នឹងហ្មង?

សារីម៖ ចាំ! នៅសម្រាន្តនៅហ្នឹង ហើយទៅគេឱ្យៗយើងទៅទទួលទានបាយជាមួយពួកគេ។ ដូចយើងទៅធ្វើការនៅអង្គរជ័យអញ្ចឹង ចាំ! ហើយពិសេសពេលយើងទៅដល់ហ្នឹងស្រាប់តែពួកនាងខ្លះ ដែលទៅជាមួយពួកខ្ញុំហ្នឹង គេស្គាល់បងប្អូនគេ គេជួបបងប្អូនគេ ចាំ! ពេលដើរទៅធ្វើការហ្នឹងស្រាប់តែពួកហ្នឹងស្គាល់ពួកយើងថា យើងហ្នឹងមកពីស្រុកបារាំង ព្រោះគេស្គាល់បងប្អូនគេនោះ។ ស្រាប់តែមួយថ្ងៃក្រោយមក យើងបាត់អីវ៉ាន់នៅក្នុងវិហារយើង ជាពិសេសខ្ញុំ។ ខ្ញុំនៅមានលុយ២៥០ហ្វ្រង់ពេលហ្នឹង។ខ្ញុំយកទៅទុកបង្ការខ្លួនខ្ញុំ ស្រាប់តែមកវិញបាត់លុយហ្នឹងអស់រលីង ចាំ! ប៉ុន្តែពួកយើងខ្ញុំមិនដឹងអ្នកណាបាត់អីទៀតទេ។ ខ្ញុំគ្រាន់តែដឹងថា ខ្ញុំបាត់លុយហ្នឹងទេ។ ប៉ុន្តែខ្ញុំក៏មិននិយាយអីដែរកុំឱ្យថា បែកការណ៍តទៅទៀត។

សារីមៈ ចាំ! ខ្ញុំសុំបន្តរឿងធ្វើការនៅការដ្ឋានវត្តស្លែងតទៅទៀត ចាំ! រួចទៅខ្ញុំជួបយុវនារីខ្លះ ដែលធ្វើការនៅអង្គរជ័យ នៅវត្តស្លែងហ្នឹង។ ខ្ញុំឃើញនាងម្នាក់ ខ្ញុំសួរថា «ម៉េចទៅអ៊ំជ័យ?» ស្រាប់តែនាងហ្នឹងគាត់កំពុងតែលោតបេះដូង។ នាងគាត់ប្រាប់ខ្ញុំថា «ហាក! ក្បត់ហើយ»។ រួចពេលហ្នឹងខ្ញុំភ័យមែនទែន ព្រោះ អ៊ំជ័យ នង សួនដែលថា ធ្វើមេប្រធានធំនៅការដ្ឋានអង្គរជ័យ ដល់ឮសូរនាងហ្នឹង ថាក្បត់អញ្ចឹង ខ្ញុំលែងហ៊ាននិយាយតទៅទៀត។ ហើយទៅនាងហ្នឹងក៏ថា «ពួកវាក្បត់ដូចតែគ្នាអញ្ចឹង នែ! មកកន្លែងវត្តស្លែងហ្នឹងពួកក៏ក្បត់ដែរ។ វាអត់ឱ្យយើងហូបទាំងអស់ តែបាយនិងទឹកប្របហុក។ នាងដែលមកពីអង្គរជ័យហ្នឹងនិយាយថា ពួកវា ពួកដែលនៅវត្តស្លែងហ្នឹងក្បត់គឺថា វាស៊ីចាក់ប្រាស់តែគ្នាវា ចំណែកយើងវិញ វាអត់ឱ្យអីស៊ីសោះ វាឱ្យស៊ីតែទឹកប្រហុក ចាំ! ពេលហ្នឹងយើងមានតែបាយ និងទឹកប្រហុកហ្នឹង ហើយទឹកប្រហុករាវៗ។ ហើយពេលអត់អីហូប មានតែបាយ និងទឹកប្រហុកអញ្ចឹង ពួកខ្ញុំទៅបូតម្អមនៅតាមភ្លឺស្រែវានោះសម្បូរ ចាំ! ម្អមស្រែ ចាំ! ដុះឡើងក្រញុំៗអញ្ចឹង ហើយល្អណាស់ ផ្កាវាឡើងពណ៌ស្វាយ ហើយពួកខ្ញុំទៅដកមកគេហៅថា ម្អបក្តាម។ យើងយកវាមកទទួលទានជាមួយទឹកប្រហុកហ្នឹងទៅ។ យូរៗទៅវាចង់មុតក្រពះយើង ចាំ! ដូចវារឹងពេក។

រាសីៈ បាទ! កាលហ្នឹងឆ្នាំណាបាទ អ្នកស្រី...?

សារីមៈ ចាំ! ពេលហ្នឹងគឺតាមខ្ញុំចាំ ដូចជាចុងឆ្នាំ១៩៧៧ ហើយចាំ! ដល់យើងធ្វើការអញ្ចឹងទៅ យើងជញ្ជូនស្រូវ ជញ្ជូនអីយកមកដាក់នៅក្នុងវត្តហ្នឹង គឺថា ស្រូវគរដូចភ្នំអញ្ចឹង។ ស្រូវហ្នឹងពណ៌មាស គឺដូចមាសអញ្ចឹង គេគរវាទាំងស្នឹមៗអញ្ចឹងថា ខ្ពស់ៗ ហើយស្រាប់តែថ្ងៃមួយ ពេលកណ្តាលអធ្រាត្រហ្នឹងស្រាប់តែគេស្រែកថា «អូ! ភ្លើងឆេះៗ»។ បន្ទាប់មកពួកយើងហ្នឹងនាំគ្នារត់ចេញពីវិហារហ្នឹងមក។ រួចខ្ញុំហ្នឹងភ័យណាស់ ព្រោះខ្ញុំចងអង្រឹងសម្រាន្តនៅសរសេរវិហារហ្នឹង។ រួចខ្ញុំក៏ខំវារចេញមក។ រួចខ្ញុំខ្លាចនាង មុនី និងនាង សុធី ដែលជាកូនរបស់លោកហ៊ីន អ៊ុនហ្នឹង ដែលសម្រាន្តនៅលើធ្នើៗហ្នឹង ជាន់ធ្នើហ្នឹងបះឈើមកសង្កត់លើខ្ញុំនោះ ចាំ! ខ្ញុំវារចេញ

ពីវិហារហ្នឹងមក មកដល់ឃើញភ្លើងឆេះកុដិរបស់លោក ចាំ! រួចទៅវាឆេះគំនរស្រូវដែលយើងគរហ្នឹង ហើយអត់មានអ្នកណារកទឹករកអីមកស្រោចទេ។ តែពួកយើងដែលថាស្រីៗចេញពីវិហារហ្នឹងមក ហើយនាំគ្នាយកប៉ោត យកអីទៅដួសទឹកយកមកស្រោច កុំឱ្យភ្លើងហ្នឹងវាឆេះ។ ប៉ុន្តែយើងថា ភ្លើងហ្នឹងឆេះពេញទំហឹងហើយ យើងធ្វើអីក៏មិនរួចដែរ។ ហើយពួកខ្ញុំនាំគ្នា ដូចថា ចង់យំណា ព្រោះស្តាយស្រូវដែលយើងខំជញ្ជូនមកនោះ ចាំ! ហើយខ្ញុំឃើញម្នាក់នោះឈរនៅជិតកុដិលោកហ្នឹង។ ខ្ញុំឃើញសសរហ្នឹងឆេះសុស ហើយវារៀបរលំ។ ស្រាប់តែម្នាក់ហ្នឹងដែលឈរជិតហ្នឹងបានដើរចេញផុត ហើយសសរហ្នឹងរលំចំកន្លែងគាត់ឈរហ្នឹង។ យើងឃើញថា អូ! ម្នាក់នេះមានសំណាងមែន ចាំ!

ហើយដល់ស្អែកឡើងចប់រឿងឆេះស្រូវឆេះអីអស់ ឆេះកុដិលោកអីអស់ច្រើនអញ្ចឹងទៅ  យើងដឹងថា អូ! ពួកគេហ្នឹងមានការចាក់សាំងអីជុំវិញវិហារដែលពួកខ្ញុំនៅហ្នឹង។ គេថា គេចង់ដុតពួកយើងដែលនៅក្នុងវិហារហ្នឹង ចាំ!

រាសី៖ អ្នកណាចង់ដុត បាទ?

សារីមៈ ចាំ! ឮសូរគេនិយាយអញ្ចឹង ព្រោះគេថា មានចាក់សាំងជុំវិញអញ្ចឹង ហើយដល់លើកក្រោយមកបានឮសូរគេនិយាយថា ពួកអ្នកដុតស្រូវឱ្យឆេះហ្នឹងគឺសុទ្ធតែពួកខ្មាំងដែលធ្លាប់ធ្វើវិទ្ធង្សនា មានលួចចាក់ទឹកបញ្ចូលក្នុងសសៃរបស់យោធាបដិវត្តន៍ ចាំ!

មុនពេលគេដុតស្រូវហ្នឹង គឺយប់មួយហ្នឹង ជាងពាក់កណ្តាលអធ្រាត្រហ្នឹង ស្រាប់តែឮសូរគេស្រែកថា «ខ្មាំងៗៗ» ដល់អញ្ចឹងទៅ ពួកយើងហ្នឹង ឮល្វើយៗអញ្ចឹង ក៏នាំគ្នារត់ចេញពីវិហារមក ហើយស្រាប់តែមកដល់ខាងក្រៅហ្នឹងអត់ឃើញមានអីសោះគឺពួកនាងយុវនារីខ្លះហ្នឹងគាត់ប្រឡែងគ្នា ហើយគាត់លោតតោងបេះដូង ពេលយប់ហ្នឹង ហើយគាត់ស្រែកអញ្ចឹង ចាំ! ហើយដល់រួចទៅបានគេប្តូរពួកខ្ញុំស្រីៗ ដែលទៅហ្នឹង ឲ្យមកនៅផ្ទះមួយទៀត ឆ្ងាយពីវត្តហ្នឹង ហើយទៅពួកកូនទូតក៏មកនៅកន្លែង

ជិតហ្នឹងដែរ ចាំ!

រាសី៖ បាទ! អ្នកស្រីមានប្រសាសន៍ថា ពួកកូនទូតហ្នឹង ពួកកូនទូតជំនាន់ណា?

សារីម៖ ចាំ! ពួកកូនទូតដូចជាកូនលោកហោ ណាំហុង កូនលោក ចែម ស្នួន ដែលគេធ្លាប់ធ្វើទូតឱ្យរណសិរ្សសម្ដេចសីហនុ ហើយត្រឡប់ចូលទៅវិញនោះ ចាំ! ពួកកូនទូតអស់ហ្នឹងគឺនៅបឹងត្របែកម្ខាងទៀតដែលកន្លែងពួកទូតនៅ ក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេសដែលមានលោក អៀង សារី ជារដ្ឋមន្ត្រី ការបរទេសពេលនោះ។

រាសី៖ បាទ! អញ្ចឹងពេលធ្វើការ ខាងអ្នកស្រីធ្វើការលំបាកយ៉ាងដូចម្ដេច ហើយខាងកូនអ្នកទូតហ្នឹងធ្វើការលំបាកដូចគ្នា ឬក៏យ៉ាងម៉េចដែរ?

សារីម៖ ចាំ! ពេលដែលយើងទៅនៅវត្តស្លែងគឺធ្វើការដូចគ្នា។ ទៅជញ្ជូនស្រូវដូចគ្នា។ ទៅសែងដីដូចគ្នាអញ្ចឹងចាំ!

រាសី៖ ចុះៗរឿងហូបចុក?

សារីម៖ ចាំ! យើងហូបកន្លែងជាមួយគេហ្នឹង។ កន្លែងការដ្ឋានគេ។ គេឱ្យយើងហូបម៉េច អ្នកអស់ហ្នឹងក៏ហូបអញ្ចឹងដែរ។

រាសី៖ បាទ! ហើយតើអ្នកស្រីមានដែលមានឱកាស ឬនិយាយជាមួយនឹងកូនអ្នកទូតទេ?

សារីម៖ ចាំ! ខ្ញុំពេលដែលយើងទៅធ្វើការហ្នឹង ខ្ញុំសង្កេតឃើញកូនអស់លោកទូតអស់ហ្នឹងកសាងគ្នាអាក្រក់ៗណាស់ចាំ! ដូចអត់មានត្រាប្រណីថាអ្នកមានកម្លាំងខ្សោយ អ្នកណាទន់ខ្សោយដូចថាកើតមកមានកាយសម្បទាមិនមាំមួនអីទេចាំ! ព្រោះខ្ញុំសង្កេតឃើញម្នាក់ហ្នឹងកូនលោក ចែម ស្នួន នាងហ្នឹងដូចថា គាត់ខ្សោយ។ វាខ្សោយធ្វើការមិនសូវបានទេ។ តាមខ្ញុំមើលគាត់ទៅ ឃើញសុខភាពគាត់អន់។ រួចទៅពួកដែលថាអ្នកកូនអស់លោកទូតដែលមកជាមួយគ្នាហ្នឹងគឺថា កសាងដោយពាក្យមុតៗណាស់។ខ្ញុំឃើញអញ្ចឹង ខ្ញុំថា អ្នកអស់នេះអត់មានយោគយល់គ្នាទេ។ អ្នកខ្លះមានកម្លាំង អ្នកខ្លះខ្សោយ។ ម្លោះហើយឱ្យធ្វើការដូចគ្នាមិនកើតទេចាំ។ ពេលយើងត្រឡប់ពីការដ្ឋានវត្តស្លែងវិញ ប្រហែលជាពីរអាទិត្យក្រោយមក ខ្ញុំឃើញមានឡាន

ឃ្លុបមួយហ្នឹងបើកកាត់ផ្លូវបឹងត្របែកដែលជាកន្លែងពួកខ្ញុំនៅហ្នឹងចូលទៅកន្លែងពួកទូតនៅ។ ខ្ញុំឃើញឡានឃ្លុបហ្នឹងពណ៌បៃតងចាស់។ ខ្ញុំគិតថា ឡានហ្នឹងប្រាកដជាឡានដឹកខ្មោចហើយ ច្បាស់ជាទៅដឹកខ្មោចនាងដែលកូនលោក ចែម សួន ដែលខ្ញុំឃើញថាខ្សោយចេះតែដកដង្ហើមផុតៗនៅការដ្ឋានវត្តស្លែងហ្នឹងហើយ។ រំលងប៉ុន្មានថ្ងៃក្រោយមក មែន! ខ្ញុំឮសូរគេថានាងហ្នឹងស្លាប់ដោយសារស្នះបេះដូងនៅបឹងត្របែកហ្នឹងក្រោយពីត្រឡប់ពីការដ្ឋានវត្តស្លែងហ្នឹងមកវិញ។ ចំណែកឯកូនលោកទូតម្នាក់ទៀត គឺកូនរបស់លោក អៀង គន់សុគី ដែលម្ដាយ ឈ្មោះ ប៊ុន ធូក នោះ គាត់ហ្នឹងពេលយើងដើរពីធ្វើការយប់ៗត្រឡប់មកកន្លែង យើងនៅដែលឆ្ងាយពីវិហារវត្តស្លែងហ្នឹង។ នាងហ្នឹងមើលទៅឃើញគាត់ដូចរញ៉ីរញ៉ៃ។ គាត់ខ្លាច ហើយសតិអារម្មណ៍គាត់មិននឹងនរ។ ទៅគាត់និយាយប្រាប់យើងថា គាត់ ហ្នឹងខ្លាចណាស់ព្រោះនៅហ្នឹងឃើញដូចមានខ្មាំងច្រើនណាស់។ ខ្ញុំហើយនឹងមិត្តសានដែលធ្វើពេទ្យហ្នឹងជួយប្រាប់គាត់ថា ហ៊ឺស! នែកុំបារម្ភច្រើនពេកព្រោះអង្គការបានប្ដូរយើងមកនៅឆ្ងាយពីវិហារហ្នឹងហើយៗឱ្យប្រមូលសតិអារម្មណ៍ឡើងដើម្បីយើងមានកម្លាំងធ្វើការឱ្យអង្គការ។

ពាសី៖ បាទ! និយាយអញ្ចឹងនៅពេលនៅវត្តស្លែងហ្នឹង តើគេឱ្យស្លៀកពាក់ខ្មៅ ឬក៏មានពណ៌ អីដែរ?

សារីម៖ ចាំ! នៅការដ្ឋានវត្តស្លែងសម្លៀកបំពាក់របស់យើងច្រើនតែខ្មៅ។

ពាសី៖ បានន័យថាអត់មានការតម្រូវឱ្យស្លៀកពាក់ទេ?

សារីម៖ ដូចអត់ចាំ! អត់មានការតម្រូវទេចាំ!

សារីម៖ តទៅនេះ ខ្ញុំនឹងជម្រាបពីមនុស្សខ្លះដែលធ្វើឱ្យខ្ញុំចាប់អារម្មណ៍ពេលយើងទៅធ្វើការនៅការដ្ឋានវត្តស្លែង។ ក្នុងចំណោមពួកយើងដែលទៅហ្នឹងមានបងម្នាក់ដែលយើងហៅគាត់ថាបងរ៉ុន។ បងហ្នឹងធ្លាប់ធ្វើជាឈ្នួលអ្នកការទូត។ បងរ៉ុនហ្នឹងចូលស្រុកខ្មែរតាមផ្លូវលំហូជីមិញ។ គាត់សុទ្ធតែហាត់នៅស្រុកចិនមុននឹងចូលស្រុក ដូចជាហាត់សែង លីអីធ្ងន់ៗឡើងភ្នំដើម្បីឱ្យធ្លាប់។ បង រ៉ុន ហ្នឹងពេលដែលធ្វើដំណើរតាមផ្លូវលំ

ហ្វជីមិញចូលដល់កម្ពុជាក្នុងតំបន់រំដោះគឺថាគាត់បានសរសើរពួកកម្មាភិបាល បដិវត្តន៍ហ្នឹងថា សុភាពរាបសារបដិវត្តន៍គឺគួរសមទន់ភ្លន់ណាស់។ ស្រាប់តែដល់ទៅនៅវត្តស្លែងហ្នឹងគឺថាមានមនុស្សមកពីច្រើនកន្លែងមកធ្វើការ។ ដូច្នេះពេលខ្លះគេបញ្ជូនយើងទៅធ្វើការមិនមែនជិតកន្លែងដែលយើងអាចមកទទួលទានបាយថ្ងៃត្រង់បាន។ គេដឹកបាយទៅចែកយើង។ គេដឹកបាយមួយរទេះ។ ពួកហ្នុងដែលអ្នកទៅធ្វើការហ្នឹងក្រុមរៀងៗខ្លួនដោយឱ្យមេក្រុមរបស់ខ្លួនទៅយកបាយ។ ពួកយើងចេះតែចាំ។ ដល់ពួកយើងទៅយកអស់បាយ។ នៅសល់បន្តិច។ រួចទៅបងវ៉ុន ប្រតិកម្ម។ គាត់ខឹង។ បងវ៉ុនថា ពួកនេះសុទ្ធតែខ្នាំង សុទ្ធតែក្បត់ជាតិ។ វាមកយកបាយមុន។ វាអត់មានគិតអ្នកនៅក្រោយវា។ យើងឃើញបងវ៉ុននិយាយអញ្ចឹង ខ្ញុំដូចស្ទើបដែរ។ ឃើញថា ដូច្នេះខ្ញុំអត់ឆ្ងល់ទេពេលដែលឃើញពួកនោះទៅយកបាយដោយមិនគិតគូរ ដល់អ្នកដទៃ។ បានន័យថា ពួកបងប្អូនយើងដែលគេចាត់ចែងកិច្ចការហ្នឹងអត់មានរបៀបអញ្ចឹងហ្នុងព្រោះធ្លាប់មានឧទាហរណ៍ស្រាប់។ កាលនៅតាលៃពួកយើងបានលើកឡើងពីជំហរសន្សំព្រោះគាត់ទុកបាយក្តាំង ហើយនឹងប្រហុកផ្អកឱ្យស្អុយរលួយនៅក្រោមផ្ទះមួយហ្នឹង។ ពេលយើងកសាងគេពីជំហរសន្សំសំចៃ ស្រាប់តែគេរឹតត្បិតមកលើយើង។ គេបន្ថយរបបអង្ករយើង។ ដល់ខ្ញុំឮសូរបងវ៉ុននិយាយអញ្ចឹងទៅ ខ្ញុំគិតថា នេះនាំឱ្យសៅហ្មងដល់ខ្លួនឥតប្រយោជន៍ព្រោះយើងកំពុងតែនៅក្នុងកណ្តាប់ដៃពួកហ្នឹងហើយ។ ពេលមកដល់ជំរំយើងនៅបឹងត្របែកវិញ បងវ៉ុនសុំសារ៉ែន ទៅពេទ្យធ្មេញ។ សារ៉ែនហ្នឹងជាប្រធានខ្មែរក្រហមធំនៅហ្នឹង។ រួចទៅសារ៉ែន ថា បងឯងហ្នឹងធ្លាប់ទៅពេទ្យតាំងពីសង្គមចាស់ច្រើនដងហើយ ដូច្នេះទុកកន្លែងឱ្យបងប្អូនយើងទៅម្តង។ នៅបឹងត្របែកហ្នឹងក្រោយមកឃើញបាត់ បងវ៉ុនហ្នឹងទៅ។

រាសី៖ បាទ! ប្រហែលជាយកទៅ។

សារីម៖ ហើយពេលនៅការដ្ឋានវត្តស្លែងហ្នឹង ពេលយើងឈប់សម្រាកមុនហូបបាយល្ងាច ខ្ញុំនិងម្នាក់ឈ្មោះសាន ដែលគាត់ធ្វើពេទ្យ ដែលពួកយើងហៅគាត់ថាសានសុទ្ធ ព្រោះ

គាត់មានកូនស្រីគាត់ឈ្មោះ សុទ្ធ។ ហើយកុំឱ្យច្រឡំជាមួយម្នាក់ទៀតឈ្មោះសាន ដែរ ដែលមានកូនស្រីឈ្មោះ យ៉ាន។ អ្នកហ្នឹងយើងហៅគាត់ថា សាន យ៉ាន។ សាន សុទ្ធ ហើយនឹងខ្ញុំចូលចិត្តធម្មជាតិដូចគ្នា។ ឱ្យតែពេលសម្រាកម្តងៗ យើងចូលទៅ កៀនគុម្ពឫស្សី ហើយយើងសម្រាកមុនពេលរៀបបាយល្ងាច។ ពួកខ្ញុំហើយនឹង សាន សុទ្ធ អង្គុយមើលថ្ងៃលិចគឺថា ដុំព្រះអាទិត្យហ្នឹងដូចជាដុំភ្លើងមួយយ៉ាងធំ ដែលកំពុងឆេះអញ្ចឹង ហើយសម្រុតខ្លួនគាត់យឺតៗចុះទៅពួននៅជើងមេឃហ្នឹង ថា មុននឹងចូលដេក ហើយជះពន្លឺក្រហមថ្លាពេញវាលមួយចំហៀងមេឃ ថាហ្នឹងជា ទិដ្ឋភាពមួយនៅទីវាលដែលល្អដក់ជាប់ក្នុងដួងចិត្តរបស់យើងខ្ញុំ។ រហូតមកដល់ថ្ងៃ ហ្នឹង។ ពេលដែលយើងឈប់សម្រាកហ្នឹង សាន សុទ្ធ ហ្នឹងបានរៀបរាប់ប្រាប់ខ្ញុំអំពី ការនឹកស្រណោះខ្លួនដែលមកចោលប្តីពីស្រុកចិនយកកូនមក។ សាន ហ្នឹងបានទៅ រៀន ស្រុកចិនតាំងពីតូច។ គាត់ជាកូនលោក វាំង អ៊ី។ គាត់ទៅរៀនស្រុកចិនដោយ មាន បងប្អូនប្រុសគាត់ទៅជាមួយផង ហើយឮសូរថា គាត់ហ្នឹងហាក់ដូចជាមាន ចំណងជិតស្និទ្ធដូចជាកូនចិញ្ចឹមរបស់លោក ជូ អេនឡាយ អញ្ចឹង។ បងប្រុសរបស់ គាត់ហ្នឹងក៏ចូលស្រុកវិញដែរ។ បងប្រុសគាត់ម្នាក់ហ្នឹងមានប្រពន្ធទៅជាមួយផង។ ដល់ខ្មែរក្រហមចូលស្រុកសាន សុទ្ធ ក៏សុំប្តីគាត់ត្រឡប់មកស្រុកវិញ។ គាត់ថាគាត់ នឹកស្រុកពេក។ ប្តីគាត់ខំឃាត់ ប៉ុន្តែគាត់មិនព្រម។ ឥឡូវនេះគាត់រង់ចាំដំណឹងពីប្តី គាត់។ គាត់បានប្រាប់ខ្ញុំថា គាត់មិនចង់នៅបឹងត្របែកតទៅទៀតទេ។ គាត់ចេញទៅ ធ្វើពេទ្យនៅដូចជាពេទ្យរុស្ស៊ីជាដើម ព្រោះគាត់ចេះជំនាញខាងចាក់ម្ជុលវិទ្យាសាស្ត្រ មែនទែនចាំ! ហើយគាត់សួរខ្ញុំថា ចុះបងឯងគិតម៉េចដែរ? ខ្ញុំថាចំពោះខ្ញុំៗមកស្រុក នេះហាក់ ដូចជាខ្ញុំសុខចិត្តបោះចោលជីវិតខ្ញុំនៅបឹងត្របែកចុះពីព្រោះខ្ញុំអត់មាន ជំនាញអីដូច សាន ទេ។ សានអាចទៅធ្វើការកន្លែងផ្សេងៗដើម្បីជួយមនុស្សច្រើន ជាងនៅបឹងត្របែក។ ប៉ុន្តែខ្ញុំសុខចិត្តធ្វើពលកម្មនៅបឹងត្របែកតទៅទៀត រហូតដល់ ពេលណាខ្ញុំបានជួបកូនខ្ញុំពីព្រោះធ្វើពលកម្មស្រួលជាងទៅធ្វើការអ្វីដែលអង្គការប្រើ ឱ្យនិយាយតាមពាក្យសម្តីរបស់គេពីព្រោះខ្ញុំរឹងអណ្តាត។ ខ្ញុំមិនអាចនិយាយតាម អង្គការបដិវត្តន៍ហ្នឹងបានទេ។ សានស្រណោះប្តីគាត់ ហើយគាត់បានប្រាប់ខ្ញុំថា

ពេលមុននឹងគាត់ចេញមក ប្ដីគាត់ហើយនឹងគាត់បានច្រៀងបទមួយថាទឹកទន្លេមេគង្គហូរថា! ហើយគេទាំងពីរនាក់បានលាគ្នា ហើយថាទោះជាយើងបែកគ្នាយ៉ាងណាក្ដី ក៏យើងនៅតែផឹកទឹកទន្លេមេគង្គដូចគ្នា។ ថ្ងៃមួយ នៅការដ្ឋានគាត់ឆ្លើយពេលដែលគេបញ្ជូនយើងទៅច្រូតស្រូវ។ ថ្ងៃហ្នឹងខ្ញុំមុតជើងនឹងសង្កសីផង ហើយពេលច្រូតស្រូវវាក្ដៅពេក។ ខ្ញុំអត់ស្រួលខ្លួនស្រាប់។ ខ្ញុំងើបឈរឡើង ខ្ញុំពត់ខ្លួនហើយខ្ញុំនិយាយថា យី! ព្រះអាទិត្យអើយក៏អត់មានត្រាប្រណីអីមកដល់កម្មករកសិករដែលកំពុងច្រូតស្រូវសស្រាក់សស្រាំ បើកថ្ងៃអីក៏ក្ដៅម្ល៉េះ។ ម៉េចក៏មិនធ្វើឱ្យមានពពកអីខ្លះមក ដើម្បីឱ្យយើងបានម្លប់ប្រយ័ត្នតែល្ងាចហ្នឹង ពេលអង្គប្រជុំហ្នឹងខ្ញុំកសាងព្រះអាទិត្យហ្នឹងម្ដងហើយ។ ខ្ញុំថាដែលមិនចេះជ្រោមជ្រែងក្នុងបដិវត្តន៍អញ្ចឹង។ រួចទៅអ្នកច្រូតស្រូវទាំងអស់គ្នាហ្នឹងនាំគ្នាសើច គិលឡើង រួចទៅខ្ញុំក៏ដូចធូរខ្លួន ហើយយើងក៏ច្រូតស្រូវតទៅទៀត។ រួចទៅស្រាប់តែល្ងាចឡើង ពេលប្រជុំជីវភាពហ្នឹង អ្នកផល្លា ដែលជាប្រធានក្រុមបានកសាងខ្ញុំថា ខ្ញុំហ្នឹងចង់បំផុសបំផុលមិត្តយើងនៅពេលធ្វើការថា! ហើយស្អែកឡើងគឺខ្ញុំគ្រុនក្ដៅខ្លាំង។ ខ្ញុំអត់បានទៅធ្វើការទេ ហើយទាំងថ្ងៃត្រង់ខ្ញុំឃើញគេយកខ្មោចច្រើនមកដុត ហើយវាឈ្ងៀមក្លិនខ្មោចពេក ខ្ញុំ ងើបឡើងខ្ញុំរត់ទៅសួរម្នាក់ៗដែលឈឺដូចខ្ញុំដែរថា មានឃើញគេយកខ្មោចមកដុតទេ? ហើយអ្នកហ្នឹងគាត់ស្ទុះមកឱបខ្ញុំថា បងឯងមមើមមាយហើយ។ ល្ងាចបន្តិចបានគាត់ឈឺស្រាល ដើរទៅយកបបរមកឱ្យខ្ញុំហូប។ ពេលយើងឃើញថ្ងៃលិចនៅវាលស្រែម្ដងៗ សាន តែងតែកំប្លែង ហើយប្រាប់ខ្ញុំថា បងឯងចង់កសាងព្រះអាទិត្យទៀតទេ? យើងនាំគ្នាសើច។ ហើយខ្ញុំប្រាប់សាន ថា ខ្ញុំមកស្រុកខ្មែរហ្នឹងជីវិតខ្ញុំដូចខ្ញុំបោះចោលអញ្ចឹង។ អញ្ចឹងហើយបានខ្ញុំឆ្លើយជាមួយអ្នកផល្លា ដែលកសាងខ្ញុំហ្នឹងថាដើម្បីឱ្យខ្ញុំបានធូរអារម្មណ៍ ហើយក៏មិត្តយើងក៏បានធូរអារម្មណ៍ធ្វើការតទៅទៀតព្រោះវាក្ដៅពេក។

ខ្ញុំសុំបន្តរឿងនៅវត្តស្លែងតទៅទៀតថា ប្រហែលមួយអាទិត្យមុនយើងត្រឡប់មកបឹងត្របែកវិញ។ ពេលនៅសម្រាកមុនថ្ងៃត្រង់ យើងបានឃើញឡានតូចមួយពណ៌សបើកចូលទៅតាមវាលស្រែគឺថាលឿនមើលទៅលឿនអាក្រក់មែនទែន។ ពួកយើង

នាំគ្នាសួរថា ចុះអ្នកណាក៏បើកឡានអីអាក្រក់ម្ល៉េះ? ស្រាប់តែមានអ្នកខ្លះស្គាល់។ គេថាឡានហ្នឹងគឺកូនប្រសាររបស់លោក អៀង សារី។ គេបើកមកមើលកិច្ចការអីនៅតាមកន្លែងដែលយើងធ្វើការហ្នឹង។ ថ្ងៃមួយក្រោយពេលយើងចេញពីរោងបាយនៅវត្តស្លែង ស្រាប់តែខ្ញុំឃើញអ្នកម្នាក់ឈ្មោះអ្នកហែម រ៉ាវ៉ាន់។ គាត់ធ្លាប់រៀននៅសាលានរោត្តម ជាមួយខ្ញុំ។ ប៉ុន្តែគេនៅរៀនថ្នាក់លើខ្ញុំ។ ឃើញគាត់ឈរមើលគេចេញពីរោងបាយមក។ គាត់ស្លៀកពាក់របៀបដូចកម្មាភិបាលខ្មែរក្រហម។ នៅវត្តស្លែងមានដើមផ្កាចំប៉ីច្រើនណាស់។ ផ្កាក៏ច្រើន ហើយពួកខ្មែរក្រហមបានប្រាប់យើងថាផ្កាចំប៉ីហ្នឹងគេលក់ក្រៀមទៅឱ្យក្រុងហុងកុងសម្រាប់ឆុងទឹកផឹក គឺថាលាងសម្អាតគ្រឿងក្នុងខ្លួនហ្នឹងពីជាតិពុលចាំ! ហើយក្រោយពេលដែលខ្ញុំជាដើងបន្តិចមក ខ្ញុំទៅរែកដីអត់កើតទេ។ គេឱ្យខ្ញុំធ្វើជាអ្នកលុងដីដើម្បីឱ្យគេរែក។ ដល់ខ្ញុំចូលលុងដីទៅ ខ្ញុំឃើញថាដីហ្នឹងវាត្រូវតែរលំហើយ។ ខ្ញុំវារចេញមកវិញ។ អ្នកយុវនារីគេនៅពីខាងក្រៅខ្ញុំ។ គេប្រាប់ថា កុំចេញមក។ ចូលទៅវិញ។ គេថាមិនទាន់បានទេ។ លុងទៀត។ ខ្ញុំថា ទេ បើចង់លុងទៀតចូលទៅខ្លួនឯង។ ខ្ញុំក៏វារចេញមក។ ដល់ខ្ញុំមិនទាន់បានងើបឈរផងស្រាប់តែក្រឡេកក្រោយទៅឃើញ។ ដីហ្នឹងសង្កត់នាងហ្នឹងដែលវារចូលទៅហ្នឹង។ វារលំមក។ វាសង្កត់នាងហ្នឹង។ ពួកគេខំកាយដីយកនាងហ្នឹងទៅពេទ្យទៅចាំ! ហើយមានមិត្តយើងខ្លះប្រាប់ខ្ញុំថា យី! បងឯងប្រយ័ត្នមានរឿង? ខ្ញុំថាមានរឿងយ៉ាងម៉េច បើខ្ញុំប្រាប់ហើយថាដីហ្នឹងវារលំឥឡូវហើយៗមិនជឿខ្ញុំ។ ថ្ងៃមួយ ពេលល្ងាចដែលយើង ត្រឡប់មកពីធ្វើការវិញ ស្រាប់តែខ្ញុំឃើញមានឡានឡំប្រីតាមួយហ្នឹងបើកចូលទៅផ្ទះដែលមកនៅវាលស្រែ ហើយពេលហ្នឹងខ្ញុំឃើញអញ្ចឹង។ ខ្ញុំក៏ទៅប្រាប់នាងដានី ថា ដានី ល្ងាចឡានហ្នឹងច្បាស់ជាមកយកដានីឯងទៅជួបប្តីហើយៗ ដានីគាត់សួរខ្ញុំថា ម៉េចបានបងឯងដឹង? ខ្ញុំថាចុះបើអង្គការផ្សាយតាម រ៉ាត់យោ (វិទ្យុ) ថា កាត់ផ្តាច់ទូតជាមួយយួន ហើយអញ្ចឹងប្តីដានីឯងធ្វើទូតនៅហាណូយហ្នឹងមិនត្រូវត្រឡប់មកផ្ទះវិញ។ ស្រាប់តែគេមកប្រាប់ឱ្យដានីហ្នឹងរៀបចំអីវ៉ាន់ ហើយដានីក៏ចេញទៅ។ សុំជម្រាបថាដានីហ្នឹងគឺជាមនុស្សម្នាក់ ដែលខ្ញុំហៅគាត់ថា អា ប៊ុលដូហ្សែ (Bulldozer) កាលនៅជំរំបឹងត្របែក

ព្រោះគាត់មាឧមាំ ហើយពេលដែលយើងលើកជើងដំរីបុកសង្កសីសម្រាប់ធ្វើបង្គីរែក ដីនោះ ខ្ញុំហើយដានីហ្នឹងពេលខ្លះយើងនាំគ្នាវាយព្នសូរសង្កសីខ្លាំងផង យើងនាំគ្នាស្រែកច្រៀងលេងដូចច្រៀងបទបារាំងផ្សេងៗអញ្ចឹងទៅ។ ដានីមានកូនប្រុសគាត់តូចមកជាមួយផង។ ដានី មានបងប្អូនបីនាក់ដែលត្រឡប់ទៅស្រុកវិញ។ អ្នកដានីហ្នឹងគឺគាត់ឈ្មោះ ប៉ុក ដានី ចាំ! ហើយបងស្រីគាត់ឈ្មោះ ប៉ុក ម៉ូណា ហើយប្អូនស្រីគាត់ទៀតឈ្មោះ ប៉ុក យ៉ានីន ជាពិសេសបងប្អូនស្រីរបស់អ្នកប៉ុក ដានី ហ្នឹងកាន់កិច្ចការសំខាន់ៗណាស់នៅក្នុងរបបខ្មែរក្រហម។ អ្នកប៉ុក ម៉ូណា ធ្វើជាប្រធានរាល់តែដង ហើយនឹង អ្នកប៉ុក យ៉ានីន បង្រៀនភាសាអង់គ្លេសឱ្យយុវជនស្នូលរបស់ខ្មែរក្រហមណោះចាំ!បងប្អូនប្រុសគាត់ម្នាក់ហ្នឹងគេហៅ ចេង ជាបងប្អូនឪពុកតែមួយម្តាយដោយខ្លួនជាមួយដានីក៏ទៅស្រុកវិញដែរគឺគាត់មានប្រពន្ធ សៀម តែប្រពន្ធគាត់ហ្នឹងអត់មកទេ ហើយចេងត្រូវពួកខ្មែរក្រហម សារ៉ន ធ្វើបាបខ្លាំងណាស់ ហើយចាប់គ្នាយកទៅកាត់សក់ក្រឡឹងមើលតែសាធមិស្លាដូងអញ្ចឹងចាំ!ប៉ុន្មានថ្ងៃក្រោយពីដានី ចេញទៅ ពួកយើងហ្នឹងក៏បានចេញមកវិញដែរ។ ពេលដែលយើងចេញហ្នឹងខ្ញុំមើលទៅឃើញ វណ្ណា សប្បាយជាងគេ ព្រោះ វណ្ណា អត់ចូលចិត្តកាំជណ្តើរផ្ទះដែលយើងនៅក្នុងវាលស្រែនៅការដ្ឋានវត្តស្លែងនោះទេព្រោះជណ្តើរហ្នឹងធ្វើពីឬស្សីមូលៗ។ ពេលឡើងជណ្តើរហ្នឹងម្តងៗ វណ្ណាធ្វើមុខជូរ។ ដល់យើងមកដល់បឹងត្របែកវិញ គេដាក់ពួកយើងឱ្យនៅផ្ទះមួយជាមួយគ្នានៅមាត់ផ្លូវចូលទៅជំរំបឹងត្របែកយើងតែម្តងចាំ! ហើយយើងក៏បោសសម្អាតផ្ទះហ្នឹងទៅ។ ស្រាប់តែម៉ែអាយោ ស្រែកថា អ្ហូយ! មើលលុយដុល្លារមួយបាច់។ ហើយទៅបានពួកយើងទាំងអស់គ្នាថា យកចេញមក។ យកមករាប់មើលដើម្បីឱ្យឃើញទាំងអស់ គ្នា។ យើងរាប់មើលទៅឃើញលុយដុល្លារនៅក្នុងបាច់ហ្នឹងមានក្រដាសរុំព័ទ្ធវា។ យើងរាប់មើលទៅឃើញ៧០០ដុល្លារ។ រួចយើងនាំគ្នាយកលុយហ្នឹង ទៅឱ្យប្រធានយើងនៅកន្លែងហ្នឹងទៅដើម្បីឱ្យគេដឹងព្ទ។ ហើយយប់ហ្នឹងស្រាប់តែមានគេស្រែកថា មនុស្សចូលភូមិៗ។ ពួកយើងហ្នឹងនាំគ្នាចេញមកឈរនៅរានហាល។ អ្នកដែលខំរកមនុស្សដែលចូលភូមិហ្នឹង រកអត់ឃើញ។ ប៉ុន្តែពួកស្រីៗយើងមើលពីលើទៅ។ យើងឃើញមាន

ពាងច្រើនណាស់តម្រៀបនៅ កន្លែងជិតរោងបាយយើង។ ហើយអ្នកដែលរកមនុស្ស ហ្នឹងថា ឃើញមនុស្សរត់មកនៅជិតម្ដុំហ្នឹង។ ដល់អញ្ចឹងយើងពួកស្រីៗនៅឈរពីលើ យើងថា ឥឡូវហ្នឹងបើកពាងៗមើលត្រូវប្រយ័ត្ន។ ស្រាប់ដល់ពេលបើកពាងមើលទៅ ចាប់បានមែន។ មនុស្សហ្នឹងហើយ មនុស្សហ្នឹងអត់មានអ្នកណាក្រៅមេខ្មែរក្រហម ដែលត្រួតពីលើយើងហ្នឹងមកចូលភូមិយើង។ ដល់តែយើងចាប់បានម្នាក់ហ្នឹង យើង ហៅឈ្មោះមិត្តមន។ យើងចាប់បានមិត្ត មន ហ្នឹងគាត់ថា ហ៊ឹ! គាត់មកដើម្បី ពិសោធន៍ មើលមើល៍ តើមិត្តយើងពូកែចាប់ខ្មាំងប៉ុណ្ណាចាំ! ហើយសុំជម្រាបថា ដល់ ពេលយើងទៅដល់បឹងត្របែកវិញហ្នឹងគឺសារ៉ននៅតែជាមេធំ។ ហើយសារ៉នបានឱ្យ យើងធ្វើការច្រើន។ ខ្ញុំទៅដល់ដំបូង ខ្ញុំចាប់អារម្មណ៍ថាមានម្នាក់នោះឈ្មោះ អេង ហ្នឹងដែលថា គាត់មានបច្ចេកទេសទុកម្ហូបឱ្យបានយូរនោះ។ ខ្ញុំសួរថា អេង ម៉េចអេង ឯងម៉េចក៏ស្គម ហើយមុខឡើងខ្មៅអញ្ចឹង? អេងហ្នឹងថា អូ! តាំងពីពួកបងឯងចេញ ទៅ យើងនៅនេះធ្វើការខ្លាំងមែនទែន គឺថាធ្វើការស្លាប់រស់ មានរឿងរ៉ាវច្រើន ដែល កើតមានឡើង មានការចោទគ្នាថាបម្រើខ្មាំងយួន។ សូមជម្រាបថា ពេលហ្នឹងៗគឺ យួនចាប់វាយតាមជាយដែនស្រុកខ្មែរយើងហើយៗ សារ៉ន ហ្នឹងគឺថា បានប្រើឱ្យ យើងហ្នឹងជីករណ្ដៅ! ជីកកន្លែងសម្រាប់ចិញ្ចឹមត្រី ហើយពេលហ្នឹងខ្ញុំចេះតែឆ្ងល់ឱ្យ យើងទៅជីកពេលយប់ៗ។ ខ្ញុំថាចុះជីកកន្លែងសម្រាប់ចិញ្ចឹមត្រីអី បើបឹងត្របែក ប៉ុណ្ណាណីហើយ។ បើចង់ចិញ្ចឹមត្រី យកពូជត្រីមកដាក់នៅក្នុងបឹងហ្នឹងទៅ។ ហើយ នេះមកជីកកន្លែងត្រីអីនៅចន្លោះផ្ទះ ហើយអញ្ចឹងរវាងរលំផ្ទះហ្នឹង។ វាបាក់ចូលអាង ចិញ្ចឹមត្រីហ្នឹងហើយ។ ពួកយើងក៏ចេះទៅជីករាល់យប់។

យើងឮសួរថាទាហានយួនហ្នឹងបានដុតផ្ទះ ហើយចាប់រំលោភស្រីខ្មែរនោះច្រើនរាប់ មិនអស់ ហើយព្រមទាំងគេឱ្យដឹងពីទឹកចិត្តរបស់យុវជនយួនដែលមកចូលធ្វើ ទាហានមកច្បាំងនៅស្រុកខ្មែរហ្នឹង គឺអ្នកខ្លះហ្នឹង គឺបង្ហាញថាខ្លួនហ្នឹងអត់ចង់មកទេ ប៉ុន្តែត្រូវតែបង្ខំចិត្តឱ្យមកច្បាំងហ្នឹង ពីព្រោះខ្លួន ពិបាកវេទនាពេក ហើយត្រូវការ ស្ពរសេសម្រាប់ឱ្យម្ដាយខ្លួនឯង ហើយសារ៉នរហូតដល់ពេលហ្នឹង បានប្រាប់យើងថា

បើយើងមានខោអាវពណ៌អីអាចស្លៀកពាក់បានហើយនឹងឱ្យយើង បើសិនជាមានពូជគ្រាប់ជីអីឱ្យយកមកដាំ ដើម្បីមានជី មានសាឡាត់។

រាសី៖ បាទ! យើងថ្ងៃនេះបន្តពីរឿងស្ថានការណ៍នៅបឹងត្របែកហ្នឹង តើក្រោយមក នៅតឹងតែងដដែល ឬក៏មានការធូរថយអីយ៉ាងម៉េចដែរបាទ?

សារីម៖ ចាំ! សុំជម្រាបថាស្ថានការណ៍នៅបឹងត្របែកហ្នឹងអត់មានធូរថយអីទេ សារ៉ែនបានហៅយើងទៅប្រជុំនៅសាលាឈើវនាងនាងយ៉ាងច្រើនដង ហើយពេលប្រជុំមួយនោះបានហៅកូនលោក សារិន ឆាក ឈ្មោះ ឆន។ លោក សារិន ឆាក ជាអ្នកទូតជើងចាស់ជំនាន់សម្តេចឪនោះដែលត្រឡប់ទៅវិញដែរ ហើយកូន គាត់ឈ្មោះ ឆនមានសញ្ញាបត្រខាងវិស្វកម្មអេឡិចត្រូនិកនៅជាមួយពួកខ្ញុំ។ សារ៉ែន បានហៅទៅឱ្យជួសជុលវ៉ាត់យោ (វិទ្យុ) មួយពេលយើងកំពុងប្រជុំ។ ឱ្យគ្នាជួសជុលនៅក្រៅ។ ដាក់តុមួយនៅក្រៅ។ រួចទៅដល់ធ្វើមិនកើតសារ៉ែន បានរិះគន់ថា ចុះ អាំងហ្សេនញើ (វិស្វករ) អីក៏គ្រាន់ធ្វើវ៉ាត់យោ (វិទ្យុ) ប៉ុណ្ណឹងមិនដើរ។ ហើយតាមខ្ញុំមើល បែបមិនបានឱ្យគ្រឿងប្រដាប់អីគ្រប់គ្រាន់សម្រាប់ជួសជុលទេ។ ហើយចេញមកវិញ អ្នកខ្លះបានប្រាប់ ឆន ថាម៉េចក៏មិនទាមទារគ្រឿងប្រដាប់ឱ្យគ្រប់មកបើថាយើងធ្វើមិនកើតមានគ្រឿងប្រដាប់គ្រប់ហើយ ចាំបន្ទោសយើង។ គេក៏ចាត់តាំងឱ្យខ្ញុំចិញ្ចឹមទា។ ខ្ញុំភ័យណាស់ព្រោះគេអត់ឱ្យម្ហូបអីសោះ។ ខ្ញុំក៏សុំទូកគេមួយចាំ។

សារ៉ែនបានធ្វើបាបបងប្អូនប្រុសអ្នកដានី ដែលត្រឡប់ចូលទៅស្រុកវិញ។ គាត់ហ្នឹងឈ្មោះ ចេង ព្រោះអីចេង មានប្រពន្ធសៀម។ ប្រពន្ធគាត់អត់ត្រឡប់ទៅវិញទេ។ ហើយតាមខ្ញុំឮពាក្យចចាមអារ៉ាម សង្ស័យថា ចេង ជាភ្នាក់ងារស៊ីអាយអេចាំ។

រាសី៖ បាទ! ក៏ប៉ុន្តែអត់មានការចាប់យកទៅណាទេ គ្រាន់ថាធ្វើឱ្យអាម៉ាស់មុខអញ្ចឹងទេបាទ!?

សារីម៖ ចាំ! ក្រោយមក អ្នកទាំងអស់ហ្នឹងបាត់ខ្លួនអស់ទៅចាំ! ថ្ងៃមួយ ពេលធ្វើការការងារសង្គមកិច្ច មានម្នាក់ឈ្មោះ លី យើងខ្ញុំហៅគាត់មិត្ត លី ហើយប្តីគាត់ឈ្មោះម៉ន។ ម៉នធ្លាប់ធ្វើប្រធានមន្ទីរបឹងត្របែកហ្នឹងដែរ។ មិត្ត ម៉ន ជាអ្នកធ្លាប់ធ្វើការនៅរោងចក្រ

អគ្គិសនីកម្ពុជា ហើយបានចូលធ្វើជាភ្នាក់ងារខ្មែរក្រហម។ គេក៏យកមកឱ្យនៅបឹងត្របែកជាមួយពួកយើង។ មិត្ត លី ប្រាប់ខ្ញុំថា សារ៉ន ហ្នឹងបានប្រាប់ប្តីគាត់ថា ទ័ពរបស់អង្គការខ្មែរក្រហមខ្លាំងពូកែណាស់វាយៗយួនចូលដល់ព្រៃនគរ។ ពេលខ្ញុំសើចខ្ញុំថា យី! មិត្ត លី តាមខ្ញុំយល់ទ័ពអង្គការខ្មែរក្រហមអត់ស្គាល់ផ្សារ។ ដល់វាយទៅចូលជាយដែនក្នុងស្រុកយួនជាប់ព្រំដែនខ្មែរ គេមានផ្សារហើយស្មានតែព្រៃនគរ។ ខ្ញុំថា ព្រៃនគរនៅឆ្ងាយពីយើង ហើយធំទៀត។ ហើយទ័ពអង្គការគ្រាន់តែចូលទៅវង្វេងតាមផ្លូវគេ។ វាទៅណាលែងរួចហើយ។ លី ហើយនឹងខ្ញុំនិយាយការរាក់ជ្រៅមិនដែលបែកការណ៍អីទេចាំ! ហើយដល់ពេលៗមុនបុណ្យចូលឆ្នាំខ្មែរ ឆ្នាំ១៩៧៨ គេឱ្យយុវនារីហាត់ធ្វើឡើងឆាក សម្តែងតួ ហើយយុវជន យុវនារីខំហាត់ដើម្បីសម្តែង ប៉ុន្តែគេប្រើពាក្យខ្លាំងៗ វាយខ្ទាំងគ្រប់ រូបភាពនៅគ្រប់ទីកន្លែង ហើយគេហាត់ គេលើកដៃចង្អុលមកថា វាយខ្ទាំងគ្រប់រូបភាពគ្រប់ទីកន្លែង។ ពួកយើងកំពុងឈរមើល។ យើងដូចភ្ញាក់។ យើងងាកខ្លួនរេចេញ។ គេចង្អុលមកដូចជាចំមិត្តយើងអញ្ចឹង បានន័យថា ស្ថានការណ៍ហ្នឹងវាតឹង។ គេរាវរកខ្មាំងសឹងតែគ្រប់ពេលវេលាចាំ! ហើយប្រធានមន្ទីរយើងដូរញឹកញាប់។ មានម្នាក់នោះឈ្មោះ ភាគ។ គេដូរគាត់ឡើងធ្វើប្រធាន។ គាត់ធ្លាប់ធ្វើពេទ្យឡើងធ្វើប្រធានមន្ទីរ។ ពួកអ្នកនៅក្នុងបឹងត្របែកចេះតែហៅគាត់ថា ថៅកែភាគ ចាំ! អីៗស្រេចលើថៅកែភាគ។

រាសី៖ បាទ! ពេលហ្នឹងក្រែងខ្មែរក្រហមអត់មានឋានៈ មានវណ្ណៈអី ដល់ពេលហៅថៅកែអញ្ចឹងអត់អីទេ?

សារីម៖ ចាំ! ពួកហ្នឹងនៅពីខាងក្រៅប្រជុំគ្នាឯងអញ្ចឹងនិយាយលេង ហើយហៅ ថៅកែភាគ។ ភាគហ្នឹងមិនបានប៉ុន្មានៗទេគេយកគាត់ហ្នឹងចេញទៅទៀតចាំ! រួចដល់ពេលដែលលោក ហ៊ិន អ៊ុន ឡើងធ្វើប្រធាន គេចេះកសាងខ្ញុំថា ខ្ញុំហ្នឹងមានវណ្ណៈបញ្ញាជនហ្នឹងក្រាស់នៅក្នុងខ្លួន ឱ្យតែខ្ញុំដើរទៅណា ខ្ញុំចេះតែរើសក្រដាសអីមើលតាមផ្លូវចាំ! ខ្ញុំអញ្ចឹងមែន។ ខ្ញុំឃើញក្រដាស ខ្ញុំរើសមើលហើយ។ ហើយគេកសាងខ្ញុំថា ខ្ញុំហ្នឹងលួចមើលសៀវភៅមៅ សៀវភៅ ក្រហមរបស់ប្រធានមៅហ្នឹងពេលយប់ៗ។ ខ្ញុំប្រាប់

ថា ខ្ញុំអត់មើលអីកើតទេ ពីព្រោះភ្នែកខ្ញុំហ្នឹងមើលអក្សរអត់ឃើញទេឥឡូវនេះ ទាល់មានពន្លឺច្រើនណាស់។ រួចទៅស្រាប់តែថ្ងៃមួយ ធ្វើការចាប់អារម្មណ៍រឿងនយោបាយទឹក ហើយខ្ញុំបញ្ចេញយោបល់ច្រើន។ ស្រាប់តែប្រធានក្រុមខ្ញុំប្រាប់ថា អញ្ចឹងឱ្យខ្ញុំសរសេរការចាប់អារម្មណ៍មួយពីរឿងនយោបាយទឹក។ ខ្ញុំប្រកែក។ ខ្ញុំថា ខ្ញុំមិនសូវពូកែសរសេរ។ ប្រធានក្រុមខ្ញុំហ្នឹងគឺឈ្មោះអ្នក ឆេង ទូច ប្រពន្ធ ហ៊ីន អ៊ុន សុខចិត្តសរសេរហើយយកមកឱ្យខ្ញុំសរសេរ មកឱ្យខ្ញុំអាននៅក្នុង អង្គប្រជុំ។ ខ្ញុំឡើងទៅមើលនៅក្នុងអង្គប្រជុំខ្ញុំមើលអត់កើតព្រោះខ្ញុំមើលអត់ឃើញ។ រួចមានម្នាក់។ ម្នាក់ហ្នឹងពាក់វ៉ែនតាមនុស្សចាស់។ គាត់ហ្នឹងឈ្មោះ រ៉ុន។ គាត់ពាក់វ៉ែនតា។ ខ្ញុំទៅកញ្ឆក់វ៉ែនតាគាត់យកមកពាក់ស្រាប់តែខ្ញុំមើលឃើញ។ តាំងពីថ្ងៃហ្នឹងមក ពួកហ្នឹងលែងចោទខ្ញុំថា ខ្ញុំហ្នឹងលួចមើលសៀវភៅហើយ បានខ្ញុំប្រាប់ថា បើខ្ញុំមើលសៀវភៅបារាំងម៉ូហ្សេ (Mauger) ដែលខ្ញុំធ្លាប់បង្រៀនភាសាបារាំង។ ប្រហែលពេលខ្លះខ្ញុំមើលមែនពីព្រោះវាអក្សរធំៗ។

រាសីៈ បាទ! ប៉ុន្តែហេតុអីបាននៅពេលហ្នឹងខ្មែរក្រហមមានការឧបត្ថម្ភគាំទ្រពីប្រទេសចិន? ម៉េចបានមិនឱ្យមើលសៀវភៅម៉ៅ?

សារីមៈ ចាំ! ខ្ញុំឆ្ងល់ដែរ ប៉ុន្តែខ្ញុំអត់សួរតវ៉ាអីទេចាំ! ពីព្រោះថា យើងជជែកវែកញែកថាកុម្មុយនីស្ត ហើយមិនឱ្យមើលសៀវភៅកុម្មុយនីស្តស្អីនាំតែមានរឿង។ ខ្ញុំក៏ប្រាប់ថា ខ្ញុំអត់ដែលមានសៀវភៅក្រហមទៀតផង។ ហើយនៅបឹងត្របែក ដល់ស្ថានការណ៍តឹងអញ្ចឹងពេកទៅ ខ្ញុំក៏បានជម្រុះរ៉ាត់យោ (វិទ្យុ) ខ្ញុំ ហើយយាយ យ៉ែម ក៏គាត់ជម្រុះមាសរបស់គាត់ច្រើនថែមទៀត។ ខ្ញុំឃើញយាយ យ៉ែម មានមាសច្រើន ខ្ញុំចេះតែចង់ឱ្យតម្រុយគាត់យល់ថា គាត់គួរតែទុកមាសខ្លះដើម្បីរក្សាខ្លួនគាត់។ ខ្ញុំចេះថា ខ្សែដៃនេះល្អណាស់។ ក្បាច់ បុរាណគួរទុក១-២ ជាអនុស្សាវរីយ៍ទៅ។ ទុកអាពីរនេះធ្វើជាអនុស្សាវរីយ៍ទៅ។ ប៉ុន្តែយាយ យ៉ែម យកមាសគាត់ទាំងអស់ទៅជម្រុះអស់ទៅចាំ! អ្នកពាក់វ៉ែនតាខ្លះរហូតដល់ចង់លែងហ៊ានពាក់វ៉ែនតា។ សារ៉ែន បានអំពាវនាវរកអ្នកចេះ អ្នកចេះបង្ហាត់ធ្វើចលនាផ្ទាំងក្រដាសពណ៌រួមគ្នាដើម្បីបង្កើត ជារូបភាពមួយ

តាមចលនាភ្លេងនោះ។ ចំណែកឯ សារ៉ន វិញ ពេលដែលគាត់មកមើលយើងជីកអាងយប់ៗ គាត់ស្លៀកសារ៉ុងសូត្រ ហើយពាក់អាវយឺតអេមីណង់ (Eminent) ដែលវាលឃ្លៀកដូចសំណាញ់នោះ ហើយលាប ទឹក អប់ឡើងក្រអូប។ ប្រពន្ធគាត់ឃើញពាក់នាឡិការបស់ វណ្ណា ដែលទិញពីប៊ីហ្សង់សុង (Besancon)! ពួកយើងឃើញអញ្ចឹងក៏នាំគ្នាកេះមើល ហើយសើចចម្អកក្នុងចិត្ត។ ថ្ងៃមួយ យើងរើសបានក្រដាសមួយបោះពុម្ព។ គេនិយាយថា ត្រូវយាមពួករណសិរ្សឱ្យបានមាំខ្លាចពួកហ្នឹងរត់។ ស្រាប់តែ ថ្ងៃមួយ គេក៏ហៅយើងទៅប្រជុំ។ យើងឃើញលោក អៀង សារី មកប្រជុំនៅពេលហ្នឹង។ ខ្ញុំចាំលោក អៀង សារី ពេលហ្នឹងជិះឡានមួយខ្មៅ ហើយឡានហ្នឹងដូចឃ្លុប់អញ្ចឹង ហើយកញ្ចក់ឡានខាងក្រោយ។ កញ្ចក់វាតូច មែនទែនចាំ!។

រាសី៖ អរគុណបាទ។ នេះជាលើកទី២ លើកទី៣ ហើយដែលអ្នកស្រីបានជួបលោក អៀង សារី?

សារីម៖ ចាំ! នេះលើកទី២ទេចាំ! ដែលគាត់មកប្រជុំម្តងនេះ។ ហើយពួកយើងដល់គេ ហៅប្រជុំនៅសាលាបឹងត្របែកអញ្ចឹងក៏ដូចជាឆ្ងល់ណាស់ម៉េចក៏លោក អៀង សារី មក? លោក អៀង សារី មកហ្នឹងគឺលោកប្រធានបឹងត្របែកដែលឈ្មោះ ហ៊ុន អ៊ុន ខំលើកឡើងដើម្បីធ្វើសេចក្តីរាយការណ៍ពីការដាំបន្លែថាបានល្អចម្រើន ដឹកទៅប៉ុន្មានគីឡូឱ្យខាងលោក អៀង សារី នោះខាងក្រសួងការបរទេសនោះចាំ! ប៉ុន្តែលោក អៀង សារី គាត់អត់មានត្រូវការចាប់អារម្មណ៍ពីរឿងថាអ្នកឯងដាំបន្លែបានល្អអីប៉ុន្មានទេណា។ គាត់ចង់ដឹងពីស្ថានការណ៍នៅបឹងត្របែកយ៉ាងម៉េច។ មានម្នាក់នោះ គេងើបឡើង។ ម្នាក់នោះឈ្មោះ កង សន្និវ៉ាត់។ គាត់មកពីស្រុកបារាំង។ គាត់ទើបមកដល់ដែរទេ។ ម្តាយនៅសាលាតិចណូចាំ! គាត់មកដល់នៅបឹងត្របែកហ្នឹងតែម្តង ហើយគាត់លើកឡើងពីរឿងថា យើងជួបការគាបសង្កត់ពីប្រធាន សារ៉ន ផង ពីខាងប្រធានយើងផង។ ហើយអ្នកខ្លះក៏លើកឡើងពីរឿងដែលយើងនៅសាលាតិចណូ។ ពេលគេឱ្យយើងទៅប្រជុំនៅសាលមហោស្រពសាលាតិចណូ គេឱ្យយើងដើរដូចលោក សង្ឃអញ្ចឹងចាំ! មួយមុខ មួយក្រោយ អត់ឱ្យដើរពពាក់ពពូនគ្នា។ ហើយនៅ

បឹងត្របែកគេមិនឱ្យយើងទៅដល់ចិញ្ចើមផ្លូវថ្នល់ទៅពេទ្យរុស្ស៊ីហ្នឹងផង។ យើងនៅតែខាងក្នុងៗ។ ពួកយើងក៏ប្រាប់លោក អៀង សារី ថា បានឮសូរយុទ្ធនារីខ្លះនិយាយថា ពួកយើងជាប់គុកទេតើ ហើយទៅក៏ឱ្យ លោក អៀង សារី ដឹងពី សារ៉ន ដែលឱ្យយើងជីកអាងសម្រាប់ចិញ្ចឹមត្រីនៅចន្លោះផ្ទះពីរនៅជិតសាលាឈើរនាងនាង ចាំ! ហើយនឹងឱ្យដឹងថា សារ៉ន ហ្នឹងនិយាយ ថាមិត្តកើត ដែលធ្វើប្រធានមុនគេនៅបឹងត្របែកជាមនុស្សអត់បានការដែលអង្គការបញ្ជូនមក។ ដល់អញ្ចឹងទៅបានលោក អៀង សារី ឆ្ងល់ណាស់ គាត់ថា យី! ដល់គេជម្រិតតឹងអញ្ចឹង ម៉េចក៏អត់មានអ្នកណានាំពាក្យបណ្តឹងហ្នឹងទៅគាត់ ទៅខាងលើ? រួចទៅពួកយើងឆ្លល់ថា ឱ្យយើង ប្តឹងទៅខាងលើយ៉ាងម៉េចបើសារ៉ន នៅពីលើយើង។ យើងទៅប្តឹងសារ៉ន។ យើងទៅឈោងទៅខាងណា។ យើងអត់មានផ្លូវសម្រាប់ទៅប្តឹង។

រាសី៖ ហើយអញ្ចឹងគាត់មានចាត់វិធានការអីដែរដល់តែឮចឹងៗ?

សារីម៖ ចាំ! ពេលហ្នឹងគាត់សើរើការចាត់តាំងថ្មីទៅ។ ខ្ញុំចាំពេលហ្នឹង លោក អៀង សារី បានរំសាយប្រធានមុនចោលអស់ទៅចាំ! រួចទៅបានចាត់តាំងស្រីម្នាក់ ឈ្មោះប៉េង ធ្វើជាប្រធានខាងនារី ហើយនឹងប្រធានឃ្លាំងម្ហូបអាហារដែល យើងទទួលទានរាល់ថ្ងៃ។ ខ្ញុំស្គាល់អ្នកប៉េង។ គាត់ពីដើមមក ឈ្មោះមែនទែន សំប៊ុន ហើយធ្វើជាគ្រូបង្រៀន ហើយគាត់ចូលទៅតំបន់រំដោះតាមប្តីគាត់នៅឆ្នាំជាង៧០។ ប៉ុន្តែដល់ពេលគាត់ទៅដល់ឮថាប្តីគាត់ចងកស្លាប់ទៅ។ ប្តីគាត់ឈ្មោះជី គឹមអាន ជាអ្នកធំខ្មែរក្រហមដែលរត់ចូលព្រៃក្នុងឆ្នាំ៦០ជាង ហើយមានសញ្ញាបត្រវិស្វករខាងមើលធាតុវិស្វករ អាក្រូណូម (Agronomy)។ គាត់ក៏ទៅនៅតំបន់រំដោះហ្នឹងទៅ ហើយខ្មែរក្រហមក៏បាន យកពួកគាត់ហ្នឹងមកឱ្យនៅជាមួយពួកយើងខ្ញុំទៅ។ អ្នកហ្នឹងមានកូនដល់ ១២នាក់ឯណោះ ហើយដល់ពេលគេចាត់តាំងប្រធានខាងលើសព្វគ្រប់ទៅ បានបង ៣៧ ខ្ញុំស្គាល់គាត់តាំងពីគាត់នៅក្រមុំនោះព្រោះគាត់ជាពួកម៉ាករបស់បងជីទួតមួយខ្ញុំម្នាក់ឈ្មោះ អ៊ុយ សម្បត្តិ។ បង ៣៧ ធ្លាប់មកលេងផ្ទះបងសម្បត្តិ។ នៅផ្ទះកាប់គោ ខ្ញុំក៏ស្គាល់គាត់តាមហ្នឹង ហើយគាត់ហ្នឹងក៏ខំមកនិយាយខ្ញុំថា ឱ្យខ្ញុំហ្នឹងជួយធ្វើប្រធាន

ក្រុមខាងទ្រុងទាចាំ! ជំនួសកូនស្រីគាត់ឈ្មោះ ណា ដែលធ្វើប្រធានទ្រុងទាពីមុន។ ខ្ញុំជាក្រុមនៅក្នុងទ្រុងទាព្រោះកូនស្រីគាត់ខាងលោក អៀង សារី បានដកលែងឱ្យនៅកន្លែងជាមួយពួកយើង ជាមួយបងស្រីគេម្នាក់ទៀតឈ្មោះ មុំ ក៏ទៅដែរ។ មុំ ក៏ធ្លាប់ធ្វើប្រធាននារីនៅក្នុងជំរំបឹងត្របែកយើងនៅហ្នឹងដែរ។ ដូចខ្ញុំជម្រាបលើកមុនអញ្ចឹងថា ខ្ញុំអត់ចង់ធ្វើប្រធាននៅក្នុងរបបខ្មែរក្រហមទេ។ ប៉ុន្តែដល់សម័យហ្នឹងគឺខ្ញុំឃើញខ្មែរក្រហមហ្នឹងបានផ្លាស់ឥរិយាបថរបស់ខ្លួនតាមការផ្សាយរ៉ាត់យោ (វិទ្យុ) បានលើកពីជំហរស្នេហាជាតិ មិនរើសវណ្ណៈដូចកាលពីមុនៗទៀតទេចាំ! តាំងពីមានការវាយគ្នាជាមួយយួនមកឃើញថាលើកជំហរស្នេហាជាតិ ហើយនិយាយថា យួនបានដោះមុខនាងពាក់មុខយក្សមកវាយជាមួយខ្លួនដែលកាលមុនជាមិត្ត។

រាសីៈ បាទ! ចុះប្រធានចាស់ៗដែលដកទៅហ្នឹងទៅណាអស់ទៅ?

សារីមៈ ចាំ! ប្រធានអស់ហ្នឹងកាលពីមុន សារ៉ន ពេលដូរអញ្ចឹង សារ៉ន ចេញទៅ។ ប៉ុន្តែប្រធានដែលលោក អៀង សារី មករំសាយហ្នឹង គេអត់យកចេញទៅណាទេ។ អ្នកផល្លា ហើយលោក ហ៊ីន អ៊ុន ហ្នឹងនៅបឹងត្របែកហ្នឹងដដែល ប៉ុន្តែអ្នកផល្លា ស្រងូតស្រងាត់ខ្លាំងណាស់ គាត់ចេញមកពីអង្គប្រជុំហ្នឹង គាត់ទទួលក្រមា ហើយនឹងគាត់ដើរដូចយើងកាន់ទុក្ខអញ្ចឹងចាំ!។

រាសីៈ អ្នកស្រី ហេតុអ្វីបានជាលោក អៀង សារី មកផ្ទាល់អញ្ចឹង មកផ្លាស់ប្តូរមេដឹកនាំ?

សារីមៈ ចាំ! ខ្ញុំអត់យល់។ ប៉ុន្តែគ្រាន់តែលើកក្រោយមក ខ្ញុំអត់បានសួរនាំអីទេ។ ប៉ុន្តែ ខ្ញុំចេះតែស្តាប់ទៅឮសួរគេថា សារ៉ន ហ្នឹងបានរត់។ គេដេញចាប់ សារ៉ន។ ដល់អញ្ចឹងបានខ្ញុំកាត់យល់ថា អញ្ចឹងសារ៉ន មានធ្វើអីខុសចាំ! សារ៉ន រត់។ គេដេញចាប់ដេញហ្នឹងគឺថាគាត់ជិះម៉ូតូរត់ទៅ។ គេដេញចាប់បាននៅកន្លែងណាខ្ញុំក៏មិនហ៊ានបញ្ជាក់ដែរ គ្រាន់តែថាគេចាប់បាន ចាំ! ដល់ពេលគេចាប់បាន សារ៉ន បានយើងឮសួរ ចចាមអារ៉ាមថា អាងចិញ្ចឹមត្រីដែលសារ៉ន ឱ្យយើងជីកហ្នឹងគឺប្រហែលជាទុក សម្រាប់កប់អ្នកខ្លះនៅហ្នឹងចាំ! ខ្ញុំឮសួរអញ្ចឹង ខ្ញុំព្រឺក្បាលណាស់ ព្រោះខ្ញុំដឹងថា សារ៉ន ហ្នឹងអត់ចូលចិត្តខ្ញុំទេចាំ!។

រាសី៖ នៅពេលហ្នឹងតើការហូបចុកយ៉ាងម៉េចដែរ គ្រាន់បើជាងមុនដែរឬក៏?

សារីម៖ ចាំ! ដូចខ្ញុំជម្រាបអញ្ចឹងថា ដល់ពេលមានការវាយយួន គេបន្ធូរ។ គេមិនសូវឱ្យយើងហូបអីបានច្រើនជាងមុន រហូតដល់ឱ្យយើងរៀនលាយស្លឹកដំឡូងឈើទៀតផងពីព្រោះថា យើងនឹងអាចរត់ពីចេញពីបឹងត្របែក។ហើយដល់ពេលលោក អៀង សារី បានចាត់តាំងថ្មីទៅ គេបានយកសៀវភៅមកដាក់ឱ្យយើងមើលមានទស្សនាវដ្ដីអីច្រើន ប៉ុន្តែភាសាបារាំង។ ប៉ុន្តែទស្សនាវដ្ដីហ្នឹងច្រើនតែនិយាយអំពីគោលជំហរនយោបាយរបស់ខាងកុម្មុយនីស្ត ហើយនឹងដូចថាត្អិះតិះដៀល ខាងលោកសេរី។ ពេលគេដាក់កាសែត ទស្សនាវដ្ដីឱ្យយើងមើល មានម្នាក់ជាវិស្វករឈ្មោះ សៀង ហាក់។ គាត់កសាងខ្ញុំថា នែ បង រីម ឯងម៉េចក៏រហ័សហ៊ានមើលសៀវភៅអស់ហ្នឹងម្ល៉េះ? ខ្ញុំថា ហ៊ឺ! អង្គការយកមកដាក់ឱ្យយើងមើលតើ។ ហើយរ៉ាត់យោ (វិទ្យុ)ហ្នឹងក៏គេបើកឱ្យយើងស្ដាប់ស្រួលបួល។ ហើយរហូតដល់គេក្រើនរំឭកយើងថា គួរពេលបាយហើយហ្នឹងឱ្យអង្គុយស្ដាប់រ៉ាត់យោ (វិទ្យុ)។

រាសី៖ ប៉ុន្តែរ៉ាត់យោ(វិទ្យុ) របស់ខ្មែរក្រហមហ្នឹងទេ?

សារីម៖ ចាំ! រ៉ាត់យោរបស់ខ្មែរក្រហមហ្នឹងចាំ!

រាសី៖ បាទ! ក្នុងពេលរស់នៅជាមួយខ្មែរក្រហម តើអ្នកស្រីដែលលួចស្ដាប់វិទ្យុបរទេសដូចជាវីអូអេ ជាដើមទេ?

សារីម៖ ចាំ! ខ្ញុំស្ដាប់វីអូអេ។ ពេលខ្ញុំនៅតាលែងណោះចាំ! ដល់មកនៅបឹងត្របែក ខ្ញុំអត់ហ៊ានលួចស្ដាប់សោះចាំ! ពីព្រោះខ្ញុំឃើញស្ថានការណ៍តឹងណាស់ចាំ! ខ្ញុំ ខ្លាចមានគ្រោះថ្នាក់។ តែខ្ញុំលួចមើលសៀវភៅវិញម្ដង។ សៀវភៅដែលខ្ញុំចាប់អារម្មណ៍ជាងគេគឺសៀវភៅដែលសម្ដេចនរោត្តម សីហនុ លោកសរសេរពីការពិសោធន៍របស់លោកទៅអង្គការសហប្រជាជាតិចាំ! មានចំណងជើងជាភាសា បារាំងថា មេហ្សូកណេ វណេ (Mes Journees Venez) នោះចាំ! ក្នុងមួយសៀវភៅហ្នឹងខ្ញុំចាំជាទីបំផុតដែលសម្ដេចលោកសរសេរដូចកំប្លែងអញ្ចឹងថា ពេលហ្នឹងសហរដ្ឋអាមេរិកដូចជាយកចិត្តទុកដាក់ជាមួយមេដឹកនាំរបស់សហភាពសូវៀតនោះ ពេលនោះ

គ្រូស្សឆេវ (Khrushchev) មកញ៉ីវយ៉ក មកអង្គការសហប្រជាជាតិ។ សម្តេចមានបន្ទូលថា ខាងគ្រូស្សឆេវ នោះអាមេរិកាំងបានយកចិត្តទុកដាក់រហូតដល់មានក្បួនម៉ូតូហែរហមចូលទៅអង្គការសហប្រជាជាតិ។ ហើយចំណែកឯអ្នកកាសែតវិញពពាក់ពពូនគ្នា ដើយចង់បាក់ក។ ក្រោមបង្អួចអូតែល (សណ្ឋាគារ) គ្រូស្សឆេវ ដេកមើលក្រែងលោ គ្រូស្សឆេវ ចេញទៅណាមកណាចាំ! អើតតាមបង្អួចហើយចំណែកឯព្រះអង្គវិញទៅអូនុយ (អង្គការសហប្រជាជាតិ) ដែលគ្មានអ្នកណាចាប់អារម្មណ៍ទេគឺថាត្រូវការចេតឡានឆ្ងាយពីកន្លែងប្រជុំ។ ចំណែកមកអូតែល (សណ្ឋាគារ) វិញមនុស្សបីបួនគ្រាប់ (នាក់) ចំណែកខាងពួកឥណ្ឌូនេស៊ីងណោះវិញ គេមានបុប្ផាគេហែរហមរហង់នៅ ជាន់អូតែល(សណ្ឋាគារ) ដែលសម្តេចលោកគង់នៅដែរហ្នឹង។

រាសីៈ បាទ! ម៉េចបានអ្នកស្រីរកឃើញសៀវភៅហ្នឹង?

សារីមៈ ចាំ! ពេលនៅបឹងត្របែក គេឱ្យយើងសម្អាតផ្ទះដើម្បីឱ្យមនុស្សនៅ។ ដល់ អញ្ចឹងទៅយើងទៅបោស។ យើងឃើញសៀវភៅ។ ហើយខ្ញុំចាប់អារម្មណ៍ ខ្ញុំ។ យកមកទុកចាំ! ដល់ពេលណាខ្ញុំអផ្សុក ខ្ញុំមើល។ ទោះខ្ញុំមើលចប់ ក៏ខ្ញុំនៅតែយកមកមើលទៀតដើម្បីខ្ញុំសើចព្រោះវាកំប្លែងណាស់ចាំ! យាយ យ៉ែម ដែលគាត់ សម្រាននៅផ្ទះជាមួយខ្ញុំហ្នឹង គាត់ចេះថា ក្មួយ រីម ដឹងអីទេ ឱ្យតែបានសៀវភៅ ហ្នឹងមើលឮសូរតែសើចដូចមនុស្សឆ្កួតអញ្ចឹង។ ចាំ! គេឱ្យយើងមើលកុនច្រើនដងនៅបឹងត្របែក កុនចិន មានចំណងជើងថា ស្រុកក្រទឹកហូប ចាំ! កុនខ្លះទៀតគឺជាឯកសារនិយាយពីពេលប៉ុល ពត ទស្សនកិច្ចនៅប្រទេសចិន ហើយពេលមើលកុនឯកសារហ្នឹង អ្នកដែលមកពីតំបន់រំដោះ ឃើញមនុស្សខ្លះ គេស្គាល់ គេស្រែកថា អូ! នោះមិត្ត ប៉ង់ប៉ុន្តែ ហ៊ឺស! អាប៉ង់ ហ្នឹងវាក្បត់ទៅហើយ ព្រោះវាចង់សម្លាប់ ប៉ុល ពត ហើយគេចាប់បាន។ មានគេបញ្ចាំងពីលោកលន់ ណុល ដែលអាគាំង (អាមេរិក) នាំចេញពីកម្ពុជានោះហើយ។ ពេលហ្នឹងឃើញ លន់ ណុល យំពេប ពេលឡើងកប៉ាល់ហោះ។ ម្នាក់អ្នកអូន ប្អូនហោ ណាំហុង ពេលនោះគាត់ខំមកឆ្លៀតខ្សឹបប្រាប់ខ្ញុំថា នែ! គាត់ហ្នឹងបានធ្វើការរបៀបអញ្ចឹង ដូចថាផ្តល់ យកនេះយកនោះទៅឱ្យរណសិរ្សរបស់ខ្មែរ

ក្រហមនៅក្រុងប៉ារីសពេលគាត់ចេញពីកម្ពុជាទៅ ហើយក៏គាត់ប្រាប់ខ្ញុំឱ្យ ដឹងទៀតថា បងប្រុសគាត់ ហោ ណាំហុង ពីរនាក់អូនហ្នឹងទៅធ្វើការជាមួយស្ថានទូត។ ក្នុងចង្ក្រានគឺត្រូវតែរៀបចំដបកំប៉ុង។ ម្ហូបត្រូវរៀបឱ្យស្មើ។ បើថាមិនអញ្ចឹងទេ លោក ហោ ណាំហុង មិនសុខចិត្តទេចាំ! ហើយពេលមួយគេឱ្យយើងដើរទៅមើលសៀកចិនមកសម្តែងនៅស្តាតអូរឡាំពិក។ ចិនសម្តែងសៀក។ ខ្ញុំថាគេស្ទូចត្រីបានលើគោក។ យើងទៅមើលសិល្បៈនៅសាលមហោស្រពចតុមុខ។

រាសី៖ មកសម្តែងៗផ្ទាល់ហ្មង?

សារីមេះ មកសម្តែងនៅស្រុកខ្មែរចាំ! សិល្បៈ ឆៅសេស្គូ (Ceausescu) ឈ្មោះកម្រងផ្កាភ្នំកាកប៉ាត (Les Chaines de Carpate)។ ប៉ុន្តែដឹកយើងមើលនៅសាលមហោស្រព ដល់យើងទៅមើល កម្រងផ្កាភ្នំកាក់ប៉ាត ហ្នឹងគេលេង ផុតហើយ។ គេឱ្យយើងទៅចូលមើលឃើញតែពួកនារីសិល្បករខ្មែរក្រហមហ្នឹងទៅជូសជុលផ្លូវដែក។ លេងចេញមកចបកាប់មែនទែនហ្មង សស្វាច។

រាសី៖ នៅលើឆាក?

សារីមេះ ចាំ! នៅលើឆាក។ ពេលហ្នឹងដូចខ្ញុំជម្រាបមុនហ្នឹងថា អ្នកដានី ដែល ថាប្រពន្ធទូតនៅហាណូយខ្មែរក្រហមផ្តាច់ទូតជាមួយយួនទៅ ប្តីត្រឡប់មកវិញហ្នឹង គេទៅយកគាត់ពីវត្តស្លែងមកឃើញនាងដានី ក៏ទៅមើលសិល្បៈដែរ។ ប៉ុន្តែគេទៅមើលក្នុងនាមជាប្រពន្ធទូតណា។ គេស្លៀកសុទ្ធតែសំពត់ហូលពាក់ អាវស។ ពួកយើងឃើញអ្នកដានីពីចម្ងាយអញ្ចឹងទៅ យើងគ្រាន់តែញញឹមដាក់គ្នាពីចម្ងាយ។

រាសី៖ បាទ! អត់ហ៊ាននិយាយគ្នាទេ?

សារីមេះ ចាំ! ព្រោះគេនៅឆ្ងាយពីយើង។

រាសី៖ បាទៗ! អញ្ចឹងនេះជាការផ្លាស់ប្តូរមួយពីដើមមកមិនដែលមានឱ្យមើលសិល្បៈអញ្ចឹងទេ?

សារីមេះ ចាំ! វាជាការផ្លាស់ប្តូរមួយយ៉ាងធំ ហើយរហូតដល់គេថា គេចង់បង្កើតឱ្យមាន ថ្នាក់បង្រៀនខាងវិទ្យាល័យ មហាវិទ្យាល័យអញ្ចឹងចាំ! រួចទៅគេចាត់តាំងអ្នកខ្លះនៅកន្លែងបឹងត្របែកខ្ញុំ វណ្ណា ដែលទៅពីបឹហ្សង់សុងដូចខ្ញុំហ្នឹង គឺគេបានរៀបចំគាត់ដើម្បីឱ្យទៅបង្រៀននៅសាកលវិទ្យាល័យ។ គេបាននាំអ្នកទាំងអស់ដែលគេប្រុងនឹងឱ្យទៅបង្រៀនហ្នឹង ទៅជួបអ្នកធំខ្មែរក្រហមដែលថានៅពុទ្ធិកៈ បណ្ណាល័យជិតវាំងនោះ។ នៅមុខវាំងនោះ តែខ្ញុំអត់សួរដេញដោលថា គេទៅជួបអ្នកណាទេ។ គេផ្តូរផ្តងទៀតថា មុននឹងចេញឱ្យអ្នកទៅបង្រៀនហ្នឹង គេផ្តូរផ្តងមិនឱ្យ វណ្ណា អាចរៀបការជាមួយអ្នកនោះអ្នកនេះ។ រហូតដល់គេមាននាំពួកប្រធានក្រុមនៅក្នុងជំរំបឹងត្របែកទៅដើរលេងម្តង។ ខ្ញុំចាំហើយទៅដើរលេងហ្នឹង។ ខ្ញុំធ្វើប្រធានក្រុមខាងទ្រុងទា នៅសល់តែខ្ញុំម្នាក់ទេ។ ទាំងអស់គ្នា គេនាំទៅដើរលេង។ គេនាំទៅដើរលេង។ ស្រាប់តែពេលហ្នឹងមានម្នាក់ ដែលឈ្មោះ សន្និរ៉ាត់ នោះមកប្រាប់ខ្ញុំថា បងរីមេ នៅក្នុងបឹងត្របែក ឥឡូវមានតែបងឯងមានឋានៈធំជាងគេធ្វើប្រធានទ្រុងទា។ ឥឡូវបងឯងអត់មានអ្នកណាធំជាងបងឯង។ បងឯងត្រូវតែចាត់តាំងអ្នកនេះធ្វើនេះអ្នកនេះធ្វើនោះ។ អញ្ចឹង ខ្ញុំថា សន្និរ៉ាត់ ខ្ញុំមើលតែទារបស់ខ្ញុំកុំឱ្យហើរចោលទ្រុងបានហើយ។ អ្នកណាធ្វើអី ធ្វើកិច្ចការរបស់ខ្លួនឯង។ ខ្ញុំអត់ត្រូវការចាត់តាំងអ្នកនេះឱ្យធ្វើនេះ ធ្វើនោះអីទេ! ដល់អ្នកអស់នោះត្រឡប់មកពីដើរលេងវិញមួយថ្ងៃនោះ ខ្ញុំក៏អត់សួរថា គេទៅណាមកណា ពីព្រោះគេថាលាក់ការណ៍បានច្រើនឈ្នះខ្មាំងពាក់កណ្តាលនោះ។ ម្ល៉ោះហើយខ្ញុំអត់ហ៊ានសួរដើម្បីសន្តិសុខរបស់ខ្ញុំ រហូតដល់គេនិយាយគ្នាបានខ្ញុំឮសួរថា គេទៅជិះរទេះភ្លើងទៅខាងបាត់ដំបង។ គេមើលវាលស្រែនិរតី។ តើទិន្នផលស្រូវហ្នឹងវាបានផលល្អផលអាក្រក់យ៉ាងម៉េច។ គេជិះរទេះភ្លើងទៅ។ ប៉ុន្តែគេជិះរទេះ ភ្លើងទៅឮសួរថាមានពួកខាងប៉ុល ពត លោក អៀង សារី ជិះទៅមើលដែរ។

រាសីះ បាទ! នៅពេលដែលឮសួរថាចង់បង្កើតមហាវិទ្យាល័យអញ្ចឹង តើអ្នកស្រីនៅក្នុងចិត្តមានអារម្មណ៍យ៉ាងដូចម្តេចដែរ?

សារីមេះ ចាំ! ពេលហ្នឹងខ្ញុំអត់សូវមានការខ្វល់ខ្វាយអីទេ។ ឮសូរគេថាបង្កើតមហាវិទ្យាល័យក៏យល់ថាប្រហែលជាគេចង់បង្កើតមែន។ ប៉ុន្តែខ្ញុំគ្រាន់តែគ្រវីក្បាលម្នាក់ឯង ហើយគិតថា នេះបានចំជាត្រូវនឹងពាក្យស្លោករបស់ខ្មែរក្រហមដែលគេច្រៀងថា «អង្គការនៅក្មេងខ្ចីពិត តែការពិសោធន៍ជ្រាលជ្រៅក្រៃលែង»។ ក្មេងខ្ចីពិត ការពិសោធន៍ជ្រាលជ្រៅក្រៃលែងហ្នឹង គឺថាមិនទាន់មានសាលាបឋមសិក្សាផង ស្រាប់តែលោតផ្លោះទៅរកបង្កើតវិទ្យាល័យ មហាវិទ្យាល័យអី! ហើយតាមខ្ញុំ គិតប្រហែលថា គេគ្រាន់តែបង្កើតសម្រាប់តែបង្រៀនកូនសិស្សប៉ុន្មានគ្រាប់ដែលគេមានសម្រាប់ឱ្យចេញទៅធ្វើការនៅក្នុងក្រសួងការបរទេសនៅប្រទេសក្រៅតែប៉ុណ្ណឹង។ ខ្ញុំក៏លួចសើចក្នុងចិត្តទៀត។ ប៉ុន្មានថ្ងៃក្រោយមកស្រាប់តែឮសូរលោក អៀង សារី មកទៀតហើយដើម្បីរកសៀវភៅប្រវត្តិសាស្ត្រព្រោះថា ត្រូវការចាយលុយច្រើនណាស់ដើម្បីទិញសៀវភៅប្រវត្តិសាស្ត្រ។ ពេលហ្នឹងខ្ញុំគ្រាន់តែមើលមុខ ទ្រី ម៉េងហួត ចំភ្នែកព្រោះថា ទ្រី ម៉េងហួត បានយកសៀវភៅល្អៗ សៀវភៅបច្ចេកទេសអីដែលខ្ញុំប្រមូលទុកជាមួយលោកគ្រូពេទ្យ ស៊ូ នោះ។ ទុកនៅក្រោមផ្ទះ ហើយគ្របសង្កសីកុំឱ្យភ្លៀងទទឹក។ លោក ហួត ហ្នឹង គេបានយកសៀវភៅទៅដុតចោលអស់ទៅចាំ! ខ្ញុំចេះតែគិតថា ចុះ រួចចង្រៃអីបើសៀវភៅនៅក្រោមផ្ទះហ្នឹង ហើយខំប្រើពេលហ្នឹងវាសម្រាប់តែដុត សៀវភៅហ្នឹងចោលហើយថែមកសាងពួកខ្ញុំថាមានធាតុបញ្ញាជនក្រាស់ហើយពីមុនណោះពេលគេកសាងខ្ញុំខ្លាំងពេកទៅ ខ្ញុំចេះតែពិចារណាមើលខ្លួនឯងថា «ចុះខ្ញុំម៉េចខុសគេម្ល៉េះ? ម៉េចក៏គេពួកចេះតែជឿតាមខ្មែរក្រហម។ អ្នកធ្វើហ្នឹងម៉េចក៏ខ្ញុំរកតែជេរមិនកើត។ រួច ទ្រី ម៉េងហួត ហ្នឹងសុទ្ធតែរៀនដល់បណ្ឌិតស៊ីម៉ីអីផងម៉េចក៏គេជម្រុះអាធាតុបញ្ញាជនគេបានរហ័សម្ល៉េះ។ ខ្ញុំជាអ្នករៀនបានត្រឹមបន្តិចបន្តួចធ្វើគ្រូកំប៉ិកកំប៉ុកម៉េចក៏ពិបាកជម្រុះអាធាតុបញ្ញាជនម្ល៉េះ។ ដល់ខ្ញុំគិតយូរៗទៅ ខ្ញុំថា ពួកនេះដូចថា ក្រហមហួសខ្មែរក្រហមទៀតណា ដែលគេចង់បានមុខនាទីតំណែងអីមួយនៅក្នុងរបបហ្នឹង ម្ល៉ោះហើយឃើញថាគេមិនស្មោះត្រង់នឹងខ្លួនគេ។ ដល់ ខ្ញុំវិញខ្ញុំធ្វើមិនកើត។ ហើយដល់ពេលខ្លះដូចបន្ទោសខ្លួនឯងថា ខ្លួនឯងខុសគេទៀតចាំ!»។

រាសី៖ បាទ! ហើយពេលដែលគេហៅរកគ្រូ តើហៅទាំងអស់ប៉ុន្មាននាក់ដែរ?

សារីម៖ ចា៎! ខ្ញុំមិនដឹងប៉ុន្មានទេ ប៉ុន្តែខ្ញុំគ្រាន់តែឃើញថា វណ្ណា ដែលទៅពីបឹហ្សង់សុង ដូចខ្ញុំហ្នឹងបានទៅជួបគេ។ ហើយអ្នកឯទៀតក៏បានទៅជួបដែរ។ គេបម្រុងឱ្យទៅធ្វើគ្រូ។ មានអ្នកខ្លះមកប្រាប់ខ្ញុំថា ខ្ញុំធ្វើប្រធានទ្រុងទា ដែលមាន វណ្ណា ជាកូនក្រុមឥឡូវ វណ្ណា ឡើងធ្វើគ្រូ។ ខ្លួនឯងធ្វើ មេទ្រុងទា ធ្វើប្រធានក្រុមគេហ្នឹងអត់បានទៅណា មានអន់ចិត្តអីទេ? ខ្ញុំថា ខ្ញុំសប្បាយណាស់ដែលបាននៅទ្រុងទាហ្នឹង ហើយខ្ញុំជម្រាបលោក ប៉ូច រាសី ថា ខ្ញុំបង្រៀនឆ្អែតហើយ អត់ចង់ធ្វើគ្រូបង្រៀនទៀតទេ ព្រោះថាធ្វើគ្រូបង្រៀនតាំងពីធ្វើទៅបានលុយចាយគ្រប់គ្រាន់។ ធ្វើតាំងពីមានដល់ក្រនៅសម័យលន់ ណុល។ តាំងពីកើតមកមិនដែលបានមានឱកាសចិញ្ចឹមសត្វមាន់ទាទេ ព្រោះជីដូនជីតាខ្ញុំប្រកាន់។ គាត់មិនឱ្យចិញ្ចឹមជ្រូកមាន់ទាទេ។ ទៅដណ្ដឹងកូនគេឱ្យឪពុកខ្ញុំ ជីតាខ្ញុំឃើញថាផ្ទះគេមានទ្រុងជ្រូកនៅក្រោមផ្ទះ គាត់អត់ចូលដណ្ដឹងទេ។ ដល់ឥឡូវមកនៅបឹងត្របែកបានអុំទូកទៅរើសខ្យងពីព្រលឹម ហើយមើលថ្ងៃរះនៅលើទឹកនៅបឹងត្របែក និងបានទៅចាប់ខ្យងដែលអណ្ដែតខ្លួនដូចផ្សិតខ្មៅនៅក្នុងទឹកបឹងនឹងបានស្រង់ចកធំៗប៉ុនចានឡដាក់ក្នុងទូកយកឱ្យបាយទាបាយជ្រូក។ ខ្ញុំអាចច្រៀងបទបារាំង បទខ្មែរ ឬក៏សូត្រកំណាព្យតាមខ្ញុំចិត្តខ្ញុំចង់នៅក្នុងបឹងតែម្នាក់ឯង។ ខ្ញុំសប្បាយណាស់។ ខ្ញុំអត់ចង់ទៅបង្រៀនអីទេ។ ខ្ញុំទៅពិកនិករាល់ថ្ងៃពោះទទេមើលធម្មជាតិ ហើយនឹងរើសពងខ្យងដែលនៅអារាត់អារាយនៅបឹងត្របែកយកទៅដាក់នៅកៀនកុំឱ្យគេជាន់ព្រោះពងខ្យងល្អណាស់ដូចផ្កាសម៉ាក្រញ៉ាំៗ។

រាសី៖ បាទ! អញ្ចឹងពេលដែលគេមករកគ្រូហ្នឹងគឺគេចុចឈ្មោះហ្មង មិនមែនសួរអ្នកណាស្ម័គ្រចិត្តនោះទេបាទ!?

សារីម៖ ចា៎! អត់មានបានអីមកសួរយើងទេចា៎!។

រាសី៖ បាទ! អញ្ចឹងពួកខ្មែរក្រហមដឹងដែរថាអ្នកស្រីវិលត្រឡប់ពីប្រទេសបារាំងមកហ្នឹងក្នុងនាមជាគ្រូបង្រៀនមែនទេ ពេលហ្នឹងគេដឹងមែនទេ?

សារីមេះ ចាំ! គេដឹងទាំងអស់ប្រវត្តិរូបយើង។ គេដឹងទាំងអស់នរណាជានរណារហូតដល់ពួកមេខ្មែរក្រហមថា កន្លែងនេះដូចកន្លែងសម្រាំង។ ចង់បានអីមកបឹងត្របែក។ អ្នកច្រៀងធ្វើសំឡេងខ្ពស់សំឡេងទាប។ ចង់បានអ្នកភ្លេង វិស្វករមកដូសតែពីហ្នឹងទៅមិនខ្វះទេ។

រាសីះ បាទ! ហើយម៉េចទៅគម្រោងការហ្នឹងដល់ទីបំផុតមានបានជាផ្លែផ្កាទេ?

សារីមេះ ចាំ! រឿងហ្នឹងបានតែឮសូរថាមានអញ្ចឹង។ ហៅទៅជួប។ គេនាំគ្នាទៅដើរលេងម្តង។ ដូចខ្ញុំជម្រាបពីលើកមុន។ វានៅស្តុកនៅហ្នឹងទៅអត់មានឃើញបានអ្នកណាចេញទៅណា។ ប៉ុន្តែគ្រាន់តែអ្នកដែលមកបម្រុងយកទៅធ្វើគ្រូ ក្រោយមកគេដកចេញពីកន្លែងយើងយកទៅនៅកន្លែងផ្សេង។

រាសីះ បាទ! ហើយអ្នកដែលគេដកចេញដែលថាមានឈ្មោះទៅបង្រៀនហ្នឹង ដកចេញទៅហ្នឹងក្រោយមកអ្នកស្រីបានឃើញពួកគេដែរ?

សារីមេះ ចាំ! ដល់ពេលយើងរត់ចេញពីបឹងត្របែក យើងជួបអ្នកអស់ហ្នឹង។

រាសីះ បាទ! អញ្ចឹងស្ថានការណ៍នៅពេលហ្នឹង ក្រោយពីមានគម្រោងចង់បង្កើតមហាវិទ្យាល័យហ្នឹងចូលដល់ពាក់កណ្តាលឆ្នាំ១៩៧៨ហើយមែនទេបាទ!?

សារីមេះ ចាំ! មុនហ្នឹងបន្តិច ពេលស្ថានការណ៍កាន់តែតឹង ខ្មែរក្រហមបាន និយាយ ខ្ញុំមិនបានជម្រាបពីមុន សារ៉ែន បាននិយាយថា កងទ័ពរបស់អង្គការខ្លាំងពូកែ ម្នាក់ហ៊ានវាយយួន៣០នាក់។ តាំងពីពេលដែលខ្ញុំឮសូរថាម្នាក់វាយជាមួយយួន៣០នាក់ហ្នឹង ខ្ញុំរៀបចំអីវ៉ាន់ខ្ញុំហ្នឹងដាក់ជាប់ខ្លួន។ ខ្ញុំដើរប្រាប់អ្នកដទៃដែលខ្ញុំទុកចិត្តខ្ញុំថាត្រូវរៀបចំអីវ៉ាន់។ ម្នាក់ទៀតឈ្មោះ អ្នក កេត ប្រពន្ធ សន្និវ៉ាត់។ គាត់សម្រានយប់ចោមពុងព្រោះថាក្តៅពេក។ ខ្ញុំប្រាប់អ្នកថា ត្រូវពាក់អាវ ហើយពាក់អាវល្អៗទៅពីព្រោះម្នាក់ទល់នឹង៣០ហ្នឹងមិនមែនទិស សម្រាប់ឈ្នះទេ គឺទិសសម្រាប់រត់ ហើយអ្នកហ្នឹងគាត់សួរខ្ញុំថា បងឯងដឹងពីណាមក? ខ្ញុំថា មិនស្តាប់ទេអី បើអង្គការថាម្នាក់ទល់នឹង៣០ប៉ុណ្ណឹង យើងធ្វើការវិភាគទៅដឹងហើយ។

រាសី ៖ បាទ! អីចឹងកាលហ្នឹងវិទ្យុខ្មែរក្រហម ឬមួយនៅក្នុងអង្គប្រជុំអីគេនិយាយយ៉ាងដូចម្តេចខ្លះពីរឿងបញ្ហាជាមួយប្រទេសវៀតណាមហ្នឹង ពេលហ្នឹងបាទ?

សារីម ៖ ចាំ! គេបានទៅចាក់ឱ្យយើងស្តាប់ថាយួនហ្នឹងបានវាយចូលមក ហើយខ្លួនឯងក៏បាន វាយបកទៅវិញ គឺថាច្បាំងគ្នាចុះឡើងអីចឹង រួចទៅរហូតដល់ស្ថានការណ៍តានតឹងមែនទែន គេថាឥឡូវនេះយួនហ្នឹងវាយមកហ្នឹងសឹងអស់មួយចំហៀងខាងទិសបូព៌ាហើយចាំ! ហើយខ្មែរក្រហមនិយាយប្រាប់យើងថាខ្មោចដែលមានពាក់ស្បែកជើងកង់ឡានរបស់ ខ្មែរក្រហមនោះនៅក្នុងកងទ័ពយួនផងចាំ! ហើយខ្មែរក្រហមហ្នឹងមានគម្រោងការដកមនុស្សដែលនៅដីក្រហមនោះមកចូលបឹងត្របែកវិញ។ ខ្ញុំចាំពេល ហ្នឹងដូចខែ៧ អីចឹងព្រោះទឹកឡើង។

រាសី ៖ បាទ! ហើយនៅពេលឮសូរពីរឿងសង្គ្រាមជាមួយប្រទេសវៀតណាមអីចឹងទៅតើអ្នកស្រី និងអ្នកឯទៀតនៅជាមួយគ្នាហ្នឹងមានចាប់អារម្មណ៍យ៉ាងម៉េចដែរ?

សារីម ៖ ចាំ! ពេលហ្នឹងពួកយើងមានការប្រុងប្រយ័ត្នណាស់ ខ្លាចគេថាយើងបម្រើឧបាយកលខ្មាំងនោះណា។ រួចទៅហើយខ្ញុំ ដូចខ្ញុំជម្រាបពីមុនអីចឹង ខ្ញុំបាននិយាយតែជាមួយអ្នកណាដែលខ្ញុំទុកចិត្តទេ ខ្ញុំប្រាប់អ្នក កេត ហ្នឹងឱ្យគាត់ឈប់ចោមពង់សំពត់ទៀតទៅ។ ពេលយប់ឱ្យពាក់អាវឱ្យស្រួលបួល ព្រោះយួននៅមិនឆ្ងាយពីទល់ដែនយើងទេ ប្រហែលពីស្រុកខ្ញុំកៀនស្វាយហ្នឹងប្រហែល៥០-៦០ គីឡូម៉ែត្រពីយើងហ្នឹង។ រួចទៅបើយើងរត់មិនទាន់ ពេលខ្លះយួនច្រឡំថាយើងហ្នឹងខ្មែរក្រហម គេអាចសម្លាប់យើងអីចឹងចាំ!។

រាសី ៖ បាទ! ដូច្នេះនៅក្នុងចិត្តអ្នកស្រីមានការនឹកគិតថា របបខ្មែរក្រហមប្រហែលជាដល់ ទីបញ្ចប់ហើយឬយ៉ាងម៉េចដែរ?

សារីម ៖ ចាំ! ចំពោះខ្ញុំពេលហ្នឹងដូចចុះទឹកក្រពើហើយនឹងឡើងលើខ្លាអីចឹង ហើយគឺថាការសំខាន់នោះគឺខ្ញុំត្រូវតែរក្សាជីវិតខ្ញុំហ្នឹងឱ្យរស់ ទោះជាខ្ញុំមិនចូលចិត្តខាងរបបខ្មែរក្រហមក្តី ហើយខ្ញុំក៏មិនឱ្យយួនមកឈ្លានពានទឹកដីខ្មែរដែរ ព្រោះការណ៍នេះជាការណ៍មួយដែលពិបាកទទួលយ៉ាងក្រៃលែង។ ទោះជាកាលពីពេលមុនហ្នឹងខ្ញុំ

ធ្លាប់ប្រាប់ វណ្ណា ពេល វណ្ណា គេចង់រត់ចងកសម្លាប់ខ្លួននោះ ខ្ញុំថា «វណ្ណា ឯងហ្នឹង កុំសម្លាប់ខ្លួន បើ វណ្ណា ឯងស្លាប់ទៅហ្នឹង ខ្មែរក្រហមគេអូសខ្មោច វណ្ណា ឯង ហើយគេស្តោះទឹកមាត់ដាក់លើទៀត ហើយគេថាយើងហ្នឹងជាជនក្បត់ជាតិ ប៉ុន្តែ ចំពោះយើងគេទេដែលក្បត់ជាតិ ពីព្រោះរបបនេះបានសម្លាប់ប្រជាជនខ្មែរច្រើន ណាស់» ហើយខ្ញុំប្រាប់ វណ្ណា ទៀតថា «ចាំមើលខ្ញុំគិតថា របបខ្មែរក្រហមហ្នឹងរស់ ដល់ត្រឹមឆ្នាំ៨០ ហើយបើរស់លើសពីហ្នឹងតទៅទៀតហ្នឹង គឺខ្ញុំពិតជាហ៊ានលើក ដងចបហ្នឹងវាយវិញហើយចាំ! ពីព្រោះខ្ញុំមិនអាចទ្រាំរស់នៅក្នុងរបបមួយដែលធ្វើ ឱ្យជីវិតមិនមែនជីវិតនោះទេ»។ ហើយខ្ញុំធ្លាប់បាននិយាយអីចឹងប្រាប់វណ្ណាប៉ុន្តែ ដល់តែពេល យួនវាយខ្មែរក្រហមហ្នឹងទៅ ហើយខ្ញុំឃើញថាខ្មែរក្រហមហ្នឹង គេឈប់គោរពទង់បក្ស របស់គេ ហើយបែរមកគោរពជំហរស្នេហាជាតិវិញហ្នឹង។ ខ្ញុំក៏បានសុខចិត្តទទួលធ្វើប្រធានទ្រុងទាហ្នឹងទៅ ប៉ុន្តែខ្ញុំនៅតែខំប្រយ័ត្នខ្លួនខ្ញុំ យ៉ាងក្រៃលែងចាំ! ហើយពេលខ្ញុំ ចិញ្ចឹមហ្នឹងគឺខ្មែរក្រហមអត់មានឱ្យម្ហូបអាហារអី មកឱ្យទាទេ គឺខ្ញុំរកខ្លួនឯងទាំងអស់នៅ ក្នុងបឹងត្របែកហ្នឹង គឺខ្ញុំប្រមូលដូងដែល វាជ្រុះចោលគរមកគរទុកដូចភ្នំក្នុងទ្រុងទាហ្នឹង ហើយនឹងខ្ញុំទៅចាប់ខ្យងហើយនឹង ដាំស្លឹកគ្រៃទុកឱ្យទាស៊ីទៀត។ ទាដែលខ្ញុំ ចិញ្ចឹមហ្នឹងគឺកូនទាអត់ដែលងាប់សោះ ចាំ! ឱ្យតែយើងធ្លោយអីបន្តិចហ្នឹង គេចោទ យើងថាខ្មាំង ឬក៏ ម្ល៉ោះហើយគឺថាខ្ញុំ មានការប្រុងប្រយ័ត្នចាត់តាំងឱ្យខ្ញុំធ្វើអី ខ្ញុំធ្វើ ហ្នឹង ហើយគេបន្ថែមឱ្យខ្ញុំធ្វើប្រធាន ទ្រុងទាមើលសត្វផងហ្នឹង ហើយឱ្យខ្ញុំធ្វើប្រធាន ខាងមន្ទីរកុមារទៀត។ គេយក កុមារមកឱ្យខ្ញុំមើលទៀតពេលហ្នឹង គេឱ្យខ្ញុំចិញ្ចឹម ទន្សាយទៀតសម្រាប់យកទៅ ធ្វើពិសោធន៍នៅ Institute Pasteur។ ស្រាប់តែថ្ងៃ មួយហ្នឹងពួកកុមារមកធ្វើឱ្យឆេះ ទ្រុងទន្សាយ។ ពេលនោះខ្ញុំភ័យមែនទែន ព្រោះខ្លាច គេចោទថាខ្ញុំហ្នឹងខ្មាំងអីចាំ! ចាំ! ពេលហ្នឹងមានម្នាក់ឈ្មោះ តា ជ ហ្នឹងធ្វើ Achitecteur គ្រូបង្រៀនមកពីតំបន់ រំដោះហ្នឹង គឺកសាងខ្ញុំខ្លាំងណាស់ចាំ! ប៉ុន្តែខ្ញុំ បានឆ្លើយប្រាប់ទៅវិញថា «ខ្ញុំបាន បង្រៀនកុមារសព្វគ្រប់ហើយ ប៉ុន្តែកុមារបានធ្វើការថ្លោះធ្លោយ»។

រាសី ៖ ហើយចឹងចុះដល់ពេលមានការផ្លាស់ប្តូរទៅជាអារម្មណ៍ស្នេហាជាតិអីចឹង តើការរាប់អានរបស់ខ្មែរក្រហមជាមួយអ្នកស្រី ជាមួយអ្នកដែលវិលត្រឡប់មកពីបរទេសហ្នឹងមានល្អប្រសើរជាងមុនទេ?

សារីម ៖ ចាំ! ពេលហ្នឹងមានជំហរស្នេហាជាតិអីចឹងទៅដូច ចាប់ សារ៉ន អីទៅ ដូច្នេះការរស់នៅកន្លែងយើងហ្នឹងវាមិនសូវមានការគាបសង្កត់អីទេចាំ! ហើយក្នុងការនិយាយស្តីមករកយើងអី ឈប់មើលងាយពួកបញ្ញាជននោះ។ ចុះនៅបឹងត្របែកហ្នឹងសុទ្ធតែបញ្ញាជនទាំងអស់គ្នាណា ហាក់ដូចជាយើងហ្នឹងដូចថាមានការធូរស្រាល ក្នុងខ្លួន។ ហើយទៅដល់ពួកដីក្រហមត្រឡប់មកវិញហ្នឹង គឺថាស្ថានការណ៍វាកាន់តែតឹង រហូតដល់តែគេឱ្យយើងជីកត្រង់សេ។ ខ្មែរយើងថាលេណដ្ឋានគឺកន្លែងពួន ហើយទៅយើងត្រៀមលក្ខណៈដូចខ្ញុំអីចឹង ខ្ញុំត្រៀមតាំងពីមុនរួចស្រេចហើយ ម្នាក់ទល់នឹង៣០។ ខ្ញុំរៀបចំអីវ៉ាន់ខ្ញុំមុនគេហើយចាំ! ហើយដល់រួចទៅ គេឱ្យខ្ញុំធ្វើប្រធានមន្ទីរកុមារហ្នឹង គេឱ្យយើងហ្នឹងត្រៀមលក្ខណៈថាសម្រាប់កាលណាមានរត់អី ឱ្យយើងមានបាយ ម្ហូបទុកឱ្យបានយូរសម្រាប់ឱ្យកុមារទៅ ហើយគេប្រាប់យើងថា «នែពួកបងៗកសាងខ្លួនបានហើយអាចទៅចូលព្រៃជាមួយយើងបាន»។ ពួកយើងដឹងខ្លួន ហើយថា «ហ៊ឺស! កាលមុនគេថាយើងមិនបានការអីទេមានតែកម្លាំងអត់ជំហរ មានតែជំហរអត់កម្លាំងស្រាប់តែឥឡូវគេមកសរសើរយើងថាយើងហ្នឹងអាចទៅព្រៃ បានទៀត»។

រាសី ៖ ពីព្រោះៗប្រហែលជាជាតិគេត្រូវការ បាទ! ហើយចុះអីចឹងតើនៅពេលហ្នឹងមានឮសូរគ្រាប់កាំភ្លើងល្វើយៗ?

សារីម ៖ ចាំ! មានអ្នកខ្លះហ្នឹងគេថា គេហ្នឹងបានឮសូរ ព្រោះខ្ញុំតាមខ្ញុំយល់ត្រចៀកខ្ញុំបែបធ្ងន់ ដូច្នេះពេលញ័រអីល្មមអី ខ្ញុំបែបអត់ឮទេ។

រាសី ៖ បាទ! បើអីចឹងបើតាមអ្នកស្រីមានប្រសាសន៍មិញហ្នឹង គឺពួកខ្មែរក្រហមដឹងខ្លួនថា យួនច្បាស់ជាវាយចូលហើយ បានជាត្រៀមរបៀបចូលព្រៃ របៀបធ្វើម្ហូបទុកបាន យូរហើយអីចឹង?

សារីម ៖ ចាំ! ខ្ញុំយល់ទៅថា គេដឹងហើយ ព្រោះគេថាអស់មួយចំហៀងខាងបូព៌ាហើយនោះ ចាំ! យើងគ្រាន់តែស្តាប់ទៅ យើងចេះតែខំប្រឹងតម្រង់ជំហររបស់យើងនោះខ្លាចផ្លោះផ្លោយនោះចាំ!។

រាសី ៖ ហើយអីចឹងអ្នកស្រីមានការភ័យពីរឿងសន្តិសុខទេ មានភិតភ័យថាសង្គ្រាមមកទៀតហើយ?

សារីម ៖ ចាំ! ខ្ញុំពេលហ្នឹងគិតថាពេលណាលិចសំឡូត ហើយនឹងពេលដល់កំពតសំតោងដូចថា យើងអត់មានគិតអីបានមុនទុកទេចាំ! ហើយទៅធ្វើម៉េចខំរក្សាជីវិតរបស់ខ្លួនហ្នឹង ឱ្យនៅរស់ចាំ! សូមអរគុណ។

រាសី ៖ ហើយដល់ពេលអីចឹងទៅ ក្នុងចិត្តមានក្តីសង្ឃឹមបន្តិចបន្តួចថាបើរត់ទៅអាចប្រហែល ជាជួបគ្រួសារវិញទេមើលទៅ?

សារីម ៖ ចាំ! ពេលហ្នឹងខ្ញុំបានគិតជាមួយអ្នកខ្លះ ខ្ញុំថាពេលហ្នឹងចូលក្នុងការប្រាថ្នា របស់យើងហើយ ពីព្រោះយើងគេយកមកឃុំជាប់នៅហ្នឹង ដល់តែពេលរត់ទីណាត់ទីណែងទៅ យើងនឹងបានជួបប្រជាជនហើយចាំ! ហើយដល់សម្រេចសម្រួលទៅ គឺថាយើងរត់មែនចាំ!...អ្នកដែលមកពីតំបន់រំដោះ ដែលគេមកនៅបឹងត្របែកជាមួយយើងនោះ គឺពួកអ្នកធ្លាប់ចូលព្រៃតាមខ្មែរក្រហម នោះ។ ហើយដូចជាអ្នកម្នាក់នោះឈ្មោះ អ្នក និត ដែលប្តីគាត់ឈ្មោះលោកដុកទ័រ យូ គឹមយៀត ហ្នឹងបានចូលព្រៃជាមួយខ្មែរក្រហមពេលដែលខ្មែរក្រហមវាយ លុកចូលកំពង់ស្ពឺសម័យលន់ នល់នោះ។ និតនោះបានប្រាប់យើងខ្ញុំថា នៅព្រៃចម្ការលើគឺពេលហ្នឹងខ្មែរក្រហមបានជួបប្រទះនឹងការធ្វើវិទ្ធង្សនាច្រើនដងណាស់ ពីសំណាក់ ពួកខ្មែរក្រហមដែលចូលមកពីប្រទេសវៀតណាម ហើយមានការសម្លាប់គ្នាទៅវិញ ទៅមកច្រើនដងចាំ! ហើយអ្នក និត ហ្នឹងកូនគាត់បានជួបនិរសារខ្មែរក្រហមនៅ វត្តបុទុមច្រើនដងមុននឹងគាត់បានចេញទៅព្រៃជាមួយកូនប្រុសឈ្មោះ លុច ហ្នឹង ដើម្បីទៅជួបប្តីគាត់នោះ ទោះជាគ្រូទាយថាប្តីគាត់ហ្នឹងស្លាប់ហើយ។ បើគិតជាស្មៅដុះហ្នឹងវាដល់ចង្កេះទៅហើយ ហើយអ្នក និត

ថានៅតំបន់រំដោះ បើគេចង់ពិសា ដូចជានំប៉ាវពីហាងត្រីស្គាល់អីហ្នឹង គឺគេឱ្យតែនិរសារចូលភ្នំពេញមក គឺបាននំប៉ាវទៅ ហ្នឹងក្តៅៗថា!។ ហើយនាង គុំ កូនស្រីរបស់លោក ជី គឹមអាន ហើយនឹង អ្នកគ្រូ សំប៊ុន ដែលយើងហៅគាត់ថាបងពៅ ហ្នឹងនៅបឹងត្របែកបានប្រាប់ខ្ញុំថា គ្រូពេទ្យ ជួន ជឿន នោះនៅក្នុងព្រៃមានកូនផ្ទះមួយហ្នឹងដាក់មុងពេញ ហើយពេលយប់ៗ ហ្នឹងគាត់បង្រៀនបារាំងឱ្យកូនគាត់ បើអីចឹងហើយពួកខ្មែរក្រហមហ្នឹងកសាង។ ចំណែកឯលោក ខៀវ សំផន វិញថា ពេលត្រឡប់មកពីបរទេសម្តងៗហ្នឹង គឺបានគ្រឿងកំប៉ុងមកផ្ញើម្តាយគាត់ហើយ។ ប៉ុន្តែ អ្នកនិត ហើយនឹង អ្នកពៅ ហ្នឹង ពេលទៅដល់តំបន់រំដោះហ្នឹង ប្តីគាត់ស្លាប់អស់ទៅហើយ។ ហើយគ្រួសារមួយ ទៀតគឺបង យិន ម្តាយគាត់ឈ្មោះ យ៉ាន ហើយនឹងប្អូនស្រីឈ្មោះ វ៉ន ហ្នឹង គាត់និយាយថា ពួកបងប្អូនយើងនៅតំបន់រំដោះខ្លាចគ្រាប់បែកបេ៥២ ហ្នឹងមែនទែន ហើយស្អប់អ្នកបើកកប៉ាល់ហោះរហូតដល់ហ៊ានវាយអ្នកដើរតួបើកកប៉ាល់ហោះ។ ពេលដែលមានការសម្តែងសិល្បៈ អ្នកអស់ហ្នឹងតែចុះពីលើឆាកមកវិញម្តងៗត្រូវតែមានអ្នកយាម បើមិនអីចឹងទេខ្លាចបងប្អូនយើងហ្នឹងគាត់វាយ។ នៅតំបន់រំដោះពេលណាដែលគេសម្រាលកូនហើយហ្នឹង សុកគេមិនយកទៅកប់ចោលទេ គេទុក សម្រាប់ធ្វើម្ហូប ហើយបានប្រាប់ពួកអ្នកស្រុកថា ហូបត្រយ៉ូងចេកហ្នឹងជួយខួរក្បាល ច្រើនណាស់។ ហើយនៅសម័យខ្មែរក្រហមគឺគេជេឈ្មោះអាឈួនៗនោះខ្លាំងមែនទែន មេទាហានឈ្មោះ ឈួន ហ្នឹងថាបានដណ្តើមដីប្រជាពលរដ្ឋហ្នឹងនៅសំឡូត រហូតដល់គេតែងរឿងល្ខោនបាសាក់មួយហ្នឹងលើកពីវីរភាពស្រ្តីដែលនាំស្បៀងចូលព្រៃទៅឱ្យពួកអ្នករត់ចូលព្រៃនៅសំឡូតហ្នឹងហើយនាងហ្នឹងបានកាត់ម្រាមដៃខ្លួនឯង ចោលពេលពស់ចឹក។ បទហ្នឹងថា កូនអើយម្រាមដៃម៉ែទាំងពីរគ្មានអ្វីខ្វល់ទេ ហើយក៏ មិនត្រូវស្តាយ ហើយបានដាក់អង្ករហ្នឹងក្នុងកន្ទុយក្បិនរបស់ខ្លួនហ្នឹងដើម្បីយកទៅឱ្យ អ្នកនៅក្នុងព្រៃ។ នៅបឹងត្របែកមានថៅក្រមម្នាក់ឈ្មោះ ចាន់ បុផា ដែលរត់ចូលព្រៃទៅ ហើយប្រពន្ធគាត់ទៅតាមក្រោយ។ ប្រពន្ធគាត់ថា ពេលចូលទៅហ្នឹងគាត់បានជួប ភ្លង

ម៉ាហ្គាំង ដែលចូលទៅមុនគាត់ ហើយនិយាយថា «នៅ តំបន់រំដោះហ្នឹងស្រួល រស់ ព្រោះអង្គការផ្ញើនយោបាយទិញអីវ៉ាន់ពីភ្នំពេញទៅថ្លៃ យកទៅលក់ថោក នៅតំបន់រំដោះ»។ អ្នកនោះគាត់ថាគាត់យកលុយទៅច្រើន បើចង់ពិសានំបញ្ចុក ឬបាញ់ឆែវអីគាត់មៅទាំងរោងហ្មង យកមកចែកគេឯងហូប ហើយលោក ថៅក្រម ចាន់ បុផា ហ្នឹងម្តងហ្នឹងគាត់និយាយរិះគន់ខ្លាំងៗលើចម្រៀង របស់ អង្គការបដិវត្តន៍ដែលគេប្រើពាក្យថាជាឧបករណ៍ដាច់ថ្លៃរបស់បក្សនោះ។ ក្រោយមកស្រាប់តែបាត់គ្រួសារហ្នឹងទៅចាំ។ ចំណែកតា ជ វិញដែលជា អាំងស្តេចទ័រ គ្រូបង្រៀនទៅចូលតំបន់រំដោះដែរហ្នឹង គាត់ពេលដើរហ្នឹងប្រុសៗ ខ្លះមិនឱ្យគាត់កាន់ដៃអីនៅបឹងត្របែកហ្នឹង តា ជ ហ្នឹងថា ចេះតែយកវប្បធម៌ បរទេសមកបង្ខក់បំពុល នៅក្នុងសង្គមបដិវត្តន៍។ គាត់មិនចូលចិត្តរឿងថាប្រុស ស្រឡាញ់ប្រុសអីទេ។ នៅបឹងត្របែកមានអ្នកទៅបរទេសចូលទៅចុង ក្រោយ គេហ្នឹង ខ្ញុំចាំមាននាងម្នាក់ហ្នឹង គេថាកូនរបស់លោកបណ្ឌិត ហូ តុងលិប ដែល ពូកែខាងស្រាវជ្រាវខាង កសិកម្មនោះ។ នាងហ្នឹងមានផ្ទៃពោះផង ចូលទៅ ហ្នឹង ជាមួយប្តី ហើយពេលនោះ ខ្ញុំក៏ឆ្ងល់ថា ចុះម៉េចបានគ្រួសារហ្នឹងទើបមក ដល់ អីចឹង? នាង គាត កុលណី ប្អូនស្រីលោក គាត ឈុន ហ្នឹងគាត់ថាៗ «ហ៊ឹស! ខ្វះ អីអ្នកដែលទើបមកដល់ ប៉ុន្តែអ្នកខ្លះអង្គការយកមកឱ្យនៅកន្លែងយើង ហើយ មាន អាខ្លះអង្គការយកទៅកន្លែងផ្សេង ដូច ឡុង ឆោម ដារ៉ា នៅទួលួស ក៏មក ដែរ តែអង្គការយកទៅកន្លែងផ្សេង ទៅចាំ»។ ពេលហ្នឹងខ្ញុំដឹងថា អូ! ឡុង ឆោមដារ៉ា ហ្នឹងជាសាច់ញាតិរបស់ខ្ញុំក៏មកដែរ ឡុង ឆោមដារ៉ា ហ្នឹង ជាក្មួយ របស់ ទឹម ដុង ហើយក្នុងចំណោមអ្នកថ្មីហ្នឹងគឺថាមាន អ្នកជម្លៀសបីនាក់ហ្នឹង មកនៅជាមួយ យើងដែរ។ លោកប្រុសហ្នឹងឈ្មោះ លូ ហើយ យើងហៅគាត់ថា អ៊ំ លូ គាត់ជាប់ សាច់ញាតិជាមួយត្រកូលលោក ដុកទ័រ ពេទ្យ ជួន ជឿន នោះ ហើយប្រពន្ធអ៊ំ លូ ហ្នឹងឈ្មោះ អ៊ា រ៉ែន ហើយនឹងប្រពន្ធគាត់ហ្នឹងមានបងស្រី មកជាមួយដែរ គឺឈ្មោះបង និត អ្នកទាំងបីហ្នឹងមកដល់សរសើរបឹងត្របែក យើងណាស់ថា ពួក យើងនេះរស់នៅស្អាតបាតណាស់ ហើយមានរបៀបរៀប

រយចាំ! ហើយខ្ញុំសុំ ជម្រាបថា កាលដែលខ្មែរក្រហមឱ្យយើងស្តាប់ រ៉ាត់យោ(វិទ្យុ) ហ្នឹងជូនណា ធ្វើឱ្យយើងរឹតតែខឹងខ្លាំងដូចជាខ្មែរក្រហមស្រែកថា យើងមាន របប១៥ថាំង បាយ បីពេល មានបង្អែមទៀត ហើយ ជូន ប្រសិដ្ឋ តំណាងខ្មែរក្រហមនៅអង្គការ សហប្រជាជាតិហ្នឹងគឺថា បានផ្សាយរឿងហ្នឹងឱ្យ អង្គការសហប្រជាជាតិដឹង ប៉ុន្តែ យើងនៅស្រុកវិញរបបហ្នឹងមិនទៅឆ្អែតផង។ ថ្ងៃមួយពេលឮស្ងរ៉ាត់យោ ខ្មែរក្រហមរិះគន់របបសង្គមនិយមវៀតណាមថាយក ពន្ធដាច្រើនទៅលើប្រជាពលរដ្ឋហ្នឹង ស្រាប់តែបង រ៉ែន ហ្នឹងគាត់មកប្រាប់ខ្ញុំថា «ហ៊ឺស! ដល់ខ្លួនឯងវិញហ្នឹង យកពីយើងអស់រលីង ព្រោះគេធ្វើសមូហភាព»។ ដល់អីចឹង បាន អ៊ំ លូ គាត់ថា អីចឹងហើយបានតែពេលគាត់ឱ្យលោក អៀង សារី ខ្ចីផ្ទះនៅកែបកាលពីសម័យ សង្គម ហើយកូនស្រីលោក អៀង សារី ថា «អូ! ផ្ទះនេះល្អណាស់ ហើយសប្បាយ ណាស់ ហើយ អៀង សារី ថាបន្តិចទៀត នឹងជារបស់យើង ហើយ»។ អ៊ំ លូ ថា «ហ្នឹងហើយសមូហភាព ស្រាប់ហើយ»។ សូមជម្រាបថា អ៊ំ លូ ហ្នឹងគាត់ជាអ្នកចាត់ចែង កិច្ចការធំនៅអូតែល ឡឺ រ៉ូយ៉ាល់ ចាំ! កាលពីសម័យសង្គម។ នៅបឹងត្របែក ខ្មែរក្រហមបានរៀបការឱ្យមនុស្ស ច្រើនគូ ចាំ! ហើយអ្នកគ្រូពេទ្យ សាន សុត ហ្នឹងក៏បានរៀបការជាមួយម្នាក់ដែល យើងដាក់ងារគាត់ថា ហេង បែកក្បាល នោះ ព្រោះ ហេង ហ្នឹងធ្លាក់ឈើលើ ក្បាលគាត់ហើយបែក ហើយគាត់ទៅដេកពេទ្យ ក៏គាត់ស្គាល់ សាន ហ្នឹងទៅ។ ក្រោយមកក៏បានរៀបការជាមួយគ្នា ហើយ ដល់រៀបការហើយបានប៉ុន្មាន ថ្ងៃហ្នឹង សាន ហ្នឹងបានមកប្រាប់ខ្ញុំថា ខ្មែរក្រហម បានឱ្យសំបុត្រប្តីចិនរបស់គាត់ ដែលផ្ញើមកហ្នឹងឡើងមួយជង់។ គាត់អាក់អន់ចិត្ត ណាស់មិនគួរណាខ្មែរក្រហម កាក់សំបុត្រប្តីគាត់អីចឹងសោះ ធ្វើឱ្យគាត់អស់សង្ឃឹមបាន គាត់រៀបការ។ សាន គាត់ហួសចិត្តណាស់ ហើយគាត់ថា ហ្នឹងហើយ ជាជំហរដែលថាមានប្តី ឬប្រពន្ធ បរទេសក្បត់ជាតិមួយចំហៀងខ្លួននោះចាំ។ សាន ហ្នឹងរៀបការបានតែបីខែ ហើយពេលហ្នឹងមានផ្ទៃពោះផង ខ្មែរក្រហមក៏ឱ្យគាត់ ចេញទៅនៅកន្លែងផ្សេង តែម្នាក់ឯង។ មុនហ្នឹងចេញទៅហ្នឹង សាន បានមក ប្រាប់ខ្ញុំថា ឈ្មោះគាត់

ពិតហ្នឹងគឺឈ្មោះ សាន នារី។ ហើយ ពេលដែល វាចូលលុកប្រទេសកម្ពុជាហ្នឹង ក្រោយមកខ្ញុំឮថា សាន ហ្នឹងស្លាប់នៅពេលយួន ចូលហ្នឹង ព្រោះគេយកគាត់ទៅធ្វើការនៅកន្លែងឃោសនាការបកប្រែភាសាចិន។

រាសី ៖ បាទ! តើអ្នកស្រីមានការចាប់អារម្មណ៍យ៉ាងដូចម្ដេចខ្លះអំពីអ្នកដែលមកពីដីក្រហម បាទ!?

សារីម ៖ ចាំ! អ្នកដែលមកពីដីក្រហមហ្នឹងភាគច្រើនអ្នកខ្លះមានកូនថែមទៀតផងចាំ! ហើយ អ្នកដែលអត់បានមកហ្នឹងគឺដូចជាលោកគ្រូ អាន ដែលត្រឡប់ទៅពីកន្លែងជាមួយខ្ញុំពី ស្រុកបារាំងទៅហ្នឹង ហើយអ្នកខ្លះទៀតមកដោយមកតែម្នាក់ឯង ហើយមានអ្នក ម្នាក់ហ្នឹងឈ្មោះអ្នក ទីន ប្ដីគាត់ឈ្មោះ ស្វាយ ហុកឃី គាត់ត្រឡប់មកវិញអត់ ឃើញមានប្ដីទេ ហើយខ្ញុំឆ្ងល់ក៏ខ្ញុំសួរអ្នកម្នាក់នោះថា ម៉េចបានអត់ឃើញលោក ស្វាយ ហុកឃី ហ្នឹងមក? ហើយមានអ្នកម្នាក់នៅអង្គុយជិតហ្នឹងគាត់ថា «ហ៊ឺស! អង្រ្កងរោមនៅលើដើមឈើណោះ» ហើយខ្ញុំថា«ម៉េចអីចឹង?» ហើយទៅបានគាត់ថា ប្រហែលជាប្រពន្ធហ្នឹងមានជំហរខ្ពស់ពេកជាងប្ដី ថ្ងៃក្រោយមក អ្នក ទីន ហ្នឹងខ្មែរ ក្រហមបានចេញពីកន្លែងបឹងត្របែកទៅ ហើយ ដល់ក្រោយមកទៀតបានយើងដឹង ថា គាត់ហ្នឹងអ្នកមេម៉ាយហ្នឹង គាត់ហ្នឹងបានក្លាយទៅជាប្រពន្ធលោក ជួន ប្រសិទ្ធ ដែលជាអ្នកតំណាងរបស់អង្គការខ្មែរក្រហមនៅអង្គការសហប្រជាជាតិពេលហ្នឹងចាំ! ហើយមានអ្នកម្នាក់ទៀតហ្នឹងឈ្មោះ អ្នក សូ ពីមុនគាត់មិនសប្បាយចិត្តជាមួយពួក យើងនៅបឹងត្របែកទេ ព្រោះគាត់ថាពួកយើងហ្នឹងសម្ញុំសុខបានជាម្ដាយមីង គាត់ឈ្មោះ ប្លែក វិជា ហើយនឹងប្ដីឈ្មោះ កើត ដែលជាប្រធានមន្ទីរបឹងត្របែកដំបូងហ្នឹង ត្រូវ សារ៉ន យកទៅសម្លាប់ចោល។ ហើយមានអ្នកម្នាក់ទៀត នោះឈ្មោះអ្នក ភូង ជាប្រពន្ធរបស់លោក ឡូយ ស៊ឹមឈាង ក្រោយមកធ្វើជា សមាជិករបស់គណបក្សហ្វ៊ុនស៊ីនប៉ិចនៅរដ្ឋសភាខ្មែរ។ អ្នក ភូង គាត់បានប្រាប់ខ្ញុំថា គាត់ស្រឡាញ់កម្មាភិបាលខ្មែរក្រហមនៅដីក្រហមណាស់ ព្រោះគេសុភាពរាបសារ ហើយគេចិត្តល្អ រហូតដល់

គាត់ហ៊ានថា គាត់ហ្នឹងអាចសឹងហ៊ានប្តូរជីវិតជាមួយពួក នោះ ហើយគាត់ត្រឡប់មកវិញហ្នឹង គាត់មានចង្កៀងតូចៗដែលគេធ្វើពីដបថ្នាំ ប៉េនីស៊ីលីននោះ ដាក់ប្រេងពេញហើយទៅមានដាក់ក្រួសនៅក្នុងហ្នឹង។ តាមការស្មានគឺថាអ្នកខ្លះដាក់គ្រាប់ពេជ្ររបស់គេនៅក្នុងហ្នឹង ចាំ! ហើយពួកខ្មែរក្រហមវិញ ខ្សែចង្កៀងតូចៗរបស់គេហ្នឹងគឺសុទ្ធតែជាខ្សែមាស ចាំ! ហើយប្រធានរបស់យើង នៅបឹងត្របែកហ្នឹងក្រោយមកគឺអ្នកដែលត្រឡប់មកពីដីក្រហមហ្នឹង ធ្វើជាប្រធាន គឺគាត់ហ្នឹងឈ្មោះ ហ៊ុយ គាត់ហ្នឹងដើរទ្រង់បាំងពៀចបន្តិច ចាំ! ហើយ គាត់មានប្រពន្ធគាត់ឈ្មោះ សៀវ ហើយមានកូនពីរបីនាក់ ហើយនៅៗបឹងត្របែក។ ពេលក្រោយមកហ្នឹងមានគេចែកបារីឱ្យយើងជក់ ចាំ! ហើយខ្ញុំអត់ចេះជក់ បារី ប៉ុន្តែខ្ញុំខឹង ខ្ញុំថាយើងរកតែបាយហូបមិនបាន ហើយទៅធ្វើបារីកញ្ចប់សៗ យកមកចែក ហើយខ្ញុំក៏កត់ឈ្មោះយកបារី។ ប៉ុន្តែខ្ញុំយកចែកឱ្យអ្នកដទៃដែលគេ ចេះជក់ហ្នឹង ជក់ ខ្ញុំឱ្យនាង ឆៃរ៉ាត់ កូនរបស់លោក សារិន ឆាក ហើយនឹងឱ្យ យាយ យ៉ែម។ ថ្ងៃមួយខ្ញុំយកបារីហ្នឹងទៅឱ្យយាយ យ៉ែម ស្រាប់តែតាយាយ យ៉ែម ហ្នឹងមកខ្សឹបប្រាប់ខ្ញុំនៅទ្រុងជ្រូកនោះថា «នៃក្មួយ រីម កុមារដែលដើរឃ្វាល គោស្រែកច្រៀងក្តែងៗហ្នឹងថា មហាលោតផ្លោះ មហាអុកក្តិត»។ គាត់សួរខ្ញុំថា «ម៉េច កុមារច្រៀងអីចឹង?» ហើយខ្ញុំពេលហ្នឹងឮសួរអីចឹង ខ្ញុំប្រាប់យាយ យ៉ែម ថា «កុំឱ្យ និយាយតទៅទៀតនិយាយឱ្យតែខ្ញុំឮបានហើយ ពីព្រោះរឿងហ្នឹងវាអាចមាន គ្រោះថ្នាក់ ហើយគាត់ថាម៉េចកុមារច្រៀងអីចឹង?» ខ្ញុំថា«បែបប្រហែលជាកុមារដឹង រឿងអីដែលយើងមិនដឹងអី ឬគេមិនចូលចិត្តអង្គការបដិវត្តន៍ហ្នឹងចាំ!»។

រាសី ៖ បាទ! និយាយពីបារីដែលគេចែកហ្នឹងតើគេមានដាក់ផ្លាកថាធ្វើនៅទីណាដែរ? នាំចូលមកឬធ្វើនៅស្រុកខ្មែរមកបាទ!?

សារីម ៖ ចាំ! បារីហ្នឹងកញ្ចប់សអត់មានផ្លាកមានអីទេចាំ! ប៉ុន្តែពួកស្រុកខ្មែរយើងចូលចិត្តលក់បារីណាស់ ម្តងនេះគេទៅធ្វើបារីតម្រូវអ្នកជក់ទៅវិញចាំ! មិនគិតពីរឿងបាយទឹកអីទេចាំ!។

រាសី ៖ បាទ! អីចឹងស្ថានការណ៍ដូចថាធូរបន្តិចបានទេនៅពេលហ្នឹង ពីរឿងហូបចុកពីរឿងអី ហ្នឹង?

សារីម ៖ ចាំ! យើងអត់ៗសម្បូរទេចាំ! អីចឹងបានខ្ញុំខឹងអីចឹង ខ្ញុំមួម៉ៅណាស់ឃើញចែកបារីអីចឹង ព្រោះខ្ញុំអត់ចេះជក់បារី ហើយខ្ញុំយល់ថាបាយល្អជាងបារី។

រាសី ៖ បាទៗ! ហើយហ្នឹងពេលក្រៅពីបារីគេមានចែកអីទៀតដែរ?

សារីម ៖ ចាំ! ពេលដែលខ្ញុំទៅនៅជាមួយខ្មែរក្រហមហ្នឹងគឺមានចែកក្រណាត់ខ្មៅឱ្យយើងពីរដង ហើយនឹងក្រមា ប៉ុន្តែខ្ញុំកត់ឈ្មោះយកតែម្តងទេ ដើម្បីយកឱ្យអ្នក កេត ហ្នឹង គាត់យកទៅធ្វើខោអាវឱ្យប្តីគាត់ឈ្មោះ សន្និរ៉ាត់ ហ្នឹងចាំ! ហើយចំពោះខ្ញុំបង្កើនកិច្ចការឱ្យខ្ញុំធ្វើ គឺថែមអាដែលមន្ទីរកុមារឱ្យខ្ញុំមើលទៀត ហើយនឹងឱ្យចិញ្ចឹមទន្សាយទៀត។

រាសី ៖ បាទ! ក្រៅពីកិច្ចការមើលទាហ្នឹង...?

សារីម ៖ ចាំ! ហើយខ្ញុំភ័យណាស់។ ខ្ញុំខ្លាចថាខ្ញុំធ្វើអីថ្លោះធ្លោយទៅ គេរករឿងខ្ញុំនោះ។

រាសី ៖ ចាប់កំហុសយើងនោះ?

សារីម ៖ ចាំ! ប៉ុន្តែ ខ្ញុំមានបង រ៉ែន ហ្នឹងគាត់បានជួយខ្ញុំខ្លាំងណាស់ យើងធ្វើការខ្លាំងមែនទែន ហើយផ្លាស់គ្នាដូចថាហាត់ពេក សុំគ្នាទៅសម្រាកមួយភ្លែត រួចទៅអ្នកនោះគាត់ បន្តទៅបានយើងមកវិញ ហើយគេឱ្យខ្ញុំហ្នឹងធ្វើម្ហូបសម្រាប់ទុកបានយូរឱ្យកុមារនោះ។

រាសី ៖ បាទ! កុមារប៉ុន្មាននាក់ពេលហ្នឹងមានចាំទេ?

សារីម ៖ ចាំ! កុមារមានកូនខ្ចីហ្នឹងប្រហែល៤-៥នាក់ចាំ! រួចទៅមានកុមារតូចធំច្រើន ដែរចាំ! ប្រហែល២០នាក់អីទៅ។

រាសី ៖ ហើយមើលតែពីរនាក់?

សារីមៈ ចាំ! ពីព្រោះកុមារខ្លះយើងឱ្យអ្នកខ្លះទៅជួយនាំទៅធ្វើនេះ ធ្វើនោះអីចឹងទៅចាំ! រួចទៅបានកុមារតូចៗហ្នឹងយើងនៅមើល រួចទៅមានកុមារនោះស្រាប់តែក្បាលគាត់ ប៉ោង ចាំ! រួចខ្ញុំភ័យណាស់។ ខ្ញុំឃើញគាត់ចេះតែរុកទៅបុកអាគ្រែដែកហ្នឹង។ ខ្ញុំខំតែ រើសខ្នើយ រើសអីមកទ្រាប់គាត់កុំឱ្យគាត់បុកណា ស្មានថាគាត់បុកទៅវាប៉ោងក្បាល គាត់ ដល់ខ្ញុំទៅសួរពួកពេទ្យហ្នឹងគេថា អាហ្នឹងមកពីកុមារហ្នឹងខ្វះជីវជាតិទេ ដូច្នេះកុំ ឱ្យខ្ញុំភ័យចាំ! រួចទៅគេឱ្យយើងធ្វើម្ហូបឱ្យកុមារ ហើយខ្ញុំពេលហ្នឹងខ្ញុំខំយកបន្លែយកអី មកស្ងោរដាក់លាយអង្ករ ហើយនឹងសណ្ដែកបាយបន្តិចៗទៅ។ ប៉ុន្តែឆ្ងាញ់មែនទែន ព្រោះបន្លែយើងបេះភ្លាមៗនោះចាំ!។

រាសី ៖ ស្រស់។

សារីមៈ យើងថាស៊ុបកាលរាំងពីដើមហ្នឹង ខ្ញុំថាឆ្ងាញ់អត់ស្មើរបស់យើងធ្វើខ្លួនឯងពេលហ្នឹងទេ។ ខ្ញុំទៅរើសៗមុងយកមកកាត់យកស្បៃវាហើយធ្វើជាកន្ទប ហើយ និងរើសក្រណាត់កៅស៊ូយកមកធ្វើដូចជាខោ ដូចដែលពេលយើងនៅហ្នឹងអីចឹងចាំ! ប៉ុន្តែស្បៃមុងស្រួលប្រើណាស់ ព្រោះវាឆាប់ស្ងួតចាំ!។

រាសី ៖ បាទ! ស្រណុកបោកទៀត?

សារីមៈ ចាំ! ហើយស្រាលទៀតចាំ! ហើយដល់ពេលគេឱ្យធ្វើម្ហូបសម្រាប់រត់ហ្នឹងគឺខ្ញុំដើររើសកំប៉ុងវីហ្គោយ៉ាងច្រើនយកមកចំហុយឱ្យវាងាប់មេរោគ។ ហើយរ៉ែន ប្រពន្ធអ៊ំលូប្រសប់មែនទែនរឿងធ្វើម្ហូបទុកបានយូរហ្នឹង ចាំ! យើងចំហុយសណ្ដែកបាយឱ្យដាច់ទឹក ហើយយកមកញាត់ចូលក្នុងកំប៉ុង។ យើងត្រៀមថា ពីរកំប៉ុងឱ្យទៅម៉ែកុមារម្នាក់ៗដែលមានកូនតូចនោះចាំ!

រាសីៈ អញ្ចឹងពេលហ្នឹង នៅចុងខែធ្នូ ឬក៏ចូលដើមខែមករាហើយ? បាទ!

សារីមៈ ចាំ! ពេលហ្នឹងគឺនៅចុងខែធ្នូឆ្នាំ១៩៧៨ចាំ! ហើយខ្មែរក្រហមបានមកប្រាប់យើងថាយើងត្រូវដកថយ។ យើងចេះតែសួរគ្នាថា «ហ៊ឺស! យើងទៅណាអញ្ចេះ?» ដល់ពេលយើងឡើងឡាន បានគេប្រាប់ថា ឥឡូវហ្នឹងទៅស្ថានីយ៍រថភ្លើងចាំ!

រាសីៈ	ស្ថានីយ៍រថភ្លើងនៅភ្នំពេញហ្នឹងហី?

សារីមៈ	ចាំ!

រាសីៈ	បាទ! សូមអរគុណអ្នកស្រីនៅ សារីម បាទ!

សារីមៈ	ចាំ! អរគុណលោក ប៉ូច រាសី។ ចាំ! យើងទៅដល់ស្ថានីយ៍រថភ្លើងហ្នឹង។

រាសីៈ	ស្ថានីយ៍រថភ្លើងនៅភ្នំពេញ?

សារីមៈ	ចាំ! ខ្ញុំចាំដូចជាថ្ងៃ៦មករា។

រាសីៈ	ឆ្នាំ១៩៧៩?

សារីមៈ	ឆ្នាំ១៩៧៩។ ពេលយើងទៅដល់ យើងឃើញអ្នករបួសច្រើនមែនទែន ចាំ! ហើយឃើញកន្លែងខ្លះពូកប្រឡាក់ឈាម ខោអាវប្រឡាក់ឈាម ចោលរប៉ាត់រប៉ាយ នៅស្ថានីយ៍រថភ្លើងហ្នឹងចាំ!

រាសីៈ	បាទ! សុទ្ធទាហាន ឬមានប្រជាពលរដ្ឋដែរ?

សារីមៈ	ហ៊ឹស! ខ្ញុំយល់ថា ជាយោធាខ្មែរក្រហមចាំ! អញ្ចឹងយើងអត់មានរថភ្លើងជិះទេ។ គេក៏ដឹកយើងមកវិញ ចាំ! យើងមកដល់បឹងត្របែកវិញ យើងឃើញត្រី ដែលគេដាក់គរក្រោមផ្ទះ ជាប់ចង្ក្រានបាយ។ ម្នាក់ៗធ្វើម្ហូបស្ងោរផង អាំងផង ដុតហូបតាមចិត្តចាំ! មិនដឹងធ្វើយ៉ាងម៉េច ធ្វើប្រហុកទុកក៏វាមិនកើតចាំ! ហើយពេលហ្នឹងពួកយើង ដូចថាមួរម៉ៅ ថាតាំងពីមកនៅបឹងត្របែកហ្នឹង មិនដែលបានអង្គការខ្មែរក្រហមណាយកត្រីមួយកញ្ច្រែងមកឱ្យយើងហូបទេ។ ស្រាប់តែឥឡូវ ពេលរត់លូនអញ្ចឹង ស្រាប់តែមានត្រីគរដូចភ្នំ។ អ្នកខ្លះនិយាយកំប្លែងនឹងអ្នកនេសាទម្នាក់ឈ្មោះ ពូសំភី១ ដោយនិយាយលេងថា «ពូសំភីឯងហ្នឹងទៅចាប់ត្រីតាមួយថ្ងៃស្រាប់តែបានត្រីច្រើនយកមិនអស់»។ ដល់ស្អែកឡើងបានគេដឹកយើងមកស្ថានីយ៍រថភ្លើងទៀតចាំ!

រាសីៈ	មានឮសូរកាំភ្លើងក្លងក្លាំងអីទេ? បាទ!

សារីមៈ	ចាំ! ខ្ញុំអត់សូវឮសូរអីទេចាំ! មែនទែនដូចថា យើងរវល់ពេក មិនចាប់អារម្មណ៍។

រាសី៖ ហើយចុះពេលត្រឡប់មកវិញនៅថ្ងៃបន្ទាប់ យ៉ាងម៉ិចទៀត?

សារីម៖ ចាំ! ដល់យើងមកម្ដងនេះ ទើបបានរទេះភ្លើងជិះ ចាំ! ដល់ពេលឡើងជិះរទេះភ្លើង មានម្នាក់នោះឈ្មោះស៊ីម ហ្នឹង។ គាត់ហ្នឹងធ្វើការខាងកសិកម្ម។ គាត់ស្ដីឱ្យខ្ញុំថា ខ្ញុំធ្វើទ្រុងទាម៉េចក៏មិនយកពងទាមកស្ងោរឱ្យគេហូប។ រួចទៅខ្ញុំថា «យី! ខ្ញុំមិនហ៊ានធ្វើទេ ទាល់តែអង្គការចាត់តាំងឱ្យធ្វើបានខ្ញុំហ៊ានធ្វើ ព្រោះថា ពេលដែលយើងចេញហ្នឹង គឺគេអត់ឱ្យយើងយកអីទេ យកតែខ្លួន ហើយនឹងអីវ៉ាន់ដែលយើងស្ពាយបាន ពីព្រោះយោធានឹងមកគ្រប់គ្រងកន្លែងដែលយើងនៅហ្នឹងចាំ!

រាសី៖ បាទ! នៅកន្លែងដទៃទៀត ដូចនៅតាមភូមិដ្ឋានធម្មតាអញ្ចឹង នៅពេលហ្នឹងមានឮសូរពី រឿងថា ពេលយួនជិតចូលអញ្ចឹងមានខ្មែរក្រហមសម្លាប់ប្រជាពលរដ្ឋខ្លះពេលដែលរៀបរត់ហ្នឹង។ នៅចំពោះបទពិសោធន៍របស់អ្នកស្រីអត់មានឃើញរឿងហ្នឹង កើតឡើងទេឬក៏យ៉ាងម៉េច?

សារីម៖ ចាំ! នៅកន្លែងយើងហ្នឹង តាមខ្ញុំគិតគឺគេសម្លាប់មុនហ្នឹងរួចអស់ច្រើនហើយចាំ! យើងឃើញថា គេចេះតែយកមនុស្សចេញទៅ ហើយគេថា «រាវរកខ្មាំង»ចាំ! ហើយដល់ពេលយើងរត់ គឺយើងអត់មានគ្រោះថ្នាក់អីទេ ចាំ! ពីព្រោះ ម្នាក់ៗខំប្រឹង។ គេហៅថា គោរពអង្គការវិន័យកម្រិតខ្ពស់នោះ។ បើគេឱ្យយើងងាកឆ្វេងគឺឆ្វេង។ គេឱ្យយើងងាកស្ដាំគឺស្ដាំ ចាំ!

រាសី៖ បាទៗ! សូមអញ្ជើញបន្តទៀតបាទ!

សារីម៖ ចាំ! ដល់យើងបានឡើងរទេះភ្លើង ហើយរទេះភ្លើងហ្នឹងបើកមកមកដល់ស្តុកអាចម៍រមាសក៏យើងនៅគាំងត្រឹមហ្នឹងចាំ!

រាសី៖ នៅខេត្តណា?

សារីម៖ ស្តុកអាចម៍រមាសនៅខេត្តកំពង់ឆ្នាំង ហើយខ្ញុំមើលទៅស្តុកអាចម៍រមាសជាកន្លែងមួយដែលមានទាហានសម័យសង្គមទៅហាត់នៅបន្ទាយទាហាននៅស្តុកអាចម៍រមាសនោះចាំ! ពេលដល់កន្លែងហ្នឹង គេឱ្យយើងចុះ។ យើងចុះ។ ស្មានតែចុះមួយ

ភ្លែត។ បម្រុងឡើងវិញ ប៉ុន្តែមែនទែនយើងអត់បានឡើងរទេះភ្លើងវិញទេ។ គេឱ្យយើងដើរតាមផ្លូវលំមួយយ៉ាងធំនៅស្តុកអាចម៍រមាសហ្នឹង។ ហើយយើងក៏ធ្លាក់ចូលកន្លែងមួយគេហៅខ្លុងពពកចាំ! ហើយនៅត្រង់ហ្នឹងគេឱ្យយើងនៅក្រោមផ្ទះធំមួយ។ គេឱ្យនៅលើផ្ទះក្រោមផ្ទះនៅជុំវិញផ្ទះហ្នឹង។ ហើយយើងក៏រៀបបាយ។ ហើយនៅល្ងាចបន្តិច មានម្នាក់នោះដែលមានវិទ្យុ គេបើកស្តាប់ ចាំ!។ ពួកខ្មែរក្រហមដែលចូលជាមួយកងទ័ពយួន ស្រែកផ្សាយតាមវិទ្យុថា គេបានដេញកម្ចាត់ពួកបន អៀង សារី ប៉ុល ពត ដែលជាបនគ្រួសារនិយម គឺថា វាឱ្យតែបងប្អូនវាឡើងធ្វើធំគឺថា គេបានកម្ចាត់ចេញទៅហើយ។ ពេលហ្នឹងខ្ញុំភ្ញាក់ មែនទែន ពីព្រោះថា ខ្ញុំអត់ដឹងរឿងមិនបានតាមដានថា វាដល់ណាទេចាំ! ហើយភ្លាមនោះ យើងឮស្នូរកាំភ្លើង ទម្លាក់គ្រាប់បែកនៅខាងកំពង់ឆ្នាំងចាំ! ទម្លាក់ឱ្យឆេះកន្លែងដាក់សាំងដាក់អីគឺប្រហែលជានៅម៉ុំដែលថា ខ្មែរក្រហមធ្វើវាលកប៉ាល់ហោះ។ ក្រោយមកគេចាត់ឱ្យយើងទៅនៅកន្លែងមួយជិតភ្នំអង្គ។ យើងមើលឃើញភ្នំអង្គចាំ! នៅខ្លុងពពក គេឱ្យយើងទៅនៅរោងមួយលើទួល ហើយគេបញ្ជូនអ្នកនៅទីនោះទៅច្រូតស្រូវជាមួយបងប្អូនយើងចាំ! ហើយពួកយើងហ្នឹងមានប្រុសៗច្រើនដែរ។ ពេលមកពីច្រូតស្រូវវិញ ពួកបុរសៗត្រឡប់មកវិញថា «អ៊ូយ! ទៅដល់ឃើញសុទ្ធតែស្រីៗ»។ គេច្រូតស្រូវ ហើយពួកនោះហោកញ្ញៀវឃើញថា យើងហ្នឹងសល់ប្រុសរស់នៅច្រើន។ គេថា «ចុះពួកនេះមកពីណា ម៉េចបានសល់ ប្រុសៗច្រើនម្ល៉េះ» ចាំ! ដល់ហើយពួកប្រុសៗយើងហ្នឹងដូចជាខ្លាចណាស់ ព្រោះឃើញកងនារីអស់ហ្នឹងហោកញ្ញៀវអញ្ចឹង។ គាត់ភ័យចាំ!

រាសីៈ បាទ! ហើយអញ្ចឹង ទាំងអស់គ្នាប្រហែលជាប៉ុន្មាននាក់ដែលចេញដំណើរជាមួយអ្នកស្រី?

សារីមៈ ចាំ! ជាង១០០នាក់។

រាសីៈ បាទ! ច្រើនណាស់បាទ! អញ្ចឹងអ្នកស្រីស្នាក់នៅកន្លែងហ្នឹងចំនួនប៉ុន្មានថ្ងៃដែរ?

សារីមះ ចាំ! យើងនៅយូរ ដើរចុះដើរឡើង ម្ដងគេដាស់ឱ្យយើងងើបទាំងយប់ ម៉ោងពីរភ្លឺ។ យើងដើរ ហើយគេឱ្យយើងបកមកកន្លែងដដែលវិញ ញឹកញាប់ណាស់របៀបហ្នឹង ចាំ! ហើយគេប្រើយើងឱ្យទៅជួយស្រោចទឹកបន្លែអ្នកស្រុក។ ថ្ងៃមួយស្រាប់តែឃើញកប៉ាល់ហោះហោះ។ មានស្ត្រីម្នាក់ឈ្មោះយិន ចាំ! គាត់ហ្នឹងខ្លាចកប៉ាល់ហោះ ព្រោះគាត់ធ្លាប់នៅតំបន់រំដោះ។  គាត់គ្រាន់តែឃើញកប៉ាល់ហោះភ្លាម គាត់មុជក្បាលគាត់ដាំដូងចំតិតគូទឡើងលើ។ ខ្ញុំស្រឡាំងកាំងណាស់ពេលហ្នឹង ហើយគាត់ប្រាប់ខ្ញុំថា «ហើយម៉េចមិនក្រាបៗ?»

រាសីះ គាត់ធ្លាប់ឆ្លងកាត់?

សារីមះ ចាំ! រួចខ្ញុំមិនដឹងក្រាបកន្លែងណាទេ វាលល្ហល្ហេវ។ ក្រាបទៅ ហ្វូងកប៉ាល់ហោះមើលឃើញដដែលចាំ! គាត់បាក់ស្បាតចាំ! រួចហើយគេឱ្យយើងទៅកិនស្រូវទៀតពេលខ្លះ ហើយនឹងគេឱ្យយើងទៅយកស្រូវនៅខ្សែត្រៀម ចាំ! ហើយខ្ញុំតែងតែស្ម័គ្រចិត្តទៅយក ព្រោះថា ខ្ញុំម្នាក់ឯង ហើយអ្នកដទៃទៀតច្រើនតែមានកូនតូច ហើយនឹងមានកូនខ្ចី ហើយពេលទៅយកស្រូវហ្នឹង យើងអត់មានយកកញ្ជើ ល្អីអីទៅទេចាំ! ខ្ញុំស្លៀកខោពីរជាន់។ បើបានស្រូវ យើងយកខោយើងមួយទៀតសម្រាប់ញាត់ស្រូវ ហើយអ៊ាវវាយកមកចាំ! ហើយម្ដងនោះ ពេលយើងទៅយកស្រូវហ្នឹងគឺយើងជួបគ្រាប់ផ្លោង។ ផ្លោងមកធ្វើឲ្យដាច់ស្លឹកឈើនៅរិះៗតែក្បាលយើងហ្នឹង។ ពួកយើងខំក្រាបផង លូនផង ចាំ! ហើយថ្ងៃហ្នឹងទៅយកស្រូវ តែអត់បានស្រូវអីទេ។ ពេលបកមកវិញ ប្រពន្ធលោកអន ឈ្មោះអ៊ុក កែវយុនណន។ ពេលមកវិញគាត់បាត់នាឡិការ៉ូឡិចស្គត។ ពេលដឹងថា បាត់ យើងបកទៅវិញ ឃើញនៅជាប់នឹងមែកឈើកន្លែងដែលយើងគ្រវាត់ៗចុះឡើង យើងដើរជិតហ្នឹង ចាំ! ហើយពួកបងប្អូនយើងហ្នឹង ពេលគេពឹងយើងឱ្យធ្វើអី យើងចេះធ្វើគ្រប់មុខ ចេះធ្វើតាំងពីត្បាល់កិនស្រូវអីឡើងទៅ។ គេហៅយើងថា «យី! ពួកចិននេះពូកែណាស់!»។ នៅក្នុងក្រុមយើងហ្នឹងមានតាំងពីគ្រូពេទ្យឡើងទៅ។ លោកម្នាក់ហ្នឹងឈ្មោះស៊ី ចាំ! គាត់ជាវេជ្ជបណ្ឌិត ចាំ! ហើយប្រពន្ធគាត់ឈ្មោះសៅរី។ បងប្អូនយើងនៅសហករណ៍ហ្នឹងពឹងឱ្យ

ពេទ្យស៊ីហ្នឹងទៅមើលជំងឺ។ ពេលគាត់ត្រឡប់មកវិញ គាត់ច្រើនតែបានចេកទុំអីមកជាមួយផង ចាំ! ហើយយើងទៅយកស្រូវនៅខ្សែត្រៀម ពេលខ្លះហ្នឹងយើងបេះបន្លែនៅតាមផ្លូវកន្លែងផ្ទះ ដែលគេរត់ចោល យកមកស្លចាំ!

រាសីៈ បាទ! សូមអរគុណអ្នកស្រី នៅ សារីម បាទ!

សារីមៈ ចាំ! អរគុណលោក ប៉ូច រាសី។ ចាំ! យប់មួយហ្នឹងគេឱ្យយើងចេញក្រោម ភ្លៀងសស្រិចម៉ោង២ភ្លឺ ហើយគេឱ្យយើងរាប់គ្នា១-២-៣ អញ្ចឹងទៅ។ យើងឃើញថា បាត់គ្នាបីនាក់។ ហើយអ្នកបាត់ហ្នឹងម្នាក់ឈ្មោះ ហុង ស៊ីផា ម្នាក់ឈ្មោះ អាត ចាំ! អ្នកទីបីខ្ញុំអត់ចាំឈ្មោះ ទេ។ ហើយដល់យើងចេញដើរដល់ទល់ភ្លឺគេឱ្យយើងបកមកកន្លែងដដែលវិញចាំ! ហើយដល់អញ្ចឹងយើងសន្មតថា អ្នកអស់ហ្នឹងគាត់រត់នៅក្នុងព្រៃហ្នឹង។

រាសីៈ ហើយពេលហ្នឹង អ្នកស្រីមានគិតចង់រត់នឹងគេដែរ?

សារីមៈ ខ្ញុំហើយនឹងអ្នកខ្លះដែលដើរជាមួយគ្នាហ្នឹង យើងយល់ថា យើងពិបាករត់ណាស់ រត់ទៅនាំតែស្លាប់អត់ប្រយោជន៍។ ហើយខ្ញុំចេះតែគិតថា បើយើងទៅសំឡូតអាចស្រួលរត់ ពីព្រោះវានៅជិតទល់ដែនចាំ! ហើយណាមួយយើងក៏មិនទាន់ចង់រត់អីដែរ ពីព្រោះយើងចង់ជួបអ្នកស្រុក។ អ្នកស្រុកអាចដឹងដំណឹងផ្សេងចាំ!

រាសីៈ បាទ! អញ្ចឹងអ្នកស្រីពេលហ្នឹងមានសង្ឃឹមឡើងវិញទេ ពីរឿងជួបក្រុមគ្រួសារ?

សារីមៈ ចាំ! ខ្ញុំចេះតែចិញ្ចឹមចិត្តអញ្ចឹង។ ប៉ុន្តែមិនឱ្យសង្ឃឹមពេកទេ ព្រោះខ្លាចខកចិត្តនោះចាំ! ក្នុងពេលដែលនៅទីហ្នឹងចាំ ប្រជាជនខ្លះគេរត់ទៅចូលយួន  អ្នកខ្លះរត់ទៅចូលខាងប៉ុល ពតឯណោះទៅ។ ហើយពួកខ្ញុំ ពេលហ្នឹង យើងប្រុងប្រយ័ត្នខ្លួនមែនទែន ព្រោះយើងទៅកន្លែងគេ យើងអត់ដឹងអ្នកណាខាងយួន អ្នកណាខាងប៉ុល ពតទេចាំ!

រាសីៈ អត់ដឹងអ្នកណាខាងណា ខាងណី?

សារីមៈ អត់ដឹងខាងណាខាងណី ម្ល៉ោះហើយយើងនៅជាប់កន្លែងណាដែលអ្នកគ្រប់គ្រងយើងហ្នឹងឱ្យយើងធ្វើអីយើងធ្វើតាមអ្នកហ្នឹងចាំ!

រាសីៈ ហើយអញ្ចឹង អ្នកស្រីនៅក្នុងព្រៃហ្នឹងជ្រៅដែរឬទេ?

សារីមៈ ចាំ! នៅក្នុងព្រៃហ្នឹងគឺព្រៃមែន មានជ្រូកព្រៃ ជ្រូកអី។ យើងដាក់អន្ទាក់ជ្រូកព្រៃ។ ប៉ុន្តែមេខ្មែរក្រហម គេនៅជិតៗហ្នឹងចាំ!

រាសីៈ បាទ! ប៉ុន្តែតើមានទាហានខ្មែរក្រហមនៅក្បែរដែរទេ ឬមកតាមដែរទេ?

សារីមៈ យើងជួបអ្នកដែលគេហៅ «អ្នកមូលដ្ឋាន»គេហ្នឹង។ យើងមិនដឹងអ្នកណាជាយោធា មិនយោធាអីទេ។ យើងអត់ដឹងទេចាំ!

រាសីៈ បាទ! ដូចនៅកន្លែងខ្លះ តាមខ្ញុំចាំកាលណាខ្មែរក្រហមកៀរប្រជាជនទៅអញ្ចឹង មានទាហានទៅជាមួយដើម្បីកុំឱ្យរត់។ អញ្ចឹងតើខាងអ្នកស្រីអត់មានអញ្ចឹងទេ?

សារីមៈ ចាំ! អត់ទេ។ យ៉ាងនេះ យើងអត់ហ៊ានងាកទេ។ យើងដើរតាមតែគេបញ្ជាចាំ!

រាសីៈ បាទ! អញ្ចឹងនៅមានមេកើយអីធម្មតាអញ្ចឹង?

សារីមៈ ចាំ! យើងនៅតែមានប្រធានរបស់យើងអញ្ចឹងណា។ យើងចាំស្ដាប់បញ្ជាអញ្ចឹងទៅ។ ក្នុងព្រៃហ្នឹង ពេលគេឱ្យយើងទៅកាប់ឆ្កាព្រៃ។ ថ្ងៃមួយនោះ ខ្ញុំឃើញខ្មោចកប៉ាល់ហោះតូចមួយ ដែលស្មៅដុះព័ទ្ធជុំ ពេញ។ ពួកខ្ញុំទៅរែកមើលគ្រែងឃើញដែកអីដែលយើងអាចរើសទុកយកមកប្រើបាន ហើយយើងខំកាច់ដែកខ្លះ ប៉ុន្តែ ដែកហ្នឹងស្វិតមែនទែន ចាំ! ហើយថ្ងៃខ្ញុំមួយខ្ញុំបានជួបដើមឈើមួយធំ ហើយអ្នកស្រុកប្រាប់ខ្ញុំថា «ហ្នឹងហើយគឺដើមព្រះព្នៅៗ ហើយស្គាល់ទេ?»

រាសីៈ ធ្លាប់ឮៗ បាទ!

សារីមៈ គេយកមកធ្វើថ្នាំរាគ ចាំ! គេស្ងួសមក ហើយទៅអាំង ហើយទៅ ដាំទឹកផឹក។ ខ្ញុំអរណាស់បានជួបដើមឈើដែលជាថ្នាំអញ្ចឹង។ ខ្ញុំបានទៅឱបដើមព្រះព្នៅហ្នឹង ហើយសុំឱ្យគ្រូពេជ្រស្តេចថ្នាំហ្នឹងជួយការពារពួកយើង ហើយពួកយើងសប្បាយនឹងបេះត្រួយស្តៅចាំ! ប្រហែលពាក់កណ្តាលខែ២ ទើបគេឱ្យយើងចេញម្តងទៀត។ ម្តងនេះគេឱ្យយើងជម្រុះអីវ៉ាន់ឱ្យគេ។ យើងក៏ជម្រុះអីវ៉ាន់ខ្លះឱ្យអង្គការហ្នឹងទៅ ហើយក៏ជម្រុះឱ្យគ្នាឯងទៀត ចាំ! ពេលហ្នឹងបងរ៉ែនមានប្រាក់រៀលបុរាណច្រើន។ គាត់ឱ្យខ្ញុំ

៤-៥ ហើយគាត់ឱ្យប្រាក់ខ្ទង់ខ្ញុំមួយចង្កោម ហើយនឹងឱ្យឈើបុកស្លាមួយ និងក្បាលវាជាភ្លុកធំប៉ុនអង្គាញ់ថា! ហើយគេប្រាប់យើងថា ម្តងនេះឱ្យយើងដើរទៅបរិល ហើយមានសហករណ៍ចាំទទួលបាយ ទឹកយើងតាមផ្លូវ។ ប៉ុន្តែពួកយើងបានទាមទារថា គួរឱ្យអង្គរឱ្យយើងស្ពាយសម្រាប់រៀងៗខ្លួន ហើយខ្ញុំក៏ខំប្រាប់ឱ្យកងកុមារហ្នឹងឱ្យរក្សាប៊ីដុងទឹកឱ្យបានគង់វង្ស ហើយនិងកុំឱ្យបាត់កំប៉ុងវីហ្គោ ចាំ! ព្រោះយើងគិតថាពេលរត់លូនអញ្ចឹង ម្នាក់ៗត្រូវ ម្ចាស់ការខ្លួនឯងចាំ! ហើយពេលមុនចេញដំណើរ ស្រាប់តែខ្ញុំនឹកឃើញដល់ ការសម្ភាសរបស់អ្នកកាសែត អេលីហ្សាបែត បែកយើជាមួយប៉ុល ពត ពេលដែលអ្នកកាសែតហ្នឹងចូលទៅក្នុងប្រទេសកម្ពុជាសម័យហ្នឹង ជាមួយអ្នកកាសែតអង់គ្លេសម្នាក់ ឈ្មោះ ម៉ាល់ខុំ ខត់វេល ចាំ! ហើយខ្ញុំសួរពួកយើងថា «ហើយចុះមានអ្នកកាសែត អេលីហ្សាបែតបែកយើ ហើយនឹងហើយម៉ាល់ខុំ ខត់វេល ឥឡូវម៉េចទៅហើយ?» ស្រាប់តែពួកហ្នឹងគេដឹងរឿង គេប្រាប់ខ្ញុំថា ម៉ាល់ខុំ ខត់វែលត្រូវគេសម្លាប់ទៅហើយ ចាំ! ខ្ញុំភ្ញាក់ព្រឺត ព្រោះខ្ញុំភ្លេចរឿងហ្នឹងចាំ! ហើយយើងជួបនឹងភ្លើងឆេះព្រៃ។ យើងមើលពីចម្ងាយទៅដូចមហាកំពែងរបស់ក្រុងប៉េកាំងដែលមានភ្លើងព្រិចៗពីចម្ងាយអញ្ចឹង ចាំ! ហើយពេលដើរមកដល់កន្លែងមួយហ្នឹង យើងជួបទីវាលមួយស្អាតមែនទែន ហើយមានដើមត្រម្ងងនៅមាត់បឹងហ្នឹង។ កន្លែងហ្នឹងគេហៅអូរគ្លែ ចាំ! ហើយពួកយើងទាំងអស់គ្នាហ្នឹងស្រាប់តែមកជួបជុំគ្នាច្រើនណាស់ អ្នកដែលមិនមែនដើរក្នុងហ្វូងជាមួយយើងហ្នឹងក៏មកជួបជុំគ្នា។ ដូចយើងដើរពេចនិកអញ្ចឹង កន្លែងហ្នឹង យើងមើលទៅត្រើយម្ខាងអូរហ្នឹង យើងឃើញសត្វប្រើសឱនផឹកទឹកអូរដែលមានរាងដូចបាតខ្ទះត្នោតអញ្ចឹង ចាំ! ហើយពេលហ្នឹងខ្ញុំជួបវណ្ណា។ ខ្ញុំប្រាប់វណ្ណាថា កុំឱ្យរៀបការតាមដែលខ្មែរក្រហមផ្គូរផ្គងនោះ ព្រោះយើងបានជួបប្រជាជនហើយ ហើយយើងអាចដឹងដំណឹងពីគ្រួសារយើងរៀងៗខ្លួន ចាំ! សម្រេចសម្រួលទៅ ពួកខ្ញុំហ្នឹង គេដើរចោលអស់ ចាំ! កុមារដែលកំព្រាដែលដើរជាមួយខ្ញុំ ដើរចោលខ្ញុំ ពីព្រោះខ្ញុំដើរអត់រួច ខ្ញុំឈឺជើង។

រាសី៖ នៅសល់ប៉ុន្មាននាក់?

សារីមះ	នៅសល់កុមារីបីនាក់។ ដល់ដើរយូរៗទៅ កុមារីម្នាក់ឈ្មោះជាបានជួបបងស្រីគេ ឈ្មោះ អារី ហើយអាផា។ គេក៏ទៅចោលខ្ញុំទៀត។ រួចខ្ញុំនៅសល់កុមារីពីរនាក់នៅជាមួយ ម្នាក់ឈ្មោះចាន់ ម្នាក់ឈ្មោះរី ចាំ! ហើយចាន់ហ្នឹងជាកូនរបស់ម៉ារីណា គីរីវ៉ាត់ ជាចៅរបស់ហួត សម្បត្តិ ហើយរីហ្នឹងជាចៅលោកសារិន ឆាក ចាំ! ហើយនឹងស្រីពីរនាក់សួនហើយនឹង សៀន ចាំ! សៀនជាអ្នកទៅពីប៉ារីស ត្រូវជាកូនរបស់យ៉ែម យីស៊ិន ហើយនឹងប្រុសពីរនាក់ ម្នាក់ឈ្មោះ តឹក សុនដេត និងឈ្មោះ ឌីនី ចាំ! យើងនៅសល់៧នាក់ដើរក្រោយគេ ចាំ! ហើយពេលយើងដើរហ្នឹង ពេលខ្លះយើងឃើញមាន់ព្រៃ ហើយយើងឃើញដើមផ្កាអូពីដេដុះជាប់ដូចថង់ៗជាប់នឹងដើមឈើអញ្ចឹងចាំ! ហើយពេលខ្លះយើងឃើញអូរ។ យើងដើរហាត់ពេក ហើយយើងចុះមុជក្នុងអូរហ្នឹង ទាំងខោទាំងអាវហ្នឹង ចាំ! ហើយខ្ញុំបានដើរឆ្លងកាត់កន្លែងមួយដែលគេហៅភូមិព្រៃខ្ពស់ ចាំ! ភូមិព្រៃខ្ពស់ហ្នឹងមានផ្ទះអ្នកស្រុក ផ្ទះគេធំៗណាស់ ផ្ទះក្បឿង។ ហើយយើងដើរឆ្ងាយមកទៀត  យើងបានជួបផ្ទះសំណាក់របស់អ្នកនេសាទព្រៃនាម។ យប់ហ្នឹងពួកគេបានឱ្យត្រីឆ្អើរយើងហូបម៉ាឆ្អែតចាំ! ស្អែកឡើងបានចេញដំណើរទៅទៀត ហើយយើងប្រហែលជាឃើញ ទីស្នាក់ការខ្មែរក្រហម មានរបងព័ទ្ធជុំវិញ មានដើមឫស្សីក្រាស់ៗ ហើយនៅជិតហ្នឹងមានគេចិញ្ចឹមមាន់ទា។ ទាហែលទឹកនៅវាលទំនាបទាំងហ្វូងៗ ចាំ! ហើយពួកយើងដើរមកទៀត ចាំ! យប់ប្រហែលពាក់កណ្តាលខែ២ ខ្ញុំសម្រាកនៅតាមផ្លូវរទេះ ហើយមិត្តម្នាក់ហ្នឹងខ្ញុំ មិនស្គាល់ឈ្មោះទេ តែកូនរបស់គាត់ឈ្មោះ សាសា។ យើងហៅថា «ឪសាសា»។ គាត់បើកវិទ្យុស្តាប់។ ខ្ញុំឮគាត់និយាយថា ស្តេចហ្សារបស់ស្រុកអ៊ីរ៉ង់នោះ ត្រូវគេទម្លាក់ចេញពីតំណែងហើយចាំ! ស្តេចហ្សាអ៊ីរ៉ង់ហ្នឹងគឺថា បានប្រពន្ធក្មេង ក្រោយឈ្មោះហ្វារ៉ាឌីតបា បានកូនប្រុសមួយសម្រាប់ស្នងរាជ្យ។ គាត់ហ្នឹង ឥឡូវស្រោប់តែត្រូវគេទម្លាក់ចេញពីតំណែង។ ហើយដល់ដើរលិចវាលចូល ព្រៃដេកដីផង ដេកអង្រឹងផងនោះ ពួកខ្ញុំហ្នឹងនៅក្រោយគេ ហើយយើងក៏បានមកដល់អមលាំងនៅម៉ោងប្រហែល១០ព្រឹកចាំ! ថ្ងៃមួយហ្នឹង។

រាសីះ	បាទ! សូមអរគុណអ្នកស្រី នៅ សារីម បាទ!

សារីមៈ ចាំ! អរគុណលោក ប៉ូច រាសី។ ពេលមកដល់អមលាំង ពេលហ្នឹងពួកខ្ញុំឈប់សម្រាក នៅសាលាឆទានមួយនៅតាមផ្លូវ ស្រាប់តែឃើញសុទ្ធតែពួកកម្មកររបស់ខ្មែរក្រហម ចាំ! គេស្លៀកពាក់ឯកសណ្ឋាន។ គេចេញមកគឺថា មើលទៅឃើញតែខៀវ សុទ្ធតែខៀវ ហើយមានក្រវ៉ាត់ទៃដាក់អង្គុរព័ទ្ធខ្វែងនៅលើទ្រូង ចាំ! គេដើរទាំងហ្វូងៗចាំ! ម្តងហ្វូងនេះ ម្តងហ្វូងនោះ។ ដល់អញ្ចឹង ខ្ញុំអត់ហ៊ានដើរចូលតាមផ្លូវអមលាំងហ្នឹងទេ ព្រោះឃើញកម្មករហ្នឹងច្រើនពេក។ ខ្ញុំចាំឱ្យគេទៅផុត បានខ្ញុំនាំគ្នាដើរទៅ។ ក៏ប៉ុន្តែដល់យើងឃ្លានបាយពេក យើងប្រចុយថា «ហ៊ឹស! ទៅសុំ សហាករណ៍អមលាំង សុំបាយគេហូបម្តងមើល!» ដល់ទៅសុំគេ គេឱ្យយើង ចាំ! ខ្ញុំនៅចាំថា ថ្ងៃហ្នឹងគេស្លប្រហើរត្រយ៉ូងចេក។ ប៉ុន្តែរបៀបគេហាន់ត្រយ៉ូងចេក មើលទៅគួរឱ្យសរសើរថា គេហ្នឹងហ្មត់ចត់ណាស់ ចាំ! ហើយសម្លគេហ្នឹងស្អាត។ គេឱ្យយើងមួយចានចង្កឹះម្នាក់តូចអញ្ចឹង។ ប៉ុន្តែឆ្ងាញ់ ហើយគួរឱ្យគោរពចាំ! បាយគេ។ មេសហាករណ៍គេមកនិយាយជាមួយយើងហ្នឹងគឺសុភាពរាបសារ ហើយមានពូជមានអម្បូរណាស់មើលទៅ។ យើងខ្ញុំគោរពអ្នកនៅសហាករណ៍ អមលាំងហ្នឹងមែនទែន។

រាសីៈ អមលាំងនៅខេត្តណាបាទ!

សារីមៈ អមលាំង តាមខ្ញុំគិត នៅខេត្តកំពង់ស្ពឺ ហើយអមលាំងជាមូលដ្ឋានរបស់ ខ្មែរក្រហម។ គេចំណាំថា តែកាលណាគេរត់ គេទៅអមលាំងចាំ! ចាំ! ពេលដែលយើងកំពុងចាំឱ្យឲ្យគេទៅរយាលទៅបន្តិចហ្នឹង យើងស្ទោរគ្រាប់អំពិលហូបចាំ! ហើយពេលហ្នឹង ស្រាប់ តែពួកខ្ញុំឃើញអ្នកស៊ីអ៊ី។ ប្តីគាត់ឈ្មោះលោក រស់ សារិន ទៅពីស្រុកបារាំងដែរ។ គាត់ទូលសម្ពាយធំដូចជាលអញ្ចឹងចាំ! ហើយយើងវិញស្បោងយើងតូចៗ អស់របស់ហើយ ព្រោះយើងស្ពាយមិនរួច។ ហើយពេលហ្នឹងខ្ញុំក៏នឹកសង្វៃកទៅដល់លោកយាយចាស់ៗដូចជាលោកយាយ ឡាំ ម្តាយលោក ហោណាំហុង លោកយាយ លឿម ម្តាយអ្នកស្រី ប្លែក វិផា ហើយនឹងលោកយាយ គីម ម្តាយគ្រូពេទ្យ អ៊ិន សុកាន ហើយលោកយាយ គីម។ ប៉ុន្មានខែមុនហ្នឹង គាត់ញញឹមញញែមពេលគាត់ជួបកូនប្រុសគាត់ឈ្មោះ អ៊ិន សុភាពពាក់វ៉ែនតាខ្មៅមកលេងគាត់

នៅបឹងត្របែក ចាំ! ខ្ញុំគិតថា ខ្លួនខ្ញុំហ្នឹងដើរមិនចង់រួច ចុះទំរាំលោកយាយចាស់ៗ អស់ហ្នឹងយ៉ាងម៉េចទៅហើយ។ ស្រាប់តែស្ត្រីម្នាក់នោះយកថ្នាំពេទ្យឱ្យយើង។ អ្នកស្រីយ៉ែម យុសៀវកាន់ថ្នាំពេទ្យហ្នឹង។ គាត់ទុកឱ្យពួកយើង។ អ្នកហ្នឹងប្រាប់យើងថា «អូ! គេទៅមុខអស់ហើយ យាយៗក៏អញ្ចឹងដែរ»។ ហើយអាគង់ ដែលស្ពាយកូនប្រុសឈ្មោះដូង។ កូនហ្នឹងកើតមកមានជំងឺប៉ូលីយ៉ូ ខូចជើង។ គាត់ស្ពាយកូនហ្នឹងទៅមុខអស់ហើយ ហើយពួកនោះថា តាឆោមឪពុកយួន ដារិតនោះដើរលឿនជាងគេ ចាំ! ហើយពេលពួកកម្មករនោះ ចេញផុតទៅ ទើបពួកខ្ញុំហ្នឹងដើរទៅតាមផ្លូវលំអមលាំងហ្នឹង ចាំ! ផ្លូវហ្នឹង ឡានបើកបាន។ ផ្លូវគេស្អាតណាស់ចាំ! សងខាងផ្លូវហ្នឹងមានវាលស្រែត្រង់ភ្លឹងដូចក្រឡាឈើត្រង់អញ្ចឹង ចាំ! ហើយដល់ដើរទៅបានប្រហែលជាថ្ងៃរសៀល ពួកខ្ញុំទៅលែងរួច ចាំ! ខ្ញុំឈឺជើងពេក ហើយខ្ញុំគិតថា «ហ៊ឺស! ខ្ញុំទុកជាខ្មោចយក្ខមកចាប់អី យួនមកចាប់ក៏ខ្ញុំអត់រត់ដែរម្តងនេះ»។ ខ្ញុំរត់អត់រួចទេ ឈឺជើង ចាំ! ហើយថា បើស្លាប់ក៏ស្លាប់ទៅចុះ ពីព្រោះវាទៅលែងរួចហើយ។ ហើយកុមារី ចាន់ចេះតែរករឿងពួកយើង ពេលដើរហ្នឹង ព្រោះគាត់ឈឺពោះ ដោយសារគាត់ហូបបបរគ្រាប់អំពិលច្រើនពេកចាំ! ហើយដល់អញ្ចឹង ពួកយើងក៏ចូលសម្រាកកន្លែងមួយ។ យើងឃើញដូចសមរម្យណាស់ ដូចកន្លែងដើរពេចនិកអញ្ចឹងគឺមានកៅអីផ្តៅច្រើន។ ពួកយើងក៏ចូលទៅសម្រាកកន្លែងហ្នឹង ចាំ! ស្រាប់តែមួយសន្ទុះយើងឃើញមានឡានមួយមក ចាំ! ឡានហ្នឹងដូចឡានទ្រុងអញ្ចឹង ចាំ! ខ្ញុំទៅបក់ដៃសុំឡានគេឱ្យឈប់។ គេឈប់ ហើយខ្ញុំថា «នែ! មិត្តយើង ខ្ញុំសុំផ្ញើកុមារពីរនាក់ទៅជាមួយផងបានទេ? ហើយគេសួរថា ពួកអ្ហែងទៅណា? ខ្ញុំថា «ហ៊ឺស! ដឹងអី! អង្គការថាឱ្យទៅបរិល» ហើយគេឱ្យយើងដើរតាមផ្លូវហ្នឹង។ ខ្ញុំមិនដឹងទៅតាមណាទេ។ ដល់នេះគេថា «ហ៊ឺស! អញ្ចឹងដូចគ្នា! នែ! រួចចុះរឿងអីបានបងឯងមិនទៅ?» ហើយខ្ញុំថា «គ្នាខ្ញុំច្រើនណាស់ នៅសល់ប្អូននាក់ទៀតឯណោះ» ហើយគេថា «មក! ហៅមកទាំងអស់គ្នាមក!» ដល់អញ្ចឹងខ្ញុំក៏ហៅមក។ យើងបានឡានជិះ ចាំ! គេឱ្យយើងជិះ ហើយឃើញមនុស្សគេជិះក្នុងឡានហ្នឹងគ្នាតិចទេ ប្រហែល១៥នាក់។ ហើយពួកហ្នឹងគេមានអង្ករមួយបាវនៅក្នុងឡានគេនោះចាំ! ហើយគេមានឆ្នាំងមានអី។ ហើយ

អ្នកដែលជិះនៅគែមទ្វារឡានខាងក្រៅហ្នឹង មានស្ពាយកាំភ្លើងទៀត ចាំ! ហើយឡានគេជិះហ្នឹងពណ៌បៃតងចាស់ ហើយគេហៅ វាអាស៊ីនៗ ចាំ! ឡានហ្នឹងធ្វើមកពីស្រុកចិន។ គេប្រាប់ពួកខ្ញុំថា «ពួកបងឯងពេលណាឡានឈប់កុំចុះ ពីព្រោះពេលចុះទៅជួនណាចំពេលអ្នកភៀសខ្លួន ដូចមកតាមផ្លូវអញ្ចឹងច្រើនអី។ គេដណ្តើមឡានជិះ។ បងឯងរត់មិនទាន់គេទេ»។ គេថា បើជាប់ឡានជាប់អីទុកឱ្យពួកគេរុញ។ ហើយស្រាប់តែគេយកបាយមួយបាតឆ្នាំងសល់ហ្នឹងបោះចោល រួចខ្ញុំប្រាប់គេថា «អ៊ួយ កុំបោះចោលឱ្យខ្ញុំ!» គេថា «ងាប់ហើយបាយសល់បងឯងហូបធ្វើអី!» ខ្ញុំថា «ខ្ញុំមានតែអង្ករបន្តិចបន្តួច ម្លោះហើយបាយហ្នឹងខ្ញុំយកទៅបបរ»។ ហើយគេក៏ឱ្យយើងមកចាំ! ដល់បើកឡានតាមផ្លូវហ្នឹង យើងឃើញមានអ្នកភៀសខ្លួនតាមផ្លូវ។ បើយើងមិនដែលឃើញអ្នកជម្លៀសនៅពេលចេញពីភ្នំពេញ ចាំ! ទិដ្ឋភាពពេលហ្នឹង ខ្ញុំយល់ថា ដូចគ្នា។ នៅក្នុងព្រៃហ្នឹង មានរទេះគោ ហើយមនុស្សកកកុញ ចាំ! មានអ្នកខ្លះហ្នឹងឈឺ។ គាត់សម្រានគឺថា លេចអស់ហើយគ្រឿងកេរ្តិ៍ខ្មាសអី អត់មានលាក់លៀមអីទេ។ អើយ! ខ្ញុំឃើញអញ្ចឹង ខ្ញុំអត់ហ៊ានមើល។ ខ្ញុំធ្មេចភ្នែកពិចារណាថា យើងមិនដឹងជួយ គេម៉េចកើត! យើងក៏ជួយខ្លួនយើងពិបាក។ ម្លោះហើយដូចយកប្រាសអាយុរៀងខ្លួន ទៅចាំ!

ឡានហ្នឹងគេចេះតែបើកទៅ។ គេអត់ខ្វល់ពីអ្នកនៅតាមផ្លូវអីទេ ចាំ! ហើយយើងឈប់តាមផ្លូវម្តងនៅខេត្តពោធិ៍សាត់។ ខ្ញុំឃើញកុមារច្រើនណាស់មុខក្រៀមៗ ហើយខ្ញុំក៏ចុះទៅរកមើលក្រែងលោឃើញអ្នកខ្លះដែលខ្ញុំស្គាល់ណា ហើយខ្ញុំក៏ឱ្យថ្នាំវីតាមីនទៅកុមារខ្លះ ហើយដល់ជិះឡានតាមគេហ្នឹងមកគឺថា គុណបុណ្យជួយណាស់ បានយើងមកដល់សហករណ៍ឫស្សី ចាំ! សហករណ៍ឫស្សីហ្នឹងនៅក្នុងខេត្តបាត់ដំបង ចាំ! ដែលយើងថា មោងឫស្សីនោះចាំ! មនុស្សច្រើនណាស់បោះជំរំ បោះអី។ ពួកហ្នឹងនិយាយថា «នែបង!ទិសដៅរបស់យើងមកដល់ហ្នឹង ហើយបងឯងចុះទៅ!» ហើយចាប់ពីហ្នឹងទៅ គេចាត់តាំងនៅកន្លែងហ្នឹង ចាំ! យើងក៏ទៅកត់ឈ្មោះ ចាំ! មានកន្លែងរោងគេកត់ឈ្មោះ កត់អីឱ្យគេដឹងនោះ ចាំ! ហើយដល់រួចមានអ្នកខ្លះគេមកខ្សឹបប្រាប់ខ្ញុំថា «មកដល់កន្លែងហ្នឹងប្រយ័ត្នមាត់កណា»។ មានម្នាក់មួយនោះមកតវ៉ា

ថា អត់បាយអត់អី ខ្លួនឯងរត់មកថា អង្គការទទួលខុសត្រូវ មកអត់បាយតាមផ្លូវ ប្រើពាក្យដូចថាខឹងអញ្ចឹងទៅ ស្រាប់តែម្នាក់ហ្នឹងមកអារកអ្នកហ្នឹងចោលភ្លាម ចា៎! ហើយដល់អញ្ចឹងទៅយើងខំស្តាប់ ចា៎! ហើយស្រាប់តែខ្ញុំឃើញពួក ដែលរត់មកជាមួយយើងតាមរទេះភ្លើងដែរ តែដើរលឿនជាងខ្ញុំនោះ។

រាសី៖ ជួបពួកហ្នឹងវិញ?

សារីម៖ ចា៎! អ្នកនិតហ្នឹងជាប្រពន្ធរបស់ ដុកទ័រ យូ គឹមយៀត ដែលរត់ចូលព្រៃចា៎! ស្រាប់តែខ្ញុំឃើញគាត់ហ្នឹងជិះឡានជាមួយពួកយោធា ចា៎! ខ្ញុំឃើញគាត់ចុះពីលើឡានហ្ស៊ីបមក ហើយសួរថា «អ្នកនិតមកពីណា?» គាត់ថា គេទៅមើលផ្លូវទៅគាស់ក្រឡ ចា៎! ទៅគាស់ក្រឡទៅអត់បានទេ ព្រោះពួកយួននៅវាយស្មាក់នៅខាងហ្នឹង។ ហើយពួកខ្ញុំដែលមកក្រោយគេហ្នឹង គេឱ្យយកទៅសហករណ៍ឫស្សី ចា៎! នៅសហករណ៍ឫស្សីហ្នឹង ខ្ញុំជួបម្នាក់ឈ្មោះអ៊ំ ឈៀវ។ គាត់មិនចាស់ប៉ុន្មានទេ ប៉ុន្តែយើងចេះតែហៅអញ្ចឹងចា៎! អ៊ំ ឈៀវ ហ្នឹងមកដល់មុនយើង ហើយគាត់ហ្នឹងក៏ទៅចូលខាងសហករណ៍ឫស្សីហ្នឹងជាមួយខ្ញុំដែរ។ ដល់អញ្ចឹងចំនួនមនុស្សប្រុសហ្នឹងទៅជាបីនាក់វិញចា៎! ពេលយើងទៅនៅសហករណ៍ឫស្សីហ្នឹង គេប្រើឱ្យទៅច្រូតស្រូវ។ គេឱ្យយើងទៅធ្វើស្មៅ ស្រូវ។ ខ្ញុំឃើញចម្ការក្រូចៗពោធិ៍សាត់វែងដាច់កន្ទុយភ្នែក ប៉ុន្តែមានវល្លិ៍ព័ទ្ធពេញដើមក្រូច។

រាសី៖ អត់អ្នកណាថៃទេ?

សារីម៖ ចា៎! អត់មានផ្លែក្រូចអីសោះ ហើយស្លឹកឡើងក្រៀម ហើយខ្ញុំចេះឆ្ងល់ម៉េចក៏ ចម្ការក្រូចអត់ផ្លែអញ្ចឹង! ដូចជាមិនសមសោះ។

រាសី៖ បាទ! សូមអរគុណ អ្នកស្រី នៅ សារីម បាទ!

សារីម៖ ចា៎! អរគុណ លោក ប៉ូច រាសី។ ហើយនិយាយពីផ្ទះនៅទីហ្នឹងនោះ រន្ធូត រនាបសុទ្ធតែសង្កើចឱ្យក្រញ៉ុំៗឡើងក្រហម។ អ្ហូយខ្ញុំឡើងព្រឺសាច់ ចា៎! ហើយមនុស្សឈឺភ្នែកច្រើន ភ្នែកឱ្យពព្រាកគ្រប់គ្នា ជាប់អាចម៍ភ្នែកអាចម៍អី។ និយាយពីមេសហករណ៍កន្លែងគេនៅហ្នឹង មានដំឡូងឈើគរពេញក្រោមផ្ទះ។ ប៉ុន្តែគេពិសាតែគ្នាគេហ្នឹង

ឯង។ ខ្ញុំទៅបេះស្លឹកកន្ទំថេតដាក់ហោប៉ៅពីរហៅប៉ៅរាល់ថ្ងៃដើម្បីខ្ញុំទទួលទានជាមួយបាយ។ ជួនណាមានអំបិលអញ្ចឹងទៅ ចាំ! នៅទីហ្នឹង ពេលខ្លះខ្ញុំរត់ទៀត។ គេមកប្រាប់ថា «អូ! មកហើយៗ! យើងត្រូវតែយកអីវ៉ាន់រត់ រត់ទៅមួយយប់ហ្នឹង»។ គេថា យួនដេញ ចាំ! យប់ហ្នឹងខែភ្លឺផង ខែផល្គុន ហើយពួកយើងក៏ថ្លែងថា យប់នោះមិនមែនដេកអូតែលអគារផ្កាយបួនអីទេគឺយើងដេកសុទ្ធតែអូតែលផ្កាយរាប់ពាន់ ចាំ! ហើយនៅសហករណ៍ឫស្សីហ្នឹងគេប្រយ័ត្នណាស់។ គេមិនឱ្យអំបិលយើងទេ ព្រោះគេខ្លាចខ្មាំង ព្រោះខ្មាំងត្រូវការអំបិល ចាំ! ស្រាប់តែថ្ងៃមួយនោះ គេបញ្ជូនម្នាក់នោះទៅច្រូតស្រូវនៅកន្លែងផ្សេង ហើយគាត់ហ្នឹងមានកូនខ្ចី។ ខ្ញុំទៅសុំគេទៅជំនួស ព្រោះខ្ញុំអត់មានកូន។ អ្នកហ្នឹងគាត់មានកូន។ គាត់ត្រូវការមកឱ្យកូនបៅ នាំពិបាកគាត់។ ស្រាប់តែម្នាក់នោះនៅជាប់នោះថា «ហ៊ឺស! បងឯងទៅសុំជួសគេអី! គេយកម្នាក់ហ្នឹងទៅសម្លាប់ចោលណា!» ហើយខ្ញុំក៏ឈប់និយាយទៅ។ ហើយនៅសហករណ៍ឫស្សីហ្នឹង គេប្រាប់យើងថា ដំឡូងឈើដែលគេដាំហ្នឹង បើយើងឃើញគេគាស់ ឃើញវារបើកគល់របើកអីហ្នឹង ហើយនៅសល់ក្តិបតូចតាចហ្នឹង ចាំ! គឺយើងទៅរើសមកយកហូបមិនបានដាច់ខាត។ បើកាលណាយើងរើស វាសម្លាប់យើងចោល។ វាថា លួច។ ហើយចុះរបស់ហ្នឹងយើងចោលទេតើ! ម៉េចក៏មិនឱ្យយើងរើស។ ហើយពួកខ្ញុំ ដល់ឮសូរអញ្ចឹងក៏អត់ហ៊ាន។ ពេលគេប្រាប់យើងថា ឥឡូវគេបញ្ជូនយើងទៅនៅសហករណ៍មួយទៀតដែលមានដើមដូង ដើមត្នោតគឺថា ផ្លែឈើច្រើន ហើយយើងដើរតាមគេ។ ខ្ញុំដើរៗ ឃើញតែព្រៃ ចាំ! ដល់សម្រេចសម្រួលទៅសុទ្ធតែកន្លែងគេគាស់គល់ឈើ ហើយដុតព្រៃសម្រាប់ឱ្យយើងបោះទីតាំងរស់នៅ ចាំ! គឺថា ក្នុងព្រៃមែនទែន ហើយកន្លែងហ្នឹងគេហៅត្រជាក់ចិត្ត ចាំ! ហើយគេសង់រោងបាយ។ អញ្ចឹងគេដាក់ពួកយើង ពួកមកពីបូព៌ាហើយនឹងអ្នកណាផ្សេងទៀតឲ្យនៅកន្លែងហ្នឹងចាំ!ពេលហ្នឹងខ្ញុំឃើញកុមារខ្លះអត់បាយ ស្គមដូចព្រះសង្រ្គមអញ្ចឹង ចាំ! រួចទៅរុយរោមមុខ រោមមាត់។ ខ្ញុំធ្មេចភ្នែក។ ខ្ញុំទ្រាំមើលអត់កើត។ យើងនៅកន្លែងបឹងត្រជាក់ចិត្តហ្នឹងដើរទៅមុជទឹកប្រហែលមួយម៉ោង។ ទឹកហ្នឹង អ្នកអស់ហ្នឹងដួសមុជទាល់តែរីងទឹកត្រជាក់ចិត្តហ្នឹង ចាំ! នៅទីហ្នឹង ពួកខ្ញុំហ្នឹងគឺថា ចងអង្រឹងនៅ

ក្រោមដើមឈើសម្រានយប់ៗ តែយប់មួយនោះស្រាប់ខ្ញុំយល់សប្តិឃើញថា មានមនុស្សពីរក្រុមសង់ក្លោងទ្វារចូលវត្ត ហើយមួយក្រុមហ្នឹងធ្វើផ្ចិតផ្ចង់ៗ។ ក្រុមនៅខាងក្រោមស្រែកថា «អ្លែងចុះមក អញឡើងធ្វើម្តង ធ្វើយូរពេក»។ ស្រាប់តែអ្នកចុងក្រោយហ្នឹងឡើងទៅធ្វើគួសវាសៗ ខ្វិចខ្វាច់អញ្ចឹងទៅ ក៏ចុះមកវិញ។ យើងឃើញហើយ ពេលយើងមើលពីចម្ងាយទៅឃើញល្អ តែមើលជិតមិនល្អ។ ខ្ញុំភ្ញាក់ឡើង ខ្ញុំនិយាយប្រាប់ស្ងួន ដែលចងអង្រឹងសម្រានជិតខ្ញុំ ចាំ! ខ្ញុំថា អូ! ខ្ញុំយល់សប្តិឃើញ ដូចខ្ញុំនិយាយមិញចឹង។ ស្រាប់តែមានម្នាក់ហ្នឹងឈ្មោះប្រឹម។ គាត់មកពីបូព៌ា ចាំ! ដល់ពេលល្ងាចស្រាប់តែគេប្រជុំជីវភាព ចាំ! កសាងខ្ញុំថា «នែ! យល់សប្តិបងឯងមានន័យនយោបាយ»។ ស្រាប់ខ្ញុំគិតថា «ចុំ! យល់សប្តិខ្ញុំមានន័យនយោបាយម៉េចចេះ»។ ខ្ញុំថា «ខ្ញុំអត់យល់ទេ។ អ្នកឯងថា យល់សប្តិខ្ញុំមានន័យនយោបាយអីហ្នឹង»។

ខ្ញុំសូមជម្រាបថា ប្រឹមមានឪពុកក្មេកគាត់ ម្តាយក្មេកគាត់ កូនគាត់ ប្រពន្ធគាត់ទម្ងន់នៅក្នុងពោះ ចាំ! ហើយពេលបាយម្តងៗ ពេលគេចែកបាយមកហ្នឹង បាយទទេអញ្ចឹង ខ្ញុំហូបអត់កើត ខ្ញុំហូបបានតែបន្តិច។ បាយសល់ខ្ញុំឱ្យទៅម្នាក់ដែលថា យើងហៅគាត់អ៊ំ ឈៀវ។ ប្រឹមហ្នឹងគាត់មកសួរខ្ញុំថា «អ៊ំ ឈៀវហ្នឹងប្តីអ្នកឯងហី!» ខ្ញុំថា «អូ! មិនមែនទេ។ គាត់គ្រាន់ដើរជាមួយខ្ញុំ»។ គេដូចច្រណែនឃើញខ្ញុំឱ្យបាយទៅអ៊ំឈៀវហ្នឹង។ ម៉េចក៏មិនឱ្យទៅគាត់ ដែលមានកូនអីផងនោះ ចាំ! ហើយសុំជម្រាបថាប្រឹមហ្នឹងធ្លាប់ប្រាប់ខ្ញុំថា គាត់ហ្នឹងមកពីស្វាយរៀង ដូចជាកម្មាភិបាលផង ចាំ! ហើយគាត់ធ្លាប់ហូបថ្លើម ឬបេះដូងមនុស្សឆាជាមួយស្ពៃក្តោប ចាំ! គាត់និយាយប្រាប់ខ្ញុំថា «ឆ្ងាញ់ណាស់អាហ្នឹង»។ រួចទៅខ្ញុំថា «ហ៊ឺ! »។ ខ្ញុំនិយាយចង់បន្លប់ ចាំ! ខ្ញុំមិនដែល ឮសួរមនុស្សស៊ីថ្លើមមនុស្សអីទេ។ ខ្ញុំធ្លាប់តែឮសួរយក្ស រឿង ព្រេង។ ខ្ញុំថាអញ្ចឹងចាំ! ហើយគាត់ថាទៀត «អួយ! បងនែ! មនុស្សគេសម្លាប់ស្រួលណាស់»។ កាំបិតបន្ទុះគាត់ដាក់នៅកៀនគឺពាក់ឆៀងនៅជិតនឹងទ្រូងគាត់ហ្នឹង។ ហើយគាត់ក្រៀកមនុស្សហ្នឹងមក ហើយគាត់ខ្វេះកន្លែងកៀន ក្រោមស្លាបប្រចៀវទៅ ស្លាប់ភ្លាម។

ពេលដែលទៅនៅហ្នឹង ខ្ញុំជួបម្នាក់ហ្នឹងឈ្មោះស៊ុន ចា៎! ស៊ុនហ្នឹងធ្វើប្រធានរងពីមេខ្មែរក្រហមធំនៅកន្លែងត្រជាក់ចិត្តហ្នឹង ចា៎! គាត់ប្រាប់ខ្ញុំថា គាត់ហ្នឹងអ្នកពោធិ៍សាត់។ ខ្ញុំថាម្ដាយខ្ញុំក៏អ្នកពោធិ៍សាត់ដែរ នៅភូមិពោធិ៍ត្រកួយ។ ស៊ុនហ្នឹងថា «ហ៊ឺ! ខ្ញុំនៅភូមិពោធិ៍ត្រកួយហ្នឹងដែរ»។ គាត់ហ្នឹងចៅរបស់យាយកៅនី។ ខ្ញុំថា អូ! យាយកៅនីហ្នឹង ខ្ញុំស្គាល់ ហើយនៅផ្ទះជិតផ្ទះជីដូនខ្ញុំហ្នឹង ចា៎! លោកយាយទឹមនិងលោកតាទូច ចា៎!

ពេលខ្ញុំទៅពីកៀនស្វាយទៅពោធិ៍សាត់ទៅលេងភូមិពោធិ៍ត្រកួយម្ដងៗ យាយកៅនីហៅខ្ញុំទៅលេងផ្ទះគាត់។ គាត់ឱ្យដំណាប់ស្វាយដំណាប់អីខ្ញុំញ៉ាំនោះ ចា៎! រួចក៏ស្គាល់ស៊ុនហ្នឹងទៅគឺហាក់ដូចជាយើងមានទំនាក់ទំនងអញ្ចឹងចា៎! ហើយខ្ញុំក៏ឱ្យខោអាវខ្លះដែលខ្ញុំទិញទុកឱ្យប្ដីខ្ញុំនោះទៅគាត់ ហើយគាត់ថា នែបង! គាត់ពីដើមធ្វើប៉េអឹម ហើយគាត់ថា គាត់បានឡើងធ្វើអនុប្រធានកន្លែងហ្នឹងមកពីពួកខ្មែរក្រហមសម្លាប់គ្នាគេពាយអស់ទៅ ចា៎! ហើយស៊ុនប្រាប់ខ្ញុំថា ពេលជម្លៀសមនុស្សចេញពីភ្នំពេញហ្នឹង នៅកន្លែងហ្នឹងគាត់ជួបពូជស្ដេចស្រីៗត្រកូលស៊ីសុវត្ថិ ហើយគាត់ឃើញអត់បាយ។ គាត់អាណិតពេក ក៏គាត់ខំលួចស្រូវគេយកមកឱ្យ តែពួកនោះអត់ចេះធ្វើស្រូវឱ្យចេញជាអង្ករទេ ចា៎! អង្គុយបេះគ្រាប់ស្រូវ។ ក្រោយមកគេឱ្យយើងសង់ខ្ទមនៅឆ្ងាយពីកន្លែងចងអង្រឹង ហើយខ្ញុំក៏បានជួបមនុស្សម្នាក់មកពីម្ដុំឈើកាច់ខ្យាច់សក្នុងខេត្តព្រៃវែងចា៎! អ្នកហ្នឹងពីដើមធ្លាប់នៅខេត្តកំពង់ចាម។ ដល់ពេលខ្មែរក្រហមវាយកំពង់ចាម  គាត់ក៏ទៅនៅស្រុកកំណើតរបស់គាត់វិញ ហើយគាត់បានមកនៅបាត់ដំបងហ្នឹង។ ខ្មែរក្រហមបានមនុស្សគំរូពីបាត់ដំបងទៅមាឌមាំៗទៅឱ្យពួកគាត់ឃើញ ចា៎! ហើយថា  បាត់ដំបងសម្បូរណាស់។ អញ្ចឹងហើយឱ្យអ្នកស្រុកហ្នឹងសុខចិត្តដូរមកនៅបាត់ដំបង ចា៎! ហើយកូនប្រុសគាត់ ពេលហ្នឹងអាយុប្រហែល១៦ឆ្នាំ មានប្រពន្ធអាយុស្រករៗគ្នាហ្នឹងចា៎! ហើយពួកហ្នឹងឈ្លោះគ្នាឱ្យរង៉ូវ ចា៎! គេដណ្ដើមថា «អញទៅនៅជាមួយម៉ែអញ!» ម្នាក់ទៀតថា «ទៅនៅជាមួយម៉ែអញ»។ រួចទៅខ្ញុំចេះតែសើចថា ម៉េចក៏ការពីក្មេងៗម្ល៉េះ! ហើយអ្នកហ្នឹងគាត់ប្រាប់ថា ហ្នឹងគេធ្វើតាមគោលការណ៍របស់អង្គការសម្រាប់ ចម្រើនប្រជាជន។ ហើយរៀបការទៅឱ្យ

បាននៅក្នុងភូមិ ចាំ! ហើយអ្នកហ្នឹងនិយាយថា «ហ៊ឺស! ឈ្លោះគ្នាប៉ុណ្ណឹងគ្រាន់បើហើយ។ បើអ្នកខ្លះអង្គការការឱ្យហើយ ទៅស៊ីក្លូចពុលងាប់ ចាំ! ប្រហែលថ្ងៃជិតដាច់ខែមេសា ពេលប្រជុំក្រុមហ្នឹង ស្រាប់តែប្រឹមហ្នឹងគាត់បានលើករឿងខ្ញុំយល់សប្តិហ្នឹងមកនិយាយទៀត។ ម្តងនេះ ខ្ញុំងើបឈរ ហើយឆ្លើយជាមួយប្រឹមហ្នឹងថា «នែ! មិត្តប្រឹម! ខ្ញុំមិនដឹងមិត្តឯងចង់បានអីពីខ្ញុំទេ បានតែយករឿងយល់សប្តិខ្ញុំហ្នឹងមកនិយាយទៀត»។ ហើយខ្ញុំប្រាប់ប្រឹមថា នៅក្នុងព្រៃនេះណា ខ្ញុំមានក្បាលតែមួយទេ ហើយមិត្តឯងវិញណាមានកូនពីរបីនាក់ មានប្រពន្ធ មានកូននៅក្នុងពោះ ហើយមានឪពុកម្តាយក្មេក ចាំ! ខ្ញុំយល់ថា ប្រឹមហ្នឹងបែបគាត់ចង់បានជីវិតខ្ញុំ។ ខ្ញុំក៏ឆ្លើយដូចខ្ញុំនិយាយមិញ ចាំ!

រាសី៖ នៅក្នុងអង្គប្រជុំហ្នឹងហី?

សារីមេ៖ ចាំ! នៅក្នុងអង្គប្រជុំហ្នឹងមានសួន ហើយជាមួយអ្នកដទៃទៀតដែលគេទៅធ្វើការជាមួយយើងនោះ ចាំ!

រាសី៖ អ្នកស្រីទ្រាំលែងបានហើយ បានជាហ៊ានឆ្លើយ?

សារីមេ៖ ចាំ! គឺខ្ញុំយល់ថា បើខ្ញុំនៅស្ងៀមឱ្យគេសម្លុត ប្រឹមហ្នឹងរឹតតែសម្លុតខ្ញុំ។ ហើយសូមជម្រាបថា ខ្ញុំហ្នឹងកាន់កូនខ្មោចដែរ ព្រោះថា បើងាប់ ឬជាឱ្យបាននិយាយតវ៉ាសិន ចាំ!

រាសី៖ បើនិយាយទៅអ្នកស្រីឆ្លើយមកវិញ?

សារីមេ៖ ចាំ! ដល់រួចទៅមានអ្នកនៅក្នុងអង្គប្រជុំហ្នឹងម្នាក់។ គាត់ទើបរត់មកចេញពីភ្នំពេញដែរ។ គាត់រត់មកដល់ក្រោយគេ ចាំ! ហើយគាត់ថា ម្នាក់ៗ យើងសុទ្ធតែរក្សាអាយុឱ្យរស់បានរៀងខ្លួនចេញពីយួនមកហើយគឺថា យើងមិនគួរមករករឿងគ្នានៅក្នុងព្រៃនេះទេ ចាំ! ហើយយប់ហ្នឹង ក្រោយពីអង្គប្រជុំក្រុមដែលលើកតែពីរឿងយល់សប្តិខ្ញុំហ្នឹង យើងក៏ឡើងដេកលើខ្ទមអត់ដំបូលរបស់យើងហ្នឹង។ សួនបានថា ឱ្យខ្ញុំថា «ហ៊ឺស! មិនដឹងសារីមេឯងក្លាហានដល់ម្លឹង»។

ខ្ញុំថា ខ្ញុំត្រង់។ ខ្ញុំហ៊ានអញ្ចឹង ចាំ! ស្អែកឡើងខ្ញុំថា ខ្ញុំនឹងជួបពូស៊ុនប្រាប់រឿងហ្នឹង តែ

អត់ឃើញពូស៊ុនមក ចាំ! តាំងពីគេកសាងខ្ញុំពីរឿងយល់សប្តិមក ខ្ញុំយល់សប្តិអី ក៏ខ្ញុំលាក់ទុកក្នុងខ្លួនឯងដែរ។ ម្តងហ្នឹង ខ្ញុំយល់សប្តិឃើញអាហ៊ុយ ពូកម៉ាកខ្ញុំហ្នឹងអង្គុយគងជើងក្នុងអណ្តូង រួចហើយស្រែកប្រាប់ខ្ញុំថា «នែ សារីម! ខ្លួនឯងហ្នឹងជិតបានញុំាគុយទាវហើយ»។ ខ្ញុំថា «ហ៊ឺស! ញុំាគុយទាវអីនៅក្នុងព្រៃជ្រៅអញ្ចឹង»។ ហើយអាហ៊ុយថា « ចាំមើល២-៣ថ្ងៃទៀតខ្លួនឯងនឹងឃើញហើយ»។ ហើយពេលហ្នឹងខ្ញុំរង់ចាំបុណ្យ១៧ មេសា ជំរំត្រជាក់ចិត្តហ្នឹង។ ប៉ុន្តែអត់មានធ្វើបុណ្យ១៧ មេសាអីទេ ហើយមុំពេលហ្នឹង តាមផ្លូវក្បែរជំរំដែលខ្ញុំនៅហ្នឹង ខ្ញុំឃើញមនុស្សដើរហូរហែរ ខ្លះទូលហិប ខ្លះស្ពាយស្បោង។ ខ្ញុំគិតថា ប្រហែលពួកនោះប្តូរកន្លែងនៅហើយ ចាំ! បន្តទៅយើងឃើញខ្មែរក្រហមហ្នឹងលីគ្រាប់កាំភ្លើងត្រយ៉ូងចេករបស់គេហ្នឹង ចាំ! ហើយនឹងម្តងនោះយើងឃើញឡានម៉ាកសឺដេសបើកនៅមុំផ្លូវដែលគេដេញយើងមកហ្នឹង ចាំ! ពេលពូស៊ុនមកជួបយើងគឺជិតដល់ដាច់ខែមេសា ឆ្នាំ១៩៧៩ ហើយ ហើយគាត់មកប្រាប់យើងថា «នែ!បងៗ! ឥឡូវអង្គការរំសាយ ពួកយើងហើយ»។

រាសី៖ បាទ! សូមអ្នកស្រីពន្យល់អំពីពាក្យរំសាយហ្នឹងបានន័យថាម៉េច?

សារីម៖ ចាំ! អង្គការរំសាយហ្នឹងគឺបានន័យថាអង្គការព្រលែងយើង លែងក្រុងយើងឱ្យនៅជាមួយទៀតគេទៀតហើយ។

រាសី៖ បាទ! ហើយអញ្ចឹងអង្គការគេទៅណាវិញទៅពេលហ្នឹង?

សារីម៖ ចាំ! អង្គការហ្នឹងគេអត់មានមកព្រលែងយើងចឹងទេ ហើយពូដែលមកជួបខ្ញុំហ្នឹង គេប្រាប់ខ្ញុំថា ឱ្យយើងហ្នឹងទៅរកស្រូវតាមបងប្អូនយើងដែលគេដើរទៅរកស្រូវនោះទៅ ពីព្រោះគេដឹងថា ពួកខ្ញុំហ្នឹងអត់ស្គាល់ទីកន្លែងហ្នឹង ចាំ!

រាសី៖ ពេលហ្នឹងក្រុមអ្នកស្រីនៅសល់ប៉ុន្មាននាក់?

សារីម៖ ចាំ! ពេលហ្នឹងក្រុមខ្ញុំមានមនុស្ស៨នាក់ដដែលហ្នឹង។

រាសី៖ ហើយពេលដែលគេប្រាប់ថា អង្គការរំសាយហ្នឹង អ្នកស្រីមានអារម្មណ៍យ៉ាងម៉េច?

សារីមៈ ចាំ! ពេលហ្នឹងខ្ញុំសប្បាយដូចហោះអញ្ចឹង ពីព្រោះថា ដូចរួចចេញពីឋានរកអញ្ចឹង ចាំ! ហើយយើងទាំងអស់គ្នាហ្នឹងក៏នាំគ្នាដើរតាមអ្នកស្រុកទៅរកស្រូវ ចាំ! នៅក្នុងភ្នំរូងគឺថា នៅប្រហែល៤-៥គីឡូម៉ែត្រពីកន្លែងយើងនៅហ្នឹង។ ពេលយកមកហ្នឹង យើងបុកស្រូវហ្នឹងឱ្យចេញជាអង្ករ ហើយដាំបាយហូបម៉ាឆ្អែត ឆ្ងាញ់មែនទែន ចាំ! ហើយបាយហ្នឹងផ្អែម ហើយពេលហ្នឹងអ៊ំ ឈ្លៀវបានសុំសាច់គោគេបានមួយដុំ ហើយសាច់គោហ្នឹងក៏ឆ្ងាញ់ ហើយផុយ ចាំ! ពួកហ្នឹងគេកាប់គោ ហើយគេចំហៀវខ្លាញ់ជ្រូកទៀត ចាំ! ខ្លាញ់ជ្រូកហ្នឹងឈ្ងុយ ពេញព្រៃ ចាំ! មិនដូចពេលមុនទេ។ ពេលមុនហ្នឹង យើងដើរទៅផុំស្អុយខ្មោច ហើយឮសូរតែសទ្ទឹករុយរោមង្ងង។ ចាំ! ហើយកាលនៅក្នុងព្រៃហ្នឹងមិនមែនដូចនៅបឹងត្របែកទេ អាចរើសស្វាយបានទទួលទាន។ នៅក្នុងព្រៃត្រជាក់ចិត្តហ្នឹង ខ្ញុំច្រើនតែទៅបោចស្លឹកព្រិចក្រៀមៗដាក់ហោប៉ៅ ទុកបៀមក្នុងមាត់ បៀមយូរៗទៅ វាទន់ ហើយចេញជាតិផ្អែម ហើយក៏ទំពារលេបទៅ ចាំ! ដូចបន្លែអញ្ចឹង។

រាសី៖ អ្នកស្រីមានប្រសាសន៍ថា ទៅយកស្រូវ។ តើទៅយកនៅជង្រុកគេ ឬក៏យ៉ាងម៉េច? បាទ!

សារីមៈ ចាំ! ទៅយកស្រូវហ្នឹង គឺកន្លែងដែលអង្គការរក្សាទុកនៅកន្លែងៗណា មុនគេរំសាយយើង។ គេចេះតែនាំយើងឱ្យទៅជញ្ជូនស្រូវទុកនោះ ចាំ!

រាសី៖ បាទ! បើអញ្ចឹង អ្នកស្រីស្គាល់កន្លែងហើយ?

សារីមៈ ចាំ! ទេ ខ្ញុំអត់ស្គាល់ទេ ប៉ុន្តែ ចាំ! សៀងនៅជាមួយពួកយើងហ្នឹង គាត់ក៏ធ្លាប់ទៅជញ្ជូនស្រូវទុកដែរ ចាំ! ហើយអ្នកដែលគេស្គាល់កន្លែងនោះគេទៅយក យើងដើរតាមគេ ចាំ!

រាសី៖ បាទ! ហើយក្រៅពីមានការសប្បាយចិត្ត អ្នកស្រីមាននឹកយ៉ាងម៉េចដែរដល់ក្រុមគ្រួសារដែរ?

សារីមៈ	ចា៎! ខ្ញុំគ្រាន់ឮសួរអង្គការរំសាយអញ្ចឹង ខ្ញុំប្រាប់អ្នកដែលដើរជាមួយខ្ញុំហ្នឹងថា ខ្ញុំគឺដំណើរឆ្ពោះទៅទិសខាងលិច ហើយអ្នកណាចង់ដើរជាមួយខ្ញុំដើរ  អ្នកណាចង់ទៅណាគឺស្រេចចិត្ត ចា៎! ខ្ញុំឆ្ពោះទៅទិសខាងលិចអញ្ចឹងហ្មង ចា៎!

រាសីៈ	ចង់បានន័យថា ទៅជំរំ ឬក៏ទៅណា?

សារីមៈ	ចា៎! ខ្ញុំមិនបកទៅភ្នំពេញវិញទេ ហើយខ្ញុំនឹងតម្រង់ទៅស៊ីសុផុន ពីព្រោះខ្ញុំធ្លាប់នៅស៊ីសុផុនកាលខ្ញុំធ្វើគ្រូ ទើបចេញដំបូង ចា៎! ខ្ញុំតម្រង់ទៅរកផ្ទះដែលអ្នកដែលខ្ញុំធ្លាប់សំណាក់នៅផ្ទះជាមួយគាត់ ហើយដើម្បីខ្ញុំនឹងរៀបចំដំណើរចេញទៅទល់ដែនសៀម ចា៎!

រាសីៈ	ចុះអ្នកស្រីមានគោលបំណងទៅរកគ្រួសារសិនទេ?

សារីមៈ	ចា៎! ពេលដែលគេថា រំសាយហ្នឹង គឺខ្ញុំគិតស្រេចថា បើខ្ញុំបកទៅភ្នំពេញផ្លូវឆ្ងាយ។ ហើយមានយួនអីវាយចុះឡើងតាមផ្លូវអញ្ចឹង យើងអាចមានគ្រោះថ្នាក់ខ្លាំង។ ហើយខ្ញុំគិតថា ខ្ញុំនឹងបកទៅស្រុកបារាំងវិញម្តងនេះ គឺខ្ញុំយករស់ ធ្វើម៉េចឱ្យខ្លួនខ្ញុំបានរស់ ហើយចាំស្តាប់ដំណឹង។ បើថា មានអ្នកណានៅរស់ កូននៅរស់ ខ្ញុំខំធ្វើការ ហើយខ្ញុំប្រើលុយយកអ្នកនោះចេញវិញចា៎! ម្តងនេះ ចា៎!

រាសីៈ	បាទៗ! គិតអញ្ចឹងវិញបាទ! មិនប្រថុយដូចលើកមុនទេ បាទ?

សារីមៈ	ចា៎!

រាសីៈ	ហើយពេលដែលរំសាយហើយហ្នឹង អ្នកស្រីចេញទៅហ្នឹង អ្នកស្រីមានជួបពួកទាហានយួន ទាហានអីទេ?

សារីមៈ	ចា៎! ពេលដែលចេញមកខាងក្រៅបន្តិចហ្នឹង ពេលខ្ញុំកំពុងតែឈរដងទឹកល្អក់ៗយកមកច្រោះដើម្បីឱ្យថ្លាហ្នឹង ស្រាប់តែខ្ញុំងាកមុខមកឃើញយួន ចា៎! ពេលហ្នឹងខ្ញុំភ្ញាក់ណាស់ ដូចថា មិននឹកស្មានថា ទាហានយួនបានទៅដល់កន្លែងដែលពួកយើងនៅនោះណា។ ខ្ញុំឡើងញ័រក្នុងខ្លួន ហើយខ្ញុំក៏ងាកមុខចេញទៅ។ ខ្ញុំខ្លួនឯងហ្នឹងរស់នៅក្នុងប្រវត្តិសាស្ត្រ ឃើញយួនចូលលុកលុយ ភ្នែកស្រស់ៗតែម្តង ចា៎!

រាសី៖ ហើយអញ្ចឹងពួកទាហានយួនគេមានសួរនាំអីដែរ?

សារីម៖ ចា៎! អត់ៗទេ។

រាសី៖ អ្នកស្រីសម្រេចចិត្តថា សំដៅទៅទិសខាងលិចហ្នឹង។ អ្នកស្រីធ្វើដំណើរភ្លាមៗ ឬក៏?

សារីម៖ ចា៎! ពេលហ្នឹងខ្ញុំគ្រាន់បានបាយទឹកអី ហើយមានអង្ករ មានអីគ្រប់គ្រាន់ហ្នឹង ខ្ញុំក៏ចេញ ដំណើរភ្លាមមក។ ហើយនៅតាមផ្លូវមានម្នាក់ឈ្មោះឌីនី។ គាត់កើតរោគរាកដូចខ្ញុំដែរហ្នឹង។ គាត់ស្លាប់ទៅ ចា៎! ពេលហ្នឹង ខ្ញុំក៏ជាជំងឺរាកដែរ។ ហើយខ្ញុំយល់សប្តិឃើញកូនស្រីខ្ញុំ មកហៅខ្ញុំទៅជាមួយ។ ប៉ុន្តែក្នុងយល់សប្តិ ខ្ញុំដូចដឹងថា កូនស្រីហ្នឹងស្លាប់។ ខ្ញុំថា «អូ! ម៉ាក់អត់ទៅជាមួយទេ»។ ហើយតាំងពីថ្ងៃហ្នឹងមក ខ្ញុំជារាកមួលហ្នឹងចា៎! ហើយម្នាក់ឈ្មោះឌីនីហ្នឹងរាកមួលដំណាលគ្នាជាមួយខ្ញុំហ្នឹង។ គាត់ស្លាប់ទៅ។ យើងក៏កប់ខ្មោចគាត់គ្រប់សព្វអញ្ចឹងទៅ។ ហើយសួនយកចិត្តទុកដាក់ណាស់។ គាត់លាងខ្មោចឌីនី ហ្នឹង។ រួចអ៊ុំ ឈៀ្ល ហើយនឹងដេតខំជីកដី។ រួចហើយពួកយើងហ្នឹងក៏កប់ឌីនីហ្នឹងទៅ។ ហើយយើងក៏លាគាត់ដើរមកទៀត ចា៎! ហើយស្រាប់តែពេលដើរតាមផ្លូវហ្នឹង ខ្ញុំឃើញ ប្រឹម។ គាត់ដើរជាមួយគ្រួសារគាត់។ គាត់ស្លៀកពាក់ខោអាវដូចកម្មាភិបាលខ្មែរក្រហមអញ្ចឹង រែកអីវ៉ាន់ ហើយបណ្តើរកូនឱ្យរញៀវ ហើយនឹងប្រពន្ធដើមរបស់គាត់ហ្នឹង។ ខ្ញុំទៅប្រាប់គាត់ថា នែមិត្តប្រឹម! ម៉េចបានស្លៀកពាក់ដូចកម្មាភិបាលខ្មែរក្រហមអញ្ចឹង ប្រយ័ត្នមានគ្រោះថ្នាក់ដល់ខ្លួន»។ ហើយគាត់ងាកមកមើលពួកយើង។ ពួកយើងស្លៀកច្រើនតែខោខ្មៅ ប៉ុន្តែអាវហ្នឹងពណ៌កំភ្លីកកំភ្លាក់ផ្សេងៗគ្នា ចា៎! ហើយប្រឹម ហ្នឹងដូចជាភ្ញាក់ខ្លួន ហើយគាត់អរគុណខ្ញុំ។ ហើយយើងក៏លាគ្នាទៅ ចា៎! ដល់ពេលល្ងាចហ្នឹង យើងឈប់ ហើយសម្រាកដាំបាយ ហើយពេលព្រលប់ៗហ្នឹងចា៎! យើងក៏ចេញដំណើរទៀត ដោយដើរតាមគេឱ្យទាន់ ពីព្រោះយើងមិនស្គាល់ផ្លូវ។ ពេលឃើញរទេះគេទាំងហ្វូងទៅស្រាប់តែខ្ញុំខំដើរតាមរទេះគេមកភ្លែត។ ពេលទៅដល់វាលមួយ ស្រាប់តែបាត់អស់រលីងរទេះហ្នឹងចា៎! ពេលហ្នឹង ខ្ញុំខ្លាចណាស់។ ខ្មែរយើងនិយាយថា បះសក់។ ខ្ញុំដឹងថា សក់ខ្ញុំហ្នឹងនៅលើក្បាលហ្នឹងគឺបះច្រូងឡើងលើ ចា៎! ខ្ញុំខ្លាច ព្រោះបាត់គេអស់ភ្លាមនោះ។

រាសីៈ ស្រាប់តែបាត់អស់រលីង?

សារីមៈ ចា៎! ដល់អញ្ចឹង ពួកខ្ញុំហ្នឹងក៏ទៅសម្រាកនៅមាត់ឡគេដុតឥដ្ឋមួយយប់ហ្នឹង។ ហើយនិយាយពីឃើញភ្លើងហោះពីដីទៅ ដែលខ្មែរយើងនិយាយថា ព្រាយហោះ! តែប្រហែលមកពីកន្លែងនោះជាកន្លែងកប់ខ្មោចច្រើន មានជាតិផូស្វ័រ។

រាសីៈ បាទ! ដុំភ្លើង?

សារីមៈ ចា៎! ឆ្វាចៗ អញ្ចឹងឡើងលើ ចា៎! ពួកយើងថា អូ! អត់ខ្លាចអត់អីទេ។ អាហ្នឹងផូស្វ័រទេ ចា៎!

រាសីៈ ហើយអញ្ចឹង ស្នាក់នៅទីហ្នឹងមួយយប់ ហើយបន្តដំណើរទៅទៀតហី។

សារីមៈ ចា៎! យើងចេញដំណើរទៅទៀត។ ចេញពីឡដុតឥដ្ឋមកដើរហូរហែរតាមផ្លូវ។ យើងជួបអ្នកស្រុក។ មានអ្នកមកពីស្វាយរៀងនោះ ស្រីៗពីរបីនាក់ដើររលះ រលាំងស្រាប់តែមកសួរខ្ញុំថា បើមានថ្នាំពេទ្យគួរចែកឱ្យគេខ្លះមកព្រោះទៅមុខទៀត មុខតែមានគេឆែកយកអស់ហើយ។ ពួកខ្ញុំគ្រាន់តែស្តាប់ ប៉ុន្តែយើងអត់ជឿ។ ពេលហ្នឹងខ្ញុំធ្វើព្រងើយ ខ្ញុំអត់មានឱ្យថ្នាំអី។ តាមផ្លូវមានគេបោះបំពង់ស្កត្នោត។ គេពិសាហើយ គេបោះចោល ពួកខ្ញុំទៅរើសយកមក ហើយកាប់បំពង់ច្រៀកជាដុំចែកគ្នាលិតចា៎។ ដើរមកដល់កន្លែងមួយគេហៅ ខ្ទប់។ មានផ្ទះ ផ្ទះសង្គមកិច្ចគេនោះច្រើនណាស់ក៏សំណាក់នៅទីនោះ។ បន្ទាប់មកមានពួកគេប្រាប់ថា តែអ្នកណាមានសៀវភៅមានអីប្រយ័ត្នយួនចាប់។ ខ្ញុំពេលហ្នឹងក៏ហែកសៀវភៅដែលខ្ញុំសរសេរពីរឿងថាថ្ងៃនេះជួបអីៗ ដាយរី (Diary) ខ្ញុំៗយកទៅដុតចោលអស់ចា៎! ក្នុងកំណត់សៀវភៅខ្ញុំៗបានឃើញរបៀបធ្វើជ្រូកខ្វៃរបស់បង មុយ។ បង មុយ ជាអ្នកសៀមរាប ដែលជាកូនចិនឆៃរត់ពីស្រុកកុម្មុយនីស្តចិនមកកាលឆ្នាំ១៩៤៩ណោះ។ ខ្ញុំឃើញរបៀបកត់ត្រាឆាបន្លែឱ្យជ្រោគៗតាមរបៀបអ្នកភ្នង។ អ្នកភ្នង ដែលជាប្រពន្ធ ឡូយ ស៊ឹមឈាងនោះ។ ខ្ញុំយកថ្នាំគ្រុនចាញ់ទៅដូរបានប្រហុក។ ឱ្យគេទៅស្រេចគេឱ្យ។ គេឱ្យប្រហុកពីរកំប៉ុងហ្គីហ្គោ។ ពេលហ្នឹងយើងនាំគ្នាធ្វើរទេះមួយសម្រាប់អូសអីវ៉ាន់នោះ។

មានម៉ាស៊ីនកិនស្រូវនៅកន្លែងហ្នឹងនិយាយពីអ្នកស្រុកទៅរុះម៉ាស៊ីនកិនស្រូវ។ ឃើញអញ្ចឹងខ្ញុំក៏ទៅរកលួស។ ទៅដល់អត់មានអីទេ និយាយពីម៉ត់ដូចផ្ទូរ។

រាសី៖ បាទ! ថ្នាំគ្រុនអ្នកស្រីមានប្រសាសន៍អម្បាញ់មិញ គឺថ្នាំគ្រុនយកពីស្រុក បារាំងពីមុនមកទេ?

សារីមេះ ចាំ! ថ្នាំគ្រុនចាញ់ដែលខ្ញុំទុកនៅសល់។ មានរទេះតូចមួយ។ អំ ឈ្លៀវ ដាក់អីវ៉ាន់យើងខ្លះទៅ។ យើងក៏ស្ពាយខ្លះ។ ពួកខ្ញុំពេលដើរឃើញត្រកួន ចេះតែបេះទុក។ មានមុងខ្ញុំមួយអូសត្រីតាមផ្លូវ។ ពេលខ្ញុំដើរទៅឃើញមានដំឡូងឈើច្រើនក្នុងភូមិមួយនោះ ខ្ញុំក៏ទៅសុំដំឡូងឈើគេ។ គេមិនឱ្យ។ គេប្រាប់ខ្ញុំថា អ្នកឯងទៅគេហៅឆ្កែខាំប្រើស។ ខ្ញុំទៅដល់ឆ្កែខាំប្រើសស្រាប់តែជួបម្នាក់ធ្លាប់រៀនជាមួយខ្ញុំនៅសាលាឫស្សីកូលេសនរោត្តម។ គាត់ឈ្មោះ មាស ម៉ូលី។ ឃើញគេអង្គុយនៅកាំជណ្តើរផ្ទះ។ ខ្ញុំភ្ញាក់។ អូ! ម៉ូលី។ បន្ទាប់មក ម៉ូលី ប្រាប់ខ្ញុំថា ពួកម៉ាកដែលធ្លាប់រៀនជាមួយយើងមានអ្នកមួយឈ្មោះអ្នក មាជ វិមុត កូនលោក និគុណ ថា វិមុត នៅរស់ ហើយនឹងកូនប្រុសឥឡូវធ្វើដំណើរទៅបាត់ដំបង។ ម៉ូលី ថា ប្តីគាត់នៅបរទេស។ យើងបានដំឡូងក៏បន្តដំណើរទៅទៀត។ ពេលខ្ញុំទៅរកដំឡូងនៅឆ្កែខាំប្រើសគឺចំថ្ងៃទី១ ខែឧសភា ចាំ! ខ្ញុំចាំថ្ងៃហ្នឹងថ្ងៃទី១ ខែឧសភា ថ្ងៃបុណ្យការងារនោះចាំ! ចេញពីឆ្កែខាំប្រើសទៅពួកខ្ញុំបានទៅដល់ភូមិមួយ ស្រាប់តែខ្ញុំជួបបងថ្លៃស្រីរបស់ប្អូនស្រីខ្ញុំ។ គាត់ឃើញខ្ញុំគាត់ស្គាល់ខ្ញុំ ហើយគាត់ប្រាប់ថា ស្លាប់អស់ហើយ។ ខ្ញុំសួរថាអ្នកណាខ្លះ? គាត់ប្រាប់ខ្ញុំថា ប្អូនស្រីអ្នកឯង ឈ្មោះ យូ សុផល ហើយនឹងកូនស្រី ហើយនឹងប្តីវាឈ្មោះ ហាក់។ ខ្ញុំបន់កុំឱ្យគេនិយាយប្រាប់ខ្ញុំពីរបៀបប្អូនស្រីខ្ញុំស្លាប់នាំរឹតតែឈឺចាប់។ ខ្ញុំសុំជម្រាបថា ប្អូនស្រីខ្ញុំឈ្មោះ យូ សុផល ហ្នឹងធ្វើគ្រូបង្រៀន ហើយខ្ញុំបានខ្ចី ខ្សែកមាសមួយខ្សែពាក់ទៅស្រុកបារាំង។ ប្អូនគាត់ឈ្មោះហាក់ គឺឈ្មោះ សែប ចុងហាក់ធ្វើវិស្វករខាងសាធារណការ។ គាត់ថា ហាក់ ប្អូនប្រុសគាត់មិនព្រមរស់ក្នុងរបបខ្មែរក្រហមទេ។ គាត់ហ្នឹងជាប្រពន្ធស័ក្តិ៥។ គាត់ខំយកចិត្តខ្មែរក្រហមធ្វើការបែកដៃគាត់អស់ហើយ។ គេឱ្យធ្វើគាត់ធ្វើចុងភៅ។ ហើយគាត់ខំលាក់ទឹកបបរខាប់ៗយកទៅឱ្យ

ហាក់ ហូប។ ប៉ុន្តែគេមិនព្រម លេបទឹកបបរហ្នឹងទេ។ គេសុខចិត្តអត់ទាល់តែស្លាប់ ព្រោះគេថាគេមិនសុខចិត្តរស់នៅក្នុងរបបព្រៃផ្សៃហ្នឹងទេចា៎! អ្នកប្រពន្ធស័ក្តិ៥ហ្នឹង ជាម្តាយរបស់នាង ស៊ូ សុវត្ថិធារី និង ស៊ូ សុនណារី ដែលធ្លាប់ជាកូនសិស្សខ្ញុំ។ គាត់បន្តថា ប្អូនស្រីហ្នឹងអត់ចេះខ្លាចខ្មែរក្រហមទេ។ ខ្មែរក្រហមតាមដាន ប្អូនស្រីខ្ញុំរហូតទៅជីកកប់អីនៅកន្លែងណា គេទៅតាមកាយភ្លាម សូម្បីតែវាទៅ បត់ជើងធំហ្នឹងក៏គេទៅកាយដែរព្រោះពួកនៅហ្នឹងយល់ថា ប្អូនស្រីខ្ញុំអ្នកមាន ថាទៅកប់មាស។ សុំជម្រាបថា ប្អូនស្រីខ្ញុំកាលនៅពីក្រមុំធ្លាប់ឈឺរលាក ខួរក្បាលបាត់ស្មារតីច្រើនថ្ងៃ។ ម្លោះហើយដល់ជាមកវិញ និយាយមិនខ្លាចអ្នកណា ខឹងអីទេ។ ហើយចិត្តក៏មិនហ្នឹងនរទៀត។ ខ្ញុំដើរចេញពីជួបបងថ្លៃប្អូនស្រី ទាំងទឹកភ្នែកខ្ញុំហូរមិនដឹងខ្លួនព្រោះខ្ញុំនឹកស្តាយប្អូនស្រី។ យើងបានដើរមកដល់ថ្នល់ជាតិ។ យើងដើរដូចហោះអញ្ចឹង។ ស្រួលដើរណាស់។

ពាសីៈ ផ្លូវជាតិ?

សារីមៈ ចា៎! ផ្លូវជាតិ។ ពេលដើរតាមផ្លូវនៅមុខផ្ទះខ្លះ យើងឃើញគេរាំវង់ដូរអង្ករ។ ពួកខ្ញុំទៅស្នាក់នៅអនុវិទ្យាល័យមោង ជួបប្រុសម្នាក់សក់វែងសឹងដល់ស្មា! គាត់មានហ្គីតាមួយ។ គាត់ដេញបទពីសង្គម។ ខ្ញុំសួរថា ចុះអ្នកឯងបានហ្គីតានេះមកពីណា? គាត់ថា គាត់ទៅគាស់យកពីកន្លែងខ្មែរ ក្រហមយករបស់គាត់ទៅទុក។ ខ្ញុំសួរថា ម៉េចសក់វែងម្ល៉េះ? គាត់ថា ពេលជិតចប់ហ្នឹង គាត់រត់ចូលនៅតែក្នុងព្រៃ។ អត់ឱ្យខ្មែរក្រហមប្រើទេ។ គាត់ ច្រៀងបទអញ្ចឹងទៅ យើងក៏ទៅនាំគ្នាច្រៀងលេងជាមួយគាត់មានបទអានី អញ្ចឹង។

ពាសីៈ បាទ! ហើយអញ្ចឹងពេលហ្នឹងគេលែងស្លៀកខ្មៅអស់ហើយ?

សារីមៈ ចា៎! អ្នកណាមានខោអាវអីស្លៀកទៅចា៎! ពួកខ្ញុំនេះមែនទែនអត់មានសូវសល់ខោអាវពណ៌ទេ។ នៅសល់តែខោអាវខ្មៅដែលយើងយកពីស្រុកបារាំង។ វាស្រាលៗក្រណាត់ក្រែប។ វាមាំ។ វាអត់រហែកទេ។

រាសី៖ បាទ! ដូចថាជួបអ្នកស្រុកអី គេមិនសង្ស័យថា អូ! គេស្លៀកខ្មៅ យើងជាមូលដ្ឋានខ្មែរក្រហមអីទេ?

សារីម៖ មិនទេចាំ! ប៉ុន្តែនាង សៀន ដែលដើរជាមួយខ្ញុំនិយាយថា គាត់ឮសូរ ពួកអ្នកស្រុកគេថា ឥឡូវហ្នឹងមានពួកមកតាម អៀង សារី នោះឥឡូវហ្នឹងកំពុង រត់ខ្ចាត់ខ្ចាយហើយ។ ពួកយើងដល់ឮសូរអញ្ចឹងក៏ព្រលឹមឡើងខំធ្វើដំណើរតទៅទៀតចាំ! យើងខំលាក់អត្តសញ្ញាណយើង។

រាសី៖ បាទ! ខ្លាចមានការយល់ច្រឡំ?

សារីម៖ ចាំ! ដល់ពេលទៅដល់បាត់ដំបង ខ្ញុំខំរកផ្ទះឪពុកមាជីដូនមួយខ្ញុំឈ្មោះ យឹម ផាន់ដែលប្រពន្ធគាត់ឈ្មោះ ដួង ផាន់ ម្តុំផ្លូវទៅផ្ទះចៅហ្វាយខេត្ត។ តែខ្ញុំរកមិនឃើញ។ ពេលហ្នឹង ខ្ញុំឃើញទាហានយួនដេញចាប់មនុស្ស។ នៅតាមផ្លូវមុនឆ្លងស្ពាននៅមុខផ្ទះចៅហ្វាយខេត្ត ខ្ញុំឃើញអ្នកថៃ ពួកម៉ាកខ្ញុំដែលសួររកនំប៉ាវ។ គាត់ជាប្រពន្ធរបស់រស់ ពិន កំពុងតែអង្គុយ ផ្លុំភ្លើងដាំបាយជាមួយឈ្មោះ ស្រី វ៉ាន់ហោង។ ស្រី វ៉ាន់ហោងច្រើនតែធ្វើជាងនៅបឹងត្របែក។ យើងក៏បានគ្នាដើរតទៅទៀតឡើងប្រាំបួននាក់ហើយគ្នាយើងឥឡូវ។ ពេលទៅដល់ផ្សារអន្លង់វិល នៅបាត់ដំបង ស្រាប់តែខ្ញុំ ធុំក្លិនឈ្ងុយម្ហូបគុយទាវ បបរអញ្ចឹង ស្រាប់តែខ្ញុំនឹកឃើញដល់ការយល់សប្តិ ដែលអាហ៊ុយ ពួកម៉ាកខ្ញុំ និងប្រពន្ធរបស់លោក យូ គឹមទុយ ប្រាប់ខ្ញុំថា ខ្ញុំជិតបានញ៉ាំគុយទាវហើយ។ ក្នុងយល់សប្តិនៅត្រជាក់ចិត្ត ពួកយើងក៏អត់ចូល ផ្សារទេ។ យើងខំស្រូតរូតដំណើរទៅទៀត។ យើងក៏ដើរទៅដល់ម្តុំភ្នំតូច ភ្នំធំ។ ពេលហ្នឹងភ្លៀង។ យើងចូលជ្រកនៅក្រោមផ្ទះមួយអត់ជញ្ជាំងនៅសល់តែដំបូលទេ។ ពេលហ្នឹងស្រាប់តែមានអ្នកមកជ្រកភ្លៀងដែរ។ គេនិយាយថា ឥឡូវពួកទាហានយួនឱ្យចិនចេញទៅទល់ដែនច្រើនណាស់។ ដូច្នេះចិនលក់អង្ករដើម្បីទិញមាស ហើយមាសឡើងថ្លៃ។ ពេលមុនចេញដំណើរទាំងភ្លៀងពីកន្លែងក្រោមផ្ទះដែលយើងជ្រកនៅជិតភ្នំតូចភ្នំធំ ខ្ញុំឱ្យកុមារីពីរនាក់ទៅសុំស្ករ។ ម្នាក់បានពីបីស្លាបព្រាយកមកហូប។

រាសី៖ កាលហ្នឹងមានចាយលុយឬនៅ?

សារីមេះ ចាំ! ពួកយើងមិនដឹងជាចាយអីផងចាំ! អ្នកហ្នឹងគាត់ស្អាតណាស់ដូចអ្នកម្នាង ម៉ូនិច អញ្ចឹង។ គាត់មានរទេះគោធំ និងមានគោពីរមានបួក ហើយកូន គាត់មួយហ្នឹង។ កូនប្រុសម្នាក់អាយុប្រហែល១៦ឆ្នាំ ការប្រពន្ធ អាយុ១៦ឆ្នាំដូចគ្នា។ ប្រពន្ធទើបទម្ងន់៤-៥ខែ។ កាលពីសម័យខ្មែរក្រហម អ្នកហ្នឹងមានធុងសម្រាប់ដាក់ថ្នាំបាញ់ពន្លត់ភ្លើង ដាក់ស្ករពេញ។ យើងដឹងថាគាត់ជាប្រពន្ធទាហាននៅប៉ៃលិន។ គាត់ថាគាត់បានចេញទៅស្រុកសៀមពេលដែលខ្មែរក្រហមយកស្រុកភ្លាមហ្នឹង តែគាត់មិនចេះនៅ។ គាត់ក៏បកមកវិញ ហើយគាត់ប្រាប់ខ្ញុំថា អាប៉ុក ដែលខ្ញុំស្គាល់អ្នកលក់ដេប៉ូហ្វាម៉ាស៊ី (ឱសថស្ថានរង) នៅប៉ៃលិន។ ប្អូនម្ចាស់ហាង ហៃ នារី ហ្វាម៉ាស៊ីបន្ទាយស្រីនៅភ្នំពេញបានចេញទៅស្រុកបារាំងហើយ។ ខ្ញុំក៏បបួលអ្នកហ្នឹងថា ម៉េចចង់ទៅស្រុកបារាំងទេយើង? ទៅជាមួយគ្នា។  គាត់ថាគាត់នឹងទៅធ្វើស្រែនៅម្តុំពួក។ ខ្ញុំគិតថាអ្នកនេះប្រហែលប្រពន្ធកម្មាភិបាលខ្មែរក្រហមហើយចាំ! បានមានរទេះគោ ហើយមានគោមានបួកអញ្ចឹងចាំ! ស្រាប់តែនៅឆ្នាំ១៩៨២ ពេលខ្ញុំទៅនៅមីនីសូតា ពេលបុណ្យរំលឹកគុណ (Thanksgiving) ស្រាប់តែខ្ញុំជួបអ្នកហ្នឹង។ គាត់ទើបមកដល់។ គាត់រវល់តែសៀមយកទៅទម្លាក់ចោលនៅភ្នំដងរែក។ ខ្ញុំក៏ស្គាល់ឈ្មោះអ្នកហ្នឹង។ គាត់ឈ្មោះ អ្នក សុក សុន។ អ្នកសុក សុន ថារទេះគោធំដែលគាត់មានហ្នឹងគឺខ្មែរក្រហមរត់ចោល។

ពួកខ្ញុំខំធ្វើដំណើរទាំងភ្លៀងតម្រង់ទៅស្វាយស៊ីសុផុន។ ក្នុងពេលដែលយើងដើរ យើងបានជួបឡានទាហានយួន។ ឡានឃ្លប់បិទជិត។ ដឹកផវ៉ាន់គគ្រឹកគគ្រេង។ តាមផ្លូវយើងក៏បានជួបទាហានយួន ជាពិសេសចូលទៅងូតទឹក។ ពួកទាហានយួនជាពិសេសចូលចិត្តស្រីៗដែលសម្បុរជ្រះស។ ហើយទាហានយួនច្រើនតែចេះច្រៀងរាំវង់ខ្មែរយើងពីរបីបទ  ដូចជាបទផ្កាយលើមេឃជាដើម។ ថ្ងៃមួយពួកទាហានយួនមកប្រាប់ សួន ថា នាង សៀន ជាខ្មែរក្រហម ព្រោះសៀន បានជជែករឿងអីជាមួយទាហានយួន ហើយ សួន ក៏ខំជួយការពារសៀន ថា គាត់អត់ចេះនយោបាយអីទេ។ គាត់ចេះតែនិយាយទៅ ហើយពួកយើងចេញពីហ្នឹងមក។ គាត់ខំប្រាប់សៀន ថា ឱ្យ

ប្រយ័ត្នមាត់កពីព្រោះយើងមិនចង់មានរឿងជាមួយទាហានយួននៅតាមផ្លូវ ពេលដែលយើងរៀបដំណើរចេញទៅទល់ដែនទេ។ សុំជម្រាបថា សៀន ហ្នឹងគាត់ស្មោះស្ម័គ្រជាមួយពួក អៀង សារី ប៉ុល ពត ណាស់ ពីព្រោះពេលខ្លះគាត់ដូចជាចង់ទៅឡើងភ្នំតាមពួកអស់ហ្នឹង។ ពេលដែលយើងដើរពីភ្នំធំភ្នំតូចតម្រង់ទៅស៊ីសុផុន ខ្ញុំចេះតែខំសួរគេតាមផ្លូវក្រែងមានអ្នកណាគេស្គាល់គ្រួសារខ្ញុំ បងប្អូនខ្ញុំ ហើយខ្ញុំខំស្តាប់ឮសូរអ្នកណាគេបន់ស្រន់អញ្ចឹង ខ្ញុំខំស្តាប់ទៅក្រែងលោថាជួបអ្នកស្រុក ដែលមកពីម្ដុំភូមិខ្ញុំ។ ស្រាប់តែខ្ញុំឮសូរម្នាក់នោះគាត់បន់ថាលោកពូ លោកភា លោកតាដំបងដែក លោកយាយទេពអង្គធំ។ ខ្ញុំទៅសួរគាត់ថា អ្នកនៅស្រុកណា។ ហើយគាត់ប្រាប់ថា គាត់នៅម្ដុំជ្រោយអំពិល។ ខ្ញុំក៏សួរគាត់ថា មានស្គាល់សាច់ញាតិបងប្អូនខ្ញុំទេ? ដូចជាគ្រួសារ ទីម ភួង គ្រួសារ ណោ មុិច ម្ដុំជ្រោយអំពិល។ អ្នកហ្នឹងគាត់ស្គាល់។ ខ្ញុំក៏សួរគាត់ថាតើពួកម្ដុំខាងភូមិក្បាលកោះគេជម្លៀសទៅណាហើយ។ គាត់ដឹងថាទៅពោធិ៍សាត់ ហើយគាត់ប្រាប់ខ្ញុំថា អ្នកឯងកុំសង្ឃឹមបើកូនអ្នកឯងនៅតូចនោះកុំសង្ឃឹមថារស់ ក្រែងតែមានទេវតាចុះពីលើមេឃមកជួយសង្គ្រោះទើបរស់បាន។ មកដល់មង្គលបុរី ពេលដែលឆ្លងស្ពានមង្គលបុរីចេញពីម្ដុំប៉ុស្តិ៍ខ្សែលួសទៅហ្នឹង ស្រាប់តែខ្ញុំលន្លង់លន្លោចឮសូរភ្លេងនៅក្នុងខួរក្បាលខ្ញុំឡើងទ្រហឹង។ ហើយស្រាប់តែហូរទឹកភ្នែកមិនដឹងខ្លួន។ ទីកន្លែងនេះហើយដែលខ្ញុំហើយនឹងប្ដីខ្ញុំបានស្គាល់គ្នាដំបូងនៅម្ដុំពេទ្យជប៉ុននៅមង្គលបុរីនោះ។ ខ្ញុំឆ្ងល់ពេលដែលខ្ញុំឮសូរភ្លេងរងំនៅក្នុងក្បាលខ្ញុំអញ្ចឹង ខ្ញុំគិតថា ប្រហែលជាអ្នកសរសេរភ្លេងបែបឮសូរភ្លេងអញ្ចឹងហើយបានជាគេសរសេរភ្លេងកើត។ ខ្ញុំបន្តដំណើរទៅទាំងទឹកភ្នែកពេញភ្នែករហូតដល់ស៊ីសុផុន។ យើងក៏ទៅដល់ស៊ីសុផុន។ ខ្ញុំទៅរកផ្ទះលោក តាទុយ ហើយលោកយាយយាមផ្ទះដែលខ្ញុំធ្លាប់ស្នាក់នៅជាមួយកាលខ្ញុំធ្វើ គ្រូបង្រៀន។ ពេលខ្ញុំនៅក្រមុំពីរឆ្នាំនៅហ្នឹង។ គាត់ថៅកែស្រា។ ហើយទៅដល់ ឃើញផ្ទះគាត់ដែលនៅតាមផ្លូវកាច់ជ្រុងពីអនុវិទ្យាល័យស៊ីសុផុន ហើយនឹងផ្លូវសៀមរាប។ យួនយកធ្វើទីស្នាក់ការ។ ឃើញទាហានយួនយាម ខ្ញុំក៏ទៅសួរថាម្ចាស់ផ្ទះទៅណា? គេចង្អុលទៅផ្ទះមួយតូចនៅក្រោយផ្ទះហ្នឹង។ ខ្ញុំក៏ទៅជួបលោកយាយដែលថា ខ្ញុំធ្លាប់នៅ

ជាមួយ។ ខ្ញុំយកអីវ៉ាន់ទៅឱ្យគាត់គឺឱ្យកាំបិតតាំងតោមួយដែលខ្ញុំស្ពាយតាំងពីស្រុកបារាំងទៅ និងផាហ៊ុម ហើយនឹងឱ្យថ្នាំវីតាមីន ថ្នាំគ្រុនចាញ់ ថ្នាំច្រើនណាស់ដែលខ្ញុំនៅសល់។ រួចខ្ញុំក៏បបួលគាត់ឱ្យថៅទៅជាមួយខ្ញុំដូចស្រីធំ ហើយនឹងប៉ូឡាយចង់ចេញទៅស្រុកបារាំង។ ខ្ញុំអាចជួយយកទៅបាន។ រួចគាត់ក៏មិនបានឱ្យថៅមកជាមួយខ្ញុំ។ ខ្ញុំក៏លាគាត់មក។ ខ្ញុំផ្តាំថា បើឃើញម្តាយខ្ញុំមកឱ្យជួយប្រាប់ថា ខ្ញុំត្រឡប់ទៅស្រុកបារាំងវិញហើយ។ ខ្ញុំនឹកស្រណោះគាត់ដែលថា កាលខ្ញុំធ្លាប់នៅជាមួយគាត់ ពីខ្ញុំទៅបង្រៀនដំបូងនៅស៊ីសុផុន ពេលខ្ញុំបើកវិទ្យុស្តាប់ចូលបទសៀម គាត់ហាមគឺថាមិនឱ្យបើកស្តាប់បទសៀមទេព្រោះថាវារំឭកដល់ការឈឺចាប់នៅពេលដែលសៀមយកស្រុកខ្មែរសម័យឆ្នាំ៤០។ សៀមបានមកយកដីគាត់ទៅពុះចែកតូចៗឱ្យអ្នកស្រុក ហើយគាត់ថានាំតែក្រទាំងអស់គ្នា។ ដល់ឥឡូវស្រាប់តែ ខ្ញុំឃើញយួនយកផ្ទះគាត់នៅទៀត។ គាត់ទៅសង់ខ្ទមតូចមួយ។ ដូច្នេះខ្ញុំសង្វេគនឹកអាណិតគាត់។ ពេលហ្នឹង ខ្ញុំក៏ទៅសម្រាកនៅផ្លូវរទេះភ្លើង។ សុំក្រោមផ្ទះគេដេក។ គេមិនឱ្យយើងដេក។ ម្ល៉ោះហើយយើងទាំងអស់គ្នាហ្នឹងលើផ្លូវទេះភ្លើង។ ចាំ! ក្តៅស្រួលណាស់លើផ្លូវរទេះភ្លើង។ រួចទៅពួកខ្ញុំមកដល់ស៊ីសុផុន។ និយាយពីខ្ញុំលក់អីវ៉ាន់ខ្ញុំ។ ខ្ញុំលក់អាវទ្រនាប់ ខោស្លីបដែលខ្ញុំទុកយកពីស្រុកបារាំងទៅចាំ! ហើយនឹងលក់សំពត់ម៉ុងតេហ្គុយមួយបានប្រាំបួនជី។ ខ្ញុំជួបកូនសិស្សខ្ញុំដែលខ្ញុំធ្លាប់បង្រៀននៅហ្នឹង គេមកហៅខ្ញុំអ្នកគ្រូៗ។ ខ្ញុំខ្សឹបថា កុំឱ្យហៅអ្នកគ្រូ។ ខ្ញុំលក់អីវ៉ាន់ហើយក៏បានដើម។ ប្រាំបួនជីច្រើនដែរពេលហ្នឹង។ នៅផ្សារស៊ីសុផុន ខ្ញុំជួបប្រុសម្នាក់ជាប្អូនរបស់ម្ចាស់ហាងហ្វាម៉ាស៊ី បន្ទាយស្រីឈ្មោះសុាំង ហ្នឹង។ គាត់បានប្រាប់ខ្ញុំថា ហៃ នារីបងស្រីគាត់មួយគ្រួសារស្លាប់អស់ហើយទាំងប្តីឈ្មោះ សាមិត ប៉េងងួន ហើយនឹងកូនប្រុសគាត់ទាំងអស់ព្រោះខ្មែរក្រហមយកទៅវាយចោលអស់មួយរទេះពេលដែលយួនជិតចូល។ លោក ប៉េងងួន អរ។ គាត់ថាគាត់នឹងទៅភ្នំពេញវិញ មកយកហ្វាម៉ាស៊ីគាត់។

យើងក៏ចេញដំណើរទៅអូរជ្រៅ។ តាមផ្លូវនិយាយ ពីពួកដែលធ្វើការជាមួយយួន។ គេឃាត់ខ្ញុំ។ គេថាអ្នកឯងសម្បុរត្នោតអញ្ចឹងទៅណាដែរ? ស្រាប់តែខ្ញុំថា យី! ខ្ញុំនៃ!

ខ្មែរក្រហមកំពុងរកចាប់ខ្ញុំ។ បើខ្ញុំនៅក៏មិនស្រួល។ បើខ្ញុំទៅអាចងាប់អាចរស់។ ខ្ញុំសប្បាយចិត្តនឹងបានរត់ចេញ។ ខ្ញុំក៏មានម្ជុលចាក់កន្ទ្រេង និងនាឡិការកំបាក់មួយក្នុងហោប៉ៅខ្ញុំ។ ខ្ញុំបោះឱ្យពូហ្នឹងទៅ។ ខ្ញុំថា ពូឯងយកទុកឱ្យកូនប្រពន្ធចាក់អីៗទៅ។ នាឡិការនេះយកទៅដាក់ខ្សែទៅពាក់បានហើយ។

រាសីៈ យើងបន្តអំពីកាលដែលអ្នកស្រីធ្វើដំណើរទៅជំរំជនភៀសខ្លួននៅក្នុង ប្រទេសថៃ ថាតើអ្នកស្រីមានជួបនឹងអ្វីទៀតនៅក្នុងការធ្វើដំណើរទៅមុខនេះ?

សារីមៈ អូ! ខ្ញុំសូមជម្រាបរឿងតាមផ្លូវហ្នឹង។ មានអ្នកខ្លះនិយាយថា ទៅដល់ស្រុកសៀម ពួកចោរស្លៀកពាក់ខោអាវក្រហម ហើយនាំយើងចូលក្នុងបន្ទប់មួយ ហើយវាឱ្យប្តូរខោអាវទាំងអស់ ផ្លាស់ស្លៀកខោអាវវាវិញព្រោះវាចង់បានអីវ៉ាន់យើង។ ខ្ញុំឮសូរអញ្ចឹង។ ខ្ញុំដូចមិនជឿ។ មកដល់គោកនិម្មិត មាន មនុស្សច្រើនណាស់ដូចហែរផ្កាអញ្ចឹង។

រាសីៈ បាទ! គេនាំគ្នាច្រើនហ្នឹងគេនាំគ្នាធ្វើដំណើរទៅដែរ?

សារីមៈ ចាំ! ព្រោះអ្នកមួយនោះគាត់និយាយថា យួនឱ្យចេញ។ អញ្ចឹងបានជាពួកស្វ័យត្រាណធ្វើការជាមួយយួនឃាត់ខ្ញុំថា អ្នកឯងសម្បុរត្នោតបានន័យថា ខ្ញុំមិនមែនសដូចចិនម៉េចក៏ទៅណា។ ពេលខ្ញុំនៅក្នុងហ្វូងគេស្រាប់តែសួនទៅរកជួលមេខ្យល់ឯណាមកឱ្យនាំពួកយើងទៅ។ មនុស្សប្រុសពីរនាក់សុទ្ធតែកាំបិតផ្គាក់។ ខ្ញុំឃើញអញ្ចឹងខ្ញុំខ្លាច។ ឥឡូវនេះខ្ញុំនិយាយយកស្រួល ខ្ញុំថា អូ! ពូ ខ្ញុំអត់ប្រញាប់ទេ។ ចង់ចាំក្រែងឃើញបងប្អូនមកទៀត។ យើងក៏ឱ្យគាត់បន្តិចបន្តួចទៅកុំឱ្យគាត់ខឹង។ ខ្ញុំប្រាប់ថា គាត់ម្នាក់ពីរនាក់ ហើយយើងស្រីៗ និងមនុស្សដែលដើរជាមួយយើងស្មានតែគេជួយយើង។  ខ្លាចតាហ្នឹងចាប់រំលោភយើង។ យើងចាំដើរជាមួយហ្វូងមនុស្សច្រើន។ គេទៅយើងក៏ទៅជាមួយគេទៅ ពេលណាគេរៃមាសអី យើងចេះតែមានអីហុចឱ្យគេអញ្ចឹងទៅ។ ពេលព្រលឹមស្រាងៗមេខ្យល់ថា យើងត្រូវចេញដំណើរ។ ខ្ញុំពេលហ្នឹងដើបស្រណោះខ្លួន ហើយស្រណោះស្រុកខ្មែរយើង។  សឹងថាស្រែកយំ។ មិនគួរណាស្រុកយើងមានយួនមកលុកលុយអញ្ចឹង។ ហើយ ប្រហែលទៅជា

កុម្មុយនីស្តឥណ្ឌូចិនដូចពួកគេចេះតែនិយាយនៅបឹងត្របែកមានយួនត្រួតក៏មិនដឹង ឬក៏យ៉ាងម៉េច? ខ្ញុំសឹងតែបែកទ្រូង ហើយសឹងចេញដំណើរមិនរួច។ ស្រាប់តែខ្ញុំយក មាសឱ្យមេខ្យល់ ខ្ញុំនឹកស្រណោះដល់យាយ យ៉ែម ដែលឈ្នួលរបស់លោក សារិន ឆាក។ គាត់ជម្រុះមាសរបស់គាត់នៅបឹងត្របែកឱ្យខ្មែរក្រហមអស់រលីងពីខ្លួន។ ឥឡូវយាយ យ៉ែម មិនដឹងទៅជាយ៉ាងម៉េចទេ។ និយាយពីកុមារដែលដើរជាមួយ ខ្ញុំពីរនាក់ ដល់យើងប្រាប់ថា ឥឡូវយើងធ្វើដំណើរដើម្បីទៅស្រុកបារាំង។ ដើរលឿន បាត់ចោលយើងទៀត។ គេអរដែលគេនឹងបានទៅស្រុកបារាំងវិញហើយ។ ទៅ ប្រណាំងគ្នា។ ដើរលឿនបាត់រហូតដល់ខ្ញុំភ័យខ្លាចបាត់កុមារីពីរនាក់ហ្នឹងនោះ។ ខ្ញុំចេះតែហៅថា ចាំរីចាំអ៊ំខ្លាចវង្វេងបាត់។ មកដល់តាមផ្លូវចោរ សៀមវាប្លន់។ ខ្ញុំឃើញតាំងពីបាយៗដែលនៅក្នុងឆ្នាំងមួយផែនអញ្ចឹង។ ឃើញជ្រុះតាមផ្លូវរកេតរកូត ឃើញអាវទ្រនាប់ស្រីព្យួរភ្ជាប់មែកឈើ អ៊្ហយ! ពេលហ្នឹង ខ្ញុំដូចជាស្ញើបណាស់ ព្រោះ វាយកសូម្បីតែបាយក្នុងឆ្នាំងយើងដែលយើងដាំក៏វាយកបើកមើលដែរ ខ្លាចយើង ដាក់មាសពេជ្រក្នុងហ្នឹង។ រួចខ្ញុំនិយាយឱ្យអស់ ខ្ញុំពេលដើរហ្នឹងគឺថាអាពួក ចោរសៀមវាទៅខ្វេះស្រីៗ។

ពាសី៖ បាទ! វារកមាសរកអី?

សារីមេះ ចាំ! រួចខ្ញុំអត់ហ៊ានស្លៀកខោទ្រនាប់ទេ។ ខ្ញុំស្លៀកតែខោធម្មតា ខ្ញុំថាកុំឱ្យវាមកខ្វេះអី យើងនោះចាំ!

ពាសី៖ តាមផ្លូវទៅហ្នឹង?

សារីមេះ ចាំ! តាមផ្លូវមនុស្សដើរទាំងហ្វូងអញ្ចឹង ស្រាប់តែដល់កន្លែងមួយ ឃើញវា ភ្ជង់មក។ វាស្រែកថាអង្គុយៗ។

ពាសី៖ ពួកណា ទាហាន?

សារីមេះ ចាំ! ដល់ឮសូរស្រែកអង្គុយៗអញ្ចឹងទៅ យើងក៏ដាក់គូទអង្គុយ។ ហើយយើងមើល ទៅឃើញៗចោរហ្នឹងដូចខ្មែរក្រហមអញ្ចឹងស្លៀកពាក់ខោអាវខ្មៅ ប៉ុន្តែគ្រាន់តែខោ ហ្នឹងខ្លី។ ខ្ញុំខំមើលស្បែកជើងចោរ មិនមែនស្បែកជើងកង់ឡានទេចាំ! ដល់ស្តាប់

ពាក្យអង្គុយៗទៅ សំឡេងដូចចោរសៀម។ និយាយខ្មែរមិនសូវច្បាស់។ ដល់ភ្ជង់កាំភ្លើងហើយ វាចុចមនុស្សម្នាក់ៗថាឱ្យចេញ ម្នាក់នេះចេញ វាទៅឆែករូចទៅយើងភ័យណាស់ឃើញវាហៅមនុស្សចេញទៅខ្លាចវាចាប់រំលោភមនុស្សមុខយើង។ ដល់វាមកឆែក ខ្ញុំជូតក្បាលខ្ញុំ។ ខ្ញុំដោះហើយ ខ្ញុំហុចឱ្យវាទាំងអស់ថាប្រាក់ខ្ទង ប្រាក់កាក់សាច់ប្រាក់ ហើយនឹងឈើបកក្លុកដែលបង វ៉ែនឱ្យខ្ញុំ។ ខ្ញុំឱ្យទាំងអស់ទៅកុំឱ្យវាឆែកស្ទាបខ្លួនប្រាណយើង។

រាសីៈ បាទ! ចោរសៀមប្លន់ហ្នឹង គេប្លន់យើងទើបចេញពីខ្មែរក្រហមមកអញ្ចឹង ពីជំនាន់ប៉ុល ពត អញ្ចឹងហើយយើងមានទ្រព្យសម្បត្តិអីដែរ?

សារីមៈ ចាំ! ពេលហ្នឹងចោរសៀមដូចគាស់កំណាប់អញ្ចឹងមាស ពេជ្រច្រើនណាស់។

រាសីៈ បាទ! ប៉ុន្តែមានវាយធ្វើបាបមានអីទេ?

សារីមៈ ចាំ! អត់ទេ។ យើងអត់ឃើញទេ។

រាសីៈ បាទ! ហើយនៅពេលហ្នឹងអត់មានខ្លាចជាន់មីន ជាន់អីទេ?

សារីមៈ ចាំ! អ្នកនាំយើងដើរស្គាល់ផ្លូវចាំ! យើងដើរ តែតាមគេ។ យើងអត់មានគ្រោះថ្នាក់ជាន់មីនទេ។ មែនទែន មានអ្នកខ្លះបោះអង្ករ បោះប្រហុកចោល។ ពួកខ្ញុំនាំគ្នារើសស្តាយបានប៉ុន្មានយកប៉ុណ្ណឹងព្រោះយើងមិនចង់ទៅអង្គុយសុំអង្ករចែកនៅជំរំយើងទេ។

រាសីៈ បាទ! ហេតុអីបានគេនាំគ្នាចោលអង្ករអញ្ចឹងបាទ?

សារីមៈ ចាំ! អ្នកខ្លះគិតខ្លី។ គាត់បោះអង្ករនៅដៃគាត់ចោលចាំទៅអង្គុយសុំអង្ករម៉ាស៊ីនគេចែកឱ្យ! កន្លែងហ្នឹងជិតដល់ហើយ។ ខ្ញុំលស្តាយ។ ដឹងថាគេនឹងចែកអង្ករ។

រាសីៈ បាទ! ហើយអញ្ចឹងធ្វើដំណើរប៉ុន្មានម៉ោងតទៅទៀតបានទៅដល់ទល់ដែនហ្នឹង?

សារីមៈ ចាំ! ពួកយើងទៅដល់កន្លែងដីសៀមនៅប្រហែលម៉ោង២រសៀល។ យើង ចេញពីព្រលឹមទៅ។ ប្រហែលពាក់កណ្តាលខែឧសភា។ ហើយខ្ញុំគ្រាន់តែ ទៅដល់ភ្លាម ខ្ញុំ

សម្លឹងរកមើលពួកបរទេស។ ខ្ញុំចង់ជួបអ្នកកាសែតដើម្បីខ្ញុំបញ្ជូនដំណឹងមកប្អូនប្រុសខ្ញុំនៅស្រុកអាមេរិក។

រាសីៈ បាទ! អញ្ចឹងដល់កន្លែងហ្នឹងដល់ជំរំ?

សារីមៈ កន្លែងហ្នឹងគេហៅណងចាន់។ អត់មានជំរំអីទេ។ ដល់ពួកយើងទៅដល់អ្នកខ្លះបោះសំពត់កៅស៊ូជ្រក។ យើងក៏ធ្វើតាមគេឯងទៅ។ ខ្ញុំឃើញមនុស្សដូចបារាំងម្នាក់អញ្ចឹងដើរមក។ ខ្ញុំទៅនិយាយរក ហើយសួរគាត់ថា ខ្ញុំចង់បានក្រដាសសរសេរសំបុត្រហើយស្រោមសំបុត្របារាំង។ គាត់ថាគាត់មិនមែនបារាំងទេ។ គាត់ធ្វើការនៅស្ថានទូតអាមេរិក។ គាត់ប្រាប់ថា គាត់ឈ្មោះ អ៊ែរិច កូស៊ើ។ ពេលហ្នឹងខ្ញុំហៅជាបារាំង រីហ្សា កូសេ។

រាសីៈ បាទ! អញ្ចឹងមានតំណាងខាងអាមេរិកគេទៅ?

សារីមៈ ចាំ! រួចទៅខ្ញុំប្រាប់លោក រីហ្សា កូសេ ថាខ្ញុំធ្វើគ្រូ។ ខ្ញុំមកពីស្រុកបារាំង។ មកពេលខ្មែរក្រហមយកស្រុកបានហ្នឹងព្រោះខ្ញុំចង់មកជួបកូនខ្ញុំ។ កូនខ្ញុំនៅ ស្រុកខ្មែរទាំងអស់។ រួចទៅគាត់សួរខ្ញុំថា អ្នកឯងធ្វើគ្រូស្គាល់លោក ឃួច ឈីវទេ? គ្រាន់តែឮឈ្មោះហ្នឹងលោក រីស៊ើត កូសេ គាត់ក៏ចង្អុលទៅលោក ឃួច ឈីវ។ រួចទៅគាត់ប្រាប់ខ្ញុំថា អញ្ចឹងទៅប្រាប់លោក ឃួច ឈីវ ទៅថាចង់បានស្រោមសំបុត្រ ហើយនឹងក្រដាសសរសេរសំបុត្រ។ លោក រីហ្សា កូសេ ថាលោក ឃួច ឈីវ ជាអ្នកជំនួយការរបស់គាត់។ ខ្ញុំចាំយូរពេកមិនឃើញគេយកក្រដាសស្រោមសំបុត្រមកឱ្យខ្ញុំ។ ខ្ញុំក៏ទៅជួបលោក កូសេ ម្តងទៀត។ រួចទៅគាត់ក៏ទៅយកក្រដាសសរសេរសំបុត្រហើយស្រោមសំបុត្រមកឱ្យខ្ញុំ ហើយខ្ញុំសរសេរសំបុត្រហើយ គាត់ដាក់ការខ្ទង់សំបុត្រខ្ញុំ។ ផ្ញើមកកន្លែងដែលខ្ញុំស្គាល់នៅស្រុកបារាំង។

រាសីៈ ហើយផ្ញើ អ្នកស្រីប្រគល់ឱ្យគាត់?

សារីមៈ ចាំ! ខ្ញុំឱ្យគាត់ទៅ។ ហើយយើងក៏បោះជំរំនៅណងចាន់ទៅ។ ទៅដល់ ណងចាន់មានអ្នកខ្លះហ្នឹង។ អ៊ូយ! គាត់ខំផ្លាស់សំពត់ ហើយស្លៀកសំពត់ ហូល។ ខ្ញុំមើលទៅឃើញវាអាក្រក់មើលដល់ហើយ។

រាសីៈ ព្រោះរស់នៅក្នុងព្រៃ?

សារីមៈ ចាំ! រស់នៅក្នុងព្រៃ។

រាសីៈ បាទ! ហើយអញ្ចឹងហូបចុកយ៉ាងម៉េចដែរនៅក្នុងជំរំហ្នឹង?

សារីមៈ ចាំ! ខ្ញុំមានអង្ករដែលខ្ញុំរើសបាន ហើយនឹងអង្ករដែលខ្លួនមាន។ ចេះតែដាំបាយ ហូបអញ្ចឹងទៅ ហើយព្រលឹមឡើងហ្នឹងពួកស្រីៗដើរបោចស្លឹកបាស ហើយនឹង រើសខ្យងតាមវាលស្រែ ហើយពួកប្រុសៗដែលដើរជាមួយខ្ញុំ ឱ្យគាត់នៅដាំបាយ។ មានស្រះមួយនៅជិតហ្នឹង។ ខ្ញុំនៅសល់សន្ទូចខ្ញុំពីរបី។ ខ្ញុំដាក់នៅហៅចៅខ្ញុំជាប់។ ខ្ញុំឱ្យពួកប្រុសៗដែលដើរជាមួយខ្ញុំហ្នឹងយកសន្ទូចហ្នឹងទៅបង្កៃត្រី ហើយបានត្រីមក យើងអត់ហ៊ានហូបទេ។ យើងយកទៅលក់បានលុយយកទិញស្ករគ្រាប់ឱ្យកុមារពីរនាក់ដែលដើរជាមួយយើងហ្នឹងលក់។

រាសីៈ លក់ជាលុយថៃ?

សារីមៈ ចាំ! លក់ជាលុយថៃព្រោះយើងមិនដឹងថានៅយូរប៉ុណ្ណាព្រោះយើងអត់មានលុយ។ យើងអស់មាសហើយ។

រាសីៈ បាទ! ហើយអញ្ចឹងនៅកន្លែងណាងចាន់ហ្នឹងមានគេចាត់ចែងការត្រឹមត្រូវដែរទេ?

សារីមៈ ចាំ! នៅហ្នឹងមានគេអ្នកចាត់ចែង។ ថ្ងៃស្អែកឡើងពួកខ្ញុំទៅកត់ឈ្មោះ។ ហើយខ្ញុំក៏កត់ឈ្មោះខ្លួនខ្ញុំដាច់តែម្នាក់ឯង។ ហើយកូនក្មេងស្រីដែលដើរជាមួយខ្ញុំហ្នឹងក៏ខ្ញុំកត់ឈ្មោះឱ្យគេដាច់ៗពីគ្នាព្រោះខ្ញុំមិនហ៊ានយកកូនគេមកតាមខ្ញុំទេចាំ ព្រោះខ្លាចឪពុកម្ដាយគេតាមទារ។ ខ្ញុំពិបាកបញ្ជូន។

រាសីៈ បាទ! អញ្ចឹងអ្នកទាំងអស់គ្នានៅពេលហ្នឹងគឺគោលបំណងតែមួយគឺចេញទៅប្រទេសទី៣ អញ្ចឹង?

សារីមៈ ចាំ!។

រាសីៈ បាទ! ហើយពេលយើងចុះឈ្មោះអញ្ចឹង យើងមានបញ្ជាក់ថាគោលបំណងយើង ចង់ទៅស្រុកណាៗដែរ?

សារីមៈ ចាំ! ក្នុងក្រដាសកត់ឈ្មោះហ្នឹង ខ្ញុំបញ្ជាក់ថា ខ្ញុំចង់ទៅអឺរ៉ុប អូស្ត្រាលី កាណាដា និង ស្រុកអាមេរិក។ នៅណាងចាន់ហ្នឹងខ្ញុំចេះតែខំដើររកអាហ៊ុយ ប្រពន្ធលោក យូ គឹមទុយ ពីព្រោះខ្ញុំដឹងថា អាហ៊ុយ ហ្នឹងមានសំបុត្រហោះ ហើយដែលប្ដីនៅស្រុក អាមេរិកហ្នឹងទិញឱ្យតាំងពីពេលខ្ញុំកំពុងតែនៅស្រុកបារាំង តែអាហ៊ុយហ្នឹងចេញមិន ទាន់ខ្មែរក្រហម មុនខ្មែរក្រហមចូល។ ខ្ញុំយល់ថា អញ្ចឹងអាហ៊ុយ បើនៅរស់មុខតែ មកដល់ជំរំណងចាន់ដូចខ្ញុំដែរ។ ហើយបើមិនមកមានតែស្លាប់ ឬក៏ខ្មែរក្រហមកៀរ ឡើងភ្នំជាមួយពួកខ្មែរក្រហម។

រាសី៖ ធ្វើម៉េចបានដឹងថា គេទទួលជនភៀសខ្លួនចេញពេលហ្នឹង?

សារីមៈ ចាំ! យើងរៀបមកហ្នឹង យើងមានបំណងថា អ្នកដែលមានអ្នកទៅទទួលយើងយក មក ជាពិសេសដូចខ្ញុំអញ្ចឹងតា ពែរហ្ស៊ីល (Pere Zilles) (អាចារ្យគ្រឹស្តសាសានា) ដែលនៅស្រុកបារាំង គាត់សន្យាថា បើខ្ញុំហ្នឹងរត់មកវិញគាត់នឹងទៅទទួល។ ហើយ នៅណាងចាន់ហ្នឹងពួកខ្ញុំមិនសូវហ៊ានដើរហោតរហូតទៅឱ្យពួកសៀមឃើញទេ ពីព្រោះខ្លាចមានរឿងដូចថាគេមកតាមស្គាល់យើង។ តែថ្ងៃមួយ ខ្ញុំទៅរកស្រោម សំបុត្រពីកន្លែងគេកត់ឈ្មោះមកសរសេរសំបុត្រ។ ខ្ញុំអត់ចេះសៀមទេ ខ្ញុំនិយាយធ្វើ ដៃជើងហើយ ខ្ញុំគ្រាន់តែប្រើពាក្យថា សារ៉ង ចុតហ្មាយ។ ខ្ញុំក៏បានស្រោមសំបុត្រ ហើយនឹងក្រដាសសរសេរសំបុត្រមក។ សៀមម្នាក់ចេះតែសើចមើលខ្ញុំ។ ស្រាប់តែ យប់ហ្នឹងមានម្នាក់មកស្ទាបក្បាលខ្ញុំនៅពេលយប់។ ក្បាលខ្ញុំនៅក្នុងអង្រឹង។ ខ្ញុំ ដេក។ ខ្ញុំមើលមុខស្ទង់ទៅ ខ្ញុំឃើញមនុស្សមាឌធំ ដូចខ្ញុំឃើញពីថ្ងៃ។ អូ! ពេលហ្នឹង និយាយពីខ្ញុំបន់ដូនបន់តា។ ខ្លួនខ្ញុំរឹងដូចថ្មអញ្ចឹង នៅក្នុងអង្រឹងហ្នឹង។ ហើយខ្ញុំ ខំបន់។ ដល់មួយសន្ទុះ តាហ្នឹងចេញទៅចាំ!។

រាសី៖ បាទ! អញ្ចឹងសន្តិសុខពេលយប់ព្រលប់យ៉ាងម៉េចដែរ?

សារីមៈ ចាំ! មានក្មេងស្រីៗខ្លះព្រួយចិត្តណាស់។ យំថាមកដល់កន្លែងនេះហើយ រួចខ្លួន ហើយ ប៉ុន្តែមានអាពួកហ្នឹងវាចាប់រំលោភអញ្ចឹងទៅក៏យើងនាំគ្នាថាអញ្ចឹង យើងធ្វើ

ម៉េចឱ្យខ្លួនយើងឃើញអាក្រក់នោះ។ សក់អីរយើករយាកអញ្ចឹងទៅ ហើយមុខស្រមេងស្រមូញកុំឱ្យគេចាប់អារម្មណ៍នោះ។

រាសី៖ បាទ! ចុះពួកបរទេសដូចខាងតំណាងទូតអាមេរិក គេមកទេពេលថ្ងៃ ពេលយប់គេទៅវិញអស់ហើយឬយ៉ាងម៉េច?

សារីមេះ ចាំ! យើងទៅដល់ដំបូងឃើញគេមកអញ្ចឹង ប៉ុន្តែក្រោយមកយើងអត់ឃើញមានអ្នកណាមកទេ។ មានសមាគមចិនជួយមនុស្សដែលជាប់សាច់ញាតិចិនច្រើនណាស់ ហើយអ្នកខ្លះគេចេះតែអង្គុយដើម្បីទទួលជំនួយ។ ប៉ុន្តែពួកខ្ញុំអត់ដែលទៅទេព្រោះអត់ចូលចិត្តទៅអង្គុយសុំជំនួយគេ។ តែមានម្នាក់ជាអ្នកមាន។ គាត់ថាស្រណោះពួកបងឯងណាស់។ គាត់ឱ្យម៉ីកញ្ចប់យើងហ្នឹងប្អូនដប់កញ្ចប់ តែគាត់ថា ឃើញពួកយើងប្លែកខុសគេមិនដែលឃើញទៅអង្គុយសុំអំណោយពីគេទេ សុខចិត្តតែហូបស្លឹកបាសស្ងោរជាមួយ ប្រហុក។

រាសី៖ អញ្ចឹងអ្នកស្រីនៅណាងចាន់ហ្នឹងចំនួនប៉ុន្មានថ្ងៃ ប៉ុន្មានខែដែរបាទ!?

សារីមេះ ចាំ! យើងនៅចងអង្រឹងសម្រាននៅតាមទីវាលហ្នឹង។ ក្រោយមក ក៏ឃើញសាលាមួយនៅជាប់ហ្នឹង។ ពេលកូនសិស្សអត់មករៀន ពួកខ្ញុំប្រថុយណាស់ ក្រោយពីសៀមមកស្ទាបក្បាលខ្ញុំ រួចទៅខ្ញុំនាំគ្នាទៅសម្រាននៅលើរានហាលសាលារៀន។ រួចដល់យើងទៅនៅ ឃើញបានសុខ។ មានមនុស្សខ្លះទៅតាមយើង ហើយអ្នកដែលមកនៅតាមក្រោយនៅរានហាលហ្នឹងមានលោកគ្រូបង្រៀនជាមួយខ្ញុំនៅស៊ីសុផុន ឈ្មោះលោក ឈួន ខាំសេង ហើយនឹងប្រពន្ធ និងកូនគាត់ ព្រមទាំងប្អូនគាត់មកនៅកន្លែងរានហាលហ្នឹងដែរ ហើយអ្នកឯទៀតៗដែលមកតាមក្រោយហ្នឹង ខ្ញុំក៏ទៅពន្យល់ប្រាប់ថា ត្រូវធ្វើតាមខ្ញុំគឺត្រូវស្អាត ហើយកុំបត់ជើងតាពីសតាពាស ហើយពេលសៀមមកជួបត្រូវនិយាយមើលមុខសៀមហ្នឹងឱ្យចំ។ កុំឱ្យធ្វើដូចខ្លាចគេ នាំឲ្យគេមើលងាយ។ ខាងក្រោមសាលាហ្នឹងអត់មានរឿងអីទេ ព្រោះពួកហ្នឹងស្អាតដូចខ្ញុំនិយាយអញ្ចឹងហើយដូចថាធ្វើឫកឱ្យថ្លៃថ្នូរនោះចាំ! ដល់ពេលហ្នឹងប្រុសៗដែលដើរជាមួយខ្ញុំហ្នឹងក៏ទៅស៊ីឈ្នួលបោសសម្អាតកន្លែង ណាងចាន់។ ពេលយប់ គេបាន

លុយមក គេទិញបារីជក់ទៀត ហើយខ្ញុំពេលហ្នឹងខឹងណាស់ ឃើញបានលុយទិញបារីជក់អញ្ចឹង ខ្ញុំស្ទួចត្រីបានមិនទាំងហ៊ានទិញម្ហូបផង។ ហើយស្រាប់តែយប់មួយ យើងឮស្ទូរសៀមវាយពួកប្រុសៗដែលដើរមក សម្រានជាមួយពួកខ្ញុំ ជាពិសេស ស្រីវ៉ាន់ហេង។ ឮស្វូរក្តួកៗចាំ! រួចទៅពួកខ្ញុំហ្នឹងក៏នាំគ្នាងើបអង្គុយ ហើយស្រែកជាខ្មែរថា អ្នកឯងម៉េចបានជាវាយគេ? សូមកុំធ្វើអញ្ចឹងខុសរបៀប ខុសច្បាប់អញ្ចឹង។ រួចទៅបានវាឈប់ ព្រោះសៀមហ្នឹងច្រើនដងហើយចេះតែមកឈោងដៃទាញជើងសួន ពីក្រៅរបងរានហាលហ្នឹងមកពេលយប់។ កាលណាមកទាញជើងយើងអញ្ចឹង យើងនាំគ្នាងើបអង្គុយទាំងអស់គ្នា ហើយអង្គុយត្រម៉ោងក្បាលជង្គង់ ហើយស្រែកថាម៉េចមករំខានយើងអញ្ចឹង រួចទៅ ទៅវិញ។ ដល់ក្រោយមកបែបខឹង វាយពួកប្រុសៗដែលនៅសម្រានជិតពួកយើង។

រាសី៖ អញ្ចឹងអត់មានឃើញមានទាហានមកការពារទេពេលហ្នឹង? យើងនៅតែខ្លួនឯងអញ្ចឹងទៅ?

សារីមេ៖ ចាំ! ខ្ញុំដូចមិនដឹងថា មានអ្នកណាការពារទេ ប៉ុន្តែតាមខ្ញុំមើលទៅឃើញមានតែពួកសៀមដែលធ្វើការនៅកន្លែងដែលពួកខ្ញុំទៅកត់ឈ្មោះ ហើយនឹងសុំស្រោមសំបុត្រហ្នឹង ហើយជាអ្នកការពារពួកយើងនោះ។ ធ្វើការការពារយើងឯណាពេលយប់ មកយាយីយើងដូចតាមួយដែលមកស្ទាបក្បាលខ្ញុំហ្នឹងអញ្ចឹង។

រាសី៖ បាទ! អញ្ចឹងអ្នកស្រីនៅណាងចាន់ហ្នឹងចំនួនប៉ុន្មានថ្ងៃដែរ?

សារីមេ៖ ចាំ! ខ្ញុំនៅប្រហែលពីរសប្តាហ៍ រួចទៅបានមានឡានមកដឹកយើងចេញទៅ។ ពេលខ្ញុំទៅឈរតម្រង់ជួរហ្នឹង ខ្ញុំឃើញនៅជិតអណ្តូងទឹកមានម្នាក់ខ្ញុំស្គាល់មុខ ដូចជាបងជីទូតមួយខ្ញុំឈ្មោះ អ៊ុយ សណ្តាប់ ហើយខ្ញុំហៅគាត់ បងដាប់។ ដល់មើលយូរទៅស្រាប់តែខ្ញុំស្គាល់។ ខ្ញុំស្រែកហៅថា នែ! ប្អូនជីទូតមួយខ្ញុំចាំ! ឈ្មោះ នាង អ៊ុយវ៉ាន់ណេត ហើយគាត់មករកខ្ញុំ។ ហើយគាត់ក៏ស្គាល់ខ្ញុំ ភ្លាមដែរ។ ពេលហ្នឹងគាត់សួរថាបងឯងទៅណា? ខ្ញុំថា ឥឡូវប្រហែលគេដឹកខ្ញុំទៅបាងកកហើយ។ ហើយគាត់ថាអញ្ចឹងបងឯងមានអីទេ។ គាត់ចង់ឱ្យខ្ញុំជញ្ជៀនមួយវង់។ ហើយខ្ញុំថាអត់បាច់ទេ

ព្រោះខ្ញុំទៅបាងកកហើយ។ ខ្ញុំមិនត្រូវការលុយទេ។ យើងជួបគ្នាអញ្ចឹងយើងអរណាស់។ រួច អាណោត ហ្នឹងប្រាប់ខ្ញុំថា ប្តីគេឈ្មោះ ណោត សន ធ្វើពេទ្យសត្វនៅបាត់ដំបងពេលខ្មែរក្រហមចូល។ គេបានឱ្យលុយប្តីគេភៀសខ្លួនចេញ។ គេគិតស្មានថាប្រហែលប្តីគេកំពុងនៅបរទេស។ រួចទៅអ្នកដែលដើរជាមួយខ្ញុំ អ្នកថៃ ដែលគាត់រកនំប៉ាវនោះ ខ្ញុំឱ្យគាត់កាន់លុយពេលលក់ស្ករគ្រាប់បាន។ រួចទៅគាត់ថា យើងមានលុយប្រហែល៣០០បាត្រជាង។ គាត់ថាយកមកឱ្យខ្ញុំខ្លះ។ ខ្ញុំថាអត់យកទេ ទុកឱ្យគាត់ព្រោះគាត់អត់បានចេញ។ កុមារីពីរនាក់ហ្នឹងក៏អត់បានចេញ ហើយអ៊ំ ឈៀវ។ បានចេញតែខ្ញុំ សួន ហើយនឹង ឈាង ហើយនឹងប្រុសម្នាក់ ឈ្មោះ វ៉ាន់ ហេង ហើយនឹងម្នាក់ទៀតឈ្មោះ ដេត។

រាសី៖ តើអ្នកណាអ្នកសម្រេចថា អ្នកណាបានចេញ អ្នកណាមិនបានចេញ?

សារីមេះ យើងអត់ដឹងទេចាំ! តាមខ្ញុំមើល ប្រហែលជាគេចម្រាញ់មនុស្សព្រោះពេលហ្នឹងយើងចេះតែឮសួរពាក្យចចាមអារ៉ាមថា សៀមនឹងដេញអ្នកភៀសខ្លួន។

រាសី៖ ប៉ុន្តែគេមានសម្ភាសន៍ដែរមុននឹងរើសយើង?

សារីមេះ ចាំ! អត់ទេគ្រាន់តែកត់ឈ្មោះដំបូង ហើយលើកទី២។

រាសី៖ អញ្ចឹងគេដឹកទៅណាពេលចេញពីហ្នឹងទៅ?

សារីមេះ ចាំ! ខ្ញុំចេញពីណងចាន់ទៅក្រុងលំពីនី។ ប៉ុន្តែអ្នកខ្លះទៀតទៅសួនភ្លូ។

រាសី៖ ខុសគ្នាយ៉ាងម៉េចដែរជំរំទាំងពីរហ្នឹងបាទ!?

សារីមេះ ខ្ញុំមិនដឹងទេ។ ប៉ុន្តែអ្នកមួយដែលទៅជំរំសួនភ្លូ គាត់ទៅស្រុកបារាំង។ ប៉ុន្តែអ្នកខ្លះនៅជំរំខ្ញុំក៏គេចេញទៅស្រុកបារាំងដែរ។ ពេលទៅដល់លំពីនី ខ្ញុំស្លន់ស្លោរ ណាស់ ហើយខ្ញុំក៏ខំរត់ទៅសុំអង្គការគេនៅហ្នឹងឱ្យជួយយកកុមារីកំព្រាពីរនាក់ដែលដើរជាមួយខ្ញុំដែលខ្ញុំកត់ឈ្មោះដាច់ពីខ្ញុំហ្នឹងឱ្យយកមកឱ្យខ្ញុំ។ ខ្ញុំធានាទទួលខុសត្រូវពីព្រោះខ្ញុំឮសួរគេថា សៀមនឹងយកអ្នកនៅណងចាន់ទៅចាក់ចោលនៅភ្នំដងរែកព្រះវិហារ។ ប៉ុន្តែគេយកបានតែ រី មកទេ តែ ចាន់ អត់បានមក។ ហើយឮ សួរថា

សៀមកំពុងទាមទារឱ្យអន្តរជាតិ ឬអាមេរិកឱ្យលុយសៀម ក្នុងជនភៀសខ្លួនម្នាក់ យ៉ាងហោចគឺ២៥០ដុល្លារអញ្ចឹងដើម្បីគេឱ្យជ្រកនៅដី។ តថ្លៃគ្នាបើមិនត្រូវទេ សៀមនឹងយកទៅចាក់ចោល។ ហើយពេលហ្នឹងខ្ញុំក៏បានទទួលសំបុត្រពីលោកតាអាចារ្យ ពៃរហ្ស៊ីល។ ខ្ញុំអរគុណពៃរហ្ស៊ីលដែលគាត់ថា គាត់នឹងមកយកខ្ញុំនៅខែកក្កដា ហើយគាត់សរសើរសំណាងខ្ញុំដែលបានរស់ឆ្លងកាត់ផុតពីកង់ប្រវត្តិសាស្ត្រខ្មែរក្រហមហ្នឹង ហើយនឹងចេញផុតពីណងចាន់មុនសៀមយកទៅចាក់ចោល។ នៅជំរំលំពីនី ខ្ញុំបានផ្ញើរូបថតកូនរបស់ខ្ញុំ ហើយនឹងប្តីខ្ញុំទៅឱ្យ អាចារ្យ ពៃរុយណេ ដើម្បីឱ្យគាត់ជួយស៊ើបដំណឹង។

រាសី៖ អ្នកស្រីទៅជំនំលំពីនីហ្នឹងនៅប៉ុន្មានថ្ងៃ?

សារីមេ៖ ចាំ! ខ្ញុំនៅហ្នឹងបានប្រហែលពីរសប្តាហ៍។ នៅជំរំហ្នឹង ខ្ញុំជួបកូនសិស្សខ្ញុំ ម្នាក់នៅស៊ីសុផុនចាំ! គេនៅចំណាំខ្ញុំបាន។ គេមកគួរសម ហើយគេយកសារ៉ុងមួយមកឱ្យខ្ញុំ។ ខ្ញុំបានសារ៉ុងទៅក៏ផ្លាស់ខោដែលខ្ញុំមានបោកហាល។ ស្រាប់តែអាណាវា លួចខោខ្ញុំទៅបាត់។ ខ្ញុំនៅសល់តែសារ៉ុងចាស់មួយហ្នឹង។ បង វ៉ែន ទៅដល់ដែរ។ គាត់ទៅរកសំពត់ខោអាវពីណាទេបានមកឱ្យខ្ញុំមួយសម្រាប់។ នៅលំពីនីក្នុងបន្ទប់ខ្ញុំឮសូរក្មេងស្រីម្នាក់និយាយថា គាត់អរគុណពួកអាខ្មៅដោយសារអាខ្មៅបានគាត់ចេះធ្វើការស្រែចម្ការច្រើន ហើយសប្បាយនឹងធម្មជាតិ។ ពេលហ្នឹងខ្ញុំឆ្ងល់។ ខ្ញុំរកមើលពួកខ្មៅ។ ស្មានពួកអាហ្វ្រិក។ ដល់រួចទៅបានខ្ញុំយល់ថា អូ! នាងហ្នឹងគាត់ហៅខ្មែរក្រហមថា អាខ្មៅ។ នៅលំពីនី ខ្ញុំឃើញអក្សរមុនដំបូងបំផុត។ របៀបសរសេរយកតួអក្សរបារាំងមកប្រើ។ នៅលំពីនី ខ្ញុំជួបពិន ដារិន ដែលធ្លាប់រៀននៅសាលាគរុកោសល្យជាមួយខ្ញុំ។ ប្តីគាត់ឈ្មោះ អ៊ឹង រិទ្ធីរុង ហើយនឹងជួប កុដ ប្អូនស្រីរបស់អ្នកគ្រូ មាស ភីរុណ។ អាកុដ ប្រាប់ខ្ញុំថា អ្នក មាស ភីរុណ ជាប្រពន្ធលោក ហ៊ុល ហ៊ុង បានចេញទៅស្រុកអាមេរិកហើយ។ ខ្ញុំជួបប្រពន្ធនាយ ទាហានដូចជា មាដាម ណុប ប៉ាប៉ាមូន។ មកដល់លំពីនី ស្រាប់តែ ខ្ញុំឃើញពួកអស់លោកនាយទាហានចាស់កាលពីលើកមុន។ គាត់ទៅរកអ្នកចូលក្នុង ចលនាតស៊ូ។ ពេលហ្នឹងធ្វើឱ្យខ្ញុំនឹក

ខ្មាញ់ដល់មេទាហានខ្លះសម័យលន់ ណុល។ គាត់មិនគិតខំប្រឹងច្បាំងទេ គិតតែពុករលួយ លួចគ្រឿងអាវុធយកទៅលក់ឱ្យខ្មាំង។ អ្នកខ្លះមិនលុបឈ្មោះខ្មោចទាហានចោលទេ ទុកយកប្រាក់ខែ។ ហើយខ្ញុំក៏អរគុណ ស្វាត់ខ្យា ហើយលោក តានវ៉ាន់ស៊ុយ ជាប្ដីរបស់ ស្វាត់ខ្យា ដែលបានផ្ញើលុយឱ្យខ្ញុំ៥០ដុល្លារពីបីហ្សង់សុងទៅ។ ខ្ញុំបានលុយហ្នឹង ខ្ញុំយកទៅទិញផ្លែឈើ ហើយនឹងឱ្យគេឯងខ្លះ ព្រមទាំងសម្រាប់ទិញខោអាវទៅ។ នៅជំរំ អ្នកខ្លះនៅបបួលយើងឱ្យដូរបញ្ជីជាតិដាក់អាយុតិច ជាពិសេសពួកចិនៗ។ គេថាបងប្អូនគេនិយាយថា ទាល់តែនៅក្មេងបានគេយកធ្វើការពេលទៅបរទេស។ ហើយពួកខ្ញុំហ្នឹង យើងហ្នឹង នៅរក្សាអាយុយើងដដែល។ អ្នកខ្លះបងប្អូនគេប្រាប់ទៅពីស្រុកអាមេរិកទៅថា ស្រីខ្មែរអត់សូវមានទេនៅស្រុកអាមេរិកនោះ។ មកហ្នឹងត្រូវខំទាក់ទងឱ្យស្គាល់ស្រីខ្លះដើម្បីបានមកដល់ទាក់ទងរៀបការជាមួយគេ។ ពេលមកដល់ ស្រុកអាមេរិក មានពួកខ្លះហ្នឹងចេះតែខំមកទាក់ទងពួកយើង។

រាសីៈ បាទ! នៅពេលដែលអ្នកស្រីបានអញ្ជើញទៅដល់ជំរំលំពីនីហ្នឹង តើគេមកសម្ភាសន៍នៅទីហ្នឹង ឬយ៉ាងដូចម្ដេច?

សារីមៈ ចាំ! អាមេរិកមកសម្ភាសន៍យើងច្រើនដង ហើយមានខ្មែរលោក គួច ឈីវ ហើយនឹងប្រពន្ធគាត់ឈ្មោះ ធីតា យូស មកធ្វើជាអ្នកបកប្រែ។ ដូចខ្ញុំអញ្ចឹង ពេលសម្ភាសន៍គេសួរខ្ញុំថា ខ្ញុំហ្នឹងមានចូលជាសមាជិកខ្មែរក្រហមទេនៅស្រុកបារាំង? ខ្ញុំថាអត់មានចូលជាសមាជិកខ្មែរក្រហមទេ។ ខ្ញុំគ្រាន់តែដាក់ពាក្យសុំទៅរណសិរ្សរួបរួមជាតិកម្ពុជា ហ៊្វុង (FUNK) មកស្រុកខ្មែរ។ គេសួរខ្ញុំថា ឥឡូវ អ្នកឯងទៅបរទេសយកប្ដីទៀតទេ? រួចខ្ញុំថា ខ្ញុំអត់ទាន់គិតរឿងយកប្ដី។

រាសីៈ អ្នកស្រីអញ្ជើញទៅបារាំងពេលហ្នឹង?

សារីមៈ ចាំ! ដល់ពេលគេហៅសម្ភាសន៍ ឱ្យសំបុត្រមកខ្ញុំគឺខ្ញុំដឹងថា ខ្ញុំមកអាមេរិក។

រាសីៈ អូ! អត់ទៅបារាំងទេបាទ!?

សារីមៈ ចាំ! អត់ទេ។

រាសី៖ មានអ្នកណាធានាដែរពេលហ្នឹង?

សារីម៖ ពេលដែលខ្ញុំសរសេរ ខ្ញុំដាក់ក្នុងប្រវត្តិរូបខ្ញុំនោះថា ប្អូនប្រុសខ្ញុំនៅស្រុកអាមេរិក ពេលហ្នឹងគឺពេលដែលខ្ញុំមកស្រុកបារាំងឆ្នាំ៧៤ ខែ៩ ប្អូនប្រុសខ្ញុំគេទៅស្រុកអាមេរិក។ រួចទៅគេអត់ត្រឡប់ទៅស្រុកខ្មែរវិញទេ។ ខ្ញុំចាំអាសយដ្ឋានចាំ! អាសយដ្ឋាន គឺខ្ញុំចាំក្នុងខួរក្បាល។ អញ្ចឹងចាំ! គឺខ្ញុំទន្ទេញមានអាសយដ្ឋាន ដែលថាកន្លែងខ្ញុំនៅអាសយដ្ឋាន អាចារ្យ ពែរហ្សឺល ហើយនឹង អាសយដ្ឋាន ប្អូនប្រុសខ្ញុំនៅស្រុកអាមេរិក។

រាសី៖ បាទ! តើខាងណាគេធានាអ្នកស្រីមកអាមេរិកហ្នឹងបាទ?

សារីម៖ ចាំ! កាលហ្នឹងសំបុត្រដែលគេឱ្យយើងឃើញហ្នឹង គឺឃើញអង្គការ Catholic គេអ្នកធានាខ្ញុំ។

រាសី៖ អង្គការហ្នឹងជាខាងសាសនា ឬយ៉ាងម៉េច?

សារីម៖ ចាំ! Catholic Charity គេជាអ្នកជួយឱ្យខ្ញុំចេញមកហ្នឹង។

រាសី៖ បាទ! បើអញ្ចឹងគេមិនថា យើងកាន់សាសនាគ្រិស្ត ឬក៏អត់ទេ គឺយកមកដោយរឿងមនុស្សធម៌?

សារីម៖ ចាំ! គេជាអ្នកទទួលយើង។ យើងអត់មានបានចូលសាសនាអីទេ។

រាសី៖ បាទ! គេៗមានឱ្យអ្នកស្រីធ្វើខសន្យាអីថា យើងមកនេះយើងចូលសាសនាទេ?

សារីម៖ ចាំ! អត់មានទេ។

រាសី៖ អញ្ចឹងអ្នកស្រីអញ្ជើញចេញពីប្រទេសថៃមកវិញនៅថ្ងៃណាដែរ?

សារីម៖ ចាំ! មុននឹងយើងចេញហ្នឹង ខាងជំរំគេឱ្យយើងទៅដើរលេងបាងកកមួយថ្ងៃដើម្បីយើងទិញខោអាវ។ ទិញអីវ៉ាន់នោះចាំ!។

រាសី៖ គេនាំយើងចេញ ឬក៏ឱ្យយើងចេញដោយសេរី?

សារីម៖ ចាំ! យើងទៅដើរលេងខ្លួនឯង។

រាសី៖ អូ! បាទ។

សារីមេ៖ ចាសៗ! ពេលដែលខ្ញុំឡើងកប៉ាល់ហោះចេញពីស្រុកសៀម ទើបខ្ញុំដឹងថា ខ្ញុំពិត ជាបានរួចផុតពីរបបអវិជ្ជារបស់ខ្មែរក្រហមពិតមែន។ តែខ្ញុំបារម្ភព្រួយទៅដល់គ្រួសារខ្ញុំដែលខ្ញុំរកមិនទាន់ឃើញ។ ខ្ញុំមកស្រុកអាមេរិកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧៩។

សារីមេ៖ ចាំ! មកដល់សាន់ហ្វ្រាន់ស៊ីស្កូ គឺនៅពេលព្រលឹមមែនទែន។ ខ្ញុំមើលទៅខាងក្រោម ឃើញដូចទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូកំពុងតែស្រមុកក្រោបឱបជាប់នឹងឆ្នេរសមុទ្រ។ ពេលយើងចុះមក បានជិះកប៉ាល់តូចមួយទៀតទៅស្តុកតុន។ ចុះដល់ដីស្តុកតុន នៅចំណតយន្តហោះ ឃើញអាមេរិកម្នាក់ ហើយនឹងស្រីអាស៊ីពីរនាក់ ព្រមទាំងកូនក្មេងពីរនាក់ឈរទទួលពួកយើង។ ពួកយើងខ្ញុំមាន ទាវ វ៉ាន់ណុល កូនសិស្សខ្ញុំនៅសាលាវិទ្យាល័យអនុវត្តន៍ (Lyce D'Application) ហើយនឹងប្រពន្ធរបស់គេ ដែលកំពុងមានផ្ទៃពោះ ហើយនឹងគ្រួសារម្នាក់ទៀតមានកូនពីរបីនាក់។ ទៅដល់ហ្នឹងខ្ញុំនិយាយអង់គ្លេសរកអ្នកអាមេរិកថា ខ្ញុំមកហ្នឹងតែម្នាក់ឯង។ គាត់ថាយី! ខ្ញុំហ្នឹងចេះអង់គ្លេស។ រួចខ្ញុំថា ខ្ញុំចេះតែបន្តិចៗទេ។ ស្រីទាំងពីរនាក់ហ្នឹងខ្មែរប្រពន្ធលោកសារឿន ហើយហ្វីលីពីន ប្រពន្ធលោក យុទ្ធ ហុង។

រាសី៖ គេសម្រេចថា អ្នកស្រីទៅស្តុកតុនហ្នឹងដោយវិធីណា?

សារីមេ៖ ចាំ! មកដល់ស្តុកតុនហើយបានខ្ញុំដឹងថា ដែលថាខ្ញុំបានមកស្តុកតុនហ្នឹងដោយសារខ្មែរនៅស្តុកតុន ដូចជាលោក គីត ប៉ុង ហើយនឹងលោក កុយ សារឿន ស្ម័គ្រចិត្តថានឹងជួយយកអាសារពួកខ្ញុំពេលទើបមកដល់ ហើយនឹងនាំទៅសុំ ជំនួយដើម្បីរស់នៅស្រុកអាមេរិកដំបូងសិន។ ជាជនភៀសខ្លួន គេយកខ្ញុំទៅផ្ញើផ្ទះលោក កុយ សារឿន និងប្រពន្ធគាត់។ ពីរខែក្រោយមក សួរគេឯងចុះឡើងទៅបាន ខ្ញុំរកប្អូនប្រុសខ្ញុំឈ្មោះ យូ សឹមអោក ឃើញដោយសារលោក ស៊ុន ស្រេង អ្នកធ្វើទាហានម៉ារីនជាមួយប្អូនប្រុសខ្ញុំនៅសាន់ហ្វ្រហ្សេ។ គាត់ប្រាប់ខ្ញុំ។

រាសី៖ ប្អូនបង្កើត?

សារីមេះ ចាំ! ប្អូនប្រុសខ្ញុំបង្កើតមកទទួលខ្ញុំទាំងយប់។ ហើយខ្ញុំក៏ទៅនៅផ្ទះជាមួយ ប្អូននៅសាន់ហូហេរ្យ។

រាសីះ បាទ! ពេលប៉ុន្មានខែមកដល់អាមេរិកដំបូង អ្នកស្រីធ្វើការអីខ្លះ?

សារីមេះ ចាំ! ខ្ញុំថា ខ្ញុំសុំវ៉ាកង(សម្រាក) បីខែព្រោះខ្ញុំធ្វើការហត់សម័យប៉ុល ពត។ ជើងខ្ញុំនៅប្រេះនៅឡើយ។ ខ្ញុំថាមិនបាច់ទៅរៀនអង់គ្លេសនៅសាលាទេ យើងមើលទូរទស្សន៍។ ខ្ញុំឮស្គរតាមគេឯងថា កុមារីកំព្រាដើរជាមួយខ្ញុំ ជាកូនរបស់ ម៉ានីណា គីរីវ៉ាត់ សៀមយកទៅចាក់ចោលនៅភ្នំដងរែក ហើយត្រូវគ្រួសារអ្នកភូមិសុំ ហើយក្រោយមកឮចចាមអារ៉ាមថា បងប្អូនរបស់ចាន់ (កុមារីកំព្រា) រកចាន់ ឃើញ ហើយបានយកចាន់ទៅជាមួយ។ ខ្ញុំពេលហ្នឹងខំបន់ស្រន់ឱ្យ ចាន់ បានសេចក្តីសុខ។ អាចារ្យ ពែរវីណេ (Pere Venet) ក៏បានផ្ញើសំបុត្រមកឱ្យខ្ញុំថា គាត់រកកូនស្រីខ្ញុំមិនឃើញទេ។ នៅស្រុកអាមេរិកពេលមកដល់ឃើញ មនុស្សធាត់ច្រើនពេក ខ្ញុំនឹកស្រណោះដល់អ្នកអត់បាយ។ ហើយពេលណា ឃើញគេពាក់វ៉ែនតា ខ្ញុំចេះតែភ័យខ្លាចខ្មែរក្រហមសម្លាប់។

រាសីះ បាទ! ហើយនៅពេលណា អ្នកស្រីបានដំណឹងពីក្រុមគ្រួសារនៅស្រុកខ្មែរ?

សារីមេះ ចាំ! ប្រាំមួយខែក្រោយមក គឺនៅខែ១១ ខ្ញុំបានទទួលសំបុត្រមួយពីស្រុកបារាំង បងដួង បងជីទួតមួយខ្ញុំប្រពន្ធលោក ចៅ ស៊ីអ៊ួ បានផ្ញើសំបុត្រមួយមកឱ្យខ្ញុំថា បានដំណឹងតាមអ្នកស្រី ប្លែក ភិរុណ ដែលយកសំបុត្រមួយពីស្រុកខ្មែរមក ដែល បងប្អូនជីទួតមួយស្រីខ្ញុំម្នាក់ឈ្មោះ កាមីន បានផ្ញើមកពីកៀនស្វាយ។ ផ្ញើមកឱ្យបង អ៊ួ។ ក្នុងសំបុត្រហ្នឹងគេរាប់តែអ្នកសល់។ ក្នុងផ្ទះខ្ញុំគឺសល់ម្នាក់ ប្អូនស្រីខ្ញុំឈ្មោះ យូ សុខភឿន ហៅ ជា។ គ្រួសារពូខ្ញុំឈ្មោះ យូ ផុន សល់កូនស្រីគាត់ម្នាក់ឈ្មោះ យូ ភីដាន ហៅ ស្រីមុំ។ គ្រួសាររបស់បងស្រី បងដួង ឈ្មោះបង ដាន សល់កូនស្រីគាត់ម្នាក់ឈ្មោះ ប៉ូ កល្យានី ហៅតូ។ ប្អូនស្រីពុកខ្ញុំម្នាក់ឈ្មោះ យូ ម្លិះ ក៏នៅរស់ដែរ។

រាសីះ បាទ! ចុះគ្រួសាររបស់អ្នកស្រីផ្ទាល់ហ្នង មានបានដំណឹងអីទេ?

សារីមះ ចាំ! គេរៀបរាប់ថាផ្ទះខ្ញុំហ្នឹងសល់តែប្អូនស្រីខ្ញុំ។ មើលសំបុត្រហ្នឹងហើយ ខ្លួនខ្ញុំហ្នឹងដូចបែកខ្ទាយអញ្ចឹង។ ដូចផ្ទុះខួរក្បាលអញ្ចឹង ញ័រ អង្គុយក៏មិនកើត ឈរក៏មិនកើត ចេះតែខំដកដង្ហើមវែងៗយូរទៅបានស្រួលឡើង វិញ ហើយខ្ញុំកោសក់។ ខ្ញុំកាន់ទុក្ខគេទាំងអស់គ្នា។ គេប្រាប់ថា បងប្រុសខ្ញុំពីរនាក់ដែលមិនទៅជាមួយឪពុកម្តាយខ្ញុំគឺគេដឹងថានៅរស់ ប៉ុន្តែម្នាក់នៅជិតទល់ដែនសៀម ហើយម្នាក់ទៀតនោះនៅខាងស្រុកទន្លេ។ ក្រោយមកគឺត្រូវទាំងអស់។

ពាសីះ ដល់ពេលហ្នឹង អ្នកស្រីនៅជាមួយប្អូនតទៅទៀត ឬយ៉ាងដូចម្តេចបាទ?

សារីមះ ចាំ! ខ្ញុំនៅជាមួយប្អូនប្រុស។ មុនដឹងដំណឹង ខ្ញុំរៀនបើកឡាន។ ទៅប្រឡង។ ចង់ជាប់។ ស្រាប់ដល់បានដំណឹងអញ្ចឹងមក ខ្ញុំភ្លេចក្រហមក៏បើកឆ្លង។ ខ្ញុំគិតថា បើតែនៅបើកឡានទៀត មុខតែស្លាប់។ អ្នកនៅស្តុកតុនបាននាំខ្ញុំទៅនិយាយឲ្យគេស្តាប់នៅសាកលវិទ្យាល័យកាលីហ្វ័រនី ប៊ឹកឃ្លី (UC Berkeley) ម្តង ព្រោះថាមាន អាមេរិកខ្លះចង់ជួយបង្កើនឡានពេទ្យចល័តមួយសម្រាប់យកទៅជួយ ជនភៀសខ្លួននៅតាមទល់ដែន។

ពាសីះ ចំពោះគ្រួសារអ្នកស្រី តើអ្នកស្រីមានដឹងពិស្តារថាស្វាមីអ្នកស្រីស្លាប់ដោយការ អត់បាយ ឬក៏យ៉ាង? ចុះកូនយ៉ាងម៉េច?

សារីមះ ចាំ! ដំណឹងដែលខ្ញុំបានពិតប្រាកដពីគ្រួសារខ្ញុំគឺប៉ុន្មានខែក្រោយមកបានប្អូនស្រីខ្ញុំឈ្មោះ យូ សុខភឿន ហៅ អាជា ហ្នឹងផ្ញើសំបុត្រពីខាវអ៊ីដាងមកថា គេមកជាមួយអាតូ ដោយសារគាត់បានអាសយដ្ឋានខ្ញុំពីប្អូនថ្លៃស្រីខ្ញុំឈ្មោះ នួន ចាន់ បុផា នៅអូស្ត្រាលី ហើយប្រាប់ខ្ញុំថា ក្នុងគ្រួសារយើងសល់តែប្អូនស្រីខ្ញុំម្នាក់ប៉ុណ្ណោះ។ គេជម្លៀសទៅនៅប៉ប្រាក់កូនក្នុងខេត្តពោធិ៍សាត់។ ខ្មែរក្រហមទាត់ឆ្នាំងម្ហូបដែលយើងខំរកបានដោយខ្លួនឯងហ្នឹងចោលខ្ទេចខ្ទី។ អាជា ប្អូនស្រីខ្ញុំ ប្តីខ្ញុំ ហើយនឹងប្អូនប្រុសខ្ញុំឈ្មោះ យូ សំអាត សុទ្ធតែទៅឆ្ងាយៗពីភូមិ។

ពាសីះ ទៅចល័តអស់ហើយ?

សារីមេះ ចាំ! ម្ដាយខ្ញុំ ហើយនឹងឪពុកខ្ញុំនៅមើលកូនស្រីខ្ញុំពីរនាក់ហ្នឹង! ឪពុកខ្ញុំស្លាប់មុនគេ ហើយទៅបានកូនស្រីខ្ញុំតូចជាងគេស្លាប់។

រាសី៖ ដោយជំងឺ?

សារីមេះ ចាំ! សុទ្ធតែអត់បាយ។ វាឈឺ។ ម្ដាយខ្ញុំឃើញកូនស្រីខ្ញុំទី២ស្លាប់។ ប្អូនស្រីខ្ញុំថា ម្ដាយខ្ញុំព្រួយចិត្តមែនទែន។ គាត់ហ៊ានទៅលួចស្រូវជង្រុករបស់ខ្មែរក្រហម។ គាត់ថាគាត់មិនលួចទេ។ គ្មានឯងនៅជុំវិញខ្លួន។ គាត់លួចអារអង្គការហ្នឹងហ្មង ពីព្រោះវាធ្វើបាបយើង។ គាត់លួចស្រូវគ្រាន់យកមកពិសារ ខ្លាចកូនខ្ញុំអត់។

រាសី៖ បាទ! គាត់ខឹង?

សារីមេះ ចាំ! នៅស្រុកពោធិ៍សាត់ គេហៅប៉ប្រាក់កូន កន្លែងដែលឪពុកម្ដាយខ្ញុំទៅនៅ។ ខ្មែរក្រហមថា ម្ដាយខ្ញុំលួចស្រូវដូរមាស ហើយវាចាប់ម្ដាយខ្ញុំដាក់គុក ហើយវាយចងឱ្យសេះអូស ហើយទុកឱ្យកូនស្រីខ្ញុំបងគេឈ្មោះ សាក់គូរ៉ាស់ ហៅ អាតាត់ អាយុ៥ឆ្នាំរស់នៅម្នាក់ឯង។ ហើយម្ដាយខ្ញុំវាវាយឱ្យសេះអូស ដាក់គុកគាត់។ គាត់ក៏ស្លាប់ទៅ។ ប្អូនស្រីខ្ញុំមកឃើញក៏សុំខ្មែរក្រហមនៅមើលកូនស្រីខ្ញុំ ថាពេលហ្នឹងកូនខ្ញុំឈឺទៅហើយ។ កូនស្រីខ្ញុំក៏ស្លាប់ទៅ។ ប្អូនប្រុសខ្ញុំ យូ សំអាត ក៏ធ្វើការធ្ងន់ពេកទាល់តែស្លាប់។ ចំណែកប្ដីខ្ញុំវិញក៏ទៅចល័តឆ្ងាយពីគេ។ ដល់មានអ្នកភូមិកន្លែងប៉ប្រាក់កូនទៅកន្លែងដែលគាត់ចល័ត គាត់ក៏សួរគេពីគ្រួសារខ្ញុំ។ ហើយអ្នកហ្នឹងប្រាប់ថាគ្រួសារអ្នកឯងស្លាប់អស់ហើយនៅសល់តែ អាជា មួយទេ គឺប្អូនស្រីខ្ញុំ។ ដល់អញ្ចឹងប្ដីខ្ញុំក្រោយមកគាត់ឈឺ។ គាត់ស្លាប់ទៅ។ ម្ដាយមីងថ្លៃខ្ញុំម្នាក់ឈ្មោះ ភិន ណារ៉ុម ប្រពន្ធពូខ្ញុំឈ្មោះ យូ ផន ត្រូវខ្មែរក្រហមពុះក្បាលគាត់ សម្លាប់ចោល។ ពេលទទួលសំបុត្រពីស្រុកសៀមម្ដងៗ ខ្ញុំសឹងតែមិនហ៊ានមើល។ ប្អូនស្រីខ្ញុំប្រាប់ខ្ញុំថា ប្ដីខ្ញុំពេលជម្លៀសទៅដល់ប៉ប្រាក់កូន គាត់បានផ្ដាំប្អូនស្រីខ្ញុំថា បើជួបខ្ញុំសូមឱ្យខ្ញុំហ្នឹងកុំនៅជាជាតិខ្មែរ។ ឱ្យចូលជាតិបារាំង។ ហើយខ្ញុំពេលដែលខ្ញុំមកដល់ស្រុកអាមេរិកយូរឆ្នាំណាស់ដែលខ្ញុំនៅយល់សប្ដិ ឃើញខ្មែរក្រហមតាមព្យាបាទយើង រហូតដល់ឆ្នាំប្រហែលជា៨៩បានខ្ញុំបាត់ឈឺពេលថ្ងៃ១៧ មេសា ម្ដងៗ ព្រោះខ្ញុំយល់សប្ដិឃើញ

ប្អូនស្រីខ្ញុំជាប់នៅខ្មែរក្រហម ហើយខ្ញុំបន់ព្រះឱ្យបំបាំងខ្លួនខ្ញុំដើម្បីខ្ញុំចូលទៅយកប្អូនស្រីខ្ញុំបានចេញមក បន់រួចខ្ញុំក៏ដើរចូលទៅ បានសម្រេចយកបងប្អូនចេញមកអស់ តាំងពីពេលហ្នឹងមកជិតដល់ថ្ងៃ១៧មេសា ហ្នឹងគឺខ្ញុំលែងឈឺហើយខ្ញុំអាចស្តាប់ភ្លេងខ្មែរ៕ (ចប់)

*កំណត់និពន្ធ៖ បន្ទាប់ពីអ្នកស្រីនៅ សារីមផ្តល់បទសម្ភាសជាមួយនឹងលោកប៉ូច រាសីពីប្រវត្តិនិទានផ្ទាល់មាត់អំពីឆាកជីវិតក្នុងរបបខ្មែរក្រហមក្រោយពីវិលត្រឡប់ពីប្រទេសបារាំងទៅកម្ពុជាវិញ អ្នកស្រីក៏ បានចូលរួមក្នុងកម្មវិធីហេឡូវីអូអេដើម្បីអនុញ្ញាតឱ្យអ្នកស្តាប់ដែលបានតាមដានប្រវត្តិនិទាននេះមានឱកាសសួរជាសំណួរផងដែរ។ ខាងក្រោមនេះជាកម្មវិធីហេឡូវីអូអេ។*

**សេចក្តីផ្តើម៖** លោកអ្នកស្តាប់ជាទីមេត្រី កម្មវិធីហេឡូវី-អូ-អេ នៅរាត្រីនេះ អ្នកស្រី នៅ សារីម ជាភ្ញៀវរបស់កម្មវិធី។ អ្នកស្រីនឹងឆ្លើយតបនឹងចម្ងល់របស់លោកអ្នកក្នុងភាគនិទានប្រវត្តិផ្ទាល់មាត់ស្តីពីជីវិតអ្នកបរទេសត្រឡប់មកកម្ពុជាក្នុងសម័យខ្មែរក្រហម ហើយលោក ប៉ូច រាសី ជាអ្នកសម្របសម្រួល សូមអញ្ជើញ។

រាសី៖ បាទៗ! សូមអរគុណ។ សួរស្តីអស់លោកអ្នកស្តាប់ជាទីមេត្រី និងជម្រាបសួរ អ្នកស្រី នៅ សារីម។

សារីម៖ ចាំ! ជម្រាបសួរលោក ប៉ូច រាសី។

រាសី៖ បាទ! ថ្ងៃនេះយើងវិលមកជួបលោកអ្នកស្តាប់យើងម្តងទៀត ប៉ុន្តែមិនមែននៅក្នុងករណីរឿងនិទានប្រវត្តិសាស្ត្រទេ ក៏ប៉ុន្តែក្នុងករណីកម្មវិធីហេឡូវីអូអេវិញម្តង ដើម្បីឱ្យ ឱកាសលោកអ្នកស្តាប់យើងទូរស័ព្ទមកសួរអ្នកស្រី ពីព្រោះខ្ញុំកន្លងមក៦២ភាគ ខ្ញុំបានសួរអ្នកស្រីច្រើនហើយ។ ឥឡូវនេះទុកឱកាសឱ្យអ្នកស្តាប់យើងម្តងសូមអញ្ជើញលោកអ្នកទូរស័ព្ទលេខ ០១២ ៥១ ៥១ ៩៤ បើលោកអ្នកមាន សំណួរ ឬចម្ងល់ចង់ជម្រាបសួរអ្នកស្រី នៅ សារីម។ នៅពេលដែលយើង កំពុងរង់ចាំសំណួររបស់អ្នកស្តាប់ ខ្ញុំសូមជម្រាបសួរអ្នកស្រីថា តើអ្នកស្រីមានស្រុកកំណើតនៅឯណាដែរ!

សារីម៖ ចាំ! ខ្ញុំកើតនៅឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ថ្ងៃ១៨ ខែមីនា។ឪពុកខ្ញុំពេលនោះឆ្នាំដែលខ្ញុំកើតគឺគាត់ជាអ្នករកទទួលទានមានទូកប៉ុកចាយ ដឹកអីវ៉ាន់ពីស្រុកខ្មែរយើងទៅព្រៃនគរ ឬក៏ទៅកំពង់ផែនានានៅខាងស្រុកយួន កម្ពុជាក្រោម។

រាសី៖ បាទ! ចុះម្តាយអ្នកស្រី?

សារីមះ ចាំ! ម្ដាយខ្ញុំជាអ្នកមកពីពោធិ៍សាត់។ គាត់រស់នៅភូមិពោធិ៍តាក្លួយ ខេត្ត ពោធិ៍សាត់ គឺថា នៅសឹងជិតផ្លូវដែករទេះភ្លើង។

រាសីះ បាទ! មុននឹងជូននាទីទៅលោក ង៉ែត នៅបាត់ដំបង សូមអ្នកស្រីសង្ខេបអំពីការសិក្សារៀនសូត្ររបស់អ្នកស្រីបន្តិចបាទ។

សារីមះ ចាំ! ខ្ញុំរៀននៅឃុំក្បាលកោះ ។ បានទៅរៀននៅសាលានៅគគីរ រួចក៏បានប្រឡងជាប់ចូលសាលាអនុវិទ្យាល័យព្រះនរោត្តម។ ពេលនោះសុទ្ធតែស្រី។ ជាប់ឌីប្លូម ហើយទៅក៏ទៅរៀននៅ វិទ្យាល័យស៊ីសុវត្ថិ។ ដល់ប្រឡងបាក់ឌុបហើយបានខ្ញុំចូលធ្វើសិស្សគ្រូបង្រៀន។ រួចក៏ចេញធ្វើគ្រូនៅស៊ីសុផុន។ នៅទីនោះពីរឆ្នាំបានត្រឡប់មកបង្រៀននៅភ្នំពេញនៅសាលាវិទ្យាល័យអនុវត្ត គឺក្នុង សាលានរ័ម៉ាល់ជាប់វិមានឯករាជ្យ។ រួចក៏បានអាហារូបករណ៍មកស្រុកបារាំងឆ្នាំ៧៥។

រាសីះ បាទ! ឥឡូវនេះខ្ញុំសុំជូនសំណួរ ជូននាទីទៅលោក ង៉ែត នៅខេត្តបាត់ដំបង។ ជម្រាបសួរលោក ង៉ែត បាទ!។

ង៉ែតះ បាទៗ! ជម្រាបសួរបង។

រាសីះ បាទៗ! សូមអញ្ជើញមានសំណួរចុះបាទៗ! សូមអញ្ជើញលោក។

ង៉ែតះ បាទៗ! ជម្រាបសួរបាទ! ខ្ញុំសួរថា បង នៅ សារីម ចូលមកស្រុកខ្មែរពីឆ្នាំណាដែរបង?

សារីមៈ ចាំ! ខ្ញុំបានអាហារូបករណ៍មករៀននៅស្រុកបារាំង ហើយទៅស្រុក ខ្មែរនៅឆ្នាំ៧៦ ខែមករា ពេលដែលខ្មែរក្រហមយកស្រុកខ្មែរបានហើយ។

ង៉ែតះ បាទៗ! ហើយបងរស់នៅកន្លែងណាដែរអញ្ចឹងបង?

សារីមះ ចាំ! ដូចខ្ញុំជម្រាបក្នុងរឿងប្រវត្តិសាស្ត្រ ប្រវត្តិនិទានផ្ទាល់មាត់ ខ្ញុំចូលទៅ គឺខ្មែរក្រហមបានដាក់ឱ្យនៅក្នុងសាលាមួយឈ្មោះសាលាតិចណូរូស្ស៊ី។ គេដាក់សុទ្ធអ្នកទៅពីបរទេស។ រួចហើយបានគេតែចល័តយើងទៅដូចជា អង្គរជ័យ ទៅភូមិតាលៃ ទៅវត្តស្លែង ហើយទៅបានបកមកជំរំហៅបឹងត្របែក។

ង៉ែត៖ បឹងត្របែកហ្នឹងនៅខាងជំនាន់គេហៅខាងបញ្ញាជនហីបង?

សារីម៖ ចាំ! បានន័យថា ពួកអ្នកទៅពីស្រុកបារាំងទៅគេដាក់កន្លែងដោយដុំគេមិនយក ទៅដាក់នៅជាមួយប្រជាជនទេ។ អ្នកដែលទៅជំនាន់ខ្ញុំហ្នឹងមានអ្នកទៅពីមុនខ្ញុំ ហើយគេដាក់ជាមួយប្រជាជន។ នៅបឹងត្របែករហូតដល់យួនចូលស្រុកខ្មែរ។

ង៉ែត៖ បាទៗ! ជំនាន់ដែលគេចាប់ សារ៉ន ហ្នឹងបងនៅហ្នឹងដែរអី?

សារីម៖ ចាំ! ខ្ញុំដឹងប៉ុន្តែខ្ញុំមិនដឹងគេចាប់ពេលណាទេ គ្រាន់តែបាត់ សារ៉ន ទៅបានដឹង ថាគេចាប់ សារ៉ន។ សារ៉ន ធ្វើមេនៅហ្នឹង។

រាសី៖ បាទ! លោកង៉ែត មានសំណួរអីទៀតទេ ខ្ញុំសុំទុកឱកាសដើម្បីឱ្យអ្នកស្តាប់ យើងឯទៀតសួរបាទ! សូមអញ្ជើញលោកបញ្ចប់សំណួរ។

សារីម៖ លោកៗ ង៉ែត ស្គាល់ សារ៉ន ហី?

ង៉ែត៖ បាទៗ! ខ្ញុំកាលហ្នឹងនៅរៀនហ្នឹងដែរបង។

សារីម៖ រៀននៅណាចាំ!?

ង៉ែត៖ រៀននៅសាលាបឹងត្របែក នៅជាមួយ សារ៉ន ហ្នឹង។

សារីម៖ អូ! អញ្ចឹងដែលពួកកូនសិស្សពាក់អាវខ្មៅៗ ហើយគេរៀននៅជិតកន្លែងសាលាបឹងត្របែកហ្នឹង ខ្ញុំធ្លាប់ឃើញចាំ!។

ង៉ែត៖ បាទៗ! នៅៗគ្រូ ..នីន ហ្នឹងបង្រៀនខ្ញុំ គ្រូបង្រៀនអង់គ្លេសណា។

សារីម៖ យ៉ានីន ប៉ុក យ៉ានីន។

ង៉ែត៖ បាទ! ... យ៉ានីន ហ្នឹង អ្នកស្រីណា?

សារីម៖ ចាំ!

ង៉ែត: បាទៗ! ហ្នឹងប្រពន្ធខ្ញុំហើយហ្នឹងបាទ!។

សារីម៖ ចាំ!

រាសីៈ អរគុណលោក ង៉ែត ដែលមកកម្មវិធីហោឡូវី-អូ-អេរបស់យើងនេះបាទៗ! ឥឡូវនេះ អ្នកស្រីយើងទទួលសំណួរពីព្រះតេជគុណសម្បត្តិ នៅខេត្តកោះកុងបាទ! សូមនិមន្ត ព្រះតេជគុណមានសំណួរ។

សម្បត្តិៈ ម្រើនពរ ញោម ប៉ូច រាសី និង ញោម ស្រី នៅ សារីម។

សារីមៈ ករុណាថ្វាយបង្គំ។

សម្បត្តិៈ អាត្មាចង់សួរសំណួរពីរ។ សំណួរទី១តើញោមបានគេចផុតពីរបបប្រល័យ ពូជសាសន៍គឺពួកអាវខ្មៅ បានទៅសហរដ្ឋអាមេរិកហ្នឹងទៅតាមរយៈ ការ (អាពាហ៍ពិពាហ៍)ផ្លូវការណាដែរ? សំណួរទី២ តើញោមមានព្រះជន្មប៉ុន្មានដែរហើយ សព្វថ្ងៃ? សូមចម្រើនពរ។

សារីមៈ ចាំ! ខ្ញុំករុណាបានមកស្រុកអាមេរិកនេះដោយសារពេលបានរត់ចេញពីប្រទេស កម្ពុជាដើរតាមផ្លូវគោកនិម្មិតទៅដល់ណងចាន់។ ករុណា ហើយបានមកស្រុក អាមេរិកនៅថ្ងៃទី១៦ ខែ៦ មកដល់សាន់ហ្វ្រាន់ស៊ីស្កូ។ សំណួរទី២ ខ្ញុំករុណាខ្ញុំស្តាប់ មិនបាន។

រាសីៈ អាយុប៉ុន្មាន?

សារីមៈ ចាំ! ខ្ញុំករុណាឥឡូវហ្នឹងអាយុ៦៨ឆ្នាំ។

រាសីៈ ក្នុងពេលទន្ទឹងរង់ចាំសំណួរអ្នកស្តាប់យើងខ្ញុំចង់សួរអ្នកស្រីមួយដែលយើងមិនបាន និយាយគ្នានៅក្នុងកម្មវិធី៦២ភាគហ្នឹង គឺក្រោយពីបានមកដល់អាមេរិកមក អ្នកស្រី បានបង្កើតវិទ្យុខ្មែរមួយនៅអាមេរិក។ សូមអ្នកស្រីមានប្រសាសន៍ពីរឿងនេះបន្តិច បាទ?

សារីមៈ ចាំ! កាលនោះខ្ញុំនៅរដ្ឋមុនីសូតា ទីក្រុងមីណាផូលីស ហើយពេលដែលស្រុក អាមេរិកមានសង្គ្រាមនៅឈូងសមុទ្រពែក្ស ខ្ញុំបាននិយាយប្រាប់អស់លោក យាយ ចាស់ៗថា នៅស្រុកអាមេរិកឥឡូវនេះមានចម្បាំង ហើយគាត់ថា យី! មិនដឹងមាន ចម្បាំងអីទេ ខ្ញុំចេះតែនិយាយ។ ដូច្នេះគាត់មិនចេះភាសា ហើយក៏មិនដែលស្តាប់

វិទ្យុ។ អត់មានវិទ្យុខ្មែរ។ ខ្ញុំគិតថា ពួកគាត់អត់ចេះអត់ដឹងស្ថានការណ៍ជុំវិញខ្លួន។ អញ្ចឹងគួរតែមានវិទ្យុមួយនិយាយភាសាខ្មែរ។ ខ្ញុំចង់បង្កើតវិទ្យុ។ ខ្ញុំឈប់ធ្វើការ។ ខ្ញុំមករកកន្លែង។ ពីរនាក់ប្ដីខ្ញុំហ្នឹងក៏បានបង្កើតវិទ្យុឈ្មោះថា The Khmers in Me-nessota បានន័យថាខ្មែរនៅមីនីសូតានៅឆ្នាំ១៩៩២ រហូតដល់៩៩ ដល់ខ្ញុំមកនេះទៅបានខ្ញុំឈប់ ហើយផ្ទេរទៅឱ្យអ្នកដទៃជួយធ្វើ។

រាសីៈ អញ្ចឹងនៅបន្តទៀតបាទ! វិទ្យុហ្នឹង?

សារីមៈ ចាំ! វិទ្យុហ្នឹងនៅបន្តចាំ។

រាសីៈ បាទ! ឥឡូវនេះយើងមានអ្នកស្រី ចាន់ថា មកពីខាងខេត្តកំពង់ធំបាទ! ជម្រាបសួរអ្នកស្រីចាន់ថា។

ចាន់ថាៈ ជម្រាបសួរលោក ប៉ូច រាសី និង សូមជម្រាបសួរអ្នកស្រី នៅ សារីម។

សារីមៈ ចាំ! ជម្រាបសួរ។

ចាន់ថាៈ ចាំ! ខ្ញុំមានសំណួរពីរ ទី១ ខ្ញុំគ្រាន់តែចង់ដឹងថា តើអ្នកស្រីបានចាកចេញពីប្រទេសកម្ពុជាទៅនៅជំរំពេលណា? ខ្ញុំបានស្ដាប់វគ្គខ្លីៗបានខ្លះ។ ពេលខ្លះ ខ្ញុំក៏តាមដានជាប់ទៅ។ ខ្លះខ្ញុំក៏អត់បានតាមដានទៅ។ ខ្ញុំចង់ដឹងថាតើអ្នកស្រីចេញពីកម្ពុជានៅឆ្នាំណាទី១ ហើយទី២ ខ្ញុំចង់ដឹងថា តាមខ្ញុំស្ដាប់ប្រវត្តិទៅ អ្នកស្រី ដូចជាមិនសូវបានទទួលទារុណកម្មពីរបប ប៉ុល ពត ទេ ព្រោះថា តាមប្រវត្តិ អ្នកស្រីនិយាយឃើញថា ដូចជាតិចតួច។ មិនដូចខ្ញុំនៅកាលណោះ ខ្ញុំនៅតូច ប៉ុន្តែ ខ្ញុំ ក្រុមគ្រួសារម្ដាយឪពុកខ្ញុំ ហើយនឹងកូនពលរដ្ឋខ្មែរយើងក្នុងប្រទេសកម្ពុជាទាំងមូលបានទទួលទារុណកម្មយ៉ាងខ្លាំងធ្ងន់ធ្ងរ។ ប៉ុន្តែដូចតាមស្ដាប់ប្រវត្តិអ្នកស្រីមានភាពកម្រត់កម្រកន្លែងដឹកដៃក្មេងទៅឆ្លងទៅតាមគោកនិម្មិតទៅតាមជំរំមានចោរប្លន់ ចោរលួច។ ប៉ុន្តែដូចពុំសូវបានទទួលទារុណកម្ម តើមែនដែរឬមិនមែន ព្រោះភាគនិទានខ្លីៗ ខ្ញុំស្ដាប់បានខ្លះភាគខ្លះ ខ្ញុំក៏ខ្ញុំស្ដាប់អត់បាន អញ្ចឹងខ្ញុំចង់ដឹងថា ទី១ អ្នកស្រីចេញពីស្រុកកម្ពុជាយើងនៅឆ្នាំណា និងតើអ្នកស្រីបានទទួលទារុណកម្មដូចពួកខ្ញុំ និងប្រជាពលរដ្ឋខ្មែរដទៃទៀតដែរឬទេ ពីរបបប៉ុល ពត?

សារីមេះ ចាំ! ខ្ញុំជម្រាបអ្នកស្រី ចាន់ថា ថា ពួកខ្ញុំនេះគឺថាមិនមែនជាអ្នកជម្លៀសទៅតាមជនបទដូចបងប្អូនខ្មែរយើងដែលត្រូវជម្លៀសចេញពីភ្នំពេញទេ។ ខ្ញុំអ្នកត្រឡប់ពីបរទេសចូលកម្ពុជា ពេលខ្មែរក្រហមយកស្រុករួចទៅហើយ។ ដូច្នេះខ្មែរក្រហមបានយកពួកយើងទៅដាក់នៅក្នុងជំរំដូចខ្ញុំបានជម្រាបពីពេលមុនអញ្ចឹង។ ប៉ុន្តែយើងអត់បាយ យើងអត់មានអីហូប។ យើងមានតែបបររាវៗ។ គេឱ្យយើងធ្វើការដូចអ្នកដទៃអញ្ចឹង។ សែងអាចម៍ សែងអីគ្រប់សព្វ។ ពេលខ្លះយើង ដើរដួលទន់ជង្គង់ ហើយខ្មែរក្រហមបានយកពួកយើងទៅសម្លាប់ច្រើននាក់រាប់រយនាក់។ ដូចខ្ញុំអីគឺថាយើងមិនដាច់បាយទេ ប៉ុន្តែយើងអត់បាយ។ យើងអត់អាហារ ហើយគេប្រមាថមើលងាយយើងនោះពីព្រោះៗថា យើងបានរៀនសូត្របានចេះដឹង។ ខ្មែរក្រហមគេមិនចូលចិត្តសញ្ញាបត្ររបស់យើងទេ។ គេចូលចិត្តតែសញ្ញាឃើញ។ បើទារុណកម្មនោះ ខ្ញុំមិនធ្លាប់បានខ្មែរក្រហមយកទៅវាយចងអីទេពីព្រោះខ្ញុំអត់ដែលបានលួចអីខ្មែរក្រហមដែរ ប៉ុន្តែម្តាយខ្ញុំត្រូវខ្មែរក្រហមវាយឱ្យសេះអូស។ ហើយកូនខ្ញុំទាំងពីរបានស្លាប់ ដោយសារអត់បាយពីព្រោះគេត្រូវជម្លៀសទៅកន្លែងផ្សេងៗដែលខ្ញុំមិនដឹង។

រាសីះ បាទ! សូមអរគុណអ្នកស្រី ឥឡូវនេះយើងមានលោកអ្នកស្តាប់យើងម្នាក់ គឺលោកភ័ក្រមកពីខេត្តបន្ទាយមានជ័យ។ ជម្រាបសួរលោក ភ័ក្របាទ!។

ភ័ក្រះ បាទ! ជម្រាបសួរពីស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ជម្រាបសួរលោក អ៊ំស្រីសារីមេ។ ខ្ញុំសូមសួរថា តើដែលអ៊ំត្រឡប់មកពីស្រុកបារាំងវិញ ដល់បឹងត្របែកឃើញមានប៉ុន្មាននាក់? សព្វថ្ងៃដូចជា ហោ ណាំហុង មានឃើញទេ? សំណួរទី១ ហើយសំណួរទី២ ខ្ញុំសូមថ្លែងអំណរគុណ អ៊ំដែលមានអាយុថ្លៃ ថ្លៃហួសពីថ្លៃជាង ពេជ្រទៀត ដែលបានដើរកម្សត់កម្រ ដែលខ្ញុំឮតាមអ៊ំអត្ថាធិប្បាយនោះហើយខ្ញុំ សូមថ្លែងអំណរគុណអ៊ំទាំងអស់គ្នាដែលបានរស់នៅក្នុងសម័យប៉ុល ពត ខ្ញុំសូម អរគុណជម្រាបលាអ៊ំ។

សារីមេះ ចាំ! សូមអរគុណលោក ភ័ក្រ។ មិញនេះគឺថាលោក ហោ ណាំហុង ដែលលោកលើកឡើងហ្នឹង គឺខ្ញុំគ្រាន់តែដឹងថា គាត់ហ្នឹងធ្វើទូតសម័យសម្តេច សីហនុ ធ្វើ

របណាសិរ្ស វាយជាមួយ លន់ ណុល នោះ។ ពួកខាងទូតទៅនាំចូលទៅស្រុកខ្មែរ វិញ ទៅបម្រើនយោបាយរណសិរ្សខ្មែរក្រហមជាមួយសម្តេចសីហនុ ហើយខ្ញុំមិន ដែល បានឃើញគាត់ទេ។ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា គាត់ហ្នឹងនៅកន្លែងបឹងត្របែកហ្នឹង ជាប់ ជាមួយកន្លែងដែលខ្ញុំនៅ។ គេនៅម្តុំពួកអ្នកទូត។ ពួកខ្ញុំនេះជាមនុស្ស ធម្មតា។ ជា កូនសិស្ស ជាគ្រូបង្រៀននៅម្តុំអញ្ចឹងទៅ។ ខ្ញុំមិនដែលឃើញគាត់ទេ។ ខ្ញុំឃើញតែ កូនគាត់។ ឃើញបងប្អូនគាត់ដែលរស់ជាមួយខ្ញុំ ជាពិសេសកូនគាត់បានទៅធ្វើការ នៅវត្តស្លែងនោះជាមួយខ្ញុំ។ ប៉ុន្តែនៅ ក្រុមផ្សេងពីគ្នា។

រាសី៖ បាទ! តែសំណួរមួយទេ តែទី២ គាត់ដូចថាជូនពរអ្នកស្រីដែលជាអ្នកអាយុវែ្វ។

សារីមេះ៖ ចាំ! សូមអរគុណ។ ខ្ញុំសរសើរសំណាងខ្លួនឯងដែរ។ ប៉ុន្តែខ្ញុំបានរស់តែម្នាក់ឯង។ ប្តី ខ្ញុំ ហើយនឹងកូនខ្ញុំ ឪពុកម្តាយខ្ញុំស្លាប់ទាំងអស់ចាំ។

រាសី៖ បាទ! ខ្ញុំចង់សួរអ្នកស្រីថាតើ តាំងពីចេញពីស្រុកខ្មែរនៅឆ្នាំ៧៩ អ្នកស្រីដែលអញ្ជើញ ត្រឡប់ទៅវិញដែរបាទ?

សារីមេះ៖ ចាំ! ខ្ញុំត្រឡប់ទៅស្រុកខ្មែរម្តងនៅឆ្នាំ១៩៩៣ ពេលដែលអ៊ុនតាក់កំពុងតែចូល កម្ពុជា។ ពេលហ្នឹងខ្ញុំមានចូលអង្គការមួយគេហៅថា អឹម អា អេ គឺថាជាអង្គការ មនុស្សធម៌ទេ ដូចថាការកែប្រែចិត្តអញ្ចឹង អង្គការហ្នឹងក៏គេទៅ ខ្ញុំក៏ទៅប្រជុំជាមួយ អង្គការហ្នឹងពីរអាទិត្យ។

រាសី៖ បាទ! នៅពេលអ្នកស្រីអញ្ជើញទៅវិញអញ្ចឹង៩៣ មានអារម្មណ៍ម៉េចដែរ?

សារីមេះ៖ ចាំ! ខ្ញុំទៅឃើញស្រុក។ ទាល់តែខ្ញុំធ្មេចភ្នែកបានខ្ញុំមើលភ្នំពេញឃើញ។ ខ្ញុំឃើញតែ ផ្ទះរបស់បងប្អូនខ្ញុំទាំងអស់។ ឃើញតែផ្ទះ។ ប៉ុន្តែអត់មានមនុស្សដែល ជាបងប្អូនខ្ញុំ រស់នៅទេពីព្រោះមាមីងខ្ញុំស្លាប់អស់រលីង។ នៅសល់តែប្អូនជីដូនមួយម្នាក់គត់ខាង ឪពុក។ អ្នកនៅកៀនស្វាយនៅជិតភ្នំពេញ ហើយបងប្អូនខ្ញុំទៅនៅភ្នំពេញទាំងអស់ គ្នាទៅគឺថាពេលខ្មែរក្រហមជម្លៀសហ្នឹងគឺខ្មែរក្រហម អត់ចូលចិត្តអ្នកដែលនៅ ជាប់ៗភ្នំពេញប៉ុន្មានទេ។

រាសីៈ បាទ! នៅពេលហ្នឹងអ្នកស្រីបានអញ្ជើញត្រឡប់ទៅកន្លែងអ្នកស្រីធ្លាប់នៅទាំងប៉ុន្មាន នៅជំនាន់ខ្មែរក្រហមដែរបាទ?

សារីមៈ ចាំ! អត់ទេ។ បឹងត្របែកក៏ខ្ញុំមិនបានទៅដែរ។

រាសីៈ មិនចង់ទៅ ឬក៏មិនដែលទៅ?

សារីមៈ ឃើញសាលាតិចណ្ហ។ ពេលហ្នឹងខ្ញុំរវល់ពេក ហើយពេលនោះគឺខ្ញុំនៅក្នុងចិត្តខ្ញុំ គឺថាវានៅសោកសង្រេងខ្លាំង។ ខ្ញុំមិនសូវចង់ឃើញកន្លែងដែលមានទុក្ខ។

រាសីៈ តើអ្នកស្រីសព្វថ្ងៃមានការទាក់ទង គ្នាជាមួយនឹងមិត្តភក្តិ ឬអ្នកដែលចូលទៅស្រុកខ្មែរវិញពីបរទេសដែរ ដែលនៅសល់ នៅរស់នៅ?

សារីមៈ ចាំ! មានការទាក់ទងច្រើនដែរ ជាពិសេសមិត្តភក្តិដែលយើងស្គាល់ និងជួបគ្នានៅសម័យខ្មែរក្រហម នៅបឹងត្របែក។ រស់ហើយនឹងអ្នកខ្លះបានចូលទៅជាមួយខ្ញុំ គឺថាជាមនុស្សដែលធ្លាប់រៀនជាមួយគ្នា ប៉ុន្តែមកស្រុកបារាំង។ គាត់ឈឺ។ គាត់មកមើលជំងឺនៅស្រុកបារាំង។ ដល់ពេលខ្មែរក្រហមយកស្រុកគាត់មកតែម្នាក់ឯង ដូចខ្ញុំមកបានអាហារូបករណ៍តែម្នាក់ឯងអញ្ចឹង។ យើងត្រឡប់ទៅវិញ ហើយអ្នកអស់នោះក៏គាត់នៅរស់។ គាត់រត់មកវិញ។ គាត់នៅស្រុកបារាំង។ ពេលខ្លះយើងទៅជួបគ្នា។ ឆ្នាំ ១៩៨៩ ខ្ញុំទៅស្រុកបារាំងដំបូង។ ក្រោយពីចេញពីបឹងត្របែកមក។ ទៅជួបអ្នកដែលរស់នៅបឹងត្របែកជាមួយគ្នាហ្នឹង។ គឺថាពេលនេះយើងទៅដល់។ យើងមិនកើតទុកដូចពេលមុន។ យើងនិយាយពីរឿងកើតទុក្ខយកមកសើច។ ដូចយើងកំប្លែងសើចរឿង សារ៉ន វាធ្វើបាបយើងយ៉ាងម៉េច ហើយ សារ៉ន យកអីវ៉ាន់របស់យើងជម្រុះយកទៅឲ្យប្រពន្ធខ្លួនឯងពាក់ រួចយកទឹកអប់ ដែលយើងជម្រុះឱ្យទៅលាប។ ហើយស្លៀកសារ៉ុងសូត្រពាក់អាវយឺតអេមីណង់ ហើយមកអង្គុយមើលយើងកាប់ដីធ្វើអណ្តូង។ សារ៉ន ថាទុកឱ្យ ចិញ្ចឹមត្រី ហើយជីកអណ្តូងចិញ្ចឹមត្រីនៅក្បែរៗផ្ទះដែលនៅក្នុងសាលារៀនជិតបឹងត្របែក ហើយខ្ញុំចេះតែឆ្ងល់។ ចិញ្ចឹមត្រីនៅក្បែរសរសរផ្ទះអញ្ចឹងមែនទែន សារ៉ន ជីកអណ្តូងចង់ទុកកប់ពួកយើង។ ប៉ុន្តែយើងអត់ដឹង។

រាសីៈ បាទ! អ្នកស្រីខឹងពួកខ្មែរក្រហមទេសព្វថ្ងៃហ្នឹង?

សារីមែះ ចាំ! ខ្ញុំខឹងនឹងខ្មែរក្រហមមេៗ។ មេខ្មែរក្រហមធំៗ។ ខ្ញុំមិនសប្បាយចិត្តពីព្រោះគាត់មានតម្រិះចេះដឹងហើយគាត់មកធ្វើស្រុកយើងឱ្យទៅអញ្ចឹង។ ប៉ុន្តែចំពោះខ្មែរក្រហមដែលគ្នាអ្នកអត់ចេះអក្សរគឺខ្ញុំអាណិតគាត់ទៅវិញពីព្រោះគាត់ធ្វើតាមអ្នកទាំងអស់ហ្នឹង។ ដូច សារ៉ន ថា ខ្មែរក្រហមខ្លះហ្នឹង កម្មាភិបាលខ្លះរបស់គេក្តាប់នយោបាយអង្គការមិនបានដូចៗគ្នាទេ។ ដល់ខ្ញុំឮស្ងួរក្តាប់មិនបានដូចៗគ្នាអញ្ចឹងអាហ្នឹងមានគ្រោះថ្នាក់ណាស់ពីព្រោះស្រេចតែការបកស្រាយរបស់ម្នាក់ៗ ម្ល៉ោះហើយខ្ញុំឃើញគាត់មិនទាំងចេះអក្សរផង។ ដូច្នេះគាត់បង្គាប់ឱ្យខ្ញុំធ្វើអីគឺខ្ញុំធ្វើតាមដោយអត់មានតវ៉ាទេចាំ!

រាសីះ បាទ! សព្វថ្ងៃ សារ៉ន រស់នៅឯណា?

សារីមែះ ចាំ! បើតាមខ្ញុំដឹងដូចខ្មែរក្រហមគ្នាគេយកទៅសម្លាប់ចោលហើយចាំ ពីព្រោះគាត់ធ្វើមេកន្លែងដែលពួកខ្ញុំនៅបឹងត្របែក។ គេមានមេខ្មែរក្រហមមួយត្រួតពីលើយើងអញ្ចឹងទៅ ហើយនឹងមេអ្នកដែលទៅពីស្រុកបារាំងហ្នឹងជាប្រធានបន្ត។ សារ៉ន ឱ្យបញ្ហាមកត្រូវធ្វើយ៉ាងម៉េច។ ដល់ធ្វើបាបពួកយើងខ្លាំងពេកយកទៅសម្លាប់ច្រើនពេកអញ្ចឹងទៅបានថាឮស្ងួរគេចាប់ សារ៉ន។ ក្រោយពីគេចាប់ សារ៉ន បាត់ទៅ បាន អៀង សារី មកនៅបឹងត្របែក មកសើរើចាត់តាំងជាថ្មី។

រាសីះ បាទ! សូមអរគុណអ្នកស្រីបាទ! ឥឡូវនេះមានលោកអ្នកស្តាប់ម្នាក់គឺលោក កូឡាន ខេត្តកំពង់ចាម។

កូឡានះ បាទ! ខ្ញុំសូមសួរអ្នកស្រីថា កាលដែលអ្នកស្រីបែកពីប្តីទៅ នៅបែកពីកាលណា ព្រោះកាលស្តាប់សំណួរដែលអ្នកស្រីបានលើកឡើង ហើយនឹងបាននិយាយពីប៉េកាំងមកហាក់ដូចជាអត់ដែលឮស្ងួរប្តីអ្នកស្រីសោះ។ នេះសំណួរទី១។ សំណួរទី២ សួរថា នៅបឹងត្របែកហ្នឹងមានពីណាខ្លះដែលជាអ្នកគ្រប់គ្រងអ្នកមកពីស្រុកបារាំងមកហ្នឹង បាទ! ហើយសំណួរទី៣ សុំសួរថា ប្រសិនណា ជាឯកសារទាំងអស់ហ្នឹងគ្រប់ភាគហ្នឹងបើសិនណាជាអាចបោះពុម្ពបានសុំចែកចាយឱ្យ ឬលក់ដូរសម្រាប់យកជាឯកសារសម្រាប់មើលទាំងអស់គ្នាផងបានអត់។ សុំប៉ុណ្ណឹង សុំអរគុណ។

សារីមៈ ចាំ! ខ្ញុំសូមកែតម្រូវ។ ខ្ញុំអត់ដែលមានផ្សាយពីប៉េកាំងទេ។ យើងផ្សាយភាគនិទានប្រវត្តិផ្ទាល់មាត់ហ្នឹងតាមវីអូអេ សំឡេងសហរដ្ឋអាមេរិកនៅអាមេរិកនេះ។ ខ្ញុំសូមជម្រាបថា ខ្ញុំមកស្រុកបារាំង គឺខ្ញុំបាន អាហារូបករណ៍បារាំងឱ្យមករៀន គឺខ្ញុំមកតែម្នាក់ឯងទេ។ ប្ដីខ្ញុំ ហើយនឹងកូនទាំងពីរនៅស្រុកខ្មែរ។ ខ្ញុំឱ្យម្ដាយខ្ញុំ ហើយនឹងប្ដីខ្ញុំហ្នឹងអ្នកមើលកូនឱ្យខ្ញុំ។ ដូច្នេះក្នុងពេលខ្ញុំនិទានហ្នឹង គឺភាគខ្ញុំមិនអាចអត់មានភាគខ្លះដែលត្រូវនិយាយពីប្ដីទេ។ ដូច្នេះមិនបាននិយាយពីប្ដីទេ។ ហើយដល់ភាគចុងបញ្ចប់គ្រាន់ថាមាននិយាយខ្លះ។ អ្នកដែលគ្រប់គ្រងនៅបឹងត្របែកមាន សារ៉ន ជាមេធំខាងខ្មែរក្រហម។ រួចទៅខាងអ្នកដែលទៅពីស្រុកបារាំងទៅហ្នឹង ដំបូងមានម្នាក់ហ្នឹងឈ្មោះមិត្ត កើត។ ឈ្មោះ គាត់ហ្នឹងគាត់ចូលទៅក្នុងប្រទេសកម្ពុជាវិញគឺសុទ្ធតែដើរតាមផ្លូវលំហូជីមិញ។ ដូច្នេះ គាត់ចូលជាមួយរណសិរ្សសម្ដេចឪ។ គាត់មកធ្វើមេនៅកន្លែងខ្ញុំនៅបឹងត្របែកដំបូង។ អាហ្នឹងនិយាយពីបឹងត្របែក។ បើនៅកន្លែងសាលាជំរំតិចណូវិញ គឺថាមានឈ្មោះ ទ្រី ម៉េងហួត ហើយមេធំគេហ្នឹងឈ្មោះ កុំហើយមេបន្ទាប់មកខ្មែរក្រហមឈ្មោះ យន។ ឈ្មោះ ហោអ្នកទៅពីស្រុកបារាំង។ ហ្នឹងនៅសាលាតិចណូ ហើយដល់នៅបឹងត្របែកមានឈ្មោះ សារិន មានឈ្មោះ ភាគ, ហ៊ីង អ៊ុន, ម៉ន ហើយនឹង ហ៊ុយ បន្ទាប់ៗ។ ពេលយួនកំពុងវាយចូលហ្នឹងមានម្នាក់ឈ្មោះ ហ៊ុយ។ គាត់ធ្វើមេ។

រាសីៈ បាទ! សូមអរគុណអ្នកស្រី នៅ សារីម បាទ! ពេលវេលាយើងនៅខ្លីមែនទែន សូមអ្នកស្រីរៀបៗរាប់បន្តិចអំពីការរៀបអាពាហ៍ពិពាហ៍របស់អ្នកស្រីឡើងវិញនៅអាមេរិកហ្នឹងបាទ!។

សារីមៈ ចាំ! ដល់ខ្ញុំមកដល់ស្រុកអាមេរិកហ្នឹង ខ្ញុំដឹងដំណឹងសព្វគ្រប់ថា ប្ដីខ្ញុំ កូនខ្ញុំ ម្ដាយឪពុកខ្ញុំស្លាប់អស់ទៅ ហើយខ្ញុំនឹកថា ខ្ញុំចាស់ហើយ ខ្ញុំចង់បានកូន ព្រោះកូន ស្លាប់អស់។ ខ្ញុំក៏ជួបជាមួយប្ដីខ្ញុំសព្វថ្ងៃ។ យើងបានកូនមួយ ឥឡូវនេះ គេធំហើយ។ អាយុជាង២០ហើយ គេរស់នៅមីនីសូតា។ កូនស្រីមានកិច្ចការងារគេធ្វើស្រួលបួល។

រាសី៖ បាទ! ខ្ញុំសូមអរគុណអ្នកស្រី នៅ សារីម និងសូមអរគុណអស់លោកអ្នកស្ដាប់ទាំងអស់គ្នាដែលបានតាមដានកម្មវិធីហេឡូវីអូអេ និងជម្រាបលាអ្នកស្រី នៅ សារីម បាទ! សូមអរគុណ។

សារីម៖ ចា៎! សូមជម្រាបលាលោក ប៉ូច រាសី៕